ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ តែងតែចងចាំថ្ងៃ៧ មករា

◆ សំណើសុំធ្វើការផ្លាស់ប្ដូរទាក់ទងនឹងការចូលរួមរបស់ដើមបណ្ដឹង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨១ ខែមករា ឆ្នាំ២០១៥

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨១ ខែមករា ឆ្នាំ២០១៥


## មាតិកា


◆ តែងតែចងចាំថ្ងៃ៧ មករា ............................................................១

**ផ្នែកឯកសារ**

◆ ហាក់ គឹមឈៀង ហៅ ទ្រី អនុប្រធានក្រុមដាំងក្រឡឹង ........................៣

◆ ដំណឹងយុវជន យុវនារីបដិវត្តន៍ .......................................................៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ឯកសារនៅតែធ្វើឲ្យម្តាយខ្ញុំចងចាំ ..................................................១៥

◆ ស្ត្រីចូលរួមកសាងសន្តិភាព និងផ្សះផ្សាជាតិ ....................................១៧

◆ ចាប់ពីរបបខ្មែរក្រហមដល់ ឧប្បត្តិហេតុ ហាំបាលី ............................២១

◆ ប្រវត្តិសាស្ត្រមិនអាចបដិសេធ និងបំភ្លេចបាន ................................២៨

**ផ្នែកច្បាប់**

◆ សវនាការស្តីពីសេចក្តីថ្លែងបើកសំណុំរឿង០០២ ..............................៣០

◆ សំណើសុំធ្វើការផ្លាស់ប្តូរទាក់ទងនឹងដើមបណ្តឹង ................................៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបកស្រាយពាក្យ "អ្នកទទួលខុសត្រូវ ........................................៤៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ក្លាយជាក្មេងកំព្រាដោយរបបខ្មែរក្រហម .........................................៤៩

◆ ដំណើរភៀសខ្លួនឆ្លងដែនចេញពីរបប ..............................................៥៤




ប្រជាជនត្រឡប់ទៅស្រុកកំណើត ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នាដៃលេខនេះ** ៖ អេង កុកថាយ, ហ៊ុយ សម្ផស្ស, លឹម ជ័យទត្ត, ឌី សុជាតា, ទួន ឡៃហ៊ុល, ម៉ៃឃើល កាណាវ៉ាស, ស៊ាង ចិន្តា, ជា សីហា **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុនិន្ទ **អ្នកបកប្រែ** ៖ សយ សូលីដា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# តែងតែចងចាំថ្ងៃ៧ មករា

ថ្ងៃនេះជាថ្ងៃទី៧ ខែមករា ដែលនៅថ្ងៃនេះកាលពីឆ្នាំ ១៩៧៩ ប្រជាជនកម្ពុជាត្រូវបានរំដោះឲ្យរួចផុតពី អំពើប្រល័យពូជសាសន៍ ។ ទោះជាយ៉ាងណាក៏ដោយ ច្រើនឆ្នាំកន្លងផុតទៅ បុគ្គលមួយចំនួនចាប់ផ្តើមយល់ឃើញថា ថ្ងៃ៧ មករា គឺជាការចាប់ផ្តើមនៃការចូលលុកលុយនិងត្រួតត្រារបស់ប្រទេសវៀតណាម មកលើប្រទេសកម្ពុជា ដូច្នេះ ថ្ងៃនេះមិនគួរមានពិធីរំលឹកអបអរសាទរច្រើននោះទេ ។ ប៉ុន្តែ ខ្ញុំខ្លួនឯងផ្ទាល់ជឿជាក់ថាការរំដោះប្រជាជនពីអំពើប្រល័យពូជសាសន៍មានសារសំខាន់ជាងការបាត់បង់បណ្តោះអាសន្ននូវអធិបតេយ្យភាពរបស់រដ្ឋកម្ពុជា ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំទទួលស្គាល់ថាមានការជជែកវែកញែកជាអន្តរជាតិអំពីភាពត្រឹមត្រូវ និងសមរម្យនៃការផ្តួលរលំរបបប្រល័យពូជសាសន៍ដោយប្រើប្រាស់ការត្រួតត្រាបរទេស ។ ការរំដោះប្រជាជនពីរដ្ឋាភិបាលដែលឃោរឃៅដោយប្រើមធ្យោបាយយោធាបានកើតឡើងពីរបីដងដែរ ចាប់តាំងពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ត្រូវបានអនុម័តក្នុងឆ្នាំ១៩៤៨ ។

ការរំដោះជនរងគ្រោះពីសេចក្តីស្លាប់ដោយការកាប់សម្លាប់រង្គាលគឺជាទំនួលខុសត្រូវដ៏សំខាន់មួយរបស់សហគមន៍អន្តរជាតិ ។ ទ្រឹស្តី “ទំនួលខុសត្រូវក្នុងការការពារ” ធ្វើឲ្យការរំដោះឲ្យរួចពីអំពើប្រល័យពូជសាសន៍ មានសារសំខាន់ជាងគោលការណ៍របស់រដ្ឋ ។

ដូច្នេះហើយ ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ គួរតែជាថ្ងៃដែលបណ្តាប្រទេសអាស៊ានយ៉ាងហោចណាស់ ចូលរួមការលើកកម្ពស់ការយល់ដឹងពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងប្រទេសរបស់ពួកគេ ជាមួយនឹងគោលដៅបញ្ចូលការសិក្សាពីអំពើ



កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ វាយចូលទីក្រុងដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ នៅខែមករា ឆ្នាំ១៩៧៩

ប្រល័យពូជសាសន៍ទៅក្នុងប្រព័ន្ធអប់រំក្នុងតំបន់ ។

ការធ្វើសមាហរណកម្មអាស៊ានមិនអាចទៅរួចទេ ប្រសិនជាគ្មានការយល់ដឹងពីប្រវត្តិសាស្ត្រ និងសង្គមជារួម ។ អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាគួរតែត្រូវបានបង្រៀននៅបណ្តាប្រទេសអាស៊ាន ពីព្រោះអំពើនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាក្នុងរបៀបមួយដែលបានប៉ះពាល់ដល់មនុស្សជាតិគ្រប់រូប ។

តាមការយល់ឃើញរបស់ខ្ញុំ ក្រៅពីសម្រេចឲ្យបានភាពចម្រុងចម្រើន និងសន្តិសុខ អាស៊ានមានកាតព្វកិច្ចជំរុញឲ្យសិទ្ធិមនុស្ស និងការអប់រំសីលធម៌មានភាពប្រសើរឡើងលើកកម្ពស់ការយល់ដឹងពីអំពើសាហាវយង់ឃ្នងដែលបានកើតឡើងនៅក្នុងតំបន់ អប់រំក្មេងជំនាន់ក្រោយនៅបណ្តាប្រទេសអាស៊ាន ពីអំពើប្រល័យពូជសាសន៍កើតឡើងក្នុងប្រទេសកម្ពុជា និងបង្កើតគំរូមួយសម្រាប់ការពារប្រជាពលរដ្ឋក្នុងបណ្តារដ្ឋជាសមាជិកអាស៊ាននាពេលអនាគត ។

កម្មវិធីសិក្សានេះគួរតែត្រូវបានបញ្ចូលទៅក្នុងផែនការការងាររថ្មីរបស់អាស៊ានទាក់ទិននឹងការអប់រំក្នុងលក្ខណៈជាកម្មវត្ថុបន្ថែមដែលទទួលស្គាល់ភាពលំបាកវេទនា ដែលប្រជាជនកម្ពុជាជួបប្រទះពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ និងភាពឈឺចាប់ទាំងឡាយរបស់ប្រជាជននៅទីម៉ររខាងកើតពីចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៩៩ ។

ចាប់តាំងពីការបង្កើតអាស៊ានក្នុងឆ្នាំ១៩៦៧ មកតំបន់អាស៊ីអាគ្នេយ៍ធ្លាប់ឆ្លងកាត់សង្គ្រាមស៊ីវិល និងអំពើប្រល័យពូជសាសន៍បណ្តាលឲ្យមានការបាត់បង់ជីវិតរាប់លាននាក់ ។ សង្គ្រាមដែលគួរឲ្យកត់សម្គាល់ជាងគេ គឺសង្គ្រាមនៅក្នុងតំបន់ឥណ្ឌូចិនរីឯអំពើប្រល័យពូជសាសន៍វិញគឺជាស្នាដៃរបស់ខ្មែរក្រហម ដែលជាអង្គភាពមួយកាន់លទ្ធិកុម្មុយនីស្តម៉ៅជ្រុលនិយម និងបានប្រព្រឹត្តអំពើសាហាវយង់ឃ្នងមកលើប្រជាជនខ្លួនឯង ។

ករណីប្រល័យពូជសាសន៍នេះខុសប្លែកពីការសម្លាប់យ៉ាងរង្គាលមកលើជនជាតិ Holocaust ដែលជនរងគ្រោះ និងជនដៃដល់ត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងកើតឡើងក្នុងក្របខ័ណ្ឌជម្លោះសកល ។ នៅប្រទេសកម្ពុជា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងក្នុងក្របខ័ណ្ឌជម្លោះតំបន់ និងក្នុងបរិបទមួយមិនមានការជ្រៀតជ្រែកនេះមានន័យថា រដ្ឋជាសមាជិកអាស៊ានដឹងច្បាស់ពីអ្វីដែលកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជានាពេលនោះ ប៉ុន្តែជ្រើសរើសផ្លូវខុសគឺការមិនជ្រៀតជ្រែក ។

ពិតមែនហើយ នៅពេលនោះ ប្រទេសកម្ពុជាមិនទាន់ជាសមាជិកនៃសហគមន៍មួយនេះនៅឡើយ តែនេះគឺជាមេរៀនគួរឲ្យចាប់អារម្មណ៍មួយ ដែលអាស៊ានគួរតែបង្រៀនក្មេងជំនាន់ក្រោយ និងចោទសួរសំណួរអំពីការទទួលខុសត្រូវខាងសីលធម៌ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍កើតមានឡើងក្នុងតំបន់ ។

សន្តិសុខ និងការសហការផ្នែកសេដ្ឋកិច្ចក្នុងអាស៊ាននឹងមិនមានន័យឡើយ ប្រសិនបើអំពើសាហាវយង់ឃ្នងកើតឡើងក្នុងរដ្ឋជាសមាជិក នៅពេលដែលរដ្ឋជាសមាជិកដទៃទៀត ធ្វើដូចជាអ្នកឈរមើលហេតុការណ៍ដោយគ្មានការខ្វល់ខ្វាយ ។

**អេង កុកថាយ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.dccam.org

# ហាក់ គីម ឈៀង ហៅ ទ្រី អនុប្រធានក្រុមជាងក្រឡឹង អង្គភាពកាត់ដេររដ្ឋ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៩០០៨*

ហាក់ គីមឈៀង ហៅ ទ្រី មុនអង្គការចាប់ខ្លួនមានតួនាទីជាអនុប្រធានជាងក្រឡឹង នៅអង្គភាពកាត់ដេររដ្ឋ ។ ទ្រី មានអាយុ៤២ ឆ្នាំ កើតនៅភូមិក្បាលកោះ ឃុំទឹកវិល ស្រុកស្អាង តំបន់២៥ ។ ទ្រី រៀនបានត្រឹមថ្នាក់ទី១០ប៉ុណ្ណោះ នៅសាលាវត្តសូភី ឃុំក្បាលកោះ ។ មុនចូលបដិវត្តន៍ ទ្រី ប្រកបរបរស៊ីឈ្នួលភ្ជួរដី និងត្បាញសូត្រ ។ ដោយសារ ជីវភាពគ្រួសារមានសភាពយ៉ាប់យ៉ឺនខ្លាំងពេក ទ្រី បានសម្រេចចិត្តចេញពីភូមិកំណើតមកភ្នំពេញ ដើម្បីរកការងារធ្វើ ។

ចាប់ពីឆ្នាំ១៩៦០ ដល់១៩៦៩ ទ្រី បានមករស់នៅភ្នំពេញស៊ីឈ្នួលឲ្យថៅកែស្រីឈ្មោះ ហួ អស់រយៈពេល៦ខែ ក៏ប្តូរទៅរៀនជួសជុលឡានជាមួយថៅកែម្នាក់ទៀតឈ្មោះ ម៉ឹយ ជាខ្មែរគិញ (សម្ងាត់ពាក់ដោយពីរជាន់) នៅខាងត្បូងវិមានឯករាជ្យអស់រយៈពេល៨ខែ ។ ទ្រី ត្រូវឈ្មោះ ម៉ឹយ បំពាក់បំប៉នគោលជំហរឲ្យចូលធ្វើជាខ្មែរគិញធ្វើការបម្រើឲ្យខ្លួនដោយសន្យាឲ្យលុយចាយ ។ តាមការណែនាំរបស់ ម៉ឹយ, ទ្រី បានស្គាល់ខ្មែររយៈគិញមួយចំនួនមានឈ្មោះ រឿន, សន, តេង, ចាន់ថា, ថន, រុន, ចៅស៊ី, ម៉េង និង សារូ ងាយស្រួលទាក់ទងគ្នាពេលធ្វើសកម្មភាព ។ កិច្ចការដែលត្រូវធ្វើនៅពេលនោះ គឺឲ្យតាមដានគ្រូ និងសិស្សណាដែលមាននិន្នាការប្រឆាំងជាមួយទូតអាមេរិក ឲ្យតាមដានគ្រូ និងសិស្សជួបប្រជុំគ្នានៅទីកន្លែងណាខ្លះ និងតាមដានមនុស្សណាខ្លះដែលចេញចូលក្នុងសាលា ហើយនៅពេលយប់ តាមដានគ្រូៗដល់ផ្ទះ មើលតើគ្រូៗទាំងអស់នោះចេញទៅណាមកណាខ្លះ ។ ពេលតាមដានដឹងគ្រប់ពីសកម្មភាពហើយត្រូវរាយការណ៍ឲ្យខ្លួន (ម៉ឹយ) ឬក៏រាយការណ៍ទៅឲ្យខ្មែររយៈគិញណាមួយផ្សេងទៀតក៏បាន ។ ធ្វើគិញបម្រើឲ្យ ម៉ឹយ បានមួយរយៈ ទ្រី ក៏បានឈប់វិញដោយគិតឃើញថា ធ្វើគិញគ្មានអនាគតល្អ ហើយម្យ៉ាងភ័យខ្លាចគេចាប់ខ្លួន និងម្យ៉ាងទៀតព្រួគេថាស្អប់អ្នកធ្វើគិញ ទ្រី បានសម្រេចចិត្តទៅរស់នៅកំពង់សោមវិញ ។ ពេលនោះ ទ្រី បានរៀបចំគ្រួសារ ហើយបន្តនៅស៊ីឈ្នួលគេ នៅការ៉ាស់ឡាន ។



កម្មករនៅរោងចក្រក្រឡឹង នៅឃ្លាំងរដ្ឋ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

នៅខែឧសភា ឆ្នាំ១៩៧០ ទ្រី និងមិត្តភក្តិម្នាក់ទៀតឈ្មោះ រ៉ា ត្រូវថៅកែឈ្មោះ ហាយ ពិន និងមេជាងជួសជុលឡានឈ្មោះ ថន បានអប់រំ ទ្រី

បញ្ចូលខ្សែ សេ.អ៊ី.អា ជាលើកទី២ ជាមួយទាហានស័ក្តិ ៥ឈ្មោះ សួស ជា នៅកំពុងសោម ។ ផែនការរបស់ សេ.អ៊ី.អា ដែលត្រូវធ្វើនៅពេលនោះគឺៈ

◆ ទី១ ស៊ើបរកខ្មែរក្រហមដែលធ្វើសកម្មភាពឃោសនាបំផុសចលនាប្រជាជនក្នុងក្រុង ។

◆ ទី២ បំផុសប្រជាជនក្នុងក្រុងកុំឲ្យជឿលើមាគ៌ានយោបាយរបស់ខ្មែរក្រហម បំផុសប្រជាជនឲ្យធ្វើប៉មការពារក្រុង កុំឲ្យខ្មែរក្រហមចូលធ្វើសកម្មភាពក្នុងក្រុងបាន

◆ ទី៣ កសាងកម្លាំង សេ.អ៊ី.អា ឲ្យបានកាន់តែច្រើនឡើងៗថែមទៀត ដើម្បីប្រឆាំងខ្មែរក្រហម ។ ពេលនោះ សួស ជា បានណែនាំ ទ្រី ឲ្យស្គាល់ខ្សែរយៈ សេ.អ៊ី.អា ចាស់ៗមានឈ្មោះ តាំង សេង, គង ហេង, ហាក់, និង ហាយ ពិន ហើយបានឲ្យធ្វើការទាក់ទងជាមួយគ្នាដើម្បីបម្រើកិច្ចការ សេ.អ៊ី.អា ។

ក្រោយពីបានទទួលការណែនាំពី សួស ជា ហើយ ទ្រី និងបក្សពួកបានដើរប្រមូលកៀងគរប្រជាជនឲ្យទៅជួយធ្វើប៉មនៅបន្ទាយទាហាន លន់ នល់ ជួយយាមការពារមិនឲ្យខ្មែរក្រហមចេញចូលក្រុងបាន ហើយឆ្លៀតក្នុងឱកាសនោះកសាងកម្លាំង សេ.អ៊ី.អា បានចំនួន៨នាក់ថែមទៀត ។

ឆ្នាំ១៩៧៤ សួស ជា និង ធី បានដាក់ផែនការឲ្យ ទ្រី និង វ៉ា ដើរស៊ើបរកខ្មែរក្រហម ចាត់តាំងកម្លាំងយាមកាមការពារក្រុងកំពង់សោម មិនឲ្យកម្លាំងរបស់ខ្មែរក្រហមចេញចូលធ្វើសកម្មភាពក្នុងក្រុងបាន និងបំផុសប្រជាជនកុំឲ្យមានជំនឿលើបដិវត្តន៍របស់ខ្មែរក្រហមជាដើម ។ ក្រោយមក ប្រហែលជាកន្លះខែមុនថ្ងៃរំដោះ ឈ្មោះ ធី និង ស្រ៊ី បានកោះហៅខ្សែរយៈ សេ.អ៊ី.អា ទាំងអស់ដែលនៅសេសសល់ពីការចាប់ខ្លួនបង្ខំឲ្យធ្វើទាហានបម្រើឲ្យរដ្ឋការលន់ នល់ ចូលរួមប្រជុំនៅហាងមេគង្គ ដែលឈ្មោះ ធី ជាអ្នកដឹកនាំប្រជុំនៅពេលនោះ ។

ធី បាននិយាយថា សព្វថ្ងៃនេះខ្មែរក្រហមវាខ្លាំងណាស់ ទ័ពរបស់លន់ នល់ ប្រហែលជាទប់ទល់មិនឈ្នះទៀតទេ ព្រោះបន្ទាយធំៗមួយចំនួន ទោះបីជា រឹងមាំយ៉ាងណាក្តី ក៏នៅតែមិនអាចទប់ទល់ខ្មែរក្រហមឈ្នះដែរ ។ ហេតុនេះកម្លាំង សេ.អ៊ី.អា របស់យើងក៏ត្រូវចាញ់ដែរ ។ ពិតមែនតែ សេ.អ៊ី.អា របស់យើងចាញ់មែន ប៉ុន្តែចលនា សេ.អ៊ី.អា របស់យើងនៅតែមានសកម្មភាពដដែល ។ យើងទាំងអស់គ្នាត្រូវត្រៀមខ្លួនជានិច្ច ពេលខ្មែរក្រហមកាន់អំណាច យើងត្រូវបន្លំខ្លួនចូលបង្កប់ជ្រៀតចូលក្នុងជួរខ្មែរក្រហម ។ បើខ្មែរក្រហមប្រើឲ្យយើងធ្វើអី យើងត្រូវតែបំផ្លាញកិច្ចការទាំងនោះចោល ហើយបំផុសប្រជាជនកុំឲ្យមានជំនឿលើខ្មែរក្រហម ។ ម្យ៉ាងទៀត យើងត្រូវខំប្រឹងប្រែងបំផ្លាញកម្លាំងរបស់ខ្មែរក្រហមតាមគ្រប់វិធីដែលយើងអាចធ្វើទៅបាន ត្រូវបំផ្លាញសម្ភាររបស់រដ្ឋគ្រប់ទីកន្លែងតាំងពីគ្រឿងម៉ាស៊ីនផ្សេងៗជាដើម ។

ថ្ងៃរំដោះ ១៧មេសា ឆ្នាំ១៩៧៥ ទ្រី ត្រូវបានជម្លៀសឲ្យទៅនៅភូមិព្រៃនប់ ឃុំព្រៃនប់ ស្រុកវាលរេញ ហើយបាននៅធ្វើការជាមួយប្រធានភូមិ ។ ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៥ ទ្រី បានជួបឈ្មោះ អេង ហើយ អេង ក៏បានណែនាំ ទ្រី ឲ្យទៅធ្វើការជាមួយឈ្មោះ ញ៉ែម នៅយានដ្ឋានដឹកជញ្ជូនជើងគោកកំពង់សោម ។ ឆ្លៀតក្នុងឱកាសនោះដែរ អេង បានបញ្ចុះបញ្ចូល ទ្រី ឲ្យចូលរួមធ្វើសកម្មភាពក្នុងចលនា សេ.អ៊ី.អា បន្តទៀតជាមួយបក្សពួករបស់ខ្លួនមានឈ្មោះ អួន ជាអ្នកទទួលស្គាល់ ហើយបានណែនាំឲ្យស្គាល់ខ្សែរយៈមានឈ្មោះ អួន, វ៉ាន់, សឿន, ស៊ូ, ណោង, និល, វុធ, ផល់, រុន, ទៀង, ហ៊ុន, សាក់, ឡូត, មី, ស្រ៊ិន, ហាក់, វី, ទូច, និងឈ្មោះ ថា រីឯសកម្មភាពដែលត្រូវអនុវត្តគឺៈ

◆ ទី១ បំផុសមហាជនដែលធ្វើការជាមួយយើងកុំឲ្យមានជំនឿលើមាគ៌ាបដិវត្តន៍របស់ខ្មែរក្រហម ។

◆ ទី២ ធ្វើឲ្យរាំងស្ទះដល់ការដឹកជញ្ជូនសម្ភារផ្សេងៗ គឺធ្វើយ៉ាងណាឲ្យឡានខូចច្រើន បំផុសឲ្យអ្នកបើកបរ និងជាងជួសជុលឡានមានទំនាស់ជាមួយគ្នាជាដើម ។

ខែសីហា ឆ្នាំ១៩៧៥ អួន បានហៅសមាជិក សេ.អ៊ី.អា ទាំងអស់ឲ្យមកចូលរួមប្រជុំដើម្បី ណែនាំសមាជិកក្នុងក្រុមឲ្យបានស្គាល់គ្នាផង និងទទួលផែនការយកទៅអនុវត្តផង ។ ពេលនោះ អួន បាននិយាយថា កិច្ចការដែលយើងត្រូវធ្វើប្រឆាំងនឹងបដិវត្តន៍នោះ គឺយើងខំប្រឹងប្រែងធ្វើបានមួយចំនួនហើយ ប៉ុន្តែរហូតមកដល់ពេលនេះបដិវត្តន៍នៅតែរឹងមាំដដែល ។ ហេតុនេះ យើងត្រូវធ្វើសកម្មភាពឲ្យខ្លាំងក្លាលើសមុនទៀត ។

◆ ទី១ ត្រូវដើរដោះម៉ាស៊ីនឡានណាដែលនៅល្អៗតាមថ្នល់

បំផ្លាញចោលឲ្យអស់កុំឲ្យអង្គការយកទៅប្រើការបាន ។

◆ ទី២ បំផុសចលនាមហាជនឲ្យអស់ជំនឿលើមាគ៌ាបដិវត្តន៍ ។

◆ និងទី៣ ដោះកង់ឡានណាល្អៗ ទៅប្តូរយក គោ មាន់ ទា មកធ្វើម្ហូបដែលទង្វើនេះក៏ជាសកម្មភាពមួយ ធ្វើឲ្យរាំងស្ទះដល់ដំណើរការដឹកជញ្ជូនរបស់អង្គការដែរ ។

រំលងបាន១០ថ្ងៃក្រោយពីប្រជុំមក អួន បានធ្វើសកម្មភាពផ្ទាល់ដោយចាត់តាំងឈ្មោះ វ៉ាន់ និង ថា ឲ្យដោះកង់ឡានដែលកំពុងបម្រើការដឹកជញ្ជូនចំនួន១០កង់ យកទៅភូមិភាគឧត្តរ ប្តូរបានគោពីរក្បាល និងមាន់មួយចំនួនយកមកធ្វើម្ហូប ។ បន្ទាប់មកទៀត អួន បានចាត់តាំងកម្លាំងមួយចំនួន ដើរដោះម៉ាស៊ីនឡាននៅតាមផ្លូវថ្នល់ចាប់តាំងពីវត្តជម្ពូវ័ន្ត រហូតដល់កំពង់សោម ឡានរបស់អ្នក ជម្លៀសទុកចោលនៅតាមផ្លូវ បានចំនួនពី២០ទៅ៣០ម៉ាស៊ីន ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ ញ៉ែម បានចាត់តាំង ទ្រី ឲ្យទៅអង្គភាពកាត់ដេររដ្ឋអូរប្ញស្សីភ្នំពេញ ដើម្បីជួសជុលឡានឲ្យអង្គការ ។ នៅទីនោះ ទ្រី បានទាក់ទងខ្សែរយៈឈ្មោះ គុណ តាមការផ្តាំផ្ញើរបស់ ញ៉ែម ។ គុណ បានណែនាំឲ្យស្គាល់ខ្សែរយៈបន្តទៀតឈ្មោះ សួ ។ សួ បានហៅ ទ្រី ឲ្យចូលរួមប្រជុំនៅផ្ទះរបស់ខ្លួនមានឈ្មោះ ឃន ប្រធានក្រុមជាងឡាននៅអង្គភាពកាត់ដេរ, ស្រស់ យុទ្ធជនបើកឡាននៅមន្ទីរកាត់ដេរ និង នីម ប្រធានក្រុមបើកឡានចូលរួមប្រជុំដែរ ។ សួ បានប្រកាសថា កម្លាំង សេ.អ៊ី.អា ទាំងអស់បានទទួលផែនការពីថ្នាក់លើឲ្យបំផ្លាញសម្ភាររបស់រដ្ឋ ជំរុញកម្លាំងបដិវត្តន៍ឲ្យធ្វើការងារក្តៅគគុកដើម្បីឲ្យមហាជនថមថយកម្លាំងធ្លាក់ខ្លួនឈឺ សម្ភារផ្សេងៗត្រូវយកទៅលាក់ទុកឲ្យបាត់ កុំឲ្យអង្គការឃើញ ។

ក្រោយពេលប្រជុំហើយបក្សពួករបស់ ទ្រី បានចេញធ្វើសកម្មភាពយកម៉ាស៊ីនក្រឡឹងចំនួន៤គ្រឿង និងឡានទៅលាក់ទុកនៅតាមផ្ទះចាក់សោមិនឲ្យអង្គការដឹងជាង១០គ្រឿង ។

ក្រោយមកមានខ្សែ សេ.អ៊ី.អា មួយចំនួនទៀត បានមកធ្វើការនៅក្នុងអង្គភាពកាត់ដេរនេះដែរ ។ ចំណែកអង្គភាពផ្នែកជាងជួសជុលឡានមានឈ្មោះ សួត ជាប្រធាន, សួ អនុប្រធាន និងឈ្មោះ ឡុន ជាសមាជិក ។ សួត បានហៅសមាជិក សេ.អ៊ី.អា ទាំងអស់មកជួបជុំគ្នាសាជាថ្មីមានឈ្មោះ សួ, ឡុន, ស្រស់, ឃន, នីម, ភាប់ ប្រធានជាងឈើអង្គភាពកាត់ដេរ, ប្រាប យុទ្ធជននៅរោងក្រឡឹង៧៨, ហឿន ប្រធានរោងជាងក្រឡឹង (បច្ចុប្បន្នប្រធានជួសជុលម៉ាស៊ីនដេរ), ម៉ុញ អនុប្រធានមន្ទីរកាត់ដេរ (អង្គការចាប់ខ្លួនហើយ), តូ ប្រធានបង្កើនផល (អង្គការចាប់ខ្លួនហើយ), វ៉ាន់ ប្រធានសង្គមកិច្ច (អង្គការចាប់ខ្លួនហើយ), ដាន់ ប្រធានសំណង់ (អង្គការចាប់ខ្លួនហើយ), និងឈ្មោះ ស៊ិន អនុប្រធានសំណង់ (អង្គការចាប់ខ្លួនហើយ) ។ ពេលនោះ សួត បានដាក់ផែនការឲ្យក្រុមរបស់ខ្លួនធ្វើសកម្មភាព ។ ក្រោយពីប្រជុំបាន១០ថ្ងៃ ឡុន និង សួ បានណែនាំកម្លាំងថ្មីចំនួន១២នាក់ទៀតឲ្យ សួត បានស្គាល់មានឈ្មោះ ហួន យុទ្ធជនជាង ឡាន, ចុល យុទ្ធជនធ្វើត្រល់(អង្គការចាប់ខ្លួនហើយ), វ៉េត យុទ្ធជនជាងឈើ៧៨ (អង្គការដកទៅបង្កើនផល), ខុម យុទ្ធជនជាងឈើ៧៨ (អង្គការដកទៅបង្កើនផល), ធឿន យុទ្ធជនជាងឈើ៧៨ (អង្គការដកទៅបង្កើនផល), ស្រ៊ិន យុទ្ធជននៅរោងជាងក្រឡឹង, ហាត ប្រធានក្រុមឡាន, ទីម យុទ្ធជនធ្វើរទេះ (បច្ចុប្បន្នយុទ្ធជនសំណង់ និងស្ពដែកនៅក្រសួងកាត់ដេរ), អ៊ី ប្រធានក្រុមបត់កាត់, មី (មុនអង្គការចាប់ខ្លួនជាសមាជិកកងធំនៅកាត់ដេររដ្ឋ), នឿន ប្រធានក្រុមសំណង់ (បច្ចុប្បន្នអនុកងតូចទី១ ខាងក្រឡឹង), វ៉ុធ យុទ្ធជនជាងឈើ (បច្ចុប្បន្នអនុក្រុមខាងស្ពដែក), និង ពេជ ប្រធានក្រុមជាងឈើ (បច្ចុប្បន្នប្រធានក្រុមនៅរោងជាងក្រឡឹង) ។ បន្ទាប់មក សួត បានចាត់តាំងឲ្យឈ្មោះ ហឿន និង ទីម ដឹកនាំសមាជិក ធ្វើសកម្មភាពបន្ទុំកុមារនៅផ្នែកក្រឡឹង ឲ្យសម្រុកធ្វើត្រល់ ធ្វើរទេះ បត់ក្រណាត់ គ្មានពេលឈប់សម្រាក ធ្វើឲ្យបាក់ផ្លែកាំបិត ម៉ាស៊ីនក្រឡឹង ធ្វើឲ្យឆេះម៉ូទ័រជាដើម ។

ឆ្នាំ១៩៧៧ គុណ និងបក្សពួកមួយចំនួនត្រូវបានអង្គការចាប់ខ្លួនជាបន្តបន្ទាប់ ។ ពេលនោះ នារីឈ្មោះ ខន បានឡើងធ្វើជាប្រធានកាត់ដេរជំនួសគុណ ហើយបានដឹកនាំកម្លាំង សេ.អ៊ី.អា ដែលនៅសេសសល់ពីការចាប់ខ្លួនធ្វើសកម្មភាពបន្តទៀត ។ ចំណែក ឡុន និង សួ បានហៅ ទ្រី និងសមាជិកផ្សេងទៀតមកប្រជុំមានឈ្មោះ មុី, តាអ៊ី, នឿន, ពេជ, ផល់, ចុល, ហឿន, វ៉េត, ហាត, ស្រ៊ិន, វ៉ុធ, ឃន, ស្រស់ និងមានខ្សែរយៈថ្មី៤នាក់ទៀតឈ្មោះ អឿន ប្រធានក្រុមធ្វើត្រល់, បូ ប្រធានក្រុមស្ពដែក, ហ៊ាន ប្រធានពួកបើកឡាន, ខន អនុក្រុមធ្វើត្រល់ ។ ឡុន បានលើកឡើងថា ខ្សែ សេ.អ៊ី.អា របស់យើងបច្ចុប្បន្ននេះចុះខ្សោយជាលំដាប់ ហេតុនេះយើងត្រូវរៀបចំខ្សែសន្ទាក់

និងពង្រឹងកម្លាំង សេ.អ៊ី.អា របស់យើងឡើងវិញក្រោមការដឹកនាំរបស់ ខន និង ម៉ុញ ។ មិនយូរប៉ុន្មាន នៅពាក់កណ្តាលឆ្នាំ១៩៧៧ ខ្សែរយៈរបស់ ខន ត្រូវអង្គការចាប់ខ្លួនអស់ ហើយអង្គការបានចាត់តាំងឲ្យឈ្មោះ យ៉ុង ធ្វើប្រធានកាត់ដេររដ្ឋបន្តពីនារី ខន ចំណែកនារី វ៉ុន ជាអនុប្រធាន និងឈ្មោះ នឿន ដែលជាខ្សែរយៈចាស់របស់ ទ្រី ត្រូវបានយ៉ុងចាត់តាំងឲ្យធ្វើជាសមាជិក ។ សកម្មភាព សេ.អ៊ី.អា នៅក្នុងអង្គភាពទាំងមូលត្រូវបានផ្អាកជាបណ្តោះអាសន្នសិន ក្នុងខណៈពេលដែលអង្គការចាប់ខ្លួននារី ខន និងសមាជិកខ្សែរយៈ ។ ប្រហែលបីបួនខែក្រោយមក នឿន ចូលមករៀបចំ និងដឹកនាំក្រុម សេ.អ៊ី.អា ឡើងវិញ ហើយបានហៅខ្សែរយៈ សេ.អ៊ី.អា ទាំងចាស់ទាំងថ្មី មកប្រជុំដើម្បីទទួលផែនការយកទៅអនុវត្តបន្តទៀត ។

ខែឧសភា ឆ្នាំ១៩៧៨ នឿន បានហៅ ទ្រី, ពេជ, ផល់, ទឹម មកប្រជុំម្តងទៀតនៅក្នុងរោងជាងក្រឡឹង ។ នឿន បានលើកឡើងថា នៅរោងជាងក្រឡឹង យើងត្រូវបំផ្លិចបំផ្លាញសម្ភារឲ្យខូចខាតជារៀងរាល់ថ្ងៃ ហើយបន្តធ្វើយ៉ាងណាឲ្យមហាជនជឿជាក់មកលើកម្លាំង សេ.អ៊ី.អា របស់យើង ហើយអស់ជំនឿលើមាគ៌ាបដិវត្តន៍ ។ ក្រោយពេលប្រជុំ ទ្រី និង ពេជ ក្រឡឹងធ្វើឲ្យខូចកង់រទេះ បត់ក្នុងមួយថ្ងៃ ខូចអស់ពីរឬបី ពេលពត់ដែកធ្វើឲ្យខូចដែកអស់ជាច្រើន ពេលជួសជុលគ្រឿងម៉ាស៊ីនផ្សេងៗ មិនប្រុងប្រយ័ត្ន មិនយកចិត្តទុកដាក់ខ្ជីខ្ជានឹងការងារ ដែលជាហេតុធ្វើឲ្យខូចសម្ភារអង្គការហូរហែ ។ ក្រោយមកឈ្មោះ យ៉ុង ត្រូវបានអង្គការចាប់ខ្លួន ហើយបានចាត់តាំងឈ្មោះ លីន ឲ្យមកក្តាប់អង្គភាពកាត់ដេរវិញ ឯឈ្មោះ វ៉ាន់ ធ្វើប្រធានក្រសួងរឹង នឿន មកធ្វើអនុកងទី១វិញ ។ ពេលនោះ ទ្រី និងបក្សពួកបានផ្អាកធ្វើសកម្មភាពរបស់ខ្លួនមួយរយៈ ដើម្បីឲ្យសភាពការណ៍វិលទៅរកភាពស្ងប់ស្ងាត់ ។ ក្នុងពេលនោះដែរ អង្គការបានចាត់តាំង ទ្រី ឲ្យធ្វើជាអនុប្រធានក្រុមផ្នែកជាងក្រឡឹង ។

ខែកក្កដា ឆ្នាំ១៩៧៨ នឿន បានហៅ ទ្រី មកពិភាក្សាការងារ ។ ទ្រី បានរាយការណ៍ប្រាប់ នឿន ពីខ្សែរយៈរបស់ខ្លួនខ្លះអ្នកដឹកនាំក្រោយពេលអង្គការចាប់ខ្លួនអ្នកដឹកនាំមុនៗអស់ ។ នឿន បាននិយាយថា ការងារ និងសកម្មភាព សេ.អ៊ី.អា របស់យើងនៅតែមានដំណើរការទៅមុខជានិច្ច ទោះបី អ្នកដឹកនាំចាស់ៗត្រូវអង្គការចាប់ខ្លួនក៏ដោយ តែនៅពេលនេះយើងមានអ្នកដឹកនាំថ្មីៗទៀត មកដឹកនាំក្រុមយើង មានឈ្មោះ ជឿន ប្រធានកងធំ, ហឿន អនុកងធំ, មុី សមាជិកកងធំ, ឆាំ ប្រធានកងតូចទី១, នាគ ប្រធានកងតូចទី២ និង អឿន អនុកងតូចទី២ ។ ក្រៅពីនេះ យើងនៅមានកម្លាំងជាច្រើននាក់ទៀតដែលអាចទាក់ទងគ្នាធ្វើសកម្មភាពប្រឆាំងតទៅទៀតបាន ។ ពិភាក្សាគ្នាចប់ក៏បែកផ្លូវទៅធ្វើការរៀងៗខ្លួន ។

ជាង១០ថ្ងៃក្រោយមក សមាជិកក្នុងក្រុមរបស់ ទ្រី មានការជួបជុំមួយទៀតនៅកងតូចទី២ ក្រោមការដឹកនាំរបស់ នឿនដដែល ។ អ្នកចូលរួមប្រជុំនៅពេលនោះមានឈ្មោះ ហឿន, មុី, ឆាំ, អឿន, ពេជ, ខន, វុធ, តាអុី, ទឹម, វិន ប្រធានមន្ទីរកាន់ទូរស័ព្ទ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) , គី, ហាត, ញ៉ាំ, និង ហ៊ាម ។ នឿន បានប្រកាសនៅក្នុងអង្គប្រជុំថា ការដែលយើងប្រជុំគ្នាលើកនេះ គឺដើម្បីឲ្យសមាជិក សេ.អ៊ី.អា ទាំងអស់ស្គាល់គ្នា ងាយស្រួលធ្វើការទាក់ទងគ្នាធ្វើសកម្មភាព និងដាក់ផែនការឲ្យកម្លាំងរបស់យើងអនុវត្តផង ។

ក្រោយពេលប្រជុំ ទ្រី បានធ្វើសកម្មភាពដើរបំផុសបំផុលគ្រប់កន្លែងនៅក្នុងក្រសួងពីការហូប ចុក មានបាយ ក្តៅសម្លក្តៅ និងមានម្ហូបពីរមុខ វាយប្រហារអ្នកទទួលខុសត្រូវថ្មីៗ និងលើកសរសើរពីអ្នកដឹកនាំចាស់ៗ ។ ទី២ ការកែច្នៃសម្ភារត្រូវទុកមួយអន្លើ គិតតែពីស្នើសុំនេះ ស្នើសុំនោះពីអង្គការគ្រប់មុខគ្រប់ពេលវេលា យកដែកទៅទុកចោលហាលថ្ងៃ ហាលភ្លៀង ច្រេះស៊ីខូចដែកជាបន្តបន្ទាប់ ។ ម៉ាស៊ីនខូចមិនជួសជុលវិញទេ រួចរាយការណ៍ថា ម៉ាស៊ីនប្រើការលែងកើត ហើយស្នើសុំម៉ាស៊ីនថ្មីទៀត ។ ផែនការនេះក៏ជាចំណែកមួយដែលធ្វើឲ្យរាំងស្ទះដល់ការងារមួយចំនួនរបស់អង្គការដែរ ។

នៅចុងបញ្ចប់នៃឯកសារចម្លើយសារភាពរបស់ ទ្រី ដែលមានចំនួន៣២ទំព័រ បានបញ្ជាក់ថា ទ្រី ត្រូវបានអង្គការចាប់ខ្លួន ដោយចោទពីបទរួមគំនិតជាមួយបក្សពួកធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ និងបញ្ជូនមកមន្ទីរស-២១ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៨ ។ ទ្រី ត្រូវអង្គការបង្ខំឲ្យឆ្លើយសារភាពទោសកំហុសបំផ្លាញអង្គការបដិវត្តន៍ និងផ្តិតមេដៃទទួលស្គាល់ចម្លើយសារភាពរបស់ខ្លួន ។ ចម្លើយសារភាពរបស់ ទ្រី ត្រូវវាយជាអង្គុលីលេខឡើងវិញ ដោយធ្វើចប់នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨ និងមានឈ្មោះ មឿន ជាអ្នកសួរចម្លើយ ។

**ឆេង ខ៉េង**

# ដំណឹងយុវជន យុវនារីបដិវត្តន៍

***ដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្តន៍លេខ១-២ មករា-កុម្ភៈ ១៩៧៨***

### ***១) វីរភាពរបស់យុវជន យុវនារីកងចល័ត នៅតាមព្រំដែន***

ប្រជាជនយើងនៅតាមព្រំដែន ភាគច្រើនលើសលប់ ជាប្រជាជនក្រីក្រ ដែលមានគោលជំហរ ស្នេហាជាតិ ស្នេហាទឹកដីយ៉ាងខ្ពង់ខ្ពស់ និងមានគោលជំហរប្រយុទ្ធដាច់ខាតជាមួយខ្មាំងសត្រូវគ្រប់ប្រភេទ ។ មាតាបិតា ដែលមានធាតុវណ្ណៈដើមយ៉ាងនេះ មានគោលជំហរស្នេហាជាតិ ស្នេហាទឹកដីយ៉ាងនេះ មានគោលជំហរប្រយុទ្ធដាច់ខាតជាមួយខ្មាំងសត្រូវឈ្លានពានគ្រប់ប្រភេទយ៉ាងនេះ បុត្រា បុត្រីក៏មានធាតុពិតដូច្នេះដែរ ពោលគឺយុវជនយុវនារីកម្ពុជាយើងនៅតាមព្រំដែនក៏មានគោលជំហរ ស្នេហាជាតិ ស្នេហាទឹកដី និងគោលជំហរប្រយុទ្ធដាច់ខាតជាមួយខ្មាំងសត្រូវឈ្លានពានដែរ ។ ប្រជាជនក្រីក្រ និងយុវជន យុវនារីយើងនៅតាមព្រំដែន ត្រូវទទួលនូវការជិះជាន់ សង្កត់សង្កិន យ៉ាងធ្ងន់ធ្ងរពីសំណាក់ពួកអាក្បត់ជាតិ ពួកវណ្ណៈសក្តិភូមិ នាយទុន និងពួកវណ្ណៈជិះជាន់គ្រប់ប្រភេទ ដូចជាប្រជាជនក្រីក្រ និងយុវជន យុវនារីយើង នៅទូទាំងប្រទេសដែរ ។ តែចំណុចមួយដែលលើសពីប្រជាជនក្រីក្រនៅទូទាំងប្រទេស គឺត្រង់ដែលប្រជាជនក្រីក្រ និងយុវជន យុវនារីយើងនៅតាមព្រំដែនត្រូវទទួលរងនូវអំពើឈ្លានពានផ្ទាល់ពីសំណាក់ពួកចក្រពត្តិនិយម និងពួកវាតទីនិយមមកពីខាងក្រៅ ដែលមានចក្រពត្តិអាមេរិក និងជាពិសេស នៅពេលចំពោះមុខនេះ គឺពួកយួនឈ្លានពានវាតទីលេបទឹកដីជាប់ជាប្រចាំ ។ អំពើឈ្លានពានបាញ់រះ បាញ់ផ្លោងឆក់ប្លន់បំផ្លិច



កងយោធាខ្មែរក្រហម កំពុងប្រយុទ្ធនៅសមរភូមិមុខ

បំផ្លាញពីសំណាក់ពួកយួនឈ្លានពានរំលោភទឹកដី មកលើប្រជាជន យុវជន យុវនារីយើង នៅតាមព្រំដែន ប្រៀបបាននឹងជំងឺរុំារ៉ៃមួយ ដែលរាតត្បាត ប្រជាជន យុវជន យុវនារីយើងជាប់ជាប្រចាំ ។ ទឹកដីយើងនៅតាមព្រំដែនត្រូវឆេះខ្លោច ហើយជីវភាពប្រជាជនយើងត្រូវវិចវិលជានិច្ច គ្មានពេលណាងើបឡើងរួចបានទេ ។ ដោយត្រូវខ្វាំងទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ជិះជាន់ឆក់ប្លន់ កាប់សម្លាប់ពូជពង្សរាប់ច្រើនដំណមកហើយយ៉ាងនេះ ហើយត្រូវជិះជាន់ច្រើនជាន់ ច្រើនត្រួតធ្ងន់ធ្ងរយ៉ាងនេះ យុវជន យុវនារីយើងនៅតាមព្រំដែន មានភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈឆាបឆេះពុះកញ្ជ្រោលក្ដៅងំជាប់ជាប្រចាំ ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្ដកម្ពុជាយើង ភ្លើងកំហឹងដ៏សន្ធោសន្ធៅនេះ បានប្រែក្លាយទៅជាកម្លាំងដ៏ខ្លាំងក្លា វាយសម្រុកទៅលើចក្រពត្តិអាមេរិក ពួកអាយ៉ងធីវគីឈ្លានពានរំលោភទឹកដី និងបក្សពួកអាក្បត់លន់នល់ រួមរំដោះមាតុភូមិកម្ពុជា រំដោះប្រជាជាតិ ប្រជាជនកម្ពុជា និងរំដោះវណ្ណៈក្រីក្របានទាំងស្រុង និងជាស្ថាពរ នាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដ៏មហាអស្ចារ្យ ។

ក្រោយពីបានឆ្លងកាត់ចលនាតស៊ូបដិវត្តន៍ជាបន្តបន្ទាប់ ហើយដោយបានបក្សយកចិត្តទុកដាក់ អប់រំ បំពាក់បំប៉នជាបន្តបន្ទាប់ កំហឹងជាតិ កំហឹងវណ្ណៈរបស់យុវជន យុវនារីយើងនៅតាមព្រំដែន រឹតតែឆាបឆេះពុះពោរសន្ធោសន្ធៅឡើង ហើយប្រែក្លាយទៅជាជំហរប្រយុទ្ធកាន់តែស្រួចស្រាវទ្វេឡើងថែមទៀត ។ ជំហរប្រយុទ្ធដ៏ស្រួចស្រាវនេះ បានកែប្រែអ្វីៗទាំងអស់នៅតាមព្រំដែន ឲ្យប្រែប្រួលថ្មីជាបន្តបន្ទាប់ ។

ជាក់ស្ដែង ចាប់តាំងពីក្រោយថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥មក យុវជន យុវនារីកងចល័តយើងនៅតាមព្រំដែន បានកែប្រែទឹកដីខ្លោចនៅតាមចំនៀរព្រំដែននៃមាតុភូមិយើង ដែលធ្លាប់តែក្រៀមក្រោះជាយូរមកហើយ ឲ្យទៅជាវាលស្រែថ្មី មានប្រព័ន្ធភ្លឺ ទំនប់ប្រឡាយ ព្រែកជីក អាងទឹក មានស្រូវចម្រុះពណ៌ត្រគុំត្រកាល មានដំណាំសព្វមុខពណ៌បៃតងស្រងាត់ ខ្ទបប្រាំង ខ្ទបវស្សា មានផ្ទះសហករណ៍ដ៏សមរម្យតម្រៀបគ្នាជាជួរៗ ដែលផ្ដល់នូវសុភមង្គលដល់ប្រជាជនសមូហភាពយើង យ៉ាងកក់ក្ដៅបំផុត ។ ភូមិ ឃុំទាំងឡាយនៅតាមព្រំដែន បានក្លាយទៅជាតំបន់សេដ្ឋកិច្ច និងជាពិសេស ភូមិ ឃុំទាំងនេះ បានប្រែក្លាយទៅជាប៉មការពារដ៏រឹងមាំជួរមុខបំផុត នៃកម្ពុជាប្រជាធិបតេយ្យយើង ។

ប៉ុន្តែ នៅចំពោះមុខដែលកម្ពុជាប្រជាធិបតេយ្យយើងរីកចម្រើនទៅមុខ ដោយឯករាជ្យ ម្ចាស់ការយ៉ាងនេះ ពួកយួនដែលមានគោលបំណងជាយុទ្ធសាស្ត្រយូរមកហើយ ចង់យកកម្ពុជាប្រជាធិបតេយ្យយើង ទៅបញ្ចូលក្នុងសហព័ន្ធឥណ្ឌូចិន ដែលរណបយួន ដើម្បីលេបត្របាក់ប្រជាជាតិ ប្រជាជន និងទឹកដីកម្ពុជាយើងទាំងមូល មិនសប្បាយចិត្តទេ ។ ពួកវាក្ដៅក្រហាយសម្បើមណាស់ ។ ចាប់តាំងពីសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកត្រូវបានបញ្ចប់ ទាំងនៅកម្ពុជា ទាំងនៅវៀតណាម កាលណាមក ពួកយួនលោភលន់ តែងរិះរកគ្រប់វិធីប្រើគ្រប់ឧបាយកលខ្មៅងងឹត ធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា ប្រជាជនកម្ពុជា ប៉ុនប៉ងវាយរំលំបក្សកុម្មុយនីស្ដកម្ពុជា និងរំលំកម្ពុជាប្រជាធិបតេយ្យជាបន្តបន្ទាប់ ។ ប៉ុន្តែអំពើឧក្រិដ្ឋ



សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ ស្ដាប់ការពន្យល់ពីរបៀបប្រើប្រាស់កាំភ្លើងធំ ពីក្រុ

ផ្សេងៗ បក្សកុម្មុយនីស្តកម្ពុជា និងទឹកដីកម្ពុជាយើងកន្លងមក ដើម្បីវាយបំបាក់កម្ពុជា ហើយលេបកម្ពុជា តាមយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់វានេះ ក៏ត្រូវប្រជាជន និងកងទ័ពបដិវត្តន៍យើង ក្រោមការដឹកនាំក៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សយើង វាយកម្ចាត់ឲ្យបរាជ័យជាបន្តបន្ទាប់ ។ ដូច្នេះហើយ បានជាចាប់តាំងពីដើមខែកញ្ញា ឆ្នាំ១៩៧៧មក ពួកយួនដែលពាក់ស្លាកជាកុម្មុយនីស្ត ជាអ្នកបដិវត្តន៍សង្គមនិយម បានចាត់កងទ័ពវាជាច្រើនកងពល ដោយមានកាំភ្លើងធំ និងរថក្រោះរាប់រយគ្រឿង និងមានយន្តហោះជួយអន្តរាគមន៍នៅពេលខ្លះៗផង ឲ្យចូលមកឈ្លានពានទឹកដីយើងជាចំហ ដោយទ្រង់ទ្រាយធំ មានលក្ខណៈជាសង្គ្រាមមិនប្រកាស ដើម្បីឆក់ប្លន់ស្រូវអង្ករគោក្របី ជ្រូកមាន់របស់ប្រជាជនយើង ទៅដោះស្រាយការអត់ឃ្លានរបស់វា នៅពេលចំពោះមុខនេះ និងក្នុងគោលបំណងជាយុទ្ធសាស្ត្រលេបត្របាក់កម្ពុជាតែមួយព្រឹបតែម្តង ។ ក្នុងពេលវាយលុក ឈ្លានពានយ៉ាងកាចសាហាវនេះ ពួកខ្មាំងយួនបានកាប់ខ្ទេច សម្លាប់ខ្ទេចដុតខ្ទេច បំផ្លាញខ្ទេច ទាំងអាយុជីវិត ទាំងទ្រព្យសម្បត្តិរបស់ប្រជាជនយើងដែលវាជួបប្រទះ ។ ពួកវាឆក់ប្លន់ស្រូវនៅតាមជង្រុកប្រជាជនយើង អស់រាប់ម៉ឺនតោនដុតបំផ្លាញស្រូវទុំនៅក្នុងស្រែអស់រាប់ម៉ឺនហិកតាទៀត ដុតផ្ទះសម្បែងប្រជាជនសហករណ៍យើងអស់ទាំងភូមិៗ ឆេះខ្ទេចខ្ទីអស់ វាកាប់បំផ្លាញដំណាំដាំដុះរបស់ប្រជាជនយើងអស់ទាំងចម្ការៗ វាបំផ្លាញរហូតដល់ប្រព័ន្ធសំណង់ទឹក ដែលប្រជាជនសហករណ៍យើងខំបង្ហូរដល់ប្រព័ន្ធសំណង់ទឹក ដែលប្រជាជនសហករណ៍យើង ខំបង្ហូរញើសឈាមកសាងឡើងទាំងប្រាំង ទាំងវស្សា ។ ឃោរឃៅជាងនេះទៅទៀត វាបានចាប់យុទ្ធនារីកងចល័តយើងធ្វើបាបដោយរំលោភលេងសើចរួចហើយ បាញ់សម្លាប់ចោលបំបាត់ដានទៀត ។ និយាយរួម អ្វីៗទាំងអស់ដែលយុវជន យុវនារីកងចល័តយើង និងប្រជាជនសហករណ៍យើង នៅតាមព្រំដែន ខំបង្ហូរញើសឈាមធ្វើបានមក វាឆក់ប្លន់និងបំផ្លិចបំផ្លាញទាំងអស់ ។


មប្រឹក្សាចិន នៅសមរភូមិ

នៅចំពោះមុខអំពើឈ្លានពាន ឆក់ប្លន់ កាប់សម្លាប់ ដ៏កាចសាហាវនេះ របស់យួនឈ្លានពាន វាទី លេបទឹកដី យុវជន យុវនារីកងចល័តយើងនៅតាមព្រំដែន ក៏ដូចជាប្រជាជនយើងនៅទូទាំងប្រទេសដែរ មានកំហឹងឈឺចាប់ក្រៃលែង ។ បងប្អូន ប្តេជ្ញា រួបរួមសាមគ្គីយ៉ាងជិតស្និទ្ធជាមួយកងទ័ពបដិវត្តន៍កម្ពុជាយើង បន្តធ្វើពលិកម្មសព្វបែបយ៉ាងដោយកម្រិតខ្ពស់តទៅទៀត ដើម្បីវាយកម្ចាត់ខ្មាំង យួនឈ្លានពានលេបទឹកដី និងរាល់សកម្មភាពខ្មោងងីតខ្ម្រិជ្ឈរបស់វា ការពារទឹកដី ភូមិករ ផ្ទះសម្បែង ស្រែចម្ការ ច្បារដំណាំរបស់បងប្អូនដាច់ខាត ។ តាមរយៈនេះ ក៏រួមការពារកម្ពុជាប្រជាធិបតេយ្យ ការពារឯករាជ្យជាតិ ការពារអធិបតេយ្យជាតិ និងកិត្តិយសជាតិ ឲ្យបានស្ថិតស្ថេរគង់វង្ស និងរឹងប៉ឹង ខ្លាំងក្លាជារៀងរហូត ។ ជាក់ស្តែង បងប្អូនបានប្រយុទ្ធការពារផល និងប្រមូលទុកដាក់ផលដែលស្ថិតនៅលើសមរភូមិយ៉ាងមានះព្យាយាមស៊ូតស៊ូញ និងអង់អាចក្លាហានបំផុត ។ ពោល គឺវីរយុទ្ធជនកងទ័ពបដិវត្តន៍យើង ដេញវាយកម្ចាត់ខ្មាំងដល់ត្រឹមណា រំដោះស្រុកភូមិបានត្រង់ណា យុវជនយុវនារីកងចល័តយើង សម្រុកប្រូតកាត់ប្រមូលទុកដាក់ផលស្រូវដល់ត្រឹមនោះដែរ ។ យុវជនយុវនារីកងចល័តយើងដឹកជញ្ជូនផលស្រូវមកទុកដាក់នៅខាងក្រោយផង ហើយត្រឡប់ទៅវិញដឹកជញ្ជូន

ស្បៀង គ្រាប់ ទៅជូនកងទ័ពយើងផង ។ លេណដ្ឋានដែលយុទ្ធជនកងទ័ពបដិវត្តន៍យើងជីកពួនបាញ់ខ្មាំង ក្នុងពេលកំពុងជាប់ដៃប្រយុទ្ធគ្នា ឥឡូវបានទៅជាលេណដ្ឋានសម្រាប់ការពារខ្លួនរបស់យុវជន យុវនារីកងចល័តយើង ក្នុងពេលប្រយុទ្ធប្រមូលផលជាបន្តបន្ទាប់ ។ ឆាកប្រយុទ្ធវាយខ្មាំងលើសមរភូមិយោធារបស់កងទ័ពយើង និងឆាកប្រយុទ្ធវាយខ្មាំងខាងសេដ្ឋកិច្ចរបស់យុវជន យុវនារីកងចល័តយើង វាយសម្រុកព្រមៗគ្នាជាប់ទៅលើខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី ។ ស្នូរកាំភ្លើងតូចធំរបស់យុទ្ធជនកងទ័ពបដិវត្តន៍យើង និងស្នូរកណ្តៀវប្រូតកាត់ស្រូវ និងស្នូរបោកបែនស្រូវរបស់កងចល័តយើង លាន់ឆ្លើយឆ្លងគ្នាជាប់ទាំងយប់ ទាំងថ្ងៃ គ្មានដាច់រយៈឡើយ ។ ការវាយសម្រុកប្រូតកាត់ប្រមូលទុកដាក់ផលស្រូវនៅជាប់នឹងសមរភូមិមុខ ដែលកំពុងតែឆេះក្តៅគគុកយ៉ាងនេះ វាតែងតែមានគ្រោះថ្នាក់ និងពលិកម្មខ្លះៗជាធម្មតា ។ តែយុវជន យុវនារីកងចល័តយើង មិនដែលយកបញ្ហាទាំងអស់នេះមកចោទទេ ។ តែបញ្ហាដែលបងប្អូន ត្រូវប្រយុទ្ធដោះស្រាយជាបន្ទាន់នោះ គឺតើធ្វើយ៉ាងម៉េចដើម្បីប្រមូលផលឲ្យបានឆាប់រហ័ស កុំឲ្យខ្មាំង វាបំផ្លិចបំផ្លាញបានឬកុំឲ្យខ្មាំងវាឆក់ប្លន់បាន? ហើយតើត្រូវធ្វើយ៉ាងម៉េចទៀត ដើម្បីវាយសម្រុកប្រមូលផលស្រូវ ឲ្យបានឆាប់រហ័ស ហើយកម្លាំងបងប្អូន ក៏ការពារឲ្យបានជាអតិបរមា? ។ ជាក់ស្តែង ក្នុងការវាយសម្រុកប្រូតកាត់ក្តី បោកបែនក្តី ដឹកជញ្ជូនក្តី បងប្អូនបំបែកគ្នាធ្វើការងារជាក្រុមតូចៗ ៧-៨នាក់ ឬ១០នាក់ យ៉ាងច្រើន ដើម្បីស្រួលគេចនឹងគ្រាប់ផ្លោង ហើយការពារកម្លាំងបានជាអតិបរមា ។ បងប្អូនបានយកមាគ៌ាសង្គ្រាមឈ្លបរបស់បក្ស ទៅអនុវត្តយ៉ាងរស់រវើកនៅក្នុងការងារ លើសមរភូមិប្រយុទ្ធជាក់ស្តែង ។ យុវជន យុវនារីកងចល័តយើង នៅសមរភូមិមុខមានទស្សនៈឯកភាពគ្នាថា "ត្រូវតែប្រមូលទុកដាក់ផល និងការពារផល ដែលនៅសេសសល់ពីខ្មាំងឆក់ប្លន់ និងបំផ្លិចបំផ្លាញនេះ ឲ្យបានគត់មត់ល្អដាច់ខាត ព្រោះផលស្រូវទាំងអស់នេះ សុទ្ធតែបានមកពីកម្លាំងញើសឈាមរបស់ពុកម៉ែយើង ។ ផលស្រូវនេះហើយ ដែលជាទុនសម្រាប់កែប្រែជីវភាពប្រជាជនយើង និងកសាងមាតុប្រទេសយើងឲ្យរីកចម្រើនលោតផ្លោះ ។ ជាពិសេស បើស្រូវនេះ ធ្លាក់ចូលទៅក្នុងដៃខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី នោះផលស្រូវយើងនេះ នឹងទៅជាកម្លាំងបំប៉នខ្មាំងឲ្យវាយយើងកាន់តែខ្លាំងទៀត ។ មាគ៌ាវាយខ្មាំងខាងសេដ្ឋកិច្ចរបស់បក្សយើង ជាមាគ៌ាមួយស័ក្តិសិទ្ធិណាស់ ។ អ្វីៗដែលជាវិភាគទានរួមចំណែកវាយកម្ទេចខ្មាំងយួនឈ្លានពានលេបទឹកដីឲ្យចេញអស់ពីលើទឹកដី យើងត្រូវតែអនុវត្ត ត្រូវតែហ៊ានលះបង់ទាំងអស់ ទោះបីជា វាត្រូវការកម្លាំងកាយប៉ុណ្ណា កម្លាំងលះបង់ខាងសតិអារម្មណ៍ប៉ុណ្ណាក៏ដោយ ឬក៏ត្រូវធ្វើពលិកម្មដល់អាយុជីវិតក៏ដោយ ព្រោះបើយើងខ្ញុំយួន យើងបណ្តោយឲ្យយួនលេបជាតិយើង និងទឹកដីយើងបាន គឺបានសេចក្តីថា យើងស្លាប់ទាំងរស់ យើងស្លាប់ ដោយថោកទាបណាស់ ។ ដូនតាយើង ពុកម៉ែយើង ក៏ដូចខ្លួនយើងម្នាក់ៗដែរដែលខំតស៊ូ ខំលះបង់ និងធ្វើពលិកម្មដ៏ធំធេង សព្វបែបយ៉ាង កន្លងមក មិនមែនដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជនយើង ឲ្យរួចពីខ្ញុំកញ្ជះចក្រពត្តិអាមេរិក ហើយមកធ្វើជាខ្ញុំកញ្ជះយួនទេ ។ តែគឺយើងចង់ឯករាជ្យ ១០០ ភាគរយ ។

ដោយមានទស្សនៈត្រឹមត្រូវ ចំពោះបញ្ហាប្រទេសជាតិ ប្រជាជន ហើយពិសេស ចំពោះឯករាជ្យ និងខ្ញុំគេច្បាស់លាស់ដូច្នេះហើយ បានជាយុវជន យុវនារីកងចល័តយើង ប្រយុទ្ធប្រូតកាត់ប្រមូលទុកដាក់ផលត្រូវនៅជាប់នឹងសមរភូមិមុខ ដោយគោលជំហរទទួលខុសត្រូវខ្ពស់ និងដោយហ៊ានលះបង់គ្មានលក្ខខណ្ឌអ្វីទាំងអស់ ទាំងកម្លាំងចិត្ត ទាំងកម្លាំងកាយរហូតដល់អាយុជីវិតរបស់ខ្លួនទៀត ។ ទាំងអស់នេះ ជាវីរភាពរបស់យុវជន យុវនារីកងចល័តយើងនៅតាមព្រំដែន ដែលបានបង្ហាញដោយគំរូរស់តាមរូបភាពជាក់ស្តែង ជាចលនាប្រយុទ្ធជាក់ស្តែង នៅលើសមរភូមិប្រយុទ្ធជាក់ស្តែងក្នុងពេលកន្លងមកថ្មីៗនេះ ក៏ដូចក្នុងពេលសព្វថ្ងៃនេះដែរ ។ ទាំងអស់នេះ ក៏បានបញ្ជាក់ឲ្យឃើញថា យុវជន យុវនារីជាកូនចៅប្រជាជនក្រីក្រយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ស្មោះត្រង់នឹងបក្ស ស្មោះត្រង់នឹងប្រទេសជាតិ ប្រជាជន ស្មោះត្រង់នឹងវណ្ណៈក្រីក្រ ស្មោះត្រង់នឹងបម្រើរបបសមូហភាពរបស់បក្សអស់មួយអាយុជីវិត ដោយឥតលក្ខខណ្ឌឡើយ ។ គេទាំងឡាយ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងអស់ ដើម្បីការពារឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពដែនដីជាតិ និងកិត្តិយសជាតិ និងទង់ឯករាជ្យម្ចាស់ការរបស់បក្សយើងដាច់ខាត និងជារៀងរហូត ។

កុលបុត្រ កុលធីតាកម្ពុជា ដែលមានវីរភាពបដិវត្តន៍ខ្ពង់ខ្ពស់

បែបនេះ ពិតជាគ្មានខ្មាំងសត្រូវណា ទោះជិតក្តី ឆ្ងាយក្តី តូចក្តី ធំក្តី ពិសេស ខ្មាំងយួនឈ្លានពាន វាតទីនិយម លេបទឹកដី និងបក្សពួកវា ដែលកំពុងតែប្រឹងប្រែងប្រព្រឹត្តនូវអំពើឧក្រិដ្ឋផ្សេងៗ ដើរឧបាយកលពិសពុលសព្វបែបយ៉ាង យ៉ាងមមាញឹក ដើម្បីលេបត្របាក់កម្ពុជាប្រជាធិបតេយ្យយើងសព្វថ្ងៃនេះ មិនអាចវាយបំបាក់ និងលេបកម្ពុជាប្រជាធិបតេយ្យយើងបានឡើយ ហើយតទៅទៀត កុលបុត្រ កុលធីតាទាំងនេះ នឹងបន្តការពារប្រទេស បន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមគ្រប់ផ្នែកនៅកម្ពុជាប្រជាធិបតេយ្យយើង បានសម្រេចជោគជ័យត្រចះត្រចង់ដាច់ខាត ។

## ២) ដំហរប្រយុទ្ធវាយខ្មាំងដាច់ខាតរបស់យុទ្ធជនកងទ័ពបដិវត្តន៍យើង នៅសមរភូមិផ្លូវជាតិលេខ២

កាលនៅក្នុងសម័យសង្គ្រាមបដិវត្តន៍ ដ៏សន្ធោរសន្ធៅជាង ៥ឆ្នាំកន្លងទៅ ទោះបី ចក្រពត្តិ អាមេរិក បរិវារ និងពួកអាក្បត់ជាតិ មានអាវុធសម្បូរបែប និងទំនើបបំផុត មានកងរថក្រោះ កងកប៉ាល់ចម្បាំង កងកាំភ្លើងធំ កងថ្មើរជើងច្រើនសន្ធឹកសន្ធាប់រហូតដល់យន្តហោះយុទ្ធសាស្ត្របេ៥២ យន្តហោះប្រតិកម្មគ្រប់ធុន រាប់រយពាន់គ្រឿងយ៉ាងណាក៏ដោយ ក៏វីរកងទ័ពបដិវត្តន៍កម្ពុជាយើង ដែលសុទ្ធសឹងជាកូនចៅប្រជាជន កម្មករ កសិករក្រីក្រ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ហ៊ានប្រយុទ្ធវាយខ្មាំងដាច់ខាត គ្មានរួញរា គ្មានស្ទាក់ស្ទើរអ្វីទាំងអស់ ។ កងទ័ពបដិវត្តន៍កម្ពុជាយើង បានបញ្ចេញនូវស្នាដៃថ្មី អាវុធដ៏ឆើតឆាយអស្ចារ្យ និងពោរពេញទៅដោយពលិកម្មឈាមស្រស់ក៏ច្រើនឥតគណនា ដើម្បីបុព្វហេតុរំដោះជាតិ រំដោះប្រជាជន រំដោះវណ្ណៈក្រីក្រ ឲ្យរួចផុតពីភាពខ្ញុំគេ ដ៏ខ្មៅងងឹត និងពីមហាសមុទ្ទទុក្ខទោសវេទនាអាប់ឱនកិត្តិយសសព្វបែបយ៉ាង អស់រាប់ពាន់ឆ្នាំមកហើយនោះ បានទាំងស្រុង និងជាស្ថាពរ នៅថ្ងៃ ១៧ មេសា ១៩៧៥ ដ៏មហាអស្ចារ្យ ។

ចូលមកដល់សម័យការពារ និងកសាងប្រទេសបច្ចុប្បន្ននេះ កងទ័ពបដិវត្តន៍កម្ពុជាយើង ដែលធ្លាប់បានឆ្លងកាត់ចលនាតស៊ូបដិវត្តន៍ វាយកម្ទាត់ចក្រពត្តិអាមេរិក បរិវារ និងវាយកម្ទេចពួកអាក្បត់ជាតិគ្រប់ប្រភេទដ៏តឹងតែងស្មុគស្មាញ លំបាកវេទនា ជូរចត់ល្វីងជូរចត់បែន ប្រកបដោយជោគជ័យ បានពង្រឹង និងពង្រីកគោលជំហរប្រយុទ្ធ វាយខ្មាំងដាច់ខាតនេះ កាន់តែរឹងមាំ និងមោះមុតស្រួចស្រាវថែមទៀត ។ ពិសេស ក្នុងពេលវាយកម្ទាត់ខ្មាំងយួន វាតទីនិយម លេបទឹកដី ដែលវាប្រើទាំងកងរថក្រោះ ទាំងកងកាំភ្លើងធំរាប់រយគ្រឿង ទាំងកងថ្មើរជើងច្រើនកងពល និងមានយន្តហោះជួយអន្តរាគមន៍ខ្លះៗផង វាយលុកដោយទ្រង់ទ្រាយធំ និងជាខ្សែសង្វាក់ចូលឈ្លានពានកម្ពុជាប្រជាធិបតេយ្យ យ៉ាងព្រហើនកោងកាចនៅពេលថ្មីៗនេះ វីរកងទ័ពបដិវត្តន៍កម្ពុជាយើង បានប្រយុទ្ធវាយខ្មាំងដាច់ខាត យ៉ាងអង់អាចក្លាហានបំផុត ។ នៅគ្រប់សមរភូមិ កងទ័ពបដិវត្តន៍យើង បានអនុវត្តមាគ៌ាសង្គ្រាម ប្រជាជនរបស់បក្សយ៉ាងរស់រវើក និងស័ក្តិសិទ្ធិបំផុត វាយបំបាក់កងទ័ពយួនឈ្លានពានវាតទីលេបទឹកដី វាយឲ្យបរាជ័យរត់បាក់ទ័ពរត់គាត់រតាយទៅស្រុកវាវិញ យ៉ាងអាម៉ាស់បំផុត នៅថ្ងៃ៦ មករា ១៩៧៨ ។

ក្នុងចំណោមវីរភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់ របស់វីរប្រជាជន និងវីរកងទ័ពបដិវត្តន៍យើង នៅគ្រប់សមរភូមិដែលបានលើកជ្រោងទង់ឯករាជ្យជាតិ ទង់អធិបតេយ្យជាតិ ទង់កិត្តិយសជាតិ ទង់បូរណភាពដែនដីជាតិ និងទង់ឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនរបស់បក្សយើង យ៉ាងខ្ពស់ត្រដែតត្រដឹម វាយបំបាក់ទង់ឈ្លានពានរបស់យួន និងបក្សពួកវា ដែលអាងលើប្រទេសធំ ប្រជាជនច្រើន មានកងទ័ពច្រើន និងអាវុធសម្បូរបែប និងទំនើបៗបំផុតនោះ ឲ្យវាបរាជ័យយ៉ាងធ្ងន់ធ្ងរ និងយ៉ាងអាម៉ាស់ បំផុត នៅថ្ងៃ៦ មករា ១៩៧៨ កន្លងទៅថ្មីៗនេះ មានលេចចេញនូវគំរូវីរភាពបដិវត្តន៍ជាច្រើន ។ ក្នុងចំណោមវីរភាពទាំងអស់នេះ យើងខ្ញុំសូមលើកនូវវីរភាពមួយ ដែលបង្ហាញពីគោលជំហរប្រយុទ្ធ វាយខ្មាំងដាច់ខាតរបស់វីរយុទ្ធជនយើង នៅសមរភូមិផ្លូវជាតិលេខ២ ដែលមានគ្នាតែ១០នាក់ប៉ុណ្ណោះ ហ៊ានប្រយុទ្ធតទល់នឹងកងទ័ពយួនមួយកងពល ដែលមានអាវុធគ្រប់ធុនច្រើនសន្ធឹកសន្ធាប់ ទាំងកាំភ្លើងធំ ទាំងរថក្រោះ យ៉ាងអង់អាចក្លាហាន និងស៊ិតស្វាញបំផុត ។

ផ្លូវជាតិលេខ២ គឺជាផ្លូវដែលតភ្ជាប់ពីរដ្ឋធានីភ្នំពេញទៅដល់ព្រំដែនយួន ដោយឆ្លងកាត់ទីប្រជុំជនខេត្តតាកែវ ស្រុកកោះអណ្តែត និងស្រុកគិរីវង្ស ជាដើម ។ ចាប់តាំងពីចុងឆ្នាំ១៩៧៧មក កងទ័ពយួនឈ្លានពានវាតទីលេបទឹកដី បានប្រើរថក្រោះ កាំភ្លើងធំជាច្រើនរយគ្រឿង និងកងថ្មើរជើងជាច្រើនកងពល ដែលវាចាត់ទុកថា ជាកងទ័ពធុនឆើតៗរបស់វានោះ មកបុកឈ្លានពានចូលទឹកដី

កម្ពុជា នៅតាមផ្លូវជាតិលេខ២ ម្តុំភ្នំដិន ហើយបុកចូលជ្រៅមកដល់ទម្លាប់ ក្នុងស្រុកគីរីវង្ស និងមួយមុខព្រួញទៀតមកដល់រមេញ ក្នុងស្រុកកោះអណ្តែត ដែលមានចម្ងាយប្រមាណពី១០-២០គីឡូម៉ែត្រពីព្រំដែន កម្ពុជា-យួន ។ ស្ថិតនៅចំពោះមុខអំពើឈ្លានពានមិនឲ្យដឹងខ្លួនជាមុនរបស់កងទ័ពយួនវាតទីលេបទឹកដី មកលើមាតុភូមិកម្ពុជាជាទីស្នេហា ដោយទ្រង់ទ្រាយធំ ជាខ្សែសង្វាក់ និងយ៉ាងព្រហើនកោងកាចបំផុត នេះ វីរយុទ្ធជនយើងមួយក្រុម មានគ្នាតែ១០នាក់ ដែលមានភារៈនៅការពារព្រំដែនតាមផ្លូវជាតិលេខ២នេះ គ្មានគិតភ័យតក់ស្លុត ឬក៏ស្ញុកចិត្តលុតជង្គង់ចុះញ៉មសារភាពខ្មាំង ឬក៏បាក់បបខ្ចបខ្ចាចកងទ័ពយួនដ៏ច្រើនសន្ធឹកសន្ធាប់នោះឡើយ ។ វីរយុទ្ធជនយើង១០រូប នៅសមរភូមិផ្លូវជាតិលេខ២នេះ ដែលជាឧបករណ៍ផ្តាច់ការដ៏បរិសុទ្ធ និងស្មោះត្រង់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា និងជាកុលបុត្រដ៏ឆ្នើមនៃវីរប្រជាជនក្រីក្រ បានជ្រោងទង់វាយសម្រុកខ្មាំងយួនយ៉ាងខ្លាំងក្លាជាប់ ទាំងយប់ទាំងថ្ងៃ ដោយគ្មានគិតគូរអ៊ីទាំងអស់ ។ វីរយុទ្ធជនយើង១០រូបនេះ ដែលធ្លាប់បានលត់ដំសាកល្បងសាចុះសាឡើង នៅក្នុងភ្លើងសង្គ្រាមបដិវត្តន៍ជាង៥ឆ្នាំដ៏សន្ធោរសន្ធៅប្រឆាំងចក្រពត្តិអាមេរិក បរិវារ និងពួកអាក្បត់ជាតិឆ្កែបម្រើវា បានដេញវាយប្រហារ និងវាយកម្ទេចខ្មាំងយួនយ៉ាងខ្លាំងក្លាបំផុត ជាប់៣យប់៣ថ្ងៃ ឥតដកដៃសំចៃកម្លាំងឡើយ វាយទាល់តែវាបាក់ដល់បាក់ហើយ ទើបមានកម្លាំង១កងវរសេនាតូចវាយ ។ មួយកងវរសេនាតូចនេះ វាយខ្មាំងខ្លាំងណាស់ នៅផ្លូវលេខ២ វាយទាល់តែខ្មាំងកាន់កាប់ផ្លូវលេខ២នេះ មិនបាន ហើយយើងដណ្តើមកាន់កាប់កំណាត់ផ្លូវលេខ២ ពីទម្លាប់មកជិតថ្នល់បំបែកបានទាំងស្រុង ។

ដូច្នេះ កងទ័ពបដិវត្តន៍កម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ពិតជាកងទ័ពបដិវត្តន៍ អង់អាចក្លាហាន និងខ្លាំងពូកែ មហាអស្ចារ្យមែន! កងទ័ពនេះ ខ្មាំងធំប៉ុណ្ណា មានអាវុធសម្បូរបែបយ៉ាងណា ក៏ហ៊ានវាយដែរ ហើយវាយដាច់ខាត វាយដោយម្ចាស់ការ គំនិតផ្តើមច្នៃប្រឌិតរស់រវើក ក្នុងឋានៈជាកងទ័ពស្រួច កងទ័ពឈានមុខ និងជាអ្នកឈ្នះ អ្នកវាយសម្រុកជាន់ខ្មាំងជាប់ជានិច្ច ។ នេះហើយជាធាតុពិត និងគុណភាពប្រយុទ្ធ ដ៏ខ្ពង់ខ្ពស់បំផុតរបស់វីរកងទ័ពបដិវត្តន៍កម្ពុជាយើង ដែលមានធាតុវណ្ណៈអធនដ៏បរិសុទ្ធ មានគោលជំហរប្រយុទ្ធវាយខ្មាំងដាច់ខាតគ្រប់ពេលវេលា និងហ៊ានធ្វើពលិកម្មកម្រិតខ្ពស់បំផុត ជូនបក្ស វណ្ណៈ និងប្រជាជន ដោយឥតលក្ខខណ្ឌឡើយ ។

យើងខ្ញុំយុវជន យុវនារីបដិវត្តន៍ទូទាំងប្រទេស ប្តេជ្ញាគោរព រៀនសូត្រ នូវគោលជំហរវាយខ្មាំងដាច់ខាត គោលជំហរលះបង់ និងគោលជំហរវីរភាពដ៏ខ្ពង់ខ្ពស់របស់វីរកងទ័ពបដិវត្តន៍យើង នៅគ្រប់សមរភូមិការពារព្រំដែន ដើម្បីកសាងជួរយុវជន យុវនារីបដិវត្តន៍យើង ឲ្យទៅជាកម្លាំងស្នូល ក្នុងកិច្ចការពារឯករាជ្យជាតិ អធិបតេយ្យជាតិ កិត្តិយសជាតិ និងបូរណភាពដែនដីជាតិក្នុងពេលបច្ចុប្បន្ន ក៏ដូចតទៅអនាគតរៀងរហូតទៅ និងជាកម្លាំងស្នូលក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមគ្រប់ផ្នែក នៅកម្ពុជាប្រជាធិបតេយ្យយើង ឲ្យរីកចម្រើនថ្មីថ្មើងរុងរឿង លើគ្រប់វិស័យ ដោយសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ ។

**៣) កំហឹងឈឺចាប់របស់យុវនារីយើង នៅស្រុកកំពង់រោទិ៍ ចំពោះខ្មាំងយួនឈ្លានពាន វាតទី លេបទឹកដី**

កាលនៅក្នុងសម័យសង្គមចាស់ បងប្អូននារីក្រីក្រយើងនៅស្រុកកំពង់រោទិ៍ ក៏ដូចជាបងប្អូននារី យើងនៅទូទាំងប្រទេសដែរ តែងត្រូវទទួលរងនូវការជិះជាន់ពីសំណាក់ចក្រពត្តិ អាណានិគមនិយម ពួកអាក្បត់ជាតិ និងពួកវណ្ណៈជិះជាន់គ្រប់ប្រភេទយ៉ាងធ្ងន់ធ្ងរបំផុត ។ ខ្មាំងសត្រូវទាំងអស់នេះ វាបានចាត់ទុកនារីយើង ជាភេទទន់ខ្សោយ គ្មានកម្លាំង គ្មានសមត្ថភាពធ្វើការងារបានដូចបុរសទេ ។ ធ្ងន់ធ្ងរ ជាងនេះទៅទៀត ពួកវាបានចាត់ទុកនារីយើង គ្រាន់តែជាឧបករណ៍បម្រើការសប្បាយ ពុករលួយ ពាលាអាវ៉ាសែរបស់ពួកវាតែប៉ុណ្ណោះ ។

កាលនៅក្នុងសម័យសង្គ្រាមជាង៥ឆ្នាំកន្លងទៅ បងប្អូននារីយើងនៅស្រុកកំពង់រោទិ៍ ក៏ដូចបងប្អូននារីកម្ពុជាយើង ដែលនៅជាប់នឹងព្រំដែនកម្ពុជា យួនដែរ ត្រូវទទួលរងគ្រោះថ្នាក់ដល់អាយុជីវិត សឹងជាប្រចាំ ដោយត្រូវពួកអាធីរតីព្រៃនគរបរិវារចក្រពត្តិអាមេរិក វាចាប់បង្ខិតរំលោភលើរូបរាងកាយ យ៉ាងព្រៃផ្សៃហួសស៊ីសបំផុត នៅពេលដែលពួកវាបើកប្រតិបត្តិការសឹក ចូលឈ្លានពានរាតត្បាតលើទឹកដីយើង តែរាល់លើក ។ ចំពោះអំពើជិះជាន់មើលងាយមើលថោកមនុស្សដូចសត្វធាតុយ៉ាងនេះ របស់ខ្មាំងសត្រូវបងប្អូន

នារីយើង តែងចងគំនុំ ហើយមានកំហឹងជាតិ និងកំហឹងវណ្ណៈឆេះឡើងពុះពោរសន្ធោរសន្ធៅចំពោះពួកវាឥតដែលមានភ្លេចឡើយ ។ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាយើង បងប្អូនបានប្រែក្លាយកំហឹងឈឺចាប់នេះ ឲ្យទៅជាកម្លាំងខ្លាំងក្លាមហិមា ធ្វើបដិវត្តន៍វាយកម្ចាត់ និងកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ រួមរំដោះប្រទេសជាតិ រំដោះប្រជាជនក្រីក្រ និងរំដោះនារីភេទ លុះត្រា បានសម្រេចមហាជ័យជម្នះទាំងស្រុង និងជាស្ថាពរនៅថ្ងៃ១៧ មេសា ១៩៧៥ ។

តាមរយៈមហាជ័យជម្នះជាប្រវត្តិសាស្ត្រនេះ ប្រទេសជាតិ ប្រជាជនកម្ពុជា ពិសេស បងប្អូននារីយើង បានរំដោះខ្លួនទាំងខាងស្មារតី ទាំងខាងនយោបាយ ទាំងខាងសម្ភារ មានសិទ្ធិសេរីភាព ស្មើមុខមាត់នឹងបុរសហើយ ។ បងប្អូននារីយើងបានកាន់កាប់រដ្ឋអំណាចបដិវត្តន៍យ៉ាងណែននៅក្នុងដៃទាំងខាងនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ទាំងស្រុងហើយ ។ ក្នុងរយៈជាងពីរឆ្នាំកន្លងទៅនេះ បងប្អូននារីយើងនៅស្រុកកំពង់រោទិ៍ បានចូលរួមក្នុងមហាចលនាវាយសម្រុក ការពារប្រទេសជាតិ បន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម តាមមុខព្រួញការងាររៀងៗខ្លួន គ្មានដែល គិតគូរពីការនឿយហត់ លំបាកស្រួល ឬពលិកម្មអ្វីទាំងអស់ ។ ដូច្នេះ បានជានៅគ្រប់ទីកន្លែង ក្នុងស្រុកកំពង់រោទិ៍ទាំងមូល ទីណាៗក៏មានប្រព័ន្ធសំណង់ចាត់ចែងទឹក មានដីស្រែសម្រាប់ធ្វើមួយឆ្នាំម្តង និងពីរដងវិលចុះវិលឡើងគ្រប់រដូវ ។ ក្នុងឆ្នាំ៧៧កន្លងទៅនេះ ស្រូវស្រែក្នុងស្រុកកំពង់រោទិ៍ បានកើនច្រើនលើសលប់គ្របដណ្តប់នៅលើវាលរាបដ៏ធំធេងល្វឹងល្វើយ មានទាំងស្រូវកំពុងទុំពណ៌លឿងឆ្អិនឆ្អៅ មានទាំងស្រូវកំពុងដុះលូតលាស់ល្អត្រគុំត្រគោល ។ ក្នុងរដូវចម្រូតនេះ កសិករសហករណ៍ យុវជន យុវនារីកងចល័តយើង បានសាមគ្គីគ្នាវាយសម្រុកប្រូតកាត់ប្រមូលទុកដាក់ផល និងធ្វើស្រូវប្រាំងយ៉ាងមមាញឹកគ្រប់កន្លែង ។ ក្នុងពេលដែលបងប្អូនកំពុងដុតដៃដុតជើងវាយសម្រុកធ្វើការងារយ៉ាងមមាញឹកនេះ ខ្មាំងយួនវាគទីនិយមលេបទឹកដី បានលើកទ័ពជាច្រើនកងពល វាយលុកឈ្លានពាន ឆក់ប្លន់កាប់សម្លាប់ បាញ់រះ បាញ់ផ្លោង មកលើទឹកដីស្រុកភូមិបងប្អូនយ៉ាងព្រៃផ្សៃបំផុត ។ ដោយកងទ័ពខ្មាំងយួនឈ្លានពាន មានចំនួនច្រើនលើសលប់ ប្រើប្រាស់មធ្យោបាយសង្គ្រាមសម្បូរបែប វាយលុកចូលឈ្លានពានមិនឲ្យដឹងខ្លួនមុនយ៉ាងនេះ កសិករសហករណ៍ យុវជន យុវនារីកងចល័តយើងមួយចំនួនត្រូវពួកវាឡោមព័ទ្ធបាញ់សម្លាប់យ៉ាងឃោរឃៅបំផុត ។ ដោយឡែកតែយុវនារីកងចល័តយើងត្រូវពួកវាប្រើអាវុធគំរាមកំហែង ចាប់បង្ខំរំលោភលើរូបរាងកាយបងប្អូនយ៉ាងថោកទាបជាងសត្វតិរច្ឆានទៅទៀត ។ នៅពេលខ្មាំងប្រព្រឹត្តអំពើអមនុស្សធម៌ កំសាកថោកទាប មកលើរូបរាងកាយបងប្អូន បានប្រយុទ្ធនឹងវាយ៉ាងអង់អាចក្លាហាន ហើយមានយុវនារីយើងខ្លះ ត្រូវខ្មាំងយួនឈ្លានពាន លេបទឹក ដី ចាប់រំលោភ ហើយបាញ់ចោលបំបាត់ដានទៀត ។ ឯបងប្អូននារីខ្លះទៀត ដែលនៅសល់ត្រូវខ្មាំងយួនវាចាប់ធ្វើបាបរំលោភលើរូបរាងកាយរហូតទាល់តែសន្លប់បាត់ស្មារតីដេកស្តូកស្តឹង ។

ក្នុងសភាពការណ៍យ៉ាងនេះ កងទ័ពបដិវត្តន៍យើងបានវាយសម្រុកកម្ចាត់ និងកម្ទេចខ្មាំងវាគទី និយមលេបទឹកដី ធ្វើឲ្យវាស្លាប់និងរបួសអស់ជាច្រើននៅលើសមរភូមិប្រយុទ្ធ ហើយបានវាយដណ្តើមយកយុវនារីកងចល័តយើងមកវិញជាបន្តបន្ទាប់ ។ តែនៅពេលដែលរំដោះបានមកហើយ បងប្អូនយើង ខ្លះត្រូវសន្លប់បាត់ស្មារតី បងប្អូនខ្លះទៀតត្រូវទុរន់ទុរាយ៉ាងខ្លាំង ។ ក្នុងសភាពយ៉ាងនេះ កងទ័ពបដិវត្តន៍យើង បានសែង និងដឹកយុទ្ធមិត្តដែលត្រូវទទួលរងគ្រោះដោយអំពើឃោរឃៅព្រៃផ្សៃហ្វាស៊ីសរបស់ខ្មាំងយួនឈ្លានពាន យកទៅព្យាបាលឯមន្ទីរពេទ្យ នៅសមរភូមិក្រោយយ៉ាងរួសរាន់គ្មានបង្អែបង្អង់ឡើយ ។ ដោយការយកចិត្តទុកដាក់ថែទាំព្យាបាលយ៉ាងដិតដល់ពីពេទ្យបដិវត្តន៍យើង បងប្អូននារីមួយចំនួនច្រើន ក៏បានធូរស្រាលជាសះស្បើយជាបន្តបន្ទាប់ តែបងប្អូនខ្លះទៀត ដែលត្រូវពួកវារំលោភធ្វើបាបខ្លាំងពេកទៅ ក៏ត្រូវពលីយ៉ាងខ្លោចផ្សាបំផុត ។

យើងខ្ញុំបានធ្វើដំណើរទៅតំបន់ស្វាយរៀង ហើយបានទៅជួបសាកសួរសុខទុក្ខ យុវនារីកង ចល័តយើងដែរ ។ ពេលយើងខ្ញុំបានសួរសុខទុក្ខ និងសួរនាំពីសភាពការណ៍ជាក់ស្តែងនៅទីនោះ បងប្អូនយុវនារីកងចល័តយើងទាំងអស់ ស្រក់ទឹកភ្នែកប្រោកៗ និយាយទាំងអួលណែនដើមក មកកាន់យើងខ្ញុំ ពោរពេញទៅដោយភ្លើងកំហឹងឈឺចាប់យ៉ាងពុះពោរសន្ធោរសន្ធៅ ចំពោះខ្មាំងយួនឈ្លានពានវាគទីលេបទឹកដីថា “យើងទាំងអស់គ្នា ឈឺចាប់ណាស់ ចំពោះអំពើឈ្លានពាន វាគទី លេបទឹកដីរបស់ខ្មាំងយួន ដែលបានបង្កឲ្យមានវិនាសកម្មយ៉ាងច្រើន មកលើប្រទេសជាតិ និងប្រជាជនយើង និងចាប់រំលោភ

លើ នារីយើងខ្ញុំ យ៉ាងព្រៃផ្សៃយ៉ាងនេះ ។ កាលពីសម័យសង្គមចាស់ ពួកចក្រពត្តិ អាណានិគមនិយម ពួកអាក្សត់ជាតិ និងវណ្ណៈជិះជាន់គ្រប់ប្រភេទ វាបានរំលោភធ្វើបាបនារីកម្ពុជាយើងយ៉ាងព្រៃផ្សៃជារៀងរហូតមក ។ ដល់សម័យសង្រ្គាមបដិវត្តន៍ជាង៥ឆ្នាំកន្លងទៅនេះ ក៏ពួកអាធិរាជព្រៃនគរ វាចាប់នារីយើង រំលោភធ្វើបាបយ៉ាងព្រៃផ្សៃទៀត ។ តែចាប់តាំងពីក្រោយរំដោះមក យើងខ្ញុំទាំងអស់គ្នាស្មានថា អស់ហើយ អំពើដ៏អាស្រូវលាមកថោកទាបបែបនេះ ព្រោះចក្រពត្តិអាមេរិក អាយ៉ងធីវគីព្រៃនគរ ពួកអាក្សត់លន់នល់ និងបក្សពួកវា ព្រមទាំងរបបវា ត្រូវរលំរលាយអស់ហើយ យើងខ្ញុំរីករាយណាស់ ។ យើងខ្ញុំមានមោទកភាពយ៉ាងខ្ពស់ខ្ពស់បំផុត ចំពោះអនាគតរបស់យើងខ្ញុំជានារីភេទ ក៏ដូចជា ចំពោះនារីកម្ពុជាយើងទូទៅដែរ ។ យើងខ្ញុំតែងតែយល់ថា ចាប់ពីពេលនេះទៅ នារីភេទយើងលែងជួបប្រទះនឹងអំពើជិះជាន់ឆក់ប្លន់ ចាប់រំលោភធ្វើបាបដូចសត្វធាតុពីសំណាក់ចក្រពត្តិ និងពួកអាក្សត់គ្រប់ប្រភេទហើយ ។ បដិវត្តន៍រំដោះនារីទាំងស្រុង និងជាស្ថាពរហើយ ។ តែឥឡូវនេះ ពួកខ្មាំងយួនឈ្លានពាន វាតទី លេបទឹកដី ដែលពាក់ស្លាកបដិវត្តន៍ ពាក់ស្លាកសង្គមនិយម បានប្រព្រឹត្តនូវអំពើថោកទាប ចាប់រំលោភលើរូបរាងកាយនារីភេទយើងយ៉ាងឃោរឃៅហួសហេតុ ដូច និងលើសពីពួកទាហានអាធីវគីព្រៃនគរ ដែលជាបរិវារដាច់ថ្លៃរបស់ចក្រពត្តិអាមេរិកទៅទៀត ។ «នេះហើយជាសីលធម៌បដិវត្តន៍ដ៏អាស្រូវរបស់កងទ័ពយួន និងបក្សយួន ។ យើងខ្ញុំស្តាយណាស់ ដោយមិនបានស្គាល់ធាតុពិតរបស់វាតាំងពីពេលមុនមក មិនបាននឹកស្មានថា វាមានធាតុពិតអាក្រក់ដល់ថ្នាក់នេះ ។ ឥឡូវនេះ យើងស្គាល់ច្បាស់ហើយ ។ យើងខ្ញុំ ក៏ដូចជានារីយើងនៅតាមព្រំដែនទាំងអស់គ្នាដែរ បានជួបប្រទះនឹងស្គាល់ជាក់ស្តែងហើយ ។ មិនមែនគ្រាន់តែឮដូចពេលមុនទេ ។ ការឈឺចាប់របស់យើងខ្ញុំចំពោះអំពើដ៏មហាថោកទាបរបស់ខ្មាំងយួននេះ គ្មានអ្វីមកប្រៀបផ្ទឹមបានទេ ។ យើងខ្ញុំប្តេជ្ញាប្រែក្លាយកំហឹងឈឺចាប់នេះ ឲ្យទៅជា កម្លាំងខ្លាំងក្លាលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ឲ្យកាន់តែខ្ពស់ឡើងថែមទៀត ការពារទឹកដី ប្រទេសជាតិ ការពារកិត្តិយសជាតិ ការពាររបបសមូហភាព ការពាររដ្ឋអំណាចបដិវត្តន៍ ការពារបក្ស វណ្ណៈ និងប្រជាជន ឲ្យបានស្ថិតស្ថេរគង់វង្សដាច់ខាត ។ យើងខ្ញុំប្តេជ្ញា ប្រែក្លាយភ្លើងកំហឹងនេះ ឲ្យទៅជាកម្លាំងប្រយុទ្ធបង្ក បង្កើនផលឲ្យបានច្រើនបំផុត ដើម្បីមានស្បៀងផ្គត់ផ្គង់ជូនកងទ័ពបដិវត្តន៍យើងនៅសមរភូមិមុខ ដែលកំពុងជាប់ដៃវាយកម្ទេចខ្មាំងយួនឲ្យអស់ពីលើទឹកដី យ៉ាងអង់អាចក្លាហានឲ្យបានគ្រប់គ្រាន់បរិបូរណ៍ជានិច្ច លើកស្ទួយជីវភាពប្រជាជន ឲ្យកាន់តែសម្បូរធូរធារឆាប់រហ័ស និងរួមកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យយើងឲ្យរីកចម្រើនលើគ្រប់វិស័យ ដោយសន្ទុះលោតផ្លោះ តាមមាគ៌ាឯករាជ្យ ម្ចាស់ការរបស់បក្សកុម្មុយនីស្តកម្ពុជាយើងដាច់ខាត» ។

តាមព្រឹត្តិការណ៍ដែលពោរពេញទៅដោយមហាវិនាសកម្មព្រាត់ប្រាស់និរាស ឈឺចាប់ខ្លោចផ្សា ដោយសារអំពើរំលោភឈ្លានពានវាតទីលេបទឹកដីរបស់ខ្មាំងយួននេះ យើងខ្ញុំទាំងអស់គ្នា ដែលជាយុវជន យុវនារីបដិវត្តន៍កម្ពុជា មានកំហឹងឈឺចាប់ចំពោះខ្មាំងយួនយ៉ាងពុះពោរសន្ធោរសន្ធៅដូចគ្នានឹងបងប្អូនរួមឈាម រួមវណ្ណៈយើង នៅស្រុកកំពង់រោទិ៍ និងបងប្អូនយើងទាំងអស់ដែលនៅជាប់នឹងព្រំដែនកម្ពុជា-យួនដែរ ។ ខ្មាំងយួន វាមើលងាយ មើលថោកប្រជាជនយុវជនយុវនារីយើងខ្លាំងណាស់ ។ យួនមិនព្រមបោះបង់យុទ្ធសាស្ត្រ "សហព័ន្ធឥណ្ឌូចិន" និងបំណងលោភលន់លេបទឹកដីកម្ពុជា និងយកប្រជាជនកម្ពុជាទៅធ្វើជាខ្ញុំកញ្ជះវានោះឡើយ ។ យើងជាយុជន យុវនារីបដិវត្តន៍ ប្តេជ្ញាឯកភាពគ្នាទាំងខាងទស្សនៈគោលជំហរ ទាំងការអនុវត្តជាក់ស្តែង ដោយលើកកម្ពស់ស្មារតីឲ្យកាន់តែខ្ពស់ឡើងថែមទៀត បន្តវាយកម្ទេចនូវឧបាយកល និងសកម្មភាពដ៏ពិសពុលខ្មៅងងឹតផ្សេងៗរបស់ខ្មាំង យួនឈ្លានពានវាតទីលេបទឹកដី ឲ្យបរាជ័យគ្រប់កាលៈទេសៈដាច់ខាត ។ ព្រមជាមួយគ្នានេះ យើងទាំងអស់គ្នា ប្តេជ្ញាកសាងគោលជំហរនយោបាយសតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍គ្រប់ផ្នែក ឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាក្រហមឆ្អិនឆ្អៅឡើងគ្រប់ពេលវេលា ដើម្បីវាយសម្រុកការពារប្រទេសជាតិបន្តធ្វើបដិវត្តន៍ សង្គមនិយម និងកសាងសង្គមនិយម នៅកម្ពុជាប្រជាធិបតេយ្យយើង ឲ្យរីកចម្រើនលោតផ្លោះលើគ្រប់វិស័យយ៉ាងឆាប់រហ័ស តាមមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្ទួនខ្ទបត្ថម្ភខ្លួនរបស់បក្ស ដោយអនុវត្តពាក្យស្លោក "វាយសម្រុកខ្លាំងក្លាបំផុត និងជាប់ជានិច្ចដោយ មហាចលនា មហាជន មហាលោតផ្លោះ មហាអស្ចារ្យ" ឲ្យបានស័ក្តិសិទ្ធបំផុត ។

**ឆាំង សារៈមុនិន្ទ**

# ឯកសារនៅតែធ្វើឱ្យម្តាយខ្ញុំចងចាំ

រៀងរាល់ឆ្នាំ នៅមុនថ្ងៃរាជរដ្ឋាភិបាល ប្រារព្ធទិវាជ័យជម្នះ ថ្ងៃ៧ មករា លើរបបខ្មែរក្រហម មានកាសែត វិទ្យុ និងទូរទស្សន៍ជាច្រើន បានសរសេរ ធ្វើអត្ថាធិប្បាយ និងចាក់ផ្សាយកុន និងឯកសារចាស់ៗឡើងវិញ ទាក់ទងនឹងរបបដែលដឹកនាំដោយពុជាទូទៅថាបានកាប់សម្លាប់ប្រជាពលរដ្ឋអស់រាប់លាននាក់ ។ ប៉ុន្តែ ក៏មានប្រជាជននិងអ្នកនយោបាយមួយចំនួន បានធ្វើការរិះគន់ថា ជារឿងនយោបាយ និងជាការដែលវៀតណាមមានបំណងចូលមកឈ្លានពានប្រទេសកម្ពុជា ។

ទោះបីជាមានការយល់ខុសគ្នាយ៉ាងណាក៏ដោយ ក៏ម្តាយខ្ញុំដែលបច្ចុប្បន្នមានអាយុ៦២ឆ្នាំ រស់នៅជនបទនៃខេត្តស្វាយរៀង និងមិនជាប់ពាក់ព័ន្ធនយោបាយ នៅតែចងចាំពីហេតុការណ៍រន្ធត់ដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម ។ រៀងរាល់ថ្ងៃ ម្តាយខ្ញុំតែងតែចំណាយពេលមើលទូរទស្សន៍ ពណ៌ស-ខ្មៅ ក្រោយពីគាត់សម្រាកពីការងារស្រែចម្ការ និងធ្វើការងារផ្ទះរួចរាល់ ។ ម្តាយខ្ញុំបានមើលកុនឯកសាររយៈពេលជាង១០នាទីអំពីរបបខ្មែរក្រហម ដែលចាក់ផ្សាយដោយទូរទស្សន៍ក្នុងស្រុកមួយ ។ នៅពេលចប់កម្មវិធី ម្តាយខ្ញុំបានរៀបរាប់រឿងរ៉ាវរបស់គាត់ ប្រាប់ទៅក្មួយប្រុសខ្ញុំដែលរៀននៅថ្នាក់ទី១១ ដែលបានសួរគាត់ថា «ហេតុអ្វីបានជាទូរទស្សន៍ចាក់បញ្ចាំងឯកសារខ្មែរក្រហម?» និង «ហេតុអ្វីបានជាមានមនុស្សស្លាប់?» ដែលក្នុងនោះក៏មានរឿងរ៉ាវមួយចំនួនដែលខ្ញុំពុំធ្លាប់បានដឹងពីមុនមកទាល់តែសោះ ។ ម្តាយខ្ញុំមានស្រុកកំណើតនៅឃុំបាទី ស្រុកចន្ទ្រា ជាស្រុកមួយក្នុងចំណោមស្រុកទាំង៧ នៃខេត្តស្វាយរៀង ដែលទទួលរងគ្រោះធ្ងន់ធ្ងរដោយសារការទម្លាក់គ្រាប់បែកតាំងពីសម័យលន់ នល់ មកម្ល៉េះ ។ ម្តាយខ្ញុំជាកូនពៅ ក្នុងចំណោមបងប្អូនបង្កើតចំនួន១០នាក់ ចំណែកឪពុកខ្ញុំជាទាហាននៅក្នុងរបប លន់ នល់ ។



ម្តាយខ្ញុំ រស់នៅខេត្តស្វាយរៀង

គ្រួសាររបស់ខ្ញុំបានរស់ដោយសារការលាក់អត្តសញ្ញាណ នៅពេលកងទ័ពខ្មែរក្រហមចូលមកគ្រប់គ្រងដំបូង ។ ក្រោយមក ឈ្លបខ្មែរក្រហមបានដើរស្រាវជ្រាវប្រវត្តិរូបអ្នកដែលធ្លាប់ធ្វើការងារក្នុងរបបចាស់ និងបានហៅឪពុកខ្ញុំទៅសួរចម្លើយ ប៉ុន្តែឪពុកខ្ញុំបានកុហកថា «គាត់ជាអ្នកដើរទិញជ្រូក នៅក្នុងភូមិ» ។ ដោយឡែកអ្នកដែលឈ្លបខ្មែរក្រហមបានដឹងពីប្រវត្តិរូបច្បាស់លាស់ហើយ ខ្មែរក្រហមបានចាប់ខ្លួន ដោយមិនចាំបាច់សាកសួរឡើយ ។ នៅពេលនោះដែរ ខ្មែរក្រហមបានបញ្ជាឲ្យបងប្រុសរបស់ម្តាយខ្ញុំម្នាក់ជាជាងឈើឈ្មោះ សាត ទៅរុះព្រះវិហារវត្តប្រសព្វលក្ខណ៍ ស្ថិតនៅក្នុងឃុំមេសថ្ងក តែដោយសារតែគាត់ជាអ្នកគោរពប្រណិប័តន៍ព្រះពុទ្ធសាសនា ទើបគាត់ឆ្លើយតបទៅវិញថា «គាត់ពុំចេះរុះរើទេ គាត់ចេះតែសាងសង់»ប៉ុណ្ណោះ ។ ខ្មែរក្រហមបានចាប់ចងបងប្រុស

ម្តាយខ្ញុំ រួចយកទៅសម្លាប់ចោលភ្លាមនៅពេលព្រឹកនេះ ។ បន្ទាប់មក ទើបខ្មែរក្រហមជម្លៀសប្រពន្ធកូន របស់គាត់ចេញពីភូមិទៀត ហើយក្រុមគ្រួសារនេះបានបាត់ដំណឹងចាប់តាំងពីពេលនោះមក ។ ដោយភ័យខ្លាចនឹងហេតុការណ៍រន្ធត់នេះ នៅដើមឆ្នាំ១៩៧៦ ឪពុកម្តាយរបស់ខ្ញុំ បានសម្រេចចិត្តរត់ចេញពីភូមិ សំដៅទៅប្រទេសវៀតណាម ។ គាត់ទាំងពីរនាក់បានសុំកងទ័ពវៀតណាម ដែលយាមការពារនៅតាមបណ្តោយព្រំដែនថា ទៅតាមរកបងប្អូនដែលរស់នៅប្រទេសវៀតណាម ។ ប៉ុន្តែក៏មានគ្រួសារខ្មែរមួយចំនួនត្រូវបានកងទ័ពវៀតណាមបញ្ជូនត្រឡប់មកវិញ តាមការស្នើសុំរបស់ខ្មែរក្រហម និងតាមការដោះដូរជាមួយ គោ ក្របី ហើយអ្នកភៀសខ្លួនទាំងនោះ ត្រូវយោធាខ្មែរក្រហមសម្លាប់ចោលនៅមុខកងទ័ពវៀតណាមតែម្តង ។

ឪពុកម្តាយខ្ញុំបានរស់នៅភូមិមួយ ក្នុងខេត្តឡុងអាន ប្រទេសវៀតណាម ជាប់នឹងស្រុកចន្ទ្រា ខេត្តស្វាយរៀង ដោយគាត់ទាំងពីរនាក់ស៊ីឈ្នួលរែកដី និងប្រូតស្រូវឲ្យជនជាតិវៀតណាម ។ នៅវេលាយប់មួយ ក្នុងអំឡុងឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមបានវាយចូលដល់បឹងកញ្ជូត កន្លែងដែលម្តាយខ្ញុំរស់នៅ និងបានសម្លាប់គ្រួសារវៀតណាម ដែលមានសមាជិក៥នាក់ និងបានដុតបំផ្លាញផ្ទះ និងសម្ភារមួយចំនួន ។ ម្តាយខ្ញុំបានគេចខ្លួនទាំងភ័យតក់ស្លុត ដោយពេលនោះគាត់បានផ្ញើបងស្រីក្មេះរបស់ខ្ញុំ ដែលទើបតែមានអាយុមួយខួបទៅឲ្យអ្នកជិតខាងជួយពារ ចំណែកគាត់បានដឹកដៃបងស្រីច្បងរបស់ខ្ញុំ ស្តាយខោអាវ និងទូលរបស់របរ ។

ឪពុកម្តាយខ្ញុំ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅចុងឆ្នាំ១៩៧៨ ជាមួយនឹងបងប្អូន ។ ប៉ុន្តែ នៅតាមផ្លូវ មីងរបស់ម្តាយខ្ញុំម្នាក់បានជាន់មីនផ្ទុះស្លាប់នៅពេលគាត់ដើរចូលទៅក្នុងភូមិចាស់មួយ ដើម្បីកាប់ស្លឹកចេកវេចនំ ដែលហេតុការណ៍នេះ ម្តាយខ្ញុំបានសម្លឹងមើលពីចម្ងាយឃើញនៅសល់តែក្រមាដែលគាត់ធ្លាប់បង់កហោះប៉ើងទៅលើមេឃប៉ុណ្ណោះ ។

រហូតមកដល់សព្វថ្ងៃនេះ ម្តាយរបស់ខ្ញុំនៅតែរំឭកពីហេតុការណ៍ដែលគាត់ធ្លាប់បានឆ្លងកាត់ ប្រាប់ដល់កូនចៅ ហើយខ្ញុំគិតថារឿងរបស់គាត់មានសារសំខាន់ណាស់សម្រាប់ក្រុមគ្រួសារ ក៏ដូចជាជាតិទាំងមូល និងជាពិសេស ក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីរបបខ្មែរក្រហម ប្រសិនបើយើងមិនភ្ជាប់រឿងរ៉ាវទាំងនេះទៅនឹងផលប្រយោជន៍នយោបាយ ។ **សោម ប៊ុនថន**

# ដំណឹងស្វែងរកឪពុក

*ខ្ញុំបាទឈ្មោះ ព្រា ភារុន កើតឆ្នាំ១៩៦០ មានស្រុកកំណើតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ សព្វថ្ងៃរស់នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។*

*ខ្ញុំបាទមានបងប្អូន៥នាក់ (ស្រី២នាក់ ប្រុស៣នាក់) និងមានម្តាយឈ្មោះ នួន គីមហៀង សូមប្រកាសរកឪពុក ឈ្មោះ ព្រា ហង្សរី កើតឆ្នាំជូត ។ មុនរបបខ្មែរក្រហម ឪពុកខ្ញុំធ្វើជាពិធីការសាលាក្រុងសៀមរាប ផ្នែករៀបចំបុណ្យជាតិ ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ខេត្តសៀមរាប ក៏ដូចជាភូមិស្រុកដែលគ្រួសារខ្ញុំរស់នៅគឺភូមិទ្រាំង ។ ខ្មែរក្រហមបានស៊ើបដឹងថា ឪពុកខ្ញុំជាអតីតអ្នករដ្ឋការ ធ្វើការនៅសាលាខេត្ត ។ នៅយប់មួយចន្លោះពីថ្ងៃ១៧ ដល់ ១៩ មេសា ឆ្នាំ១៩៧៥ ខ្ញុំចាំមិនច្បាស់ ខ្មែរក្រហមបានមកហៅឪពុកខ្ញុំពីផ្ទះទាំងយប់ ដោយមិនប្រាប់ថាទៅណាទេ ។*

*អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ពីឪពុកខ្ញុំឈ្មោះ ព្រា ហង្សរី នេះ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទខ្ញុំបាទផ្ទាល់លេខៈ ០១៦ ៥១៨ ៧៨៧*

***សូមអរគុណ!***

# ស្ត្រីចូលរួមកសាងសន្តិភាព និងផ្សះផ្សាជាតិ

លោកស្រី ប្រាក់ ចន្ទ័សុខា ជាអភិបាលរងខេត្តព្រះសីហនុ ទទួលបន្ទុកមន្ទីរវប្បធម៌ និងកិច្ចការជាច្រើនទៀត ។ លោកស្រីបាន ចូលរួមជាអធិបតីនៅក្នុងពិធីសម្ពោធការដាក់តាំងពិព័រណ៍អំពីការជម្លៀសដោយបង្ខំនៅមន្ទីរវប្បធម៌ខេត្តព្រះសីហនុ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ក្នុងឱកាសនោះដែរ លោកស្រីក៏បាន ចែករំលែកនូវបទពិសោធឈឺចាប់ ការបែកបាក់គ្រួសារ ប្រាប់ដល់សិស្ស និស្សិត និងប្រជាជនទាំងអស់ដែលមកចូលរួម ។ រឿងរ៉ាវរបស់លោកស្រី បានធ្វើឲ្យអ្នកចូលរួមខ្លះ រួមទាំងប្រជាជនខ្មែរ ឥស្លាមបាននឹកឃើញឡើងវិញពីរបបខ្មែរក្រហម និងបានភ្ជាប់នឹងសាច់រឿងផ្ទាល់ខ្លួន រហូតដល់ស្រក់ទឹកភ្នែក ។ បន្ទាប់ពីចប់កម្មវិធី លោកស្រី ច័ន្ទសុខា ក៏បានផ្តល់បទសម្ភាសអំពីរឿងរ៉ាវរបស់អ្នកស្រី និងការចូលរួមរបស់ស្រីក្នុងដំណើរការរកសន្តិភាព និងការផ្សះផ្សាជាតិបន្ទាប់ពីរបបខ្មែរក្រហមដួលរលំផងដែរ ។

តាមរយៈ ការសិក្សាស្រាវជ្រាវជាច្រើន ដែលធ្វើឡើងនៅក្នុងប្រទេសក្រោយជម្លោះ និងប្រទេសធ្លាប់ឆ្លងកាត់អំពើប្រល័យពូជសាសន៍បានឲ្យដឹងថា ស្ត្រីមិនត្រឹមតែបានចូលរួមជួយកសាងសេដ្ឋកិច្ចនៅក្នុងគ្រួសារ ចិញ្ចឹមបីបាច់ និងផ្តល់ការសិក្សាដល់ក្មេងប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយសហគមន៍ឲ្យមានភាពរឹងមាំផងដែរ ។ ជាក់ស្តែង នៅក្នុងករណីប្រទេសអាហ្វ្រិកខាងត្បូងមានស្ត្រីចំនួន៥៥ភាគរយ និងនៅលីបេរីយ៉ា មាន៥១ភាគរយ បានឡើងផ្តល់សេចក្តីថ្លែងពីទុក្ខសោក និងការពិតពីជីវិតរបស់ខ្លួន ប្រាប់ដល់គណៈកម្មការស្វែងរកការពិត



លោកស្រី ប្រាក់ ចន្ទ័សុខា នៅក្នុងពិធីសម្ពោធការដាក់តាំងពិព័រណ៍អំពីការជម្លៀសដោយបង្ខំនៅមន្ទីរវប្បធម៌ខេត្តព្រះសីហនុ

នៅក្នុងប្រទេសរបស់ខ្លួន ។ ស្ត្រី កុមារ និងសហគមន៍ទាំងមូល បានប៉ះពាល់យ៉ាងខ្លាំងដោយសារសង្គ្រាម តែផលប៉ះពាល់នេះ ក៏បានផ្តល់ឱកាសដល់ស្ត្រីបានបញ្ចេញពីសមត្ថភាព និងស្វែងរកការគាំទ្រឲ្យមានភាពស្មើគ្នារវាងបុរស និងស្ត្រីនៅក្នុងប្រទេសរបស់ខ្លួនដែរ ។

ទោះបីជាស្ត្រីទាំងនោះទទួលរងនូវការលំបាក ទុក្ខសោក ការបែកបាក់ ការបាត់បង់ឪពុកម្តាយ បងប្អូន និងកូនចៅជាទីស្រឡាញ់ យ៉ាងណាក៏ដោយ ក៏ស្ត្រីមិនអស់សង្ឃឹមដែរ ស្ត្រីបានប្រែក្លាយទុក្ខសោកដែលគាត់មាន ទៅជាការតស៊ូ និងខិតខំពុះពារគ្រប់ឧបសគ្គដើម្បីឲ្យក្រុមគ្រួសារទទួលបានសុភមង្គល និងជោគជ័យ ។ ជាទូទៅ មានមនុស្សមួយចំនួន មើលមកស្ត្រីថា ទន់ភ្លន់ និងអន់ខ្សោយ និងមិនអាចធ្វើកិច្ចការអ្វីធំដុំបាន ។ ប៉ុន្តែ បើយើងមើលឲ្យទូលាយ ស្ត្រីជាជំហរ និងជាទីពឹងរបស់គ្រួសារ ។ នៅក្នុងគ្រាលំបាក សង្គ្រាម និងអត់ឃ្លាត ស្ត្រីភាគច្រើនជាអ្នកលះបង់អាហារដែលខ្លួនមាន និងជាអ្នកសន្សំសម្រាប់ទុកក្រុមគ្រួសារទាំងមូល ដូចជា អ្នកស្រី ច័ន្ទសុខា ជាដើម ។

លោកស្រី ច័ន្ទសុខា មានបងប្អូនប្រាំបួននាក់ ដែលមានឪពុកធ្វើជាប៉ូលីស និងម្តាយជាមេផ្ទះ ។ គ្រួសាររបស់លោកស្រី ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិថ្នល់ និងក្របីព្រៃមួយរយៈ បន្ទាប់មកទើប ខ្មែរក្រហមជម្លៀសឲ្យទៅនៅថ្មបាំង ។ លោកស្រីបានបែកបាក់ពីប្តីដែលធ្វើជាប៉ូលីស ដោយពេលនោះ លោកស្រីទើបតែសម្រាលកូនស្រីបានរយៈពេលតែមួយខែប៉ុណ្ណោះ ។ ក្រោយមកកូនប្រុសច្បងអាយុ៥ឆ្នាំរបស់គាត់ម្នាក់បានស្លាប់ដោយគ្មានថ្នាំព្យាបាល និងខ្វះខាតចំណីអាហារ ។

ខ្មែរក្រហមបានចាត់ទុកគ្រួសារលោកស្រី ដូចជាគ្រួសារជម្លៀសទៀតដែរ គឺជាអ្នកដែលជាប់និន្នាការ ព្រោះធ្លាប់មានប្រវត្តិធ្វើការរាជការ ។ ខ្មែរក្រហមមិនឲ្យគ្រួសារគាត់ទៅនៅជាមួយប្រជាជនចាស់ទេ គឺចាត់តាំងឲ្យទៅរុករានដីថ្មីធ្វើកសិកម្ម ។ ចំណែកលោកស្រី ទោះបីជាទើបតែឆ្លងទន្លេបានមួយខែក៏ដោយ ក៏ខ្មែរក្រហមចាត់គាត់ឲ្យធ្វើការដូចជាអ្នកផ្សេងទៀតដែរ គឺចុះស្ទូងក្នុងទឹកជម្រៅត្រឹមចង្កេះ តាំងពីព្រឹកព្រលឹមរហូតដល់ពេលល្ងាច ។

ចំណែករបបអាហារ ខ្មែរក្រហមបានចែកអង្ករឲ្យ១កំប៉ុងសម្រាប់មនុស្សម្នាក់សម្រាប់រយៈពេល៥ថ្ងៃ ប៉ុន្តែអ្នកខ្លះ ដោយសារឃ្លានខ្លាំងពេកបានហូបរបបអង្កររស់ ក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ ។ នៅថ្ងៃបន្ទាប់ ដោយសារពុំមានអាហារហូប ប្រជាជនទាំងនោះបានទៅបេះផ្លែឈើព្រៃហូប បណ្តាលឲ្យពុល និងរាករូសក៏មាន ។ ទោះបានដឹងរឿងនេះក៏ដោយ ក៏លោកស្រីនៅតែព្យាយាមស្វែងរកអាហារបន្ថែម ដូចជា ផ្លែឈើព្រៃគ្រប់ប្រភេទ ដែលអាចហូបបាន រួមទាំងដើមចេកមកហូបចម្អែតក្រពះ ។

មានរឿងមួយ លោកស្រីបានជួបប្រទះផ្ទាល់ភ្នែក ដោយសារតែឃ្លានពេកអ្នកភូមិម្នាក់ដែលជាអ្នកជិតខាង បានកាត់ស្លឹកដំឡូងដែលដាំខ្លួនឯងហូប ក៏ត្រូវឈ្លបខ្មែរក្រហមចាប់ចងស្លាបសេកដោយចោទថា លួចរបស់សមូហភាព ។ ប៉ុន្តែអ្នកភូមិម្នាក់នោះតវ៉ានិងប្រកែកជាមួយឈ្លបខ្មែរក្រហមថា ហេតុអីបានជាចាប់គាត់បើគាត់កាត់តែស្លឹកដំឡូងដែលបានដាំខ្លួនឯង ។ ប៉ុន្តែឈ្លបខ្មែរក្រហមមិនបានស្តាប់ការតវ៉ានោះទេ គឺបានចងដៃជើងគាត់ផ្អោបទៅនឹងដើមឈើ ដោយមិនឲ្យជើងធ្លាក់ដល់ដី ហើយយកផ្លែដូងខ្ចីដែលកាប់ជាចម្រៀកៗ និងមានរាងស្រួច គប់ទៅលើគាត់ជារៀងរាល់ថ្ងៃ ។ ឈ្លបខ្មែរក្រហមមិនឲ្យអាហារ និងទឹកគាត់ផឹករយៈពេល៧ថ្ងៃ រហូតដល់គាត់បាត់បង់ជីវិត ទើបឈ្លបលើកសាកសពគាត់ដាក់ទូករួចយកទៅទម្លាក់ចោលក្នុងទឹក ។ លោកស្រីបានចាំទិដ្ឋភាព និងរូបភាពរបស់អ្នកភូមិនោះដែលមានឈាមហូរ និងសម្រែកដែលគួរឲ្យអាណិតអាសូរជាប់ជានិច្ច ។ ទារុណកម្មដ៏ឃោរឃៅនៅនឹងមុខប្រជាជនបែបនេះ ធ្វើឲ្យប្រជាជនរស់នៅក្នុងសភាពភ័យខ្លាចនឹងបាក់ស្បាត ។

លោកស្រី ក៏នៅមានវិប្បដិសារី និងនឹកស្រណោះប្អូនប្រុសគាត់ជាខ្លាំង ដោយសារឃ្លានពេក ប្អូនរបស់គាត់បានដើរសុំអាហារគេហូប ។ ឃើញដូចនេះ ឈ្លបក៏វាយដំគាត់ ប៉ុន្តែលោកស្រីមិនអាចជួយប្អូនបានទេ គឺបានតែត្រឹមឈរមើលគេវាយប្អូនពីចម្ងាយប៉ុណ្ណោះ ។ ប្អូនរបស់លោកស្រីបានធ្លាក់ខ្លួនឈឺ ហើយម្តាយលោកស្រី ក៏សម្រេចចិត្តអៀវប្អូនប្រុសលោកស្រីដែលមានវ័យជំទង់ចុះពីលើភ្នំទួលពោធិ៍ទៅរកពេទ្យ ។ លោកស្រីអាណិតម្តាយរបស់លោកស្រីយ៉ាងខ្លាំង ព្រោះត្រូវដើរក្នុងចម្ងាយផ្លូវរាប់សិបគីឡូម៉ែត្រ ។ ម្តាយលោកស្រីសង្ឃឹមថា បើយកប្អូនលោកស្រីចុះមកពីភ្នំនឹងអាចរកអាហារ និងរកពេទ្យព្យាបាលបាន ជាជាងទុកចោល

នៅលើភ្នំ តែជាអកុសលដោយសារជំងឺមិនបានធូរស្បើយ ប្អូនប្រុសលោកស្រីក៏ស្លាប់បីថ្ងៃក្រោយមក ។ ចំណែក លោកស្រីនៅតែខិតខំទៅរកផ្លែឈើព្រៃ ដូចជា ផ្លែញញួមកហូបចម្អែតក្រពះ ដោយទុករបបអាហាររបស់លោកស្រីឲ្យកូនតូចៗហូប ។

ក្រោយមក កូនស្រីរបស់លោកស្រីបានធ្លាក់ខ្លួនឈឺគ្រុនទៀត ហើយលោកស្រីបានពរទៅពេទ្យសុំថ្នាំ ដែលមានពណ៌ខ្មៅលាយជាមួយកន្ទក់ ។ កូនរបស់លោកស្រីដែលទើបតែមានអាយុបួនខែប៉ុណ្ណោះ ក៏ស្លាប់នៅពេលយប់នោះទៅ ប៉ុន្តែលោកស្រីមិនហ៊ានយំឲ្យឮទេ ព្រោះមានឈ្លបមកលបស្តាប់ ។ លោកស្រីបានយំឱបសពកូនរហូតដល់ភ្លឺ ។ ព្រឹកឡើង ខ្មែរក្រហមបានយកកូនលោកស្រីទៅកប់ ដោយមិនឲ្យលោកស្រីយកទៅផ្ទាល់ដៃទេ ។ ពេលនោះលោកស្រីបានស្ទាបកូនហាក់បីដូចជានៅមានកំដៅនៅឡើយ លោកស្រីគិតថា ប្រហែលជាកូនគាត់នៅមានជីវិតប៉ុន្តែខ្មែរក្រហមមិនឲ្យទុកទេ ។ សព្វថ្ងៃនេះ លោកស្រីនៅតែគិតថា បើគាត់ប្រកែកមិនឲ្យខ្មែរក្រហមយកកូនទៅកប់ ប្រហែលជាកូនគាត់អាចនៅរស់ក៏មិនដឹង ។ ចំណែកប្តីរបស់លោកស្រី នៅយប់មួយបានឡើងមានមតិតវ៉ានៅក្នុងអង្គប្រជុំចំពោះបញ្ហាលំបាកក្នុងផែនការការងារ ដែលអង្គការដាក់ឲ្យធ្វើ និងការបង្ខិតបង្ខំឲ្យធ្វើការងារ ។ អ្នកចូលរួមទាំងអស់ មានការពេញចិត្តនឹងការលើកឡើងនេះ ប៉ុន្តែបានស្ងាត់មាត់ទាំងអស់ ។ ព្រឹកឡើង អង្គការត្រូវបញ្ជូនកងចល័តរបស់ប្តីលោកស្រី ទៅអូរចំណារដែលបានរៀបចំតាំងពីមុនមកហើយ តែអង្គការផ្លាស់ប្តូរផែនការមិនឲ្យស្វាមី និងគាត់ទៅវិញ ។ អង្គការបានប្តូរលោកស្រី ឲ្យទៅសែងដីយកទៅចាក់លើខ្នងទំនប់ គាស់ថ្មធំៗ ដោយមានអ្នកខ្លះត្រូវដុំថ្មធ្លាក់ចំជើងរបួសក៏មាន ។ ពេលធ្វើការ មិត្ត បៀង ប្រធានតំបន់ មកសួរគាត់ហាក់បីដូចជាលេងសើច តើមិត្តឯងមានកម្មសិទ្ធិអ្វីខ្លះ? លោកស្រីឆ្លើយថា «ខ្ញុំអត់មានកម្មសិទ្ធិអីទៀតទេ ព្រោះកូនស្លាប់អស់ហើយ នៅសល់តែគ្រួសារ (ប្តី) ខ្ញុំគឺមានកម្មសិទ្ធិគ្រួសារ ។ មិត្ត បៀង តមកវិញថា «មិត្តឯងអាងកម្មសិទ្ធិ (ប្តី) គ្រួសារប្រយ័ត្នថ្ងៃណាមួយបំបែកកម្មសិទ្ធិគ្រួសារទៀត មិត្តឯងប្រយត្ន័!» ។ លោកស្រីក៏ឆ្លើយរបៀបលេងសើចថា ស្រេចតែអង្គការ! ពេលនោះ ប្តីរបស់លោកស្រី ភ័យរហូតយកចន្ទុះដាក់លើគ្រែ លោកស្រីបានបន្ទោសប្តីលោកស្រី មិនគួរយកភ្លើងមកដាក់លើគ្រែទេ ព្រោះអាចបណ្តាលឲ្យឆេះផ្ទះ តែលោកស្រីមិនដឹងថា ប្តីគាត់ភ័យដោយសារខ្លាចឈ្លបមកហៅគាត់ទៅទាំងយប់ ។

មួយរយៈក្រោយមក ដោយមិនឃើញប្តី លោកស្រីក៏ដើរសួរតាមការដ្ឋាន រហូតមានប្រជាជនប្រាប់ថា មិនបាច់សួរទៀតទេ ខ្ញុំឃើញខ្មែរក្រហមមកហៅទៅបាត់ហើយ ។ ពេលនោះ លោកស្រីមិនហ៊ានយំទេ ប៉ុន្តែដើមទ្រូងលោកស្រីណែនអស់ហើយ រកនិយាយអ្វីមិនចេញសោះ ។ ព្រឹកឡើងលោកស្រីបានសួរឈ្លប តែឈ្លបអត់និយាយរកគាត់ទេ ។ បន្ទាប់មក ឈ្លបឲ្យនារីម្នាក់មកប្រាប់លោកស្រីឲ្យទៅព្រះវិហារដែលគេបោះបង់ចោល និងមានសភាពស្ងាត់ស្ងួចហើយប្រាប់លោកស្រីថា «មិត្តឯងឈប់ដើរសួរគេទៀតទៅ មិត្តក្តី យើងក្តីក៏ អត់ទៀងដែរ!» អីចឹងមិត្តខំតែធ្វើការទៅ!

ថ្ងៃមួយពេលលោកស្រី ទូលកណ្តាប់នៅវាលស្រែ មានអ្នកមូលដ្ឋានមកពីខេត្តតាកែវ និយាយថា « មិត្តឯងសំណាងហើយ នៅយប់នោះមិនមែនយកតែគ្រួសារមិត្តឯងទេ ឈ្លបយកទៅបីគ្រួសារឯណោះ ក្នុងចំណោមនេះ គ្រួសារដែលមានកូនតូចនៅក្នុងមណ្ឌលកុមារ ក៏ឈ្លបយកកូននោះទៅសម្លាប់ដែរ» ។ ក្រោយមក ទើបលោកស្រីបានឮគេប្រាប់ថា ក្រុមរែកស្រូវ (ក្រុមប្តីលោកស្រី) ឡើងតវ៉ាថា មានការលំបាក និងមានគេធ្វើបាប ហូបមិនគ្រប់គ្រាន់ ហើយសូម្បីតែរើសខ្នុរទុំជ្រុះហូបសោះក៏មិនបាននោះ ត្រូវឈ្លបសម្លាប់ទាំងអស់ តែមុននឹងសម្លាប់ ខ្មែរក្រហមកាត់ដៃកាត់ជើងរហូតដល់ខ្សោះឈាមតែម្តង ។ ពេលដឹងរឿងនេះ លោកស្រីអាណិតដល់ប្តីរបស់លោកស្រីយ៉ាងខ្លាំង ។

នៅពេលដែលលោកស្រី ធ្លាក់ខ្លួនឈឺ មានមិត្ត ឌុន ប្រធានសហករណ៍ តែងតែលួចឲ្យថ្នាំ និងបាយខ្លះទៅឲ្យលោកស្រីហូប ។ លោកស្រីមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះវាលពួច កន្លែងដែលលោកស្រីរស់នៅមានសត្វខ្លាជាច្រើន ។ នៅពេលយប់មួយ ពេលចេញពីមន្ទីរពេទ្យវិញ លោកស្រីឃើញដានជើងខ្លា ហើយរំពេចនោះស្រាប់តែឃើញខ្លានៅនឹងមុខគាត់តែម្តង ។ លោកស្រីបានផ្សងថា «ទឹកដោះម្តាយថ្ងៃសូមកុំឲ្យលោកស្រីជួបគ្រោះថ្នាក់!» ស្រាប់តែខ្លាដើរទៅផុតទៅ ។

នៅឆ្នាំ១៩៧៨ កងទ័ពវៀតណាមចាប់ផ្តើមវាយចូលមក ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅរស់នៅថ្មបាំង ។ នៅពេល

នោះ ឪពុកម្តាយរបស់លោកស្រី ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលអស់ហើយ ចំណែកប្អូនស្រីម្នាក់បានស្លាប់ ដោយសារត្រជាក់រីងពោះពេលជិះទូកត្រឡប់មករកឪពុកម្តាយវិញ ។ លោកស្រី ត្រូវជួយចិញ្ចឹមផ្គត់ផ្គង់ប្អូនប្រុសស្រីដែលនៅតូចៗ ដោយដំបូងធ្វើជាស្មៀនឃុំបិតត្រាំង ។ លោកស្រីបាននៅយាមការពារភូមិជាមួយប្រុសៗ ហើយពេលទៅប្រជុំម្តងៗ លោកស្រីត្រូវជិះក្តារ និងពេលខ្លះសុំស្នាក់គ្រាក់ទ័រប្រជាជនជិះក៏មាន ។ លោកស្រីបានទាក់ទងទៅអ្នកដែលលោកស្រីស្គាល់ ហើយដែលធ្វើការនៅក្រុងកំពង់សោម ដើម្បីសុំអង្ករ ក្រណាត់ មកចែកឲ្យប្រជាជនដែលខ្វះខាត ។

លោកស្រីត្រូវរ៉ាប់រងកិច្ចការងារឃុំទាំងអស់ ។ ប្រជាជនខ្លះដែលត្រូវរបួសធ្ងន់ ដោយសារខ្មែរក្រហមដោងគ្រាប់ដាក់ ក៏លោកស្រីបានចុះទៅជួយមើលថែរបួសអ្នកទាំងនោះជាមួយគ្រូពេទ្យដោយផ្ទាល់ដែរ ។ ប្រជាជនជាច្រើនស្រឡាញ់រាប់អានលោកស្រីថែមទាំងបោះឆ្នោតឲ្យលោកស្រីធ្វើមេឃុំដែរ តែលោកស្រីបានប្រកែក ។

នៅឆ្នាំ១៩៨០ ដល់៨១ លោកស្រី បានមកធ្វើការនៅក្រុងទទួលបន្ទុកសរុបសភាពការណ៍ និងការបង្កបង្កើនផល ។ ក្រោយមករដ្ឋបានចាត់តាំងលោកស្រីធ្វើការងារអប់រំផ្សព្វផ្សាយពីគោលនយោបាយជាតិទៀត ។ លោកស្រី បានចុះទៅភូមិដើងគោ ដោយជួយប្រូតស្រូវប្រជាជន ជួយស្ត្រីសម្រាលកូន ផ្តល់កម្លាំងចិត្តឲ្យគាត់អាចប្រកបជីវភាពបាន ។ ខ្មែរក្រហមបានស៊ើបដឹងពីលោកស្រី ហើយលោកស្រីក៏ផ្លាស់ប្តូរកន្លែងស្នាក់នៅជាញឹកញាប់ ។ លោកស្រីបានទទួលដំណឹងពីសកម្មភាពរបស់ខ្មែរក្រហម និងទទួលអាវុធជាច្រើនពីប្រជាជន ដើម្បីប្រគល់ឲ្យរដ្ឋអំណាច ។ លើសពីនោះលោកស្រីក៏បានចូលរួមក្នុងកម្មវិធីអប់រំ និងលើកស្ទួយសកម្មភាពស្ត្រីដែរ ហើយព្រមទាំងបានជួយរំដោះក្រុមស្ត្រីដែលរកស៊ីផ្លូវភេទនៅទីក្រុងកំពង់សោម យកមកអប់រំ និងផ្គត់ផ្គង់រហូតមានការងារសមរម្យ ។ លោកស្រីបានធ្វើកិច្ចការទាំងនេះ ដោយសារលោកស្រីបានបាត់បង់ បងប្អូន និងឪពុកម្តាយ កូន និងស្វាមីនៅក្នុងរបបខ្មែរក្រហម ហើយរាល់ថ្ងៃលោកស្រីបានយកធម៌មកទុកក្នុងចិត្តដើម្បីកុំឲ្យចងពៀរ ។ លោកស្រីបានធូរស្បើយខ្លះនៅពេលដែលមេដឹកនាំរបបនេះ ត្រូវបានតុលាការយកមកកាត់ទោស ។

លោកស្រីនៅតែឆ្ងល់ថា ហេតុអ្វីបានជាអ្នកមានចំណេះដឹងដឹកនាំប្រទេសធ្លាក់ទៅក្នុងការសម្លាប់រង្គាលយ៉ាងដូច្នេះ ។ នៅកន្លែងដែលលោកស្រីរស់នៅក្នុងសម័យខ្មែរក្រហម លោកស្រីឃើញឆ្អឹងខ្មោចនៅរាយពាសពេញ ដូចនេះចំនួនអ្នកស្លាប់ពិតជាមានចំនួនច្រើនណាស់ ។ ប៉ុន្តែ ពេលដែលលោកស្រីស្តាប់សវនាការមេដឹកនាំខ្មែរក្រហមឆ្លើយថា «មិនបានដឹងថាមានការកាប់សម្លាប់ប្រជាជន និងមិនបានដឹងថាប្រជាជនអត់បាយទៅវិញ» ។

រឿងរ៉ាវរបស់លោកស្រី បានបង្ហាញថា ស្ត្រីបានចូលរួមកសាងសន្តិភាព និងការផ្សះផ្សា និងបានជួយពង្រឹងនៅក្នុងសហគមន៍ទាំងមូល ។ នៅក្នុងប្រទេសក្រោយជម្លោះ និងឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃដូចកម្ពុជា ប្រជាជន មានភាពបាក់ស្បាត និងការបាត់បង់ការជឿទុកចិត្ត ។ ដូចនេះ ការយកចិត្តទុកដាក់ និងការផ្តល់ភាពកក់ក្តៅពីសំណាក់រដ្ឋអំណាច ជាពិសេស ការចូលរួមរបស់ស្ត្រីពិតជាសំខាន់ណាស់ក្នុងការស្តារប្រទេសជាតិឡើងវិញ ។ **ហ៊ុយ សម្ផស្ស**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ាន ស៊ី ស្នាក់នៅផ្ទះលេខ៤៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសស្វែងរកឈ្មោះ អៀវ ទៀងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅខេត្តកំពង់ស្ពឺ ។ ពីមុន ទៀងហាវ ជាសាស្ត្រាចារ្យរូបវិទ្យា-គីមីនៅវិទ្យាល័យអង្គរទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ទៀងហាវ និងភរិយាឈ្មោះ គួច សាយទៀង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ទៀងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០ ១២ ៩៥៨ ៥៤៦ ឬ អ៊ីមែល nhansy04@yahoo.com ។ ***សូមអរគុណ!***

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

### ៦) ពិធីទាក់ទងនឹងវដ្តជីវិត

ជារៀងរាល់ឆ្នាំ ជនជាតិចាមតែងធ្វើពិធីបុណ្យស្របទៅតាមប្រពៃណីអ៊ីស្លាម ។ ពិធីបុណ្យទាំងនេះ ត្រូវបានអនុវត្ត ដោយសហគមន៍មូស្លីមនៅទូទាំងពិភពលោក ។ ចំណុចដែលគួរឲ្យកត់សម្គាល់នោះគឺថា ទោះជាជនជាតិចាមភាគច្រើនប្រារព្ធពិធីបុណ្យដែលស្របទៅតាមក្បួនច្បាប់សាសនានិងការប្រណិប័តន៍នៅលើពិភពលោកយ៉ាងណាក៏ដោយ ក៏នៅមានចាមមួយចំនួនដែលរៀបចំពិធីបុណ្យទៅតាមទម្លាប់នៅក្នុងតំបន់ ។ ពិធីបុណ្យអ៊ីស្លាមធំពីរគឺ អេឌុល អាហា (Eidul Adha) ដែលប្រារព្ធឡើងដើម្បីបញ្ចប់ការធ្វើហាជ្ជ និងអេឌុល ហ្វីទ្រី (Eidul Fitri) ដែលជាថ្ងៃបុណ្យធំដើម្បីបញ្ចប់ពិធីបួសរ៉ាម៉ាដាន ។ ពិធីបុណ្យ ប្រចាំឆ្នាំទាំងអស់នេះរួមមានដូចខាងក្រោម៖

#### ពិធីចូលឆ្នាំអ៊ីស្លាម

ខែ មុហារ៉ាម (Muharram) សម្គាល់ដើមឆ្នាំក្នុងសាសនាអ៊ីស្លាម ។ ពិធីចូលឆ្នាំថ្មីចាប់ផ្ដើមនៅថ្ងៃទីមួយនៃខែមុហារ៉ាម ។ ខុសពីខ្មែរដែលចាត់ទុកពិធីចូលឆ្នាំថាជាពិធីធំជាងគេបង្អស់ប្រចាំឆ្នាំ ជនជាតិចាម ប្រារព្ធពិធីចូលឆ្នាំយ៉ាងស្ងៀមស្ងាត់ ។ ជនជាតិចាមធ្វើពិធីនៅវិហារ ថ្វាយបង្គំ និងសូត្រគម្ពីរគួរអាន ។



ប្រជាជនចាម ប្រារព្ធពិធីបុណ្យ អេឌុល អាហា

**អេឌុល អាហា (Eidul Adha)**

ពិធី អេឌុល អាហា ប្រារព្ធធ្វើឡើងនៅថ្ងៃទី១០នៃខែទី១២ ។ សម្រាប់ជនជាតិចាមភាគច្រើន ពិធីនេះធ្វើឡើង ២ខែ១០ថ្ងៃគត់ បន្ទាប់ពី ពិធី អេឌុល ហ្វីទ្រី (Eidul Fitri) ដែលប្រព្រឹត្តឡើងបន្ទាប់ពីខែបួសរ៉ាម៉ាដាន ។ អេឌុល អាហា គឺជា "ពិធីបូជា" ដែលប្រារព្ធឡើងដើម្បីរំលឹកដល់ការសាកល្បង និងជ័យជម្នះរបស់ព្យាការី អាប្រាហាម ។ យោងតាមគម្ពីរគួរអាន អាប្រាហាមបានបង្ហាញពីឆន្ទៈរបស់ខ្លួន ទៅដល់ព្រះអល់ឡោះ ដោយការបូជាកូនប្រុសខ្លួនគឺ អ៊ីស្មាអែល ដើម្បីជាគ្រឿងបន្ទាល់ដល់ការគោរពប្រណិប័តន៍ដល់ព្រះអល់ឡោះ ។ ប៉ុន្តែនៅពេលឃើញពីទឹកចិត្តរបស់អាប្រាហាម ព្រះអល់ឡោះបានបញ្ឈប់ អាប្រាហាម មិនឲ្យសម្លាប់កូនប្រុសខ្លួន ហើយផ្តល់សត្វចៀមមួយក្បាលដើម្បីឲ្យគាត់បូជាជំនួសវិញ ។ ជនជាតិចាម នៅកម្ពុជាប្រារព្ធពិធីបុណ្យនេះដោយការបូជាសត្វគោជំនួសសត្វពពែ ។ ជាទូទៅ អ្នកធ្វើពិធីនឹងធ្វើការបូជាសត្វ បន្ទាប់ពីខ្លួនបានឲ្យធម៌ទៅសត្វនោះ ។ សាច់គោត្រូវបានបែងចែកជាបីចំណែក មួយចំណែកសម្រាប់គ្រួសារ មួយចំណែកសម្រាប់មិត្តភក្តិ សាច់ញាតិ និងអ្នកជិតខាង ឯចំណែកដែលនៅសេសសល់គឺសម្រាប់អ្នកក្រីក្រ ។ ឈាមគោត្រូវបានយកទៅកប់នៅរណ្តៅក្បែរទីតាំងពិធីបូជា ។

នៅព្រឹកថ្ងៃធ្វើពិធី អេឌុល អាហា ជនជាតិចាមស្លៀកសម្លៀកបំពាក់ប្រពៃណីថ្មីល្អស្អាតជាងគេ ។ ជនជាតិចាមចូលរួមការថ្វាយបង្គំនៅពេលព្រឹកនៅវិហារក្នុងភូមិ ។ បន្ទាប់មក គ្រួសារ និងមិត្តភក្តិ មកជួបជុំគ្នា ដើម្បីសម្តែងការគួរសម និងផ្លាស់ប្តូរអំណោយគ្នាទៅវិញទៅមក ។ អ្នកទាំងអស់នោះ ក៏សុំខមាទោសពីគ្នាទៅវិញទៅមកដែរ ។ គ្រួសារដែលអ្នកនិពន្ធបានទៅជួប ទិញគោក្មេង និងមានសុខភាពល្អ មួយអាទិត្យមុនពិធីបុណ្យ ។ អ្នកស្រុកធ្វើការបូជាសត្វគោ នៅម៉ោងប្រហែល១២ៈ៣០នាទី ថ្ងៃត្រង់ ដែលពេលវេលានោះពន្យឺតបន្តិច ដោយសារតែគ្រួសារនេះត្រូវរង់ចាំអ្នកកាប់គោដែលរវល់ជាមួយនឹងការងារនេះពេញមួយថ្ងៃ ។ ពិធីបូជាសត្វ ដែលភាសាអារ៉ាប់ហៅថា គូបានី (Qurbani)ត្រូវធ្វើឡើងនៅអំឡុងថ្ងៃទី១០ និងទី១២ នៃខែទី១២នៃប្រតិទិនអ៊ីស្លាម ។ ដោយសារថា សត្វនេះត្រូវបានជ្រើសរើសមកធ្វើការបូជា អ្នកស្រុកម្នាក់ប្រាប់ខ្ញុំថា គោនេះមិនមែនជាសត្វគោធម្មតាទេ ។ សត្វនេះនឹងឡើងទៅឋានសួគ៌ បន្ទាប់ពីបូជារួច ។ អ៊ីស្លាមមានច្បាប់ច្បាស់លាស់សម្រាប់សត្វដែលត្រូវបូជា ។ គោនេះត្រូវមានអាយុយ៉ាងហោចណាស់ក៏ ២ឆ្នាំ គ្មានជំងឺឆ្លង និងមិនស្គមពេកឬពិការ (ដូចជាខ្វាក់ឬពិការដៃជើង) ។ សត្វនេះត្រូវតែជាកម្មសិទ្ធិរបស់គ្រួសារដែលធ្វើការបូជា មិនអាចជាគោដែលលួចពីគេ ឬយកពីអ្នកណាម្នាក់មក ដោយគ្មានការអនុញ្ញាត ។ ក៏ប៉ុន្តែក្រុមគ្រួសារសាច់ញាតិអាចចូលគ្នាទិញគោ ដែលមានសុខភាពល្អមួយបាន ។

**អេឌុល ហ្វីទ្រី (Eidul Fitri)**

ពិធីបួសតមអាហារក្នុងពេលបុណ្យរ៉ាម៉ាដាន គឺជាពិធីសាសនាអ៊ីស្លាមមួយ ដែលមានការលំបាក និងតម្រូវការខ្ពស់ ។ ពេលបានសម្រេចការតមអាហារក្នុងពិធីនេះ អ្នកស្រុកនឹងធ្វើពិធីមួយដើម្បីអបអរសាទរ ។ អេឌុល ហ្វីទ្រី គឺជាពិធីមួយដែលបម្រើដល់គោលបំណងនេះ ។ មូស្លីមនៅលើពិភពលោកឈប់ សម្រាកពីការងារមួយថ្ងៃដើម្បីចូលរួមក្នុងពិធីនេះ ។ ពិធីនេះចាប់ផ្តើមឡើងនៅថ្ងៃទីមួយបន្ទាប់ពីរ៉ាម៉ាដាន ។ មូស្លីមធ្វើពិធីថ្វាយបង្គំនៅពេលព្រឹក ។ នៅពេលថ្ងៃ មិត្តភក្តិ និងសាច់ញាតិមកជួបជុំគ្នាដើម្បីសុំខមាទោសគ្នាទៅវិញទៅមក អំពីអំពើខុសឆ្គងផ្សេងៗដែលខ្លួនធ្លាប់ប្រព្រឹត្ត ។ អ្នកស្រុកជប់លៀង និងធ្វើពិធីថ្វាយបង្គំនៅពេលល្ងាចជាមួយគ្នា ។ នៅពេលថ្ងៃ មូស្លីមតម្រូវឲ្យធ្វើទាន ដែលហៅថា ហ្សាកាត់ ហ្វីត្រា (Zakat Fitrah) ទៅដល់អ្នកក្រីក្រនៅក្នុងភូមិដែលខ្លួនរស់នៅ ។ ទាក់ទងនឹងការធ្វើទាននេះ សាសនាអ៊ីស្លាមមានច្បាប់ជាក់លាក់ មួយចំនួនទាក់ទងនឹងអ្នកផ្តល់ទាន អ្នកទទួលទាន ចំនួន និងទីតាំងនៃការដាក់ទាន ។ គោលបំណងសំខាន់សម្រាប់ការធ្វើពិធីនេះ គឺដើម្បីលាងបាបដែលមូស្លីមបានប្រព្រឹត្តនៅក្នុងពិធីបួសតមអាហារ ។ នៅឆ្នាំ ២០១១ ជនជាតិចាមភាគច្រើនធ្វើពិធីអេឌុល ហ្វីទ្រី នៅថ្ងៃទី៣០ ខែសីហា ។ ក៏ប៉ុន្តែក្រុមអ៊ីម៉ាំសាន់ រៀបចំធ្វើពិធីនេះ នៅថ្ងៃទី១ ខែកញ្ញា ។ នៅប្រទេសឥណ្ឌូ ពិធីនេះធ្វើនៅថ្ងៃទី៣១ខែ សីហា ។ ក្នុងពេលកំពុងប្រារព្ធពិធី អ្នកស្រុកទៅលេងផ្ទះមិត្តភក្តិ អ្នកជិតខាង និងសាច់ញាតិដើម្បីសុំខមាទោស ។ សកម្មភាពនេះ អ្នកស្រុកហៅថា សុំម៉ាស (som ma-as) ។

**អាគីកាស (Aqiqah)**

អ៊ីស្លាម គឺជាសាសនាដែលផ្តោតជាសំខាន់ទៅលើទស្សនៈ

នៃការបង្កើត ។ ព្រះបង្កើតលោក ព្រះអល់ឡោះ ទទួលខុសត្រូវទៅលើជីវិតនៅលើលោក ។ ហេតុនេះហើយទើបព្រះអង្គត្រូវបានរម្លឹកបង់ចាំ និងធ្វើការថ្លែងអំណរគុណពេលមូស្លីមថ្វាយបង្គំ និងពេលធ្វើពិធីបូជា ។

ការផ្តល់កំណើតដល់ទារក គឺជាពេលវេលាដ៏ពិសេសនៅក្នុងទស្សនៈរបស់សាសនាអ៊ីស្លាម ទាក់ទងនឹងការកំណត់ និងការបង្កើតលោក ។ ទារកដែលទើបនឹងកើតគឺជាមនុស្សដែលព្រះអល់ឡោះ ផ្តល់ទៅឲ្យឪពុកម្តាយនិងទៅដល់មនុស្សជាតិ ។ ហេតុនេះ អាគីកាស គឺជាពិធីសាសនាមួយធ្វើឡើងដើម្បីសម្តែងការដឹងគុណទៅព្រះអល់ឡោះដែលបាននាំទារកនោះមកកាន់ពិភពលោក ។

ឪពុកម្តាយ ឬអ្នកចិញ្ចឹមទារកគឺជាអ្នករៀបចំពិធី ។ ពេលវេលាល្អបំផុតសម្រាប់ពិធីនេះ គឺពេលទារកកើតបាន៧ថ្ងៃ ។ គ្រួសារជនជាតិចាមខ្លះពន្យារពេលធ្វើពិធី អាគីកាស រហូតដល់កូននោះធំដោយសារតែមូលហេតុមួយចំនួនដូចជា គ្រួសារក្រីក្រពេក និងបញ្ហាសង្គមផ្សេងៗដូចជា អ្នកដែលកើតនៅជំនាន់សង្គ្រាមទសវត្សរ៍ឆ្នាំ៧០ ឬ៨០ ពេលដែលប្រទេសកម្ពុជាកំពុងស្ថិតនៅក្រោមរបបខ្មែរក្រហម និងកំពុងតែស្តាបនាឡើងវិញពីរបបប្រល័យពូជសាសន៍ ។ គ្រួសារខ្លះប្រើប្រាស់ពិធីនេះដើម្បីប្រកាសពីសមាជិកថ្មីនៅក្នុងគ្រួសារទៅកាន់ញាតិជិតខាង និងមិត្តភក្តិដែលមកចូលរួម ។

ពិធីអាគីកាស មានសកម្មភាពសំខាន់ពីរ គឺការបូជាជីវិតសត្វ និងការកាត់សក់ព្រៃ ។ នៅភូមិ អ៊ីម៉ាំសាន់ ការកាត់សក់ព្រៃរបស់ទារកអាចធ្វើឡើងនៅក្នុងពិធីបុណ្យម៉ាឡូត ។ ការបូជាសត្វធ្វើឡើងដើម្បីជាការដឹងគុណដល់ព្រះអល់ឡោះដែលបានផ្តល់កំណើតកូនមកដល់ឪពុកម្តាយ ។ ការបូជានេះ ក៏ដើម្បីជាការបួងសួងសុំឲ្យព្រះអល់ឡោះតាមថែរក្សាកូននេះឲ្យផុតពីគ្រោះភ័យផ្សេងៗ នៅក្នុងជីវិត ។ គ្រួសារចាមខ្លះមិនបូជាសត្វធំៗដែលមានតម្លៃថ្លៃពេកនោះទេ ដោយសារតែជីវភាពគ្រួសារ ។ គ្រួសារនោះធ្វើការបូជាសត្វតូចៗដូចជា សត្វមាន់ ជំនួសវិញ ។

## ពិធីបុណ្យម៉ាឡូត

ពិធីបុណ្យនេះប្រារព្ធធ្វើឡើងចំថ្ងៃកំណើតរបស់ព្យាការីមហាម៉ាត់ ដែលកើតនៅថ្ងៃទី១២ ខែរ៉ាប៊ី១ *(Rabi I)* ក្នុងប្រតិទិនអ៊ីស្លាម ។ អ្នកប្រតិបត្តិតាម សាឡាហ្វី មិនប្រារព្ធពិធីបុណ្យនេះទេ ។ ជនជាតិចាម ប្រារព្ធពិធីនេះនៅវិហារអ៊ីស្លាម ជួបជុំគ្នានិងសូត្រគម្ពីរគួរអាន ។ ក្នុងសហគមន៍ អ៊ីម៉ាំសាន់ អ្នកស្រុករៀបចំនំបាយដំណើបស្អិត និងនំដែលមានរូបរាង និងទំហំខុសៗគ្នាមានក្បាច់ក្បូរយ៉ាងល្អប្រណិត ដោយមានដាក់ប្រាក់ និងស៊ុតនៅកណ្តាល ។ អ្នកស្រុកជួបជុំគ្នានៅកន្លែងមួយក្នុងភូមិ ហើយដើរជាក្បួនដង្ហែសំដៅទៅវិហារ ។ ក្រុមអ៊ីម៉ាំសាន់ធ្វើបុណ្យម៉ាឡូតដើម្បីជាការរម្លឹកទៅដល់ អ៊ីម៉ាំសាន់ អ្នកដឹកនាំសាសនាដែលបានចែកឋានទៅ នៅខែតុលារៀងរាល់ឆ្នាំ ។ មេសហគមន៍ព្រមព្រៀងគ្នាធ្វើពិធីនេះ នៅពេលវេលាណាមួយដែលស័ក្តិសម ។

## ពិធីបុណ្យសព

អ្នកនិពន្ធបានចូលរួមអង្កេតពិធីបុណ្យសពជនជាតិចាមមួយនៅខេត្តកំពង់ចាម ។ ភូមិចាមមួយ អាចមានកន្លែងបញ្ចុះសពដល់ទៅ៧កន្លែង ។ យោងតាមការរៀបរាប់របស់អ្នកស្រុក ផ្នូរតែមួយអាចប្រើបញ្ចុះសពបានម្តងទៀត ក្រោយរយៈពេល៤០ឆ្នាំ ឬពេលដែលកន្លែងបញ្ចុះសពចង្អៀតពេក ។ ពេលមនុស្សម្នាក់ស្លាប់ ជនជាតិចាមធ្វើពិធីចំអាសទឹកសម្អាតខ្លួនប្រាណ កម្ចាត់ភាពសៅហ្មងផ្សេងៗដែលតាមជាប់មកជាមួយអ្នកស្លាប់ ។ បន្ទាប់មក សាកសពនឹងត្រូវរុំជាមួយក្រណាត់សបីបំណែក ។ សាកសព ច្រើនតែកប់នៅថ្ងៃតែមួយនឹងថ្ងៃស្លាប់ ។ ប្រសិនបើស្លាប់នៅពេលយប់ សាកសពនោះនឹងត្រូវបញ្ចុះនៅព្រឹកថ្ងៃបន្ទាប់ ។

ក្រោយពីបញ្ចុះរួច ក្រុមអ៊ីម៉ាំសាន់ ធ្វើពិធីបុណ្យ៧ដងទៀត គឺខួប៣ថ្ងៃ ៧ថ្ងៃ ១០ថ្ងៃ ៣០ថ្ងៃ ៤០ថ្ងៃ និង១០០ថ្ងៃ ហើយក្រោយមកទើបធ្វើពិធីបុណ្យខួប១ឆ្នាំ ។ សាច់ញាតិ អ្នកជិតខាង និងមិត្តភក្តិ មកជួយរៀបចំពិធីជាមួយនឹងក្រុមគ្រួសារសព ។ អ្នកមកចូលរួមពិធី ចូលបុណ្យជាលុយកាក់ និងម្ហូបអាហារជាមួយម្ចាស់បុណ្យ ។ ពិធីនីមួយៗតែងតែមានម្ហូបអាហារ និងនំចំណី ។ នៅថ្ងៃធ្វើពិធីបុណ្យខួប៣០ថ្ងៃ គ្រួសារសពរៀបចំនំបញ្ចុកដែលជាម្ហូបប្រពៃណីខ្មែរ ។ នេះជាចំណុចដ៏គួរឲ្យចាប់អារម្មណ៍ ដែលការអនុវត្តបែបនេះបានក្លាយទៅជាផ្នែកមួយនៃពិធីបុណ្យសពក្រុមអ៊ីម៉ាំសាន់ ។ ជារឿយៗ សមាជិកក្រុមអ៊ីម៉ាំសាន់និយាយដោយមោទកភាពថា ខ្លួនប្រណិប័តន៍សាសនា និងរបៀបរស់នៅស្រដៀងនឹងជនជាតិខ្មែរដែរ ។ ទោះបីជានំបញ្ចុកខ្មែរជាម្ហូបប្រពៃណីខ្មែរ ជាទូទៅម្ហូបនេះ រៀបចំ

ឡើងតែក្នុងឱកាសពិសេសដែលមានមនុស្សចូលរួមច្រើន ។

នៅតំបន់ខ្លះក្នុងខេត្តកំពង់ចាម គ្មានពិធីបុណ្យអ្វីផ្សេងធ្វើឡើងបន្ទាប់ពីបុណ្យសពថ្ងៃទីមួយនោះទេ ។ ពិធីបុណ្យបែបនេះធ្វើខុសៗគ្នាពីភូមិមួយទៅភូមិមួយ ។ នៅក្នុងគម្ពីរគួរអាន មានកថាខណ្ឌមួយបញ្ជាក់ពីរយៈពេលដែលស្ត្រីមេម៉ាយអាចរៀបការម្តងទៀតបានក្រោយពីប្តីស្លាប់ទៅ ។ គម្ពីរនោះសូត្រថា “អ្នកដែលស្លាប់ចោលប្រពន្ធឲ្យនៅមេម៉ាយ ស្ត្រីមេម៉ាយនោះគួររង់ចាំរហូតដល់៤ខែ ១០ថ្ងៃទើបអាចរៀបការម្តងទៀតបាន” ។

### អ៊ីជធីម៉ាស (Ijtimas)

អ៊ីជធីម៉ាស គឺជាពិធីជួបជុំប្រចាំឆ្នាំដែលរៀបចំដោយ ក្រុម តាប្លីហ្គី ចាម៉ាត់ នៅខែមេសា ។ អ្នកដើរតាមក្រុម តាប្លីហ្គី ចាម៉ាត់ មកពីគ្រប់តំបន់ទាំងអស់នៅក្នុងប្រទេស ដើម្បីមកធ្វើពិធីថ្វាយបង្គំរួមគ្នា ជាដំណើរការមួយ ដើម្បីស្តាប់ធម៌ដែលសូត្រដោយអ្នកជំនាញសាសនាអ៊ីស្លាម មកពីបរទេស និងក្នុងស្រុក ហើយបង្កើតក្រុមតូចមួយហៅថា ជុំអះ (Chum Ah) ដើម្បីដើរផ្សព្វផ្សាយសាសនា បន្ទាប់ពីពិធី អ៊ីជធីម៉ាស នេះ ។ ក្រុម តាប្លីហ្គី ចាម៉ាត់ ផ្តោតទៅលើការដើរផ្សព្វផ្សាយសាសនានៅតាមភូមិចាមផ្សេងៗ នៅក្នុងប្រទេស ហៅថា ដាក់វ៉ះ (Dakwah) ។ ជនជាតិចាមធ្វើដំណើរចាកចេញពីផ្ទះក្នុងរយៈពេលពី៣ ទៅ៤០ថ្ងៃ ហើយត្រូវចំណាយដោយខ្លួនឯង ដើម្បីបម្រើដល់គោលបំណងនេះ ។ ជនជាតិចាមទាំងនោះវេចទៅជាមួយនូវអង្ករ ចានឆ្នាំង និងចង្ក្រាន ។ នៅឆ្នាំ២០១២ ពិធីបុណ្យអ៊ីជធីម៉ាស ប្រារព្ធឡើងនៅពីរភូមិនៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម ។ នៅកំពង់ចាម មានជនជាតិចាមចូលរួមរហូតដល់ទៅ២ម៉ឺននាក់ ។ នៅឆ្នាំ២០១១ ការដើរផ្សព្វផ្សាយនេះធ្វើឡើង សម្រាប់អ្នកគាំទ្រក្រុម តាប្លីហ្គី ចាម៉ាត់ មកពីខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រះសីហនុ និងកំពត ។

## ៦) ភាសាចាម

ភាសាចាមស្ថិតនៅក្នុងអម្បូរភាសាម៉ាឡាយូប៉ូលីនេស៊ី ដែលអ្នកនិយាយភាសានេះមាននៅប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ម៉ាដាកាស្កា និងហ្វីលីពីន ។ ក្រុម រ៉ាឡៃ (Raglai) រ៉ាដ (Rhade) ចារ៉ាយ (Jarai) ជ្រូ (Chru) និង រ៉យ (Hroi) ដែលរស់នៅក្នុងប្រទេសវៀតណាម និង កម្ពុជា និយាយភាសាចាមប្លែកៗគ្នា ។ តាមពិតអ្នកស្រុកចាម នៅខេត្តកំពង់ចាមអាចនិយាយភាសាចាមជាមួយជនជាតិចារ៉ាយ ពីខេត្តរតនគិរី ។ ក្រុមជនជាតិភាគតិច សាត់ (Tsat) នៅកោះហៃណាន់ក៏និយាយភាសាចាមដែរ ។

ទោះជាអាណាចក្រចម្ប៉ា និងខ្មែរមានទីតាំងស្ថិតនៅជាប់គ្នា ភាសាខ្មែរមានប្រភពមកពីអម្បូរភាសា អូស្ត្រូនេស៊ី ជាមួយភាសាវៀតណាម ។ ភាសាចាម មានឥទ្ធិពលពីភាសាបាលី និងសំស្ក្រឹតតិចតួច ខុសពីភាសាខ្មែរដែលទទួលឥទ្ធិពលយ៉ាងច្រើនពីភាសាឥណ្ឌាទាំងពីរ តាមរយៈសាសនាហិណ្ឌូ និងព្រះពុទ្ធ ។ ដោយសារតែប្រទេសទាំងអស់នេះស្ថិតនៅក្បែរគ្នា ភាសាចាម ខ្មែរ ថៃ និងវៀតណាម មានឥទ្ធិពលលើគ្នាទៅវិញទៅមក ។ នៅក្នុងភាសាចាមសព្វថ្ងៃ យើងសង្កេតឃើញមានឥទ្ធិពលពីភាសាខ្មែរយ៉ាងច្រើន ។

អ្នកនិពន្ធបានសង្កេតឃើញថា នៅក្នុងការសន្ទនាគ្នាធម្មតា វត្តមានពាក្យខ្មែរនៅក្នុងភាសានិយាយចាម មិនឃើញមានគួរឲ្យកត់សម្គាល់នោះទេ ។ ប៉ុន្តែនៅក្នុងការថ្លែងសុន្ទរកថាឬបទបង្ហាញដែលចាមត្រូវការប្រើប្រាស់ពាក្យពេចន៍ផ្លូវការ នោះយើងសង្កេតឃើញវត្តមានភាសាខ្មែរមានយ៉ាងច្រើន ស្ទើរតែ៣០ភាគរយ ។ នេះបណ្តាលមកពីមូលហេតុច្រើនយ៉ាង ។ ក្នុងភាសាចាមសព្វថ្ងៃ ជនជាតិចាមច្រើនប្រើ សម្រាប់ជាភាសានិយាយ ។ អត្ថបទជាភាសាចាមមានតិច ហើយជនជាតិចាមតិចណាស់ដែលអាចអាន និងសរសេរភាសាចាមបាន ។ បើគ្មានប្រព័ន្ធសំណេរ ភាសាចាមនឹងចុះអន់ថយ ។ ពាក្យចាស់លែងយកមកប្រើប្រាស់ ។ ពាក្យថ្មីកម្រនឹងអភិវឌ្ឍន៍ ។ ដោយមូលហេតុថា ជនជាតិចាមមិនអាចនិយាយពាក្យដែលមានន័យស្រដៀងគ្នា នៅក្នុងភាសាខ្លួនឯងបាន ចាមបានខ្ចីពាក្យខ្មែរមកប្រើដើម្បីបំពេញកង្វះខាតនេះ ។

អ្នកនិពន្ធបានសង្កេតពីការប្រើប្រាស់ពាក្យ “ប្រល័យពូជសាសន៍” ក្នុងភាសាចាម ។ ក្នុងភាសាចាមគ្មានពាក្យណាដែលមានន័យស្មើនឹងពាក្យប្រល័យពូជសាសន៍ទេ ហេតុនេះជនជាតិចាមបានប្រើប្រាស់ពាក្យ ខ្មែរប្រល័យពូជសាសន៍ ។ យោងតាម ហាគីម ៣០ នាក់មកពីខេត្តកំពង់ចាមដែលអ្នកនិពន្ធបាននិយាយជាមួយ ពាក្យចាមដែលមានន័យស្មើនឹងពាក្យ “ប្រល័យពូជសាសន៍” គួរតែបង្ហាញពីការសម្លាប់ប្រជាជនគ្រប់ក្រុមទាំងអស់ រួមមាន ជនជាតិចិន ខ្មែរ ពុទ្ធសាសនិក អ្នកចេះដឹង ជនជាតិចាម ដោយមិនរើសមុខ

និងមានទ្រព្យធំ ។ ពេលចាមនិយាយគ្នាជាភាសាចាម គាត់នៅប្រើប្រាស់ពាក្យ “ប្រល័យពូជសាសន៍” ដោយមិនបកប្រែឲ្យទៅជាភាសាចាមនោះទេ ។

ទោះជាយ៉ាងនេះក៏ដោយ ជនជាតិចាមនៅមានមធ្យោបាយផ្សេងទៀត ក្នុងការពិពណ៌នាពីអំពើសាហាវឃោរឃៅរបស់ខ្មែរក្រហម ។ នៅក្នុងសាសនាអ៊ីស្លាម ពាក្យ ហ្សូលឹម (zolem) មានន័យថា អំពើអាក្រក់ ក្នុងព្រះពុទ្ធសាសនានេះមានន័យថា កម្មអាក្រក់ ។ ហ្សូលឹម ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីអំពើដែលប្រាសចាកពីសីលធម៌សង្គម គិតចាប់ពីចោរលួចកំប៉ិកកំប៉ុក ទៅដល់ការឆបោក និងការប្លន់ទៅដល់ការសម្លាប់មនុស្ស ។ ប្រជាជនចាមនៅកម្ពុជាចេះទស្សនៈ ហ្សូលឹមនេះច្បាស់លាស់ណាស់ ។ ប៉ុន្តែជនជាតិចាមក៏មានពាក្យតំបន់សម្រាប់ ហ្សូលឹម ដែរ ដែលហៅថា ញ៉ាកកាយ៉ាស (nhak ka yas) ។ ដើម្បីពន្យល់ពីអំពើរបស់ខ្មែរក្រហម ប្រជាជនចាមប្រើប្រាស់ពាក្យ ញ៉ាកកាយ៉ាស ជាមួយនឹងពាក្យផ្សេងទៀត ដើម្បីពន្យល់អត្ថន័យជាក់លាក់ ។ ឧទាហរណ៍ ញ៉ាកកាយ៉ាសពុំតាហ៊ីពូជសាសន៍ (nhak ka yas pom tahy pouch sas) មានន័យថា “ការសម្លាប់ក្រុមមនុស្សយ៉ាងសាហាវឃោរឃៅ” ។ ពូជសាសន៍ជាពាក្យខ្មែរផ្សំឡើងពីពាក្យ ពូជ និងសាសន៍ ។ ប៉ុន្តែជនជាតិចាមអាចនិយាយថា ញ៉ាកកាយ៉ាសពុំតាយ ពឆេសាសន៍ (nhak ka yas pom tay pche sas) ដោយផ្លាស់ប្តូរពាក្យ ពូជសាសន៍ ទៅជា ពឆេសាសន៍ វិញ ។ ពាក្យចាមប្រើសម្រាប់ពូជ គឺ ពឆេ រីឯពាក្យចាមប្រើសម្រាប់សាសន៍ ខ្ចីមកពីពាក្យខ្មែរ ។ ទោះជាមានពាក្យពេចន៍ជំនួសពាក្យខ្មែរ ក៏ដោយ ចាមនៅតែប្រើពាក្យ “ពូជសាសន៍” ពេលសន្ទនាគ្នាជាភាសាចាម ។ ជាងនេះទៅទៀត ទ្រឹស្តីដែលទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ជាភាសាអារ៉ាប់គឺ អ៊ីបាដាទី ចាម៉ា អ៊ីយ៉ះ (ibaadati jama-'iyah) ។ អ៊ីបាដាទី មានន័យថា បំផ្លាញ ឬវាយយកជ័យជម្នះ រីឯ ចាម៉ា អ៊ីយះ មានន័យថា ក្រុម ។

ប្រជាជនចាម ប្រើភាសាចាមដើម្បីទំនាក់ទំនងគ្នាទៅវិញទៅមក ។ នៅក្រៅសហគមន៍ចាម និយាយភាសាខ្មែរជាមួយប្រជាជនមកពីសហគមន៍ដទៃទៀត ទាំងក្នុងពេលផ្លូវការ និងមិនផ្លូវការ ដូចជានៅកន្លែងធ្វើការ ទីផ្សារ ការិយាល័យ និងសាលារៀន ។ មូលហេតុចម្បងដែលបណ្តាលឲ្យជនជាតិចាមនៅបន្តប្រើប្រាស់ភាសាចាម គឺក្នុងគោលបំណងអភិរក្សវប្បធម៌ ដែលជាផ្នែកមួយនៃឫសគល់កំណើតខ្លួន ។ ក្រៅពីនោះ ជនជាតិចាមបានទទួលផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចតិចតួចណាស់ក្នុងការប្រើប្រាស់ភាសាចាម ។ ហេតុនេះហើយទើបយុវជនចាមដែលរស់នៅទីក្រុង មានការលំបាកក្នុងការរៀនភាសាចាម ។ នៅភូមិទ្រា ខេត្តកំពង់ចាម ស្ត្រីចាមជាច្រើនចេះនិយាយខ្មែរតិចតួច ឬមិនចេះនិយាយទាល់តែសោះ ពីព្រោះសហគមន៍នេះសង្កត់ធ្ងន់លើការលះបង់ចំពោះសាសនា ដើរតាមការបង្រៀនរបស់ តាប្ញីហ្គី ចាម៉ាត់ និងមានច្បាប់តឹងរ៉ឹង ចំពោះស្ត្រីក្នុងការទំនាក់ទំនងជាមួយអ្នកក្រៅ ។

ភាសាចាម នៅខេត្តបាត់ដំបងកំពុងតែរលាយបាត់បន្តិចម្តងៗ ។ អ្នកនិពន្ធបានជួបនឹងជនជាតិចាម ចំណាស់បីបួននាក់ នៅខេត្តបាត់ដំបង ដែលរៀបរាប់ថា ចាមភាគច្រើននៅក្នុងខេត្តនេះមិននិយាយភាសាចាមទាល់តែសោះ ។ ចាមនៅខេត្តនេះមានកំណើតមកពីខេត្តកំពង់ចាម និងតំបន់ផ្សេងៗទៀត ទៅទិសខាងកើត និងខេត្តចៅដុកប្រទេសវៀតណាមកាលពី២០០ឆ្នាំមុន ។ ពេលមកតាំងទីលំនៅនៅបាត់ដំបង កាលនោះខេត្តនេះមិនសូវមានជនជាតិចាមរស់នៅប៉ុន្មានទេ ។ ជនជាតិចាមរស់នៅលាយឡំគ្នានឹងប្រជាជនខ្មែរ ហេតុនេះក្មេងជំនាន់ក្រោយមិនអាចបន្តនិយាយភាសាចាមបានទេ ។ ក្រោយមកភាសានេះ ត្រូវរលាយបាត់លែងប្រើប្រាស់ ។ សព្វថ្ងៃ មូស្លីមដែលនិយាយភាសាចាមនៅខេត្តបាត់ដំបង គឺប្រជាជនចំណូលថ្មីដែលបានមករស់នៅខេត្តនេះតាំងពីសម័យខ្មែរក្រហម ចំណែកឯអ្នកស្រុកដើមលែង និយាយភាសាចាមយូរមកហើយ ។ ដោយសារចាមនៅបាត់ដំបង មិននិយាយភាសាចាមក្រុមនេះត្រូវប្រទ្បំថា ជាជនជាតិជ្វា ឬ ជ្វាគូ (Java Ku) អ្នកមានកំណើតពីប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ។

យោងតាម អ៊ីប ប្រូហ៊ីម (Ip Prohim) ដែលជា ទូន នៅខេត្តកំពត ប្រជាជនមូស្លីមនៅខេត្តកំពតប្រមាណជា២០ភាគរយនៅនិយាយភាសាចាម ។ មូស្លីមភាគច្រើននៅខេត្តនេះ ជាជនជាតិជ្វា ដែលមានចំនួនប្រមាណពី៦០ទៅ៧០ភាគរយនៃចំនួនប្រជាជនសរុប ។ អ៊ីប ប្រូហ៊ីម និយាយថា ចាមដែលមិនចេះនិយាយភាសាចាមច្រើនតែជាក្មេងៗជំនាន់ក្រោយ ដែលមិនដែលរៀនសូត្រភាសាចាមពីឪពុកម្តាយក្រោយឆ្នាំ១៩៧៩ មិនដែលរៀននៅសាលា

និងមិនដែលលើកទឹកចិត្តឲ្យនិយាយភាសាចាមនៅក្នុងសង្គមភូមិដែលខ្លួនរស់នៅ ឬភូមិផ្សេងៗទៀតនៅខេត្តកំពត ។

ពេលមានការជួបជុំពិធីសាសនានៅខេត្តកំពត ភាសាខ្មែរត្រូវបានប្រើប្រាស់នៅក្នុងការបង្រៀនសាសនា ។ ការអះអាងនេះស្របគ្នានឹងសម្តីរបស់ស្ត្រីជនជាតិជ្វាម្នាក់ដែលអ្នកនិពន្ធបានសម្ភាសន៍នៅភ្នំពេញ ដែលបាននិយាយថា ពេលអ្នកចូលរៀនជាជនជាតិចាម និងជ្វា ភាសាខ្មែរត្រូវបានប្រើប្រាស់ដើម្បីទំនាក់ទំនងគ្នានៅក្នុងក្រុម ។ ប្រជាជនជ្វានៅខេត្តកំពតនិយាយទាំងភាសាខ្មែរ និងពាក្យម៉ាឡេមួយចំនួន ។ ប្រជាជនទាំងនោះក៏ប្រើពាក្យមួយចំនួនជាភាសាចាមដើម្បីធ្វើការទំនាក់ទំនងគ្នាដែរ ។

### ៧) សម្លៀកបំពាក់ចាម

សម្លៀកបំពាក់ចាមបានទទួលឥទ្ធិពលពីសង្គមខ្មែរ និងពីសង្គមអ៊ីស្លាមនៅលើសកលលោក ។ ខុសគ្នាពីសម្លៀកបំពាក់ជនជាតិខ្មែរដែលទទួលឥទ្ធិពលពីប្រទេសឥណ្ឌា និងចិន សម្លៀកបំពាក់ចាមបានទទួលឥទ្ធិពលពីប្រទេសមជ្ឈិមបូព៌ា និងប្រទេសអ៊ីស្លាមមួយចំនួនតាមរយៈការអប់រំ ការបណ្តុះបណ្តាលផ្នែកសាសនា ការធ្វើធម្មយាត្រាទៅទីក្រុងម៉ាកាស និងតាមរយៈការធ្វើទំនាក់ទំនងជំនួញនៅប្រទេសទាំងអស់នោះ ។

### សម្លៀកបំពាក់សម្រាប់បុរស

សម្លៀកបំពាក់សម្រាប់បុរសជនជាតិចាមមិនមានអ្វីប្លែកពីបុរសមកពីក្រុមជាតិពន្ធផ្សេងៗនោះទេ ។ បុរសចាមស្លៀកសម្លៀកបំពាក់ប្រពៃណីចាម និងអ៊ីស្លាមពេលថ្វាយបង្គំ និងកម្មវិធីពិសេសផ្សេងៗ ។ សម្លៀកបំពាក់បុរសមានដូចជាវ៉ូបសាច់សូត្រវែងលុងកមូល ពណ៌ខ្មៅ ស និងប្រផេះ ។ បុរសចាមពាក់មួក ម្យ៉ាងហៅថា កន្ទឹប *(katip)* អ្នកស្រុកចាមហៅថា កាពី កាជិរ ដែលមានរូបរាង និងលម្អខុសៗគ្នា ។ បុរសខ្លះប្រើកន្សែងពណ៌សរុំក្បាលជំនួសឲ្យមួក ។ មួកក្រុមអ៊ីមាំសាន់ អាចមានទ្រង់ទ្រាយជាមួកអ៊ីស្លាម ឬប្រើក្រមាខ្មែររុំក្បាល ស្រដៀងគ្នាទៅនឹងរបៀបបុរស ឬស្ត្រីខ្មែររុំក្រមាក្បាល



ផ្សាររបស់សហគមន៍ចាម នៅភូមិទ្រា ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

*ដើម្បីទួលកញ្ច្រែង ។ លក្ខណៈពិសេសមួយទៀតរបស់បុរសចាមគឺ ថា បុរសៗដែលមាននាទីជា ទួន ហាគីម អ៊ីមាំ និងបុរសចាម ដែលជឿស៊ប់លើសាសនា ចូលចិត្តទុកពុកចង្កាវែង ។ បុរសចាមស្លៀករ៉ូបស ក្នុងពិធីបុណ្យសព ។ គាត់ស្លៀកសារ៉ុង ហើយពាក់អាវដៃវែងម្យ៉ាងហៅថា គូរ៉ុង (kourong) ពណ៌ ស ឬពណ៌ចម្រុះនៅថ្ងៃសុក្រ ពេលថ្វាយបង្គំ ពិធីចូលឆ្នាំ និងពិធីបុណ្យផ្សេងៗទៀត ។ ចំពោះបុរសដែលចូលចិត្តស្លៀករបៀបសាមញ្ញ គាត់ស្លៀកខោជាមួយនឹងគូរ៉ុង ។ បុរសចាមចំណាស់ដែលកាន់សីលដាប់លាប់ ស្លៀកខោរលុង ពណ៌ស ពាក់អាវ និងមួកកន្ទឹប ពេលថ្ងៃ និងក្នុងពិធីផ្សេងៗ ។*

## សម្លៀកបំពាក់សម្រាប់ស្ត្រី

*សម្លៀកបំពាក់ចាមសម្រាប់ស្ត្រីមានភាពប្លែកៗ និងសម្បូរបែបជាងបុរស ។ ពេលមានពិធីសំខាន់ៗ ដូចជា ពិធីបុណ្យសព រៀបការ ចូលឆ្នាំចាម បុណ្យបញ្ចប់រ៉ាម៉ាដាន និងបុណ្យម៉ាឡូត យើងសង្កេតឃើញយ៉ាងច្បាស់ ពីភាពប្លែកគ្នារវាងជនជាតិចាម និងជនជាតិដទៃទៀត ។ ពេលមានពិធីម្តងៗ ជនជាតិចាមមានសម្លៀកបំពាក់ប្រពៃណីច្បាស់លាស់ក្នុងការស្លៀកពាក់ ។ សម្លៀកបំពាក់ដែលគួរឲ្យចាប់អារម្មណ៍ជាងគេបំផុត គឺសម្លៀកបំពាក់ដែលចាមស្លៀកប្រចាំថ្ងៃ ។ សម្លៀកកបំពាក់ស្ត្រីចាមអាចចែកចេញជា ៤ក្រុម ផ្អែក ទៅតាមកម្រិតនៃការប្រតិបត្តិសាសនា ៖*

*ចាមដែលប្រតិបត្តិតឹងរ៉ឹងៈ ក្រុមនេះរួមមានស្ត្រីចាស់ៗ ដែលមានបំណងចង់ខិតកៀកនឹងព្រះអល់ឡោះ ហើយប្រណិប័តន៍ច្បាប់អ៊ីស្លាមយ៉ាងតឹងរ៉ឹង ។ នារីក្មេងៗជួនកាលត្រូវបានតម្រូវឲ្យស្លៀកសម្លៀកបំពាក់ដែលបិទបាំងសម្រស់ពីភ្នែកបុរសៗ និងជួនកាលទៀតស្លៀកពាក់បិទបាំងភាពអាក្រក់របស់ខ្លួនពីចំណាប់អារម្មណ៍បុរស ។ សម្លៀកបំពាក់សម្រាប់ក្រុមនេះមានដូចជា អាវផាយវែងពណ៌ខ្មៅ ជាភាសាអារ៉ាប់ ហៅថា ជីលបាប់ (jilbab) ។ ចំណែកឯក្បាលវិញ ត្រូវគ្របដោយកន្សែងពណ៌ខ្មៅដើម្បីបិទបាំងសក់ (ស្ត្រីភាគច្រើនទុកសក់វែង) ។ កន្សែងគ្របក្បាលនេះហៅថា ហែចាប់ (hijab) ជាភាសាអារ៉ាប់ ។ ចុងក្រោយគឺ កន្សែងគ្របមុខ (នីកាប់ និឆាប) ។ ស្ត្រីក្រុមនេះរស់នៅភូមិមួយចំនួនដូចជា ភូមិទ្រា ខេត្តកំពង់ចាម តំបន់ខ្លះទៀតនៅខេត្តកំពត ភូមិព្រែកប្រាភាគអាគ្នេយ៍ទីក្រុងភ្នំពេញ ភូមិមួយចំនួននៅខេត្ត បាត់ដំបង និងភូមិនេសាទចាមនៅខេត្តកំពង់ឆ្នាំង ។ ពេលថ្វាយបង្គំ ស្ត្រីទាំងនេះ ស្លៀករ៉ូបពណ៌ស ហើយរុំក្បាលជាមួយនឹងកន្សែង ទុកតែមុខចេញក្រៅ ។*

*ចាមដែលប្រណិប័តន៍មិនសូវជាតឹងរ៉ឹងៈ ស្ត្រីនៅក្នុងក្រុមនេះច្រើនជាស្ត្រីដែលរស់នៅទីក្រុងហើយមានទំនាក់ទំនងជាមួយក្រុមជនជាតិផ្សេងៗ ។ ក្រុមនេះគ្មានក្បួនសម្លៀកបំពាក់ ដែលត្រូវស្លៀកពាក់តាមនោះទេ តែពាក់កន្សែងក្បាលដែលមានរចនាប្លែកៗ ដើម្បីសម្គាល់ ។ ជាទូទៅកន្សែងគ្របក្បាល មានពណ៌ខ្មៅ និងមានលម្អដោយអង្កាំនៅជាយៗ ។ អាវ ខោ និងរ៉ូបដែលស្ត្រីនៅក្នុងជំពូកនេះស្លៀកពាក់ ឃើញមាន ក្រុមជនជាតិផ្សេងៗស្លៀកពាក់ដែរ ។ ការស្លៀកពាក់ពីលើដល់ក្រោម គ្មានខុសប្លែកពីសម្លៀកបំពាក់ក្រុមជនជាតិផ្សេងទេ លើកលែងតែគ្រឿងអលង្ការដែលមានក្បាច់រចនា និងពណ៌ស្រដៀងនឹងអលង្ការប្រពៃណីអារ៉ាប់ ។ ស្ត្រីមកពីក្រុមនេះទៅរៀន និងធ្វើការលាយឡំជាមួយក្រុមជនជាតិដទៃដែរ ។ ស្ត្រីទាំងនេះ ស្លៀកឯកសណ្ឋានទៅធ្វើការ ព្រមទាំងគ្របកន្សែងក្បាល ។ នៅឆ្នាំ២០០៨ សាលារៀនរដ្ឋនៅកម្ពុជា បានអនុញ្ញាតឲ្យសិស្សមូស្លីមពាក់កន្សែងគ្របក្បាលជាមួយនឹងឯកសណ្ឋានសាលា ។*

*ចាមដែលស្លៀកពាក់ត្រឹមត្រូវៈ ក្រុមនេះបង្ហាញពីចំណង់ចំណូលចិត្ត និងចរិតលក្ខណៈរបស់ស្ត្រីចាមក្នុងការស្លៀកពាក់ ។ សម្លៀកបំពាក់ក្រុមទីមួយឆ្លុះបញ្ចាំងពីការស្លៀកពាក់បែបអ៊ីស្លាម ។ ប្រពៃណីនៃការស្លៀកពាក់បែបនេះ ហាក់ដូចជាជ្រាបទៅក្រុមផ្សេងៗតិចតួចណាស់ ។ ជាទូទៅ ស្ត្រីចាមមួយចំនួនបាន និយាយថា ពេលខ្លះគាត់ត្រូវចាស់ៗឲ្យស្លៀកពាក់ឲ្យត្រឹមត្រូវតាមក្បួនខ្នាតដែលសម្លៀកបំពាក់នោះមាន ដូចជា ខោជើងវែង អាវដៃវែង រ៉ូប និងអាវដែលគ្របខ្លួនជិត ។*

*ស្ត្រីនៅក្នុងក្រុមនេះមិនសូវជាប្រណិប័តន៍សាសនាតឹងរ៉ឹងដូចស្ត្រីអំពីជំពូកខាងលើទេ ពីព្រោះស្ត្រីក្រុមនេះមិនពាក់កន្សែងក្បាលទេភាគច្រើន ។ ប្រសិនបើពាក់ គាត់ច្រើនពាក់តែកន្សែងធម្មតាដែលនៅតែទុកសក់ឲ្យឃើញដដែល ។ ស្ត្រីមកពីក្រុមនេះ ច្រើនមានទំនាក់ទំនងជាមួយប្រជាជនដែលមិនមែនជនជាតិមូស្លីម ច្រើនជាងស្ត្រីមកពីក្រុមពីរខាងលើ ហើយគាត់មកពីសហគមន៍ដែលមានជនជាតិផ្សេងៗរស់នៅចម្រុះ ។*

**អេង កុកថាយ**

# ប្រវត្តិសាស្ត្រដែលមិនអាចបដិសេធ និងបំភ្លេចបាន

មុនឆ្នាំ១៩៧០ ប្រទេសកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជារស់នៅប្រកបដោយសុខសន្តិភាព និងមានការរីកចម្រើនស្ទើរគ្រប់វិស័យ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់អតីតព្រះមហាក្សត្រ ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ។ ប៉ុន្តែ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ ប្រជាជាតិកម្ពុជាទាំងមូលបានធ្លាក់ទៅក្នុងភ្លើងសង្គ្រាមយ៉ាងសន្ធោសន្ធៅ ។



កងយោធាខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ ដើម្បីផ្តួលរំលំរបប លន់ នល់ នៅខែមេសា ឆ្នាំ១៩៧៥

អ្នកដែលទទួលរងគ្រោះខ្លាំងជាងគេនាពេលនោះ គឺបងប្អូនប្រជាជនដែលរស់នៅជនបទ ចុងកាត់មាត់ញក ។ គ្រាប់បែកប្រមាណកន្លះលានតោន ត្រូវបានទម្លាក់លើដែនដីដ៏តូចមួយនេះពីសំណាក់អាមេរិកាំង ធ្វើឲ្យប្រជាជនខ្មែរជាច្រើនពាន់នាក់បានស្លាប់ ពិការ និងបាត់បង់ផ្ទះសម្បែង ។ ដោយមានការឈឺចាប់នឹងទង្វើទាំងអស់នេះ និងជាពិសេស មានការអំពាវនាវរបស់សម្តេចឪឲ្យបងប្អូនកូនចៅទាំងអស់ចូលព្រៃម៉ាកគី ធ្វើការតស៊ូជាមួយចលនាខ្មែរក្រហមដើម្បីផ្តួលរំលំរបបសាធារណរដ្ឋរបស់លន់ នល់ ទើបប្រជាជនជាច្រើនដែលខឹងសម្បារនឹងការទម្លាក់គ្រាប់បែក និងការបាត់បង់ជីវិតសមាជិកគ្រួសាររបស់ខ្លួននោះ បានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហមជាបន្តបន្ទាប់ ហើយចំនួននៃកងទ័ពខ្មែរក្រហមក៏កើនឡើងជាលំដាប់ដែរ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងរបស់ខ្មែរក្រហម បានទទួលជ័យជម្នះទាំងស្រុងលើរបបសាធារណរដ្ឋរបស់ លន់ នល់ ។ ប្រជាជនកម្ពុជាម្នាក់ៗរីករាយនឹងជ័យជម្នះមួយនេះខ្លាំងណាស់ ហើយនឹកស្មានថា ប្រទេសរបស់ខ្លួននឹងបានសុខសន្តិភាពជាក់ជាមិនខាន ។ ម្នាក់ៗមានទឹកមុខរីករាយនិងរត់ចេញទៅទទួលស្វាគមន៍នូវវត្តមានរបស់កងទ័ពរំដោះខ្មែរក្រហមដោយមោទកភាព ។ ប៉ុន្តែ មិនបានប៉ុន្មានផង ភាពរីករាយពោរពេញដោយក្តីសង្ឃឹមនេះ ត្រូវរលាយសាបសូន្យទៅវិញ ដោយជំនួសមកវិញនូវភាពស្រឡាំងកាំង រន្ធត់ភ័យខ្លាច បន្ទាប់ពីពួកការប្រកាសបង្ខំឲ្យប្រជាជនទាំងអស់ ចាកចេញពីផ្ទះចំនួនបីថ្ងៃសិន ក្រោមហេតុផលថា បោសសម្អាតខ្មាំងដែលនៅសេសសល់ និងខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក ។ អំឡុងពេលនោះប្រជាជនជាច្រើនបានស្លាប់ និងបែកបាក់គ្រួសារ ហើយអ្នកដែលប្រកែកមិនព្រមចាកចេញត្រូវបាញ់សម្លាប់ភ្លាមៗ ។ ខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជនខ្លួនចាប់តាំងពីថ្ងៃដំបូងនៃជ័យជម្នះរបស់ខ្លួនម៉្លេះ ។ របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម បានឆក់យកសិទ្ធិសេរីភាពនិងភាពជាមនុស្សរបស់ប្រជាជន ។ ជាក់ស្តែងនៅក្នុងចំណុចមួយនៅក្នុងរឿងទណ្ឌិតដៃល្អោ ជារឿងពិតមួយរបស់អ្នករស់រានជីវិត

ពីរបបខ្មែរក្រហម ដែលផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិត បានលើកថា កម្មាភិបាលខ្មែរក្រហម បានភ្ជាល់គ្នាបាញ់ចម្ពាម កៅស៊ូលើអ្នកទោសម្នាក់ត្រូវអ្នកយាមនោះបាញ់ចំក្បាលដួលផ្កាប់មុខនឹងដី ហើយអ្នកយាមនោះនិយាយថា "ក្បាលរបស់ពួកវាមានតម្លៃ មិនស្មើនឹងខ្សៀវអាវរបស់ខ្លួនមួយផង" ។

ប្រជាជនខ្មែរត្រូវក្លាយខ្លួនជាទាសករក្នុងគុកឥតជញ្ជាំងរបស់អង្គការ ប៉ុល ពត ។ ខ្មែរក្រហមបានប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដ៏ស្រស់ស្អាត និងមានវប្បធម៌រុងរឿងរបស់ខ្លួនទៅជាវាលពិឃាត ជាទន្លេឈាម និងភ្នំឆ្អឹង ក្រោមទុក្ខវេទនារបស់ប្រជាជនរាប់លាននាក់ ។ វប្បធម៌ សាសនា ទំនៀមទម្លាប់ប្រពៃណីដ៏ល្អផូរផង់របស់ជាតិ ត្រូវខ្មែរក្រហមបំផ្លាញខ្ទេចខ្ទីដល់ឫសគល់ ។ តែរយៈពេលជាងបីឆ្នាំសោះ ប្រជាជនជាងពីរលាននាក់ត្រូវស្លាប់ដោយការអត់ឃ្លាន ជំងឺ ធ្វើការហួសកម្លាំង និងសម្លាប់ ។ អំឡុងឆ្នាំ១៩៧៧ និង១៩៧៨ ក៏មានការធ្វើបន្សុទ្ធកម្មទ្រង់ទ្រាយធំមួយក្នុងជួរកម្មាភិបាលខ្មែរក្រហម ជាពិសេសទៅលើកម្មាភិបាល និងប្រជាជនភូមិភាគបូព៌ា ដោយអង្គការចោទថា អ្នកទាំងនោះ បានចូលដៃជាមួយវៀតណាម ដើម្បីផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក ការរើបម្រះ ការប្រឆាំងតបតជាមួយអង្គការខ្មែរក្រហម បានកើតឡើងជាបន្តបន្ទាប់ ជាពិសេស ចលនាបះបោរទ្រង់ទ្រាយធំរបស់ភូមិភាគបូព៌ានេះតែម្តង ។ ប្រជាជន និងកម្មាភិបាលខ្មែរក្រហមរាប់ពាន់នាក់ បានភៀសខ្លួន ទៅប្រទេសវៀតណាម និងឡាវ ហើយក៏បានបង្កើតកម្លាំងបដិវត្តន៍ដ៏ខ្លាំងក្លាមួយ ព្រមទាំងបានឯកភាពគ្នាបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ។ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានេះ មានការគាំទ្រពីប្រជាជនគ្រប់ទិសទី និងជាពិសេសនោះ គឺទទួលការជួយឧបត្ថម្ភពីសំណាក់កងទ័ពស្ម័គ្រចិត្តវៀតណាម ។ ដោយមានកម្លាំងគាំទ្រពីកងទ័ពស្ម័គ្រចិត្តវៀតណាម កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយបក និងទទួលជ័យជម្នះលើកងទ័ពកម្ពុជាប្រជាធិបតេយ្យជាបន្តបន្ទាប់រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាត្រូវបានរំដោះជាស្ថាពរ ។

ជ័យជម្នះ ៧មករា បានបិទទំព័រសករាជដ៏ខ្មៅងងឹត និងបើកទំព័រសករាជថ្មីឡើងវិញ ទោះបីជា ប្រជាជាតិ ប្រជាជនទាំងអស់ត្រូវចាប់ផ្តើមកសាងជីវិត ប្រទេស និងជីវភាពរបស់ខ្លួន ដោយបានដៃទទេ និងពីចំណុចសូន្យក៏ដោយ តែប្រជាជនកម្ពុជា បានទាមទារមកវិញនូវសិទ្ធិសេរីភាព និងភាពជាម្ចាស់លើវាសនារបស់ខ្លួនឡើងវិញ ។ ផ្តើមចេញពីថ្ងៃជ័យជម្នះនេះ ប្រទេសកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជា ខិតខំតស៊ូប្រឹងប្រែងផ្លាស់ប្តូរកម្ពុជា ពីប្រទេសដែលសល់តែគំនរផេះផង់ ស្លាកស្នាមនៃសង្គ្រាម និងទឹកភ្នែកនៃទុក្ខវេទនារបស់ប្រជាជនខ្មែរ ក្លាយមកជាប្រទេសដែលកំពុងមានការអភិវឌ្ឍគួរឲ្យកត់សម្គាល់ ដែលប្រកបដោយសន្តិភាព អធិបតេយ្យភាព និងនីតិរដ្ឋ ។

តែទោះជាយ៉ាងនេះក្តី បច្ចុប្បន្ន ក៏នៅមានមនុស្ស និងអ្នកនយោបាយមួយចំនួន បានបដិសេធមិនទទួលស្គាល់នូវថ្ងៃជ័យជម្នះមួយនេះ ដោយចាត់ទុកថា ថ្ងៃទី៧ មករា ១៩៧៩នេះ គឺជារឿងនយោបាយ និងជាថ្ងៃដែលវៀតណាមចូលឈ្លានពាន វាតទីទឹកដីកម្ពុជា ។ ទាំងនេះ គឺគ្រាន់តែជាទស្សនៈយល់ឃើញរបស់អ្នកទាំងនោះប៉ុណ្ណោះ ។ តែអ្វីដែលសំខាន់នោះគឺ អ្នកទាំងនោះ មិនអាចប្រកែក ឬមិនទទួលស្គាល់ថា គ្មានរបបប្រល័យពូជសាសន៍លើទឹកដីកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជានោះឡើយ ។ តាមរយៈជនរងគ្រោះរាប់ពាន់នាក់ ដែលរួចរស់ជីវិតពីរបបខ្មែរក្រហម និងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាភស្តុតាងគ្រប់គ្រាន់ដែលសរបញ្ជាក់ថា ពិតជាមានរបបប្រល័យពូជសាសន៍ខ្មែរក្រហមយ៉ាងពិតប្រាកដ ជាពិសេស គឺអតីតមេដឹកនាំខ្មែរក្រហមទាំងនោះ ក៏ត្រូវបាននឹងកំពុងធ្វើការកាត់ទោសនៅតុលាការខ្មែរក្រហមបច្ចុប្បន្នដែរ ។ ការបដិសេធថាគ្មានរបបខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា គឺជាការប្រមាថយ៉ាងធ្ងន់លើជនរងគ្រោះជាងពីរលាននាក់ដែលបានបាត់បង់ជីវិត និងជនរងគ្រោះដែលរួចរស់ជីវិតពីរបបខ្មែរក្រហមនេះដែរ ។

ដូចនេះ ក្នុងនាមយើងជាអ្នកជំនាន់ក្រោយ ក៏ដូចជាមេដឹកនាំជំនាន់ក្រោយ ត្រូវតែសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្បាស់លាស់ ។ យើងមិនអាចបំភ្លេចរបបយង់ឃ្នងកាលពីអតីតកាលមួយនេះបានទេ តែយើងម្នាក់ៗត្រូវតែសិក្សា ដើម្បីជាបទពិសោធសម្រាប់ខ្លួន និងព្យាយាមទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍នេះ កើតឡើងនៅប្រទេសរបស់ខ្លួនម្តងទៀត ។

**ឆាវ សារៈមុនិន្ទ**

# សវនាការស្តីពីសេចក្តីថ្លែងបើកសំណុំរឿង០០២ ដំណាក់កាលទី២ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤

**(តចប់)**

**ខ) មន្ទីរសន្តិសុខ**

ទាក់ទងនឹងមន្ទីរសន្តិសុខ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានយកទីតាំងនៅក្នុងវត្តបារាយណ៍ជាន់ដែក ធ្វើជាមន្ទីរសន្តិសុខ ។ នៅក្នុងមន្ទីរសន្តិសុខនេះមានពលករជាច្រើននៅទំនប់១មករាត្រូវបានចាប់ខ្លួន ហើយយកមកដាក់នៅទីនេះហើយសម្លាប់ចោល ។ បន្ទាប់ពីខ្មែរក្រហមបានបញ្ចប់ បានបន្សល់ទុកនូវសាកសពដែលនៅសេសសល់ និងជីករកឃើញនៅក្នុងវត្តបារាយណ៍ជាន់ដែក គឺសាកសពមនុស្សរាប់ពាន់នាក់ដែលត្រូវបានស្លាប់នៅក្នុងការដ្ឋាននេះ ។

ចំណែកឯការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ស្ថិតនៅក្រោមប្រតិបត្តិការរបស់កងពលធំលេខ៥០២ របស់កងទ័ពបដិវត្តន៍កម្ពុជា ។ ការដ្ឋាននេះគឺជាការដ្ឋានលត់ដំ ដែលត្រូវបានប្រើប្រាស់ដើម្បី ពង្រឹងវិស័យកងទ័ពដែលចេញពីបណ្តាកងទ័ពនានា ដែលត្រូវបានបោសសម្អាត ឬអ្នកដែលត្រូវបានចាត់ទុកថា ជាជនសង្ស័យដោយសារតែប្រវត្តិរូប ឬទំនាក់ទំនងផ្ទាល់ខ្លួន ។ ការដ្ឋាននេះគឺជាគម្រោងការងារដែលត្រូវបានផ្តួចផ្តើមឡើង និងត្រួតពិនិត្យដោយគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវបានពិភាក្សាជាប្រចាំនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលនួន ជា និងខៀវ សំផន បានចូលរួម ។

ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអូរកន្សែង ក្នុងខេត្តរតនគិរី នៅមន្ទីរសន្តិសុខភ្នំក្រោល ក្នុងខេត្តមណ្ឌលគិរី និងនៅមន្ទីរស-២១ ទោះបីជានៅតាមមន្ទីរនីមួយៗខាងលើនេះមិនមានទំហំធំដូចនៅមន្ទីរស-២១ ក៏ដោយ ប៉ុន្តែគុកក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោលក៏ជាសារសំខាន់ ចំពោះសំណុំរឿងនេះដែរ ។ ដោយសារតែមាន ភ័ស្តុតាងភ្ជាប់បទឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅគុកទាំងនេះ ជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅទីក្រុងភ្នំពេញ ។ អូរកន្សែង គឺជាពន្ធនាគារយោធាជាមន្ទីរអប់រំកែប្រែរបស់កងពលធំលេខ៨០១ របស់កងទ័ពបដិវត្តន៍កម្ពុជាដែលមានមូលដ្ឋាននៅក្នុងខេត្តរតនគិរី ។ ភ័ស្តុតាងដែលត្រូវបង្ហាញពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនេះ នឹងផ្តោតសំខាន់ទៅលើការសម្លាប់ជាទ្រង់ទ្រាយធំនូវបុរសស្ត្រី និងកុមារជនជាតិចារាយមកពីវៀតណាមដែលត្រូវបានចាប់ខ្លួនដោយកងពលធំលេខ៨០១ ។ ការសម្លាប់នេះត្រូវបានរៀបរាប់ដោយប្រធាន និងអនុប្រធានគុកអូរកន្សែង ព្រមទាំងអ្នកជាប់ឃុំឃាំងដែលនៅរស់រានមានជីវិតពីគុកអូរកន្សែង ។

ប្រធាន និងអនុប្រធានគុកអូរកន្សែងទទួលស្គាល់ថា មានការប្រើប្រាស់ទារុណកម្ម រួមទាំងការវាយដំដោយប្រើដំបង ឬខ្សែរំពាត់ដោយការឆក់ខ្សែភ្លើង ។ អ្នកទាំងពីរបានពិពណ៌នាអំពីការសម្លាប់ អ្នកទោសនៅក្បែររណ្តៅបេ៥២ នៅទីតាំងជិតៗគុក និងពិពណ៌នាអំពីវិធីដែលកងទ័ព ត្រូវបានចាប់ខ្លួននៅអូរកន្សែង ផ្អែកតាមចម្លើយសារភាពនៅស-២១ ដែលបានផ្ញើមកពីទីក្រុងភ្នំពេញ និងបានឆ្លើយដាក់កម្មាភិបាលទាំងនោះថា ជាផ្នែកមួយនៃខ្មាំង ។

ភ័ស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខនេះ រួមមានរបាយការណ៍ ឬទូរលេខដែលលេខាកងពល៨០១ បានបញ្ជូនទៅសុន សេន ក្នុងនោះលេខារូបនោះបានប្តេជ្ញាគោរពតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការចាប់ខ្លួនអ្នកសង្ស័យថាខ្មាំង និងអ្នកណាប្រឆាំងនឹងមាគ៌ាបក្ស ។ សហព្រះរាជអាជ្ញា ជា លាង បានបង្ហាញថា ការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត និងឧក្រិដ្ឋកម្មផ្សេងទៀតដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខអូរកន្សែង ត្រូវបានប្រព្រឹត្តឡើងជាមួយនឹងការដឹងឮ និងស្របតាមគោលនយោបាយ និងការណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញ ។ ករណីនេះដូចគ្នានឹងភ្នំក្រោលដែរ ភ្នំក្រោលគឺជាមន្ទីរសន្តិសុខរបស់តំបន់១០៥ ជាតំបន់ស្វយ័តមួយនៅក្នុងខេត្តមណ្ឌលគិរី ដែលធ្វើការរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការអចិន្ត្រៃយនៃបក្សកុម្មុយនីស្តកម្ពុជា ។

ការស្លាប់សក្ខីកម្ម២រូប ឈ្មោះ សរ សារុន និង ខាំ ផាន់

◆ សក្ខីកម្មទី១ ឈ្មោះ សរ សារុន អតីតលេខាតំបន់១០៥ បានពិពណ៌នាថា គាត់បានធ្វើដំណើរទៀងទាត់ទៅកាន់ភ្នំពេញ ដើម្បីរាយការណ៍ជូនមេដឹកនាំមជ្ឈិមបក្សរួមមាន ប៉ុល ពត, នួន ជា និង ខៀវ សំផន ។ គាត់បានផ្តល់សក្ខីកម្មថា មេដឹកនាំបក្សកម្មុយនីស្តកម្ពុជា នៅភ្នំពេញជាអ្នកធ្វើសេចក្តីសម្រេចទាក់ទងខ្លាំងនយោបាយ ដែលចាប់ខ្លួនបាននៅក្នុងតំបន់របស់គាត់ ។ ឧទាហរណ៍ៈ អ្នកដែលបានចោទថា ក្បត់បក្ស ឬសហការជាមួយនឹងយួន ។

◆ សក្ខីកម្មទី២ ឈ្មោះ ខាំ ផាន់ក្នុងការជំនុំជម្រះលើកទី១ ខាំ ផាន់ គឺជាកម្មាភិបាលម្នាក់ដែលធ្វើការនៅក្នុងមន្ទីរទូរលេខរបស់តំបន់១០៥ និងជាកូនប្រុសរបស់លេខាតំបន់នេះមុន សោ សារុន ។ ខាំ ផាន់ បានពិព័ណ៌នាអំពីវិធីដែលតួលេខទាក់ទងនឹងបញ្ហាសន្តិសុខ ត្រូវបានបញ្ជូនទៅនួន ជា និងវិធីដែលតួលេខទាំងនេះ ត្រូវបានទទួលមកពី នួន ជា ដែលបានកោះហៅកម្មាភិបាលឲ្យទៅក្រុងភ្នំពេញ ។ សក្ខីកម្មរបស់សាក្សីទាំងនេះទាក់ទងនឹងអំណាចរបស់មេដឹកនាំមជ្ឈិមបក្ស ។ តំបន់១០៥ ស៊ីសង្វាក់ជាមួយនឹងសេចក្តីសម្រេចរបស់គណៈកម្មការមជ្ឈិមបក្សចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ស្តីពីសិទ្ធិកម្ទេចនៅក្នុង និងក្រៅជួរ ។ សេចក្តីសម្រេចនេះលើកឡើងថា សម្រាប់តំបន់ឯករាជ្យដូចជា តំបន់១០៥ សេចក្តីសម្រេចកម្ទេចត្រូវធ្វើឡើងដោយគណៈកម្មការអចិន្ត្រៃយ៍ ។ សហព្រះរាជអាជ្ញា បានបង្ហាញថា គណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា អ្នកទទួលខុសត្រូវផ្ទាល់លើការ សម្លាប់នៅលើមន្ទីរសន្តិសុខភ្នំក្រោល ។

ទូរលេខចុះខែសីហា ឆ្នាំ១៩៧៧ ដែលមានលេខាតំបន់១០៥ ឈ្មោះ ឡាំង ឪពុករបស់សាក្សី ខាំ ផាន់ បានបញ្ជូនទៅមន្ទីរ៨៧០ បានរាយការណ៍អំពីការចាប់ខ្លួនមនុស្ស៣នាក់ដែលបានរត់គេចមកពីស្ទឹងត្រែង ដែលគេជឿជាក់ថាជាខ្មាំង ។ ទូរលេខនេះស្នើសុំសេចក្តីសម្រេចមជ្ឈិមបក្សថា “តើត្រូវបោសសម្អាតពួកគេនៅទីនេះ ឬបញ្ជូនពួកគេទៅកាន់ភូមិភាគឦសាន” ។ ទូរលេខមួយនេះដែលបានផ្ញើមកពីលេខាតំបន់ សោ សារុន បានរាយការណ៍អំពីការចាប់ខ្លួនបុរស និងស្ត្រីដែលធ្វើខុសសីលធម៌ ។ ទូរលេខនេះបានលើកឡើងថា “មិត្តនេះ កាលមុនមានជាប់ចម្លើយពួកក្បត់ អាជួន ក្នុងតំបន់ ពេលនោះនៅតាមដានសកម្មភាពវាថែមទៀត តែឥឡូវនេះវាបានប៉ះពាល់សីលធម៌យ៉ាងនេះ បានចាប់ឃុំឃាំងទុកហើយ” ។ ទូរលេខនេះបានស្នើសុំមតិយោបល់ថា តើត្រូវធ្វើអ្វីចំពោះអ្នកទោសដែលបានបញ្ជូនទៅ “អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន មន្ទីរឯកសារ” ។

នៅក្នុងការស្លាប់ភ័ស្តុតាងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខរបស់តំបន់១០៥ ដែលបានកើតចេញពីលទ្ធផលនៃគោលនយោបាយ និងការណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។

ការជំនុំជម្រះពីមន្ទីរសន្តិសុខនឹងរួមបញ្ចូលទាំងមន្ទីរស-២១ ដែលជាគុកថ្នាក់ខ្ពស់បំផុតមួយ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ស-២១ គឺជាមន្ទីរសន្តិសុខមួយ ដែលស្ថិតនៅក្នុងក្រុងភ្នំពេញ ដែលបានរាយការណ៍ជូនមជ្ឈិមបក្ស ព្រមទាំងជាមន្ទីរសន្តិសុខដែល នួន ជា មើលការខុសត្រូវផ្ទាល់ នៅក្នុងអំឡុងចុងឆ្នាំក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាមន្ទីរសន្តិសុខដែលមានមនុស្សជាង១២.០០០នាក់ ត្រូវបានសម្លាប់នៅទីនោះក្នុងរយៈពេល៣ឆ្នាំ ។ ឧក្រិដ្ឋកម្មនានាបានប្រព្រឹត្តឡើងនៅ ស-២១ ត្រូវបានកត់ត្រាទុកនៅក្នុងឯកសារយ៉ាងហ្មត់ចត់ ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលធ្លាប់ធ្វើការនៅទីនោះ ហើយឧក្រិដ្ឋកម្មទាំងនេះ គ្មានអ្វីអាចជំទាស់តវ៉ាបាន ឧក្រិដ្ឋកម្មនេះបានបង្ហាញតាមរយៈប្រវត្តិរូបរបស់អ្នកទោស រូបថត និងបញ្ជីត្រូវបានរៀបចំឡើងក្រោយពេលអ្នកទោសមកដល់ស-២១ ។ ឧក្រិដ្ឋកម្មទាំងនេះ បានបង្ហាញតាមរយៈស្ទួរចម្លើយ របាយការណ៍ដែលបានរៀបរាប់ឡើងដោយបុគ្គលិកស-២១ ដែលពិពណ៌នាអំពីការប្រើប្រាស់ទារុណកម្ម និងចម្លើយសារភាពជាច្រើនទំព័រដែលបានកើតឡើងចេញពីការធ្វើទារុណកម្មជាច្រើនសប្តាហ៍ ឬច្រើនខែ ដែលចម្លើយសារភាពជាច្រើនទាំងនេះមានចំណារបញ្ជាអំពីវិធីដែលចម្លើយទាំងនេះបានបញ្ជូនទៅសុន សេន, នួន ជា និងមេដឹកនាំបក្សកុម្មុយនីស្តផ្សេងទៀត ។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅស-២១ ត្រូវបានបង្ហាញតាមរយៈបញ្ជីអ្នកទោស ដែលត្រូវសម្លាប់ចោល និងមានចំណារតបពីអគ្គការថា ឯកភាពក្នុងការសម្លាប់ ។ បញ្ជីស-២១នេះ កត់ត្រាការសម្លាប់អ្នកទោសចំនួន១៧៣នាក់ ក្នុងមួយថ្ងៃៗពីភូមិភាគឧត្តរ នាថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៧ ។ ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានបង្ហាញតាមរយៈសក្ខីកម្មលម្អិតដែលបានផ្តល់ដោយអ្នកជាប់ឃុំឃាំង អ្នកយាម និងអ្នកសួរចម្លើយមួយចំនួនតូច

ដែលរស់ នៅមានជីវិត និងធ្លាប់ធ្វើការនៅទីនោះ នៅស-២១ និងបានផ្តល់ឲ្យដោយប្រធានគុកឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានបង្ហាញតាមឆ្អឹងមនុស្សដែលនៅសេសសល់ក្រោយ ការជីកកាយពីរណ្តៅរួមនៅជើងឯក ។ រណ្តៅរួមទាំងនេះនៅសល់ស្លាកស្នាមរហូតមកដល់សព្វថ្ងៃ ។ ជាពិសេសឯកសារមួយបានបង្ហាញនូវព័ត៌មានលម្អិតគួរឲ្យព្រឺក្បាលអំពីបទពិសោធរបស់ជនរងគ្រោះ ដែលធ្លាប់ត្រូវបានជាប់ឃុំ និងសួរចម្លើយនៅមន្ទីរសន្តិសុខរបស់មជ្ឈិមបក្ស នេះជារបាយការណ៍មួយដែលសរសេរឡើងដោយកម្មាភិបាលឃុំម្នាក់នៅស-២១ ដែលពិពណ៌នាអំពីការសួរចម្លើយលេខាតំបន់ម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា ឈ្មោះ កែ គឹមហួត ។ រយៈពេលបីថ្ងៃរបាយការណ៍នេះ ឆ្លើយថា ថ្ងៃដំបូង ទារុណកម្មដោយប្រើកម្លាំងបាយ ខ្លះត្រូវបានប្រើប្រាស់ ហើយអ្នកទោសសន្លប់បាត់ស្មារតី ២ថ្ងៃក្រោយមកគាត់ត្រូវបានវាយសំពងម្តងទៀត ហើយសុខភាពរបស់គាត់បានចុះខ្សោយៗទៅ ប៉ុន្តែគាត់នៅបន្តឆ្លើយថា គាត់មិនមែនជាជនក្បត់នោះទេ រសៀលស្អែកឡើង អ្នកទោសរូបនេះ ត្រូវបានវាយដំម្តងទៀត ហើយត្រូវបានឆក់ខ្សែភ្លើង និងឲ្យស៊ីអាចម៍ ពីរបីស្លាបព្រាពេញៗ ។

កម្មាភិបាលខ្មែរក្រហមនៅមន្ទីរ ស-២១ បានធ្វើទារុណកម្មទៅលើ កែ គឹមមហួត ដោយឆក់ខ្សែភ្លើង ការធ្វើទារុណកម្មម្តងនេះមានសភាពធ្ងន់ធ្ងរ ដែលធ្វើឲ្យអ្នកទោសរូបនេះរវើរវាយ និងបានឆ្លើយសារភាពបន្តិច ។ ទោះបីជារងទារុណកម្មគួរឲ្យខ្លោចផ្សាក៏ដោយក៏ កែ គឹមហួត នៅតែប្រាប់អ្នកសួរចម្លើយថា “គាត់នឹងបិទភ្នែករង់ចាំសេចក្តីស្លាប់” អ្នកសួរចម្លើយនៅមន្ទីរស-២១ បញ្ចប់របាយការណ៍ខ្លួនដោយសរសេរថា មាគ៌ាអនុវត្តន៍របស់ខ្លួនគឺ បន្តធ្វើទារុណកម្មដោយម្ចាស់ការពីព្រោះ ខ្មាំងកំពុងបាក់ស្មារតី និងស្លាប់រហូតដល់ទីបញ្ចប់ ។ អ្នកសួរចម្លើយរូបនេះស្នើសុំមតិយោបល់ និងការណែនាំពីអង្គការក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។ ឯកសារមួយនេះ បានបង្ហាញអំពីភាពគួរឲ្យតក់ស្លុតនៅមន្ទីរស-២១ ហើយជាវិធីដែលបក្សកុម្មុយនីស្តកម្ពុជា បានធ្វើមកលើមេដឹកនាំរបស់ខ្លួនម្នាក់ ដែលបានចូលបដិវត្តន៍ក្នុងឆ្នាំ១៩៦៧ ។

**ក) ការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះបទឧក្រិដ្ឋកម្ម**

**១) ឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ**

ទោះបីជាបុរស និងស្ត្រីកម្ពុជាត្រូវបានរងគ្រោះដោយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ផលវិបាកភាគច្រើនកើតឡើងលើស្ត្រីនៅទូទាំងប្រទេសកម្ពុជាទាំងមូល ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាទម្រង់មួយនៃការធ្វើទារុណកម្មប្រចាំថ្ងៃ ពោលគឺការដាក់ឲ្យទៅជាទាសករជាមួយនឹងអ្នកពុំធ្លាប់ស្គាល់ និងពុំដែលស្រលាញ់ ។ ការដាក់ឲ្យទៅទទួលនូវការបំពារបំពាន និងការរំលោភសេពសន្ថវៈ ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាឧទាហរណ៍មួយទៀត នៃរបបខ្មែរក្រហមដែលបានប្រើប្រាស់អំណាចធ្វើជាម្ចាស់កម្មសិទ្ធិលើមនុស្ស ពោលគឺ ការចាត់ទុកប្រជាពលរដ្ឋកម្ពុជាដូចជា ទ្រព្យសម្បត្តិ សត្វធាតុ ដើម្បីយកទៅបង្កាត់ពូជ



មន្ទីរសន្តិសុខរបស់ខ្មែរក្រហម នៅវត្តចំពុះក្អែក

ជាមួយនឹងដៃគូដែលម្ចាស់កម្មសិទ្ធិជាអ្នកជ្រើសរើស ។

ផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីកម្ទេចរចនាសម្ព័ន្ធគ្រួសារចាស់ និងដាក់បុគ្គលម្នាក់ៗនៅក្រោមឆន្ទៈរបស់បក្ស សូម្បីតែក្នុងបញ្ហាបុគ្គល ដូចជា ការរៀបអាពាហ៍ពិពាហ៍នេះជាដើម ។ នោះ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងសេចក្តីណែនាំរបស់បក្សចុះឆ្នាំ១៩៧៥ ចំណងជើងថា «លោកទស្សនៈបដិវត្តន៍ និងមិនបដិវត្តន៍ចំពោះបញ្ហាកសាងគ្រួសារ» ។

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានធ្វើឡើងគ្រប់តំបន់គ្រប់អង្គការចាត់តាំងនៃរបបកម្ពុជាប្រជាធិបតេយ្យរួមទាំងតាមក្រសួងនៅទីក្រុងភ្នំពេញ ក្រោមការមើលការខុសត្រូវរបស់ខៀវ



សំផន ។ ក្នុងនេះដែរ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអតីតកម្មាភិបាលម្នាក់មកពីក្រសួងពាណិជ្ជកម្មមក ធ្វើសក្ខីកម្មសម្រាប់អង្គជំនុំជម្រះ ដែលក្រសួងនេះស្ថិតនៅការទទួលខុសត្រូវរបស់ខៀវ សំផន និងអតីតកម្មាភិបាលម្នាក់មកពីក្រសួងសង្គមកិច្ចដែល នួន ជា ជាអ្នកមើលការខុសត្រូវ ហើយអ្នកទាំងពីរនាក់នេះត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នៅក្នុងក្រសួងរបស់ខ្លួន និងអាចពិពណ៌នាអំពីការដឹងឮនិងការចូលរួមរបស់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងឧក្រិដ្ឋកម្មទាំងនេះ ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានចេញបញ្ជារៀបចំ និងធ្វើឡើងដោយកម្មាភិបាលមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានលក្ខណៈជាទ្រង់ទ្រាយធំ គឺការបង្ខំឲ្យបុរស និងស្ត្រីរៀបអាពាហ៍ ពិពាហ៍រួមមាន១០០គូក្នុងពេលជាមួយគ្នា ។ បុរស និងនារី មិនដែលត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ដូច្នេះពីមុនមកទេ ហើយគាត់ក៏ត្រូវបានកងឈ្លបរបស់ខ្មែរក្រហមតាមដាន និងបង្ខំឲ្យរួមដំណេកជាមួយគ្នាដោយផ្ទុយពីឆន្ទៈរបស់គាត់ ។

### ២) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម និងវៀតណាម

សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គូមជែន បានថ្លែងទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម ដោយប្រើប្រាស់កំណត់ហេតុរបស់បក្សកុម្មុយនីស្តកម្ពុជា ។ សហព្រះរាជអាជ្ញារូបនេះបានលើកឡើងថា នួន ជា ជាអ្នកតំណាងបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងប្រទេសកម្ពុជា ។រីឯ ខៀវ សំផន ជាអ្នកតំណាងរបបកម្ពុជាប្រជាធិបតេយ្យនៅឯក្រៅប្រទេស ។ អ្នកទាំងពីរបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាដោយលុបបំបាត់ សាសនាដូចជា បំបាត់វត្តអារាមនៅក្នុងប្រទេស ហើយព្រះសង្ឃប្រមាណ៩៥ភាគរយត្រូវបានបណ្តេញចេញ និងផ្សឹក ហើយវណ្ណៈមួយនេះត្រូវបានលុបបំបាត់ពីប្រទេសដែលឧក្រិដ្ឋកម្មទាំងអស់នេះកើតចេញពីលទ្ធផលនៃគោលនយោបាយមួយដែលធ្វើឡើងជាលក្ខណៈប្រព័ន្ធមិនមែនកើតចេញពីបុគ្គលម្នាក់នោះឡើយ ។

សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន បានចូលរួមចំណែកយ៉ាងច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយ

ខៀវ សំផន ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម និងក្រោយមកឡើង ធ្វើជាប្រមុខរដ្ឋជំនួសសម្តេចសីហនុ និងបានជំនួសតំណែង ខៀន ជាប្រធានមន្ទីរ៨៧០ និងបានតំណែងរបបកម្ពុជាប្រជាធិបតេយ្យនៅបរទេស ។ ការលើកឡើងថា ខ្លួនពុំមានអំណាចជាការកុហក ។

ចំពោះការដែល ខៀវ សំផន លើកឡើងថា ខ្លួនពុំបានដឹងអ្វីដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជារឿងមិនពិត ។ ខៀវ សំផន នៅជាមួយ ប៉ុល ពត និង នួន ជា ដែល ជាមេដឹកនាំកំពូល ហើយ ខៀវ សំផន ធ្វើដំណើរទៅបរទេស ជួបជាមួយនឹងអគ្គរាជទូត និងរដ្ឋទូត និងដឹងថា សម្តេចសីហនុ ត្រូវបានចាប់ឃុំខ្លួន និងបានដឹងថា អ្នកដែលត្រូវបានសម្លាប់ទាំងអស់នោះ គឺជាគំនិតរបស់ ប៉ុល ពត ។ ដូច្នេះមានន័យថា ខៀវ សំផនពិតជាបានជជែកជាមួយនឹង ប៉ុល ពត អំពីការចាប់ខ្លួន និងសម្លាប់មនុស្សព្រោះ ខៀវ សំផន បានហូបបាយរួចហើយបានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងរស់នៅជាមួយនឹង ប៉ុល ពត ។ ដូច្នេះ ខៀវ សំផនគឺជាបុគ្គលម្នាក់តំណាងខ្មែរក្រហមទាំងថ្នាក់ជាតិ និងអន្តរជាតិ ។

ខៀវ សំផន និង នួន ជា ចង់ទម្លាក់កំហុសទាំងអស់លើអ្នកដែលស្លាប់ទៅហើយ ដោយនិយាយថា អ្វីៗគឺ ប៉ុល ពត ជាអ្នកសម្រេច ប៉ុន្តែ របបមួយមិនអាចដឹកនាំដោយមនុស្សតែម្នាក់បានទេ ។ សហព្រះរាជអាជ្ញាបន្តថា បើដឹងថា ប៉ុល ពត ជាអ្នកបញ្ជាឲ្យសម្លាប់មនុស្ស ហើយតើហេតុអ្វីបានជា នួន ជា និង ខៀវ សំផន នៅតែបន្តនៅជាមួយ ប៉ុល ពត ជាង២០ឆ្នាំក្រោយ របបខ្មែរក្រហមដួលរលំទៀត? នេះដោយសារតែអ្នកទាំងពីររូបនេះមានភក្តីភាពជាមួយ ប៉ុល ពត ។ សហព្រះរាជអាជ្ញាបានបង្ហាញខ្សែវីដេអូមួយដែលខៀវ សំផន បានលើកឡើងថា ខ្លួននៅតែនឹក ប៉ុល ពត និងនិយាយថា ប៉ុល ពត ជាអ្នកដែលមានខួរក្បាលកម្ររកបាន ។ ប៉ុន្តែនៅពេលសម្ភាសន៍ជាមួយវិទ្យុវី.អូ.អេ នៅក្នុងឆ្នាំ២០០៧ ខៀវ សំផន បែរជានិយាយថា ប៉ុល ពត តែម្នាក់គត់ដែលជាអ្នកបញ្ជាឲ្យសម្លាប់មនុស្សទៅវិញ ។ នៅឆ្នាំ១៩៧៧ ខៀវ សំផន បានក្លាយជាសមាជិកតែម្នាក់គត់នៅក្នុងមន្ទីរ៨៧០ ដែលមន្ទីរនេះជាជីវិតរបស់បក្ស ហើយជាមន្ទីរសម្របសម្រួលក្នុងការចាប់ខ្លួន ចុងក្រោយត្រូវនឹងសម្លាប់នៅក្នុងមន្ទីរនេះ ។

រីឯជនជាប់ចោទ នួន ជា សហព្រះរាជអាជ្ញាបានលើកឡើងថា នួន ជា ជាអ្នកបង្កើតមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា និងមាននិយាយអំពីសិទ្ធិក្នុងការសម្រេចកម្ទេចទាំងក្នុង និងក្រៅជួរបក្ស ។ ហើយ នួន ជា និងប៉ុល ពត តែងតែពិភាក្សាជាមួយគ្នាមុននឹងសម្រេចធ្វើរឿងអ្វីមួយនោះ ។ សហព្រះរាជអាជ្ញាបន្តថា នួន ជា ជាអ្នកដែលត្រូវបានសម្លាប់ជាខ្មាំង គឺជាការលើកឡើងដើម្បីរួចខ្លួនតែប៉ុណ្ណោះ ។ ជាក់ស្តែងអ្នកដែលត្រូវបានសម្លាប់ គឺជាកម្មាភិបាលរបស់ខ្លួន ប្រជាជន ស្ត្រី និងក្មេងៗដែលត្រូវបាននាំយកទៅ ស-២១ ។ ដូច្នេះការលើកឡើងរបស់ នួន ជា ថា សម្លាប់ខ្មាំង ដើម្បីការពារប្រទេសគឺជារឿងមិនពិត ព្រោះការសម្លាប់ប្រជាជនអស់១ភាគ៤ពីប្រទេស តើគេអាចការពារប្រទេសដោយរបៀបណាទៅ? ការសម្លាប់នេះបានធ្វើឲ្យកម្ពុជារងគ្រោះ និងប្រឹងប្រែងងើបឡើងវិញរហូតដល់ពេលបច្ចុប្បន្ននេះ ។

### ឃ) សេចក្តីថ្លែងរបស់ជនជាប់ចោទទាំងពីររូបគឺ នួន ជា និង ខៀវ សំផន

### ១) សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ! សូមគោរពជនរួមជាតិកម្ពុជាជាទីស្រឡាញ់រាប់អាន និងជនស្មោះសច្ចភាព និងយុត្តិធម៌ទាំងអស់ជាទីគោរព ។ គោរពតុលាការ ។ ខ្ញុំ! នួន ជា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃនេះ ដោយហេតុថា តុលាការនេះ បានចាប់ផ្តើមបើកសវនាការជាលើកទី២ ប្រឆាំងនឹងខ្ញុំ ។ ខ្ញុំសូមយកឱកាសនេះ និយាយទៅកាន់ជនរួមជាតិខ្ញុំជាថ្មីម្តងទៀត ។ កាលពីពីរខែមុន ចៅក្រមនៅក្នុងបន្ទប់នេះ បានចេញសាលក្រមលើកទី១ ប្រឆាំងនឹងរូបខ្ញុំ ។ លោកចៅក្រមបានដាក់ទោសខ្ញុំ អំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីភ្នំពេញ និងការសម្លាប់ទាហាន និងមន្ត្រីនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ហើយក៏បានផ្តន្ទាទោសខ្ញុំដោយ ដាក់គុកអស់មួយជីវិត ។

លោកចៅក្រមបាននិយាយថា បក្សកុម្មុយនីស្តកម្ពុជាមានឋានានុក្រមជាសម្ងាត់ ដែលគ្រប់គ្រងដ៏មានប្រសិទ្ធភាពពីមជ្ឈិមបក្ស ។ លោកចៅក្រមបាននិយាយផងដែរថា គ្រប់កិច្ចការរបស់មជ្ឈិមបក្សទាំងអស់គឺ ប៉ុល ពត និងខ្ញុំ ជាអ្នកគ្រប់គ្រង ។ យោងទៅតាមអ្វីដែលលោកចៅក្រមបាននិយាយនេះថា យើងខ្ញុំទាំងពីរនាក់បានអនុវត្តអំណាចនៃការធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស

ដែលវាអាចបង្កើត និងអនុវត្តរាល់គោលនយោបាយ និងសេចក្តីសម្រេចរបស់បក្ស និងគ្រប់គ្រងរាល់កម្មាភិបាលរបស់ខ្មែរក្រហម ចាប់តាំងពីកូនទាហានថ្នាក់ទាប រហូតដល់សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។ នៅពេលដែលលោកចៅក្រមធ្វើសេចក្តីសម្រេចនោះ លោកចៅក្រមបានបំភ្លេចចោលទាំងស្រុងនូវភស្តុតាងច្បាស់លាស់ និងជាក់លាក់ដែលបក្សបានបែងចែកអំណាចផ្ទៃក្នុងយ៉ាងច្បាស់លាស់ ហើយភូមិភាគនីមួយៗតាមពិតអាចនឹងបានធ្វើសកម្មភាពដោយស្វ័យត ។ ផ្ទុយទៅនឹងអ្វីដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្ញុំ លោកចៅក្រមមិនបានយកចិត្តទុកដាក់លើភស្តុតាងដែលសមាជិកអចិន្ត្រៃយ៍ និងសមាជិកមជ្ឈិមបក្សដូចជា សោ ភឹម, រស់ ញឹម, វន វ៉េត កុយ ធួន និងអ្នកដទៃទៀតពិតជាមេដឹកនាំនៃក្រុមបះបោរប្រឆាំងនៅក្នុងបក្សដែលគាំទ្រដោយវៀតណាម ។ ក្រុមនេះបានធ្វើសកម្មភាពតាមទំនើងចិត្តចាប់តាំងពីពេលចាប់ផ្តើមដំបូងមកម្ល៉េះ ក្រុមនេះមានបំណងបំផ្លិចបំផ្លាញយ៉ាងខ្លាំងដល់គោលបំណងរបស់បក្ស ហើយក្រុមនេះបានបំពេញបំណងអាក្រក់របស់ខ្លួនបានទាំងស្រុង ។

លោកចៅក្រមក៏មិនបានយកចិត្តទុកដាក់ផងដែរ ទៅលើភស្តុតាងដែលខ្ញុំ និងមេធាវីរបស់ខ្ញុំ បានលើកឡើងចាប់តាំងពីពេលសវនាការលើកដំបូងដែលថា ព្រឹត្តិការណ៍ជាច្រើនបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាការឈ្លានពានមកលើទឹកដីកម្ពុជាពីសំណាក់ប្រទេសជិតខាង ជាពិសេសប្រទេសវៀតណាម គឺមានតាំងពីយូរណាស់មកហើយ ។

លោកចៅក្រម មិនបានយកចិត្តទុកដាក់ទៅលើភស្តុតាងដែលវៀតណាមបានជួយគាំទ្រដល់ក្រុម សោ ភឹម ហើយក្រោយមក តាមរយៈជំនួយនេះ ធ្វើឲ្យក្រុមនេះបានសម្រេចនូវបំណងរបស់ខ្លួន ។ នៅក្នុងសាលក្រមរបស់លោកចៅក្រមជាភាសាខ្មែរ ដែលមានកម្រាស់ជិត១០០០ទំព័រ លោកចៅក្រម មិនបានបញ្ជាក់ដោយផ្ទាល់ទៅលើភស្តុតាងទាំងនេះនៅក្នុងទំព័រណាមួយឡើយ ។ ជំនួសមកវិញលោកចៅក្រមបានច្រានចោលការឈ្លានពានរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា ហើយគិតថា នេះជាគំនិតឆ្កួតលេលាមួយ ។ លើសពីនេះទៀត លោកចៅក្រមមិនបានលើកឡើងពីអត្ថិភាពនៃក្រុមផ្សេងៗទៀតទាល់តែសោះ ។

ខ្ញុំសូមនិយាយឲ្យបានច្បាស់ថា នេះមិនមែនជាគំនិតឆ្កួតលេលានោះទេ ។ បញ្ជាក់ម្តងទៀត! ខ្ញុំសូមនិយាយឲ្យបានច្បាស់ថា នេះមិនមែនជាគំនិតឆ្កួតលេលានោះទេ ។ ដូចដែលខ្ញុំ និងមេធាវីរបស់ខ្ញុំ បានធ្វើអំណះអំណាងនៅក្នុងសវនាការលើកទី១ និងធ្វើអំណះអំណាងជាថ្មីម្តងទៀតនៅលើកទី២នេះថា ពិតជាមានក្រុមជាច្រើននៅក្នុងផ្ទៃក្នុងបក្ស វាពិតជាមានក្រុមស៊ីរូងផ្ទៃក្នុងមួយដែលគាំទ្រដោយវៀតណាម និងដឹកនាំដោយ សោ ភឹម និង រស់ ញឹម ។ ខ្ញុំមិនចង់បង្រៀនឲ្យចៅក្រមយល់ដឹងថា វៀតណាមមានមហិច្ឆតាចង់លេបទឹកដីកម្ពុជាតាំងពីយូរយាណាស់មកហើយនោះទេ តែចំណុចនេះត្រូវបានប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដឹងច្បាស់អស់ហើយ ។ ខ្ញុំនិយាយពីបញ្ហានេះបន្ថែមទៀតនៅពេលក្រោយ ។

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវអ្វីដែលចៅក្រមបានបំភ្លេចចោលចំពោះបញ្ហាទាំងអស់នេះ ។ ជំនួសមកវិញ លោកចៅក្រមបែរជាបង្ហាញនូវរឿងមួយដ៏សាមញ្ញ តែរឿងនោះវាដូចជារឿងព្រេងនិទានអ៊ីចឹង! តើរឿងនេះកើតឡើងដោយរបៀបណា? ជាការពិតណាស់ ហេតុផលមួយនោះគឺថា បើទោះជាមានការខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់របស់មេធាវីរបស់ខ្ញុំយ៉ាងណាក្តី ក៏ចៅក្រមជាតិ នៃសាលាដំបូងបានបដិសេធមិនកោះហៅលោក ហេង សំរិន ឲ្យធ្វើជាសាក្សីទេ ។ បើទោះជាសាក្សីរូប នេះពិតជាមានសារសំខាន់នៅក្នុងសវនាការនេះយ៉ាងណាក៏ដោយ ។ ហើយបើទោះជាសាក្សីរូបនេះ អាចផ្តល់សក្ខីកម្មអំពីកិច្ចប្រជុំរបស់បក្ស ដែលអាចសន្មតបានថា កិច្ចប្រជុំនោះបានសម្រេចនូវគោលនយោបាយរបស់បក្សយ៉ាងណាក៏ដោយ បើទោះជាសាក្សីរូបនេះ អាចបញ្ជាក់ពីជំហររបស់ខ្ញុំថា «ខ្ញុំមិនដែលបានបញ្ជាឲ្យសម្លាប់ទាហាន និងមន្ត្រីរបស់របបលន់នល់ និងជនស្លូតត្រង់នៅពេលធ្វើការជម្លៀស» ហើយបើទោះជាគាត់អាចពន្យល់ពីអត្តចរិតរបស់ខ្ញុំដោយលម្អិត ចាប់ពីយើងបានស្គាល់គ្នាជាង៦០ឆ្នាំមកក៏ដោយ តែផ្ទុយទៅវិញ លោកចៅក្រមបានគិតថា មេធាវីរបស់ខ្ញុំបានព្យាយាម សូមឲ្យតុលាការកោះហៅលោក ហេង សំរិន នោះគឺជាល្បិចកលទៅវិញ ។ នៅថ្ងៃនេះខ្ញុំចង់ជម្រាប លោកចៅក្រមពីចិត្តរបស់ខ្ញុំថា «ខ្ញុំមានការឈឺចាប់ណាស់ តុលាការនេះត្រូវតែបានបង្កើតឡើងដើម្បីស្វែងរកការពិត យុត្តិធម៌ និងបម្រើផលប្រយោជន៍សង្គម ប៉ុន្តែនៅក្នុងសាលក្រមលើកទី១

របស់លោកចៅក្រម ដែលបានកាត់ទោសខ្ញុំកាលពី២ខែកន្លងទៅនេះ លោកចៅក្រមពិតជាបរាជ័យក្នុងការបំពេញកិច្ចការនេះជាប្រាកដ» លោកចៅក្រមពិតជាមិនបានរកឃើញការពិត ហើយបានបន្ទាបតម្លៃយុត្តិធម៌ទៅវិញ ។ ក្រោយពេលលោកចៅក្រម ចេញសាលក្រមលើកទី១ដាក់ទោសខ្ញុំភ្លាម ខ្ញុំបានប្រាប់ឲ្យមេធាវីរបស់ខ្ញុំ ដាក់ពាក្យប្តឹងជិតចិត្តដើម្បីដកចៅក្រម និល ណុន, យ៉ា សុខន, យូរ ឧត្តរា និងចៅក្រម ឡាវ៉េញ ពីការជំនុំជម្រះក្តីមកលើរូបខ្ញុំនាពេលខាងមុខតទៅទៀត ។ តាមសាលក្រមរបស់លោកចៅក្រមលើកទី១ នេះ វាបង្ហាញថាលោកចៅក្រមមិនមានលក្ខណៈសម្បត្តិដើម្បីសម្រេចសេចក្តីលើរឿងក្តីរបស់ខ្ញុំទៀតឡើយ ។ មេធាវីរបស់ខ្ញុំបានដាក់ពាក្យប្តឹងជិតចិត្តនេះ ប្រហែលជាពីរ ឬបីសប្តាហ៍កន្លងទៅ ហើយយើងកំពុងរង់ចាំលទ្ធផលនៃការសម្រេចលើបណ្តឹងនេះ ។

មេធាវីរបស់ខ្ញុំបាន ផ្តល់អំណះអំណាងថា សាលក្រមលើកទី១ របស់តុលាការបានបង្ហាញថា លោកចៅក្រមគ្មានឯករាជភាព និងលម្អៀង ។ នេះដោយសារតែដូចជាចៅក្រមជាតិទាំងអស់ លោកធ្វើការនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល និងមានភាពភ័យខ្លាច ។ លោកចៅក្រមបានបង្ហាញឲ្យឃើញការបាត់បង់ឯករាជភាព និងស្ទើរតែគ្រប់សេចក្តីសម្រេចរបស់ខ្លួន ក្នុងការសម្រេចមិនហ៊ានកោះ ហៅលោក ហេង សំរិនជាដើម ។ លោក ហេង សំរិន មិនត្រឹមតែជាសាក្សីដ៏សំខាន់នៅក្នុងសវនាការនេះទេ តែគាត់ជាសាក្សីអត្តចរិតរបស់ខ្ញុំ ។ គាត់ជាមនុស្សសំខាន់ទី៣នៃអំណាចរដ្ឋនៅក្នុងប្រទេសកម្ពុជា ហើយជាប្រធានកិត្តិយសនៃគណបក្សប្រជាជនកម្ពុជាដែរ ។ ចំពោះចៅក្រមបារាំង ឡាវ៉េញ វិញ លោកកាន់តែអាក្រក់ទៅទៀត បើទោះជាលោកបានយល់ស្របជាមួយយើងខ្ញុំថា លោក ហេង សំរិន គួរតែមកផ្តល់សក្ខីកម្មពីព្រោះគាត់អាចផ្តល់ភ័ស្តុតាងដ៏សំខាន់ដែលសាក្សីផ្សេងទៀត មិនអាចផ្តល់បាន ។ តែទោះជាយ៉ាងណាក្តី លោកចៅក្រមនៅតែធ្វើសេចក្តីសន្និដ្ឋានដោយគ្មានមន្ទិលសង្ស័យថាខ្ញុំមានទោស ហើយមិនបាច់មានសាក្សីរបស់លោកហេង សំរិន ។ ហើយលោកចៅក្រមមិនមានឆន្ទៈ សូម្បីតែប្រកាសថា ការបដិសេធមិនកោះហៅលោក ហេង សំរិន មកផ្តល់សក្ខីកម្ម គឺជាការរំលោភសិទ្ធិរបស់ខ្ញុំ ក្នុងការទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ វាគ្មានន័យអ្វីឡើយក្នុងការធ្វើសេចក្តីសម្រេចនោះទេ ប្រសិនបើលោកចៅក្រមមិនមានសេចក្តីក្លាហានគ្រប់គ្រាន់ដើម្បីរក្សានូវជំហររបស់ខ្លួននោះ ។ នៅក្នុងសវនាការលើកទី២នេះ លោក ហេង សំរិន នៅតែជាសាក្សីដ៏មានសារសំខាន់បំផុត ។ តាមពិតបច្ចុប្បន្ននេះគាត់រឹតតែមានសារសំខាន់ ពីព្រោះ វាកាន់តែមានសារសំខាន់ដើម្បីឲ្យយល់កាន់តែច្បាស់នូវតួនាទីរបស់វៀតណាមក្នុងការឈ្លានពានវាតទី លេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា ។

ជាអកុសលនៅក្នុងសាលក្រមទី១ របស់លោកចៅក្រមបានបង្ហាញថា លោកចៅក្រមមិនយល់ស្របទៅនឹងចំណុចនេះទេ ។ ហេតុនេះបន្ថែមទៅលើបណ្តឹងជិតចិត្តចៅក្រមទាំងបួនក្នុងចំណោមលោកចៅក្រមទាំងអស់ និងក្រោយពីខ្ញុំបានទទួលសាលក្រមទី១ ដាក់ទោសខ្ញុំភ្លាម ខ្ញុំបានណែនាំឲ្យមេធាវីរបស់ខ្ញុំដាក់ពាក្យបណ្តឹងសាទុក្ខជាបន្ទាន់ ។

នៅក្នុងបណ្តឹងសាទុក្ខនេះ បានរៀបរាប់ពីកំហុសនានា ដែលលោកចៅក្រមបានសម្រេចទាំងអង្គហេតុ និងអង្គច្បាប់ ។ នៅក្នុងសាលក្រមនោះមានចំនួនច្រើនជាង២០០ចំណុច ។ ការប្តឹងសាទុក្ខទៅនឹងសាលក្រមនោះ មិនមានន័យថា ខ្ញុំចង់បដិសេធចំពោះការឈឺចាប់របស់ជនរួមជាតិខ្ញុំនោះទេ ។ តាមពិតទៅជំហររបស់ខ្ញុំគឺផ្ទុយស្រឡះពីនេះ ។ ដូចខ្ញុំបានពន្យល់ជាច្រើនដងរួចមកហើយនៅក្នុងតុលាការនេះថា ខ្ញុំបានទទួលស្គាល់ថា មានជនរួមជាតិជាច្រើនមានការឈឺចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបង្កឡើងដោយពួកបំផ្លាញស៊ីរូងផ្ទៃក្នុង ។ ខ្ញុំសោកស្តាយជាពន់ពេកចំពោះទុក្ខលំបាក នៃបក្សកុម្មុយនីស្តកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយដូចខ្ញុំបានពន្យល់ពីខាងដើមរួចមកហើយ នៅក្នុងតុលាការនេះ ខ្ញុំមិនមានចេតនាធ្វើឲ្យជនរួមជាតិខ្ញុំរងទុក្ខបែបនេះឡើយ ។ អ្វីៗដែលវាមិនមែនជាការរវើរវាយ និងជារឿងសម្ងាត់អ្វីនោះទេ ដែលថាវៀតណាមបានព្យាយាមលេបទឹកដីកម្ពុជាក្នុងរយៈពេលរាប់រយឆ្នាំមកហើយនោះ ។ នៅក្នុងសម័យទំនើបចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៣០មក វៀតណាម និយាយអំពីការបង្កើតសហព័ន្ធឥណ្ឌូចិន ។ សហព័ន្ធឥណ្ឌូចិននេះមាន កម្ពុជា វៀតណាម និងឡាវ រួមគ្នាជារដ្ឋមួយនៅក្រោមការត្រួតត្រារបស់វៀតណាម ។ នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ វៀតណាម សម្រេចបាននូវមហិច្ឆតានេះមួយផ្នែក នៅពេលវៀតណាមឈ្លានពានប្រទេសកម្ពុជា ។

ឆ្លើយតបនឹងការឈ្លានពាននេះភ្លាមៗ សម្តេចព្រះ នរោត្តម សីហនុ បានយាងទៅអង្គការសហប្រជាជាតិ ហើយមានព្រះរាជបន្ទូលនៅចំពោះមុខស្ថាប័នសំខាន់ៗរបស់អង្គការសហប្រជាជាតិ ជាពិសេសក្រុមប្រឹក្សាសន្តិសុខអំពីការឈ្លានពានរបស់វៀតណាមនេះ និងសុំឲ្យអង្គការសហប្រជាជាតិ ជួយអន្តរាគមន៍ដល់ប្រទេសកម្ពុជា ។ ខ្ញុំសូមធ្វើការដកស្រង់បន្ទូលរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលមានព្រះរាជបន្ទូលប្រាប់ក្រុមប្រឹក្សាសន្តិសុខថា "វៀតណាមបានសម្រេចចិត្តធ្វើប្រតិបត្តិការពិសេស ដែលមានគោលបំណងតែមួយគត់ គឺគ្មានអ្វីក្រៅពីលេបយកទឹកដីកម្ពុជា ដូចជា ពស់ថ្លាន់មួយ ស្រេកឃ្លានអាហារ បង្កប់ខ្លួននៅក្នុងចំណោមសត្វស្លូតទាំងឡាយ ដោយរង់ចាំឱកាសស៊ីសត្វទាំងនោះ" ។ តាមពិតនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខ អ្នកការទូតជាច្រើនបានយល់ស្របថា វៀតណាមបានឈ្លានពានប្រទេសកម្ពុជាដោយខុសច្បាប់ រួមទាំងតំណាងរបស់សហរដ្ឋអាមេរិក ចិន និងអូស្ត្រាលី ។ នេះមិនមែនជាការរវើយរវាយទេ ទាំងអស់នេះបានកត់ត្រានៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិជាសាធារណៈ ។ ពស់ថ្លាន់វៀតណាមបានបញ្ជូនទាហានឈ្លានពានប្រទេសកម្ពុជា ដើម្បីបំពេញសេចក្តីស្រេកឃ្លានមិនចេះឆ្អែតឆ្អន់ក្នុងការពង្រីកទឹកដី និងគ្រប់គ្រងប្រទេសប្រជាជនឲ្យបានកាន់តែច្រើនទៅៗ ។ សំខាន់បំផុតនោះវៀតណាមបានលួចគាំទ្រកម្មាភិបាលក្បត់មួយចំនួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបម្រើគោលបំណងរបស់ពួកគេ ។ ការយល់ដឹងពីតួនាទីរបស់វៀតណាម គឺមានសារសំខាន់ដើម្បីស្វែងរកការពិតនៃអំពើជាច្រើននៃសវនាការលើកទី២នេះ ។

អំពើជាច្រើននៃសវនាការនេះរួមមាន៖ ប្រល័យពូជសាសន៍ជនជាតិវៀតណាម ជនជាតិចាម បទល្មើសនៅក្នុងមន្ទីរសន្តិសុខ ស-២១ និងការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ា ។ ខ្ញុំសូមបញ្ជាក់ថា បទឧក្រិដ្ឋដែលបានចោទប្រកាន់មកលើរូបខ្ញុំនៅក្នុងសវនាការលើកទី២នេះ គឺតាមពិតបានប្រព្រឹត្តដោយ សោ ភឹម, រស់ ញឹម និងជនក្បត់មួយចំនួនតូចទៀត ។ ហើយអំពើទាំងនេះបានប្រព្រឹត្តនៅក្រោមការគ្រប់គ្រង និងការយល់ដឹងរបស់អ្នកដឹកនាំដូចជារូបខ្ញុំជាដើម ។ ប្រសិនបើលោក លោកស្រីចៅក្រម កោះហៅលោក ហេង សំរិន មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការលើកទី២នេះ មិនអាចបន្តទៀតទេ ប្រសិនបើចៅក្រមកម្ពុជាបីនាក់ និងចៅក្រមបារាំងម្នាក់ក្នុងចំណោមចៅក្រមទាំងអស់ នៅតែជំនុំជម្រះក្តីរបស់ខ្ញុំទៀតនោះ ។

តាមការណែនាំរបស់ខ្ញុំ មេធាវីរបស់ខ្ញុំបានបង្ហាញហេតុផលជាច្រើនចំពោះបញ្ហានេះ ប៉ុន្តែ ហេតុផលមួយក្នុងចំណោមហេតុផលដ៏សំខាន់ទាំងនេះគឺថា លោកចៅក្រមទាំងបួននាក់បានសម្រេចសេចក្តីនៅក្នុងសាលក្រម លើកទី១រួចហើយ ។ លោកចៅក្រមបានរកឃើញថា ខ្ញុំមានទោស លោកចៅក្រមរកឃើញថា ខ្ញុំពិតជាមានអំណាចនៅក្នុងបក្ស ហើយបក្សបានបង្កើតគោលនយោបាយសំខាន់ៗជាច្រើន ។ លោកចៅក្រមបានបង្ហាញថា លោកចៅក្រមមិនអាចបើកចិត្តឲ្យទូលាយដើម្បីទទួលយកអំណះអំណាងដែលខ្ញុំ និងមេធាវីរបស់ខ្ញុំចង់លើកឡើងនោះទេ ។ ជាទូទៅ លោកចៅក្រមបានបង្ហាញឲ្យឃើញថា លោកចៅក្រមមិនជឿលើខាងយើងខ្ញុំទេ ហើយលោកចៅក្រមមិនជឿនូវអ្វីៗដែល ខ្ញុំបាននិយាយដោយសារតែវាមិនសមនឹងរឿងនិទាន ដែលលោកចៅក្រមបានសរសេរនោះទេ ។ លោកចៅក្រមបានដាក់ទោសខ្ញុំនៅក្នុងសាលក្រមលើកទី១ ខ្ញុំជឿជាក់ថា លោកចៅក្រមពិតជាលម្អៀងប្រឆាំងមកលើរូបខ្ញុំនៅក្នុងសវនាការលើកទី២នេះ ។

នៅក្រោមកាលៈទេសៈទីនេះ ខ្ញុំមិនយល់ថា ហេតុអ្វីបានលោកចៅក្រមនៅតែអាចបន្តចូលរួមសវនាការទី២នេះទៀតដោយរបៀបណានោះទេ ។ ជាការងាយណាស់ ខ្ញុំមិនអាចមើលឃើញថា ខ្ញុំអាចទទួលបានសិទ្ធិជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដើម្បីសន្មតថា ខ្ញុំគ្មានទោស រហូតដល់មានការរកឃើញ ថាមានភស្តុតាងគ្រប់គ្រាន់ដាក់ទោសដោយរបៀបណា ។ ម្យ៉ាងទៀត តុលាការមិនទាន់បានសម្រេចលើបណ្តឹងដិតចិត្តរបស់ខ្ញុំ ប្រឆាំងនឹងលោកចៅក្រមទាំងបួននាក់នៅឡើយផង ។ ខ្ញុំយល់ថា វានឹងចំណាយពេលជាច្រើនខែដើម្បីចេញសេចក្តីសម្រេចនេះ ។ នៅក្រោមច្បាប់កម្ពុជា នៅពេលភាគីណាម្នាក់មួយ ដាក់បណ្តឹងដិតចិត្តចំពោះចៅក្រមណាម្នាក់ ចៅក្រមនោះត្រូវបញ្ឈប់កិច្ចការរបស់ខ្លួនភ្លាម ដោយរង់ចាំការសម្រេចលើបណ្តឹងដិតចិត្តសិន ។ តាមការពិតមេធាវីរបស់ខ្ញុំប្រាប់ខ្ញុំថា នេះជាការអនុវត្តជាទូទៅក្នុងតុលាការ ។ ទោះជា យ៉ាងនេះក្តី ជំទូសដោយការធ្វើបែបនេះលោកចៅក្រមនៅតែបន្តការជំនុំជម្រះ

ក្តីលើកទី២ទៀត ។

លោកចៅក្រមបានបញ្ជាឲ្យខ្ញុំមកបង្ហាញខ្លួននៅក្នុងសវនាការលើកទី២នេះ ហើយលោកចៅក្រមសម្រេចបើកសវនាការលើកទី២នេះ បើទោះជាយើងខ្ញុំកំពុងរង់ចាំសេចក្តីសម្រេចពីបណ្តឹងដិតចិត្តក៏ដោយ ។ ការចេញបទបញ្ជាបែបនេះ និងការបើកការជំនុំជម្រះថ្ងៃនេះ លោក លោកស្រី ចៅក្រម ពិតជាបានបង្ហាញនូវការមិនគោរពនីតិវិធីច្បាប់នៃប្រទេសកម្ពុជា ។ នេះស្របទៅនឹងឥរិយាបថ ដែលលោកចៅក្រមបានអនុវត្តនៅក្នុងសវនាការលើកទី១ ដែលមេធាវីរបស់ខ្ញុំបានលើកអំណះអំណាងដែរ នៅក្នុងបណ្តឹងដិតចិត្ត ។ តាមរយៈការជំនុំជម្រះលើកទី១នេះ លោកចៅក្រមបានបង្ហាញពីការមិនគោរពនីតិវិធីឲ្យបានត្រឹមត្រូវ ។ ដើម្បីបម្រើគោលបំណងរបស់ខ្លួន លោកចៅក្រមបានកំណត់ និងអនុវត្តនីតិវិធីជាច្រើន ដែលមិនស៊ីសង្វាក់គ្នានៅក្នុងអំឡុងពេលសវនាការ ។ ជារឿយៗ លោកចៅក្រមបានរំលោភសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ដូចដែលមេធាវីរបស់ខ្ញុំ នឹងលើកឡើងយ៉ាងលម្អិតនៅក្នុងបណ្តឹងសាទុក្ខរបស់ពួកគាត់ ចំពោះសាលក្រមលើកទី១ ។ ខ្លួនខ្ញុំផ្ទាល់ខ្ញុំចង់ឆ្លៀតឱកាសនេះស្នើសុំលោកចៅក្រមទាំងអស់ លើកលែងតែចៅក្រមថ្មី ពិចារណាលើសេចក្តីសម្រេចរបស់ខ្លួនក្នុងការចូលរួមបន្តសវនាការនេះ ។

ខ្ញុំបានស្នើសុំឲ្យលោកចៅក្រមបញ្ឈប់សវនាការឥឡូវនេះដោយរង់ចាំរហូតដល់តុលាការចេញសេចក្តីសម្រេចថា តើលោកចៅក្រមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សវនាការលើកទី២នេះ ឬទេ ។ ខ្ញុំយល់ថា វាអាចចំណាយពេលប្រហែលជាបីខែសម្រាប់សម្រេចលើបណ្តឹងដិតចិត្ត ។ ឥឡូវនេះខ្ញុំដឹងថា លោកចៅក្រមចង់ឲ្យសវនាការលើកទី២នេះ ប្រព្រឹត្តទៅឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ ខ្ញុំក៏មានបំណងបែបនេះដែរ ដើម្បីមានឱកាសជម្រាបជនរួមជាតិខ្ញុំគ្រប់រូបនូវអ្វីដែលបានកើតឡើង ។ ប៉ុន្តែយើងបានរង់ចាំអស់រយៈពេល៥ឆ្នាំ១ខែមកហើយ ។ ការរង់ចាំបីខែទៀត សម្រាប់ការសម្រេចលើបណ្តឹងដិតចិត្តនោះក៏មិនជាអ្វីដែរ ។ ប្រសិនបើលោកចៅក្រមមិនផ្អាកសវនាការក្នុងខណៈពេលបណ្តឹងដិតចិត្តកំពុងពិនិត្យសេចក្តី-កំពុងពិនិត្យ និងសម្រេចនោះ លោកចៅក្រមធ្វើឲ្យខ្ញុំគ្មានជម្រើសផ្សេងទេ ។ ខ្ញុំសូមណែនាំ និងស្នើសុំមេធាវីរបស់ខ្ញុំឲ្យចេញពីបន្ទប់សវនាការបន្ទាប់ពីលោក ខៀវ សំផន ប្រកាសពីជំហររបស់គាត់ ហើយនឹងពហិការមិនចូលរួមរាល់សវនាការនាពេលខាងមុខនៃសវនាការលើកទី២នេះ រហូតដល់បណ្តឹងដិតចិត្តត្រូវបានសម្រេច ។

បន្ទាប់ពីជនជាប់ចោទ នួន ជា បានបញ្ចប់សេចក្តីថ្លែងរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនជនជាប់ចោទ ខៀវ សំផន ដើម្បីថ្លែងឆ្លើយតបនឹងបទចោទប្រកាន់របស់សហព្រះរាជ អាជ្ញា ។

## ២) សេចក្តីថ្លែងរបស់ជនជាប់ចោទ ខៀវ សំផន

សូមគោរពលោកប្រធាន អស់លោក លោកស្រី ចៅក្រមអស់លោកទាំងអស់ដែលមានវត្តមាននៅទីនេះ ។ ព្រះសង្ឃគ្រប់ព្រះអង្គនៅតាមវត្តអារាមនានាទូទាំងប្រទេសជាទីសក្ការៈ ។ បងប្អូនរួមជាតិជាទីគោរពស្នេហា ។ ជាដំបូង ខ្ញុំសូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំឡើងនិយាយ ។ កាលពីថ្ងៃទី០៧ ខែសីហាមុននេះ អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោសខ្ញុំដាក់គុកមួយជីវិត ក្នុងការកាត់ក្តីសំណុំរឿង០០២ ដំណាក់កាលទី១ ។

អស់លោក បានកាត់ទោសខ្ញុំ ដោយផ្អែកលើទម្រង់ភស្តុតាង និងការស្មាននានាដែលខ្ញុំជំទាស់ ហើយដោយប្រើមធ្យោបាយដែលខ្ញុំយល់ឃើញថា ជាការរំលោភលើសិទ្ធិរបស់ខ្ញុំ ដែលខ្ញុំត្រូវមាន ត្រូវបានទទួលការកាត់ក្តីដោយយុត្តិធម៌ ។ ហេតុនេះហើយ បានជាខ្ញុំបានជម្រាបមេធាវីខ្ញុំ ឲ្យប្តឹងឧទ្ធរណ៍ដែលក្នុងតុលាការនេះ គេហៅថា "បណ្តឹងសាទុក្ខ" ។ តាំងពីថ្ងៃកាត់ទោសនេះមក ការងារខ្ញុំ និងក្រុមការពារក្តីរបស់ខ្ញុំ ប្រមូលផ្តុំលើការងាររៀបចំបណ្តឹងឧទ្ធរណ៍ ។ ការងារនេះរឹតតែមានសារសំខាន់ខ្លាំងណាស់ទៅទៀត ពីព្រោះសេចក្តីសំអាងហេតុ និងសេចក្តីសន្និដ្ឋានរបស់អស់លោក នៅក្នុងការកាត់ក្តីនេះ បង្ហាញច្បាស់រួចជាស្រេចទៅហើយ ។ អស់លោកនឹងសម្រេចយ៉ាងណានៅក្នុងការកាត់ក្តីសំណុំរឿង ០០២ ដំណាក់កាលទី២ ខាងមុខនេះ គ្មានអ្វីគួរឲ្យខ្ញុំស្រពេចស្រពិលទេ ។ បើអស់លោកនៅតែប្រើរបៀបគិតគូរ ដែលខ្ញុំជំទាស់នៅចំពោះមុខតុលាការកំពូលទាក់ទងនឹងការចោទប្រកាន់ថា ខ្ញុំបានចូលរួមប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ។ ខ្ញុំដឹងជាមុនស្រេចទៅហើយថា អស់លោកប្រាកដជានឹងផ្តន្ទាទោសខ្ញុំទៀត ក្នុងការកាត់ក្តីដែលអស់លោកកំពុងតែបើកនៅថ្ងៃនេះ ។ យើងខ្ញុំបានធ្វើពាក្យប្តឹងដកសេចក្តីទុកចិត្តពីអស់លោក ដែល

ក្នុងតុលាការនេះគេហៅថា "បណ្តឹងជិតចិត្ត" ។ រហូតមកដល់ពេលនេះ នៅមិនទាន់មានការសម្រេចយ៉ាងណានៅឡើយ ។

ក្នុងសភាពរង់ចាំសេចក្តីសម្រេចចិត្តលើពាក្យបណ្តឹងយើងខ្ញុំនេះ មិនត្រូវចាត់ការអ្វីតទៅទៀតទេ តែមិនដូច្នេះ អស់លោកនៅតែទទូចបើកសវនាការវគ្គទី២ ដែលខ្ញុំទើបនិយាយអម្បាញ់នេះថា ខ្ញុំដឹងមុន ស្រេចទៅហើយ តើនៅទីបញ្ចប់នេះ អស់លោកនឹងកាត់ក្តីយ៉ាងណានោះ ។

ដូច្នេះ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីការពារខ្លួនខ្ញុំ ខ្ញុំគ្មានលទ្ធភាពអ្វីផ្សេងក្រៅពីធ្វើយ៉ាងណាឲ្យបណ្តឹងឧទ្ធរណ៍របស់ខ្ញុំនៅតុលាការកំពូល ត្រូវបានតុលាការកំពូលទទួលយកស្របតាមហើយបដិសេធការកាត់ទោសរបស់អស់លោកកាលពីថ្ងៃទី៧ ខែសីហានោះទេ ។ ទោះបីជាមេធាវីខ្ញុំបានខិតខំពន្យល់យ៉ាងច្បាស់ណាស់ក្នុងសំណើសុំពន្យារពេលហើយយ៉ាងណាក៏ដោយថា គាត់មិនអាចរៀបចំសារណាបណ្តឹងឧទ្ធរណ៍ទៀត ។ មេធាវីខ្ញុំបានប្រាប់ខ្ញុំថា គាត់មិនអាចចំណាយពេលមកចូលរួមសវនាការផង ហើយរៀបចំសារណាបណ្តឹងឧទ្ធរណ៍ដ៏សំខាន់នេះឲ្យបានហ្មត់ចត់ផងទេ ។ ដូច្នេះការសម្រេចរបស់ខ្ញុំ តើត្រូវធ្វើយ៉ាងណានៅចំពោះសភាពការណ៍បែបនេះ? ជាការសម្រេចមួយដ៏លំបាកបំផុត ដែលអង្គជំនុំជម្រះបានបង្ខំឲ្យខ្ញុំធ្វើ ហើយខ្ញុំយល់ថា មិនយុត្តិធម៌ទេ ដែលអស់លោករុញច្រានឲ្យខ្ញុំធ្លាក់ក្នុងសភាពការណ៍បែបនេះ ។ តែបើគ្មានផ្លូវណាជ្រើសរើសទេនោះ ខ្ញុំត្រូវបង្ខំចិត្តជម្រាបមេធាវីខ្ញុំឲ្យធ្វើយ៉ាងណាដើម្បីសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំមានលទ្ធភាពអតិបរមា ត្រូវបានតុលាការកំពូលទទួលបាន គឺថាឲ្យចំណាយពេលវេលាដែលគេផ្តល់ឲ្យក្នុងក្របខណ្ឌនៃការការពារក្តីខ្ញុំ ដើម្បីរៀបចំសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំឲ្យបានល្អចុះ ។ មានន័យថា គាត់ពុំអាចមកចូលរួមសវនាការក្នុងការកាត់ក្តីសំណុំរឿង០០២ បានទេ ។ ទោះបីជាការកាត់ក្តីជាកិច្ចការពារក្តីខ្ញុំក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះ មានសារសំខាន់យ៉ាងណាក៏ដោយ ព្រោះបើគាត់មកចូលរួមក៏គាត់មិនអាចរៀបចំកិច្ចការពារក្តីខ្ញុំបានល្អដែរ ហើយក៏គ្មានពេលរៀបចំសារណាបណ្តឹងឧទ្ធរណ៍បានល្អផងទៀតនោះទេ ។ សរុបមកបើមេធាវី ខ្ញុំងាកមកចូលរួមសវនាការក្នុងការកាត់ក្តីសំណុំរឿង០០២ ដំណាក់កាលទី២ បើនិយាយតាមពាក្យបុរាណខ្មែរ "ទន្សាយក៏រួច ត្រីរ៉ស់ក៏រួច" ។ ដូច្នេះ ខ្ញុំយកវិធីណាក៏ដៀសមិនផុតពីត្រូវប៉ះពាល់ដល់កិច្ចការពារក្តីរបស់ខ្ញុំ ។ ក្រោយពីបានគិតពិចារណា ហើយពិគ្រោះពិភាក្សាជាមួយមេធាវីខ្ញុំទៅខ្ញុំសម្រេចជ្រើសរើសយកវិធីដែលប៉ះពាល់ដល់កិច្ចការពារក្តីខ្ញុំ មិនសូវធ្ងន់ធ្ងរពេក ។ ចំណែកឯខ្លួនខ្ញុំវិញ ចាប់ពីថ្ងៃបើកសវនាការកាត់ក្តីខ្ញុំមក ខ្ញុំបានខិតខំធ្វើការលើសំណុំរឿងរបស់ខ្ញុំគ្មានឈប់ឈរទេ ។ ថ្មីៗនេះ ខ្ញុំហត់នឿយពេកទៅទៅជាធ្លាក់ខ្លួនឈឺ ហើយត្រូវទៅសម្រាកពេទ្យដោយខ្ញុំធ្វើការហួសកម្លាំង ។ តាមច្បាប់នៅក្នុងតុលាការ ខ្ញុំត្រូវមានលទ្ធភាពពេញលេញដើម្បីរួមធ្វើការជាមួយក្រុមការពារក្តីខ្ញុំបាទ ដរាបណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំមិនទាន់ចប់សព្វគ្រប់ ដើម្បីយកទៅដាក់ឲ្យទាន់ពេលវេលា ។ ប៉ុន្តែខ្ញុំដឹងថា ខ្ញុំមិនមានសេរីភាពដូចមេធាវីខ្ញុំទេ ដូច្នេះខ្ញុំមិនបាច់មកចូលរួមសវនាការនេះ ហើយបន្តធ្វើការតទៅទៀតនៅក្នុងបន្ទប់ឃុំឃាំង ។ ដូច្នេះ ថ្ងៃនេះខ្ញុំសូមប្រកាសជាឱឡារិកថា ដើម្បីខ្ញុំអាចចំណាយពេលធ្វើការតទៅទៀតក្នុងការការពារក្តីលើបណ្តឹងឧទ្ធរណ៍របស់ខ្ញុំ ខ្ញុំមិនមានបំណងមកចូលរួមសវនាការទេ បើតុលាការបង្ខំឲ្យខ្ញុំចូលរួមសវនាការ ជាការពិតហើយ ខ្ញុំមិនអាចប្រឆាំងបានទេ ។ ប៉ុន្តែខ្ញុំត្រូវការឲ្យមានការកត់ត្រាក្នុងកំណត់ឲ្យច្បាស់លាស់ថា រាល់ថ្ងៃដែលខ្ញុំត្រូវមកមានមុខនៅទីនេះ គឺដោយសារមានការបង្ខិតបង្ខំ ហើយនេះជាការរំលោភលើសិទ្ធិរបស់ខ្ញុំ ដែលខ្ញុំត្រូវមានដើម្បីខ្ញុំអាចចូលរួមធ្វើការក្នុងការរៀបចំសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំរហូតដល់បានត្រូវយកទៅដាក់នោះ ។ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះដោយឱឡារិកយ៉ាងនេះដើម្បីជ្រាប ។

សូមអរគុណ! ខ្ញុំសូមបន្ថែមបន្តិច ចំពោះសំណួរលោកប្រធានដែលបានលើកឡើងចំពោះខ្ញុំពីព្រឹកមិញ ខ្ញុំសូមជម្រាបលោកប្រធាននៅពេលណាដែលមេធាវីខ្ញុំ និងខ្ញុំរៀបចំសារណាឧទ្ធរណ៍បានចប់សព្វគ្រប់ ហើយយកទៅដាក់ទាន់ពេលវេលា ព្រមទាំងនៅពេលណាដែលមេធាវីទាំងអស់គ្នាខ្ញុំទាំងអស់គ្នា ក៏ត្រឡប់មកចូលរួមសវនាការនេះវិញ ។ បាទ! សូមជម្រាបប៉ុណ្ណឹងបាទ ។ អរគុណ ។

មេធាវីការពារជនជាប់ចោទ ខៀវ សំផន គឺមេធាវី អង់តា ហ្គីសសេ បានថ្លែងបន្តបន្ទាប់ពី ខៀវ សំផន ថា "ចម្លើយរបស់ ខៀវ សំផន គឺច្បាស់លាស់ហើយជាពិសេសគឺថា ការប្តឹងឧទ្ធរណ៍នេះ គឺជាការសំខាន់ណាស់" ។ មេធាវី អង់តា ហ្គីសសេ បានបន្តទៀតថា

សវនាការក្នុងថ្ងៃនេះគឺជាតួនាទីរបស់មេធាវីការពារក្តីធ្វើយ៉ាងណាឲ្យការកាត់ក្តីបានយុត្តិធម៌ និងមកពន្យល់អំពីមូលហេតុដែល ខៀវ សំផន និងមេធាវីការពារក្តីមិនមកចូលរួមសវនាការលើសំណុំរឿង ០០២ ដំណាក់កាលទី២ទេ ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ មិនទាន់បានបញ្ចប់ទោះបីជា តុលាការចេញសេចក្តីសម្រេចផ្តុយពីអ្វីដែលជនជាប់ចោទ ខៀវ សំផន និងក្រុមមេធាវីការពារចង់បានក៏ដោយ ។

ដូច្នេះ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំទៅតុលាការកំពូល សុំឲ្យផ្តល់ពេលវេលាសម្រាប់ ខៀវ សំផន ក្នុងការសរសេរបណ្តឹងសាទុក្ខ ពីព្រោះ ខៀវ សំផន ហើយនឹងមេធាវីការពារក្តីរបស់ខ្លួនមិនអាចមកចូលរួមសវនាការនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះផង ហើយនឹងសរសេរបណ្តឹងសាទុក្ខផងក្នុងពេលជាមួយគ្នាបានទេ ។

មេធាវីការពារក្តីជនជាប់ចោទ គង់ សំអុន បានលើកឡើងពីជម្រើសរបស់ ខៀវ សំផន នៃការធ្វើពហិការមិនចូលរួមសវនាការនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះ មិនមែនជាជម្រើសល្អឥតខ្ចោះសម្រាប់កូនក្តីលោកទេ ក៏ប៉ុន្តែវាអាចបញ្ចៀសនូវចំណុចអាក្រក់ខ្លាំងដល់កូនក្តីលោកបាន ។ មេធាវីបានបន្តទៀតថា លោក និងក្រុមមេធាវីការពារក្តីអាចមើលឃើញពីភាពចាំបាច់របស់តុលាការដែលតម្រូវឲ្យពន្លឿននីតិវិធីជំនុំជម្រះនេះ ដោយសារបញ្ហាប្រឈមផ្សេងៗដែលមានដូចជា វ័យចាស់ជរារបស់ជនជាប់ចោទ និងការត្រូវចំណាយថវិកាច្រើនរបស់អង្គជំនុំជម្រះជាដើម ។ ជាការពិតណាស់ សូមអង្គជំនុំជម្រះមេត្តាពិនិត្យមើលថា បញ្ហាប្រឈមទាំងអស់នេះមិនអាចយកមកធ្វើជាមូលដ្ឋានដើម្បីបំពានសិទ្ធិការពារ ខៀវ សំផន ដែលជាជនជាប់ចោទនៅក្នុងតុលាការនេះបានទេ ។ មេធាវី គង់ សំអុន បានលើកឡើងបន្ថែមថា ទោះជាយ៉ាងណាក៏ដោយការសម្រេចមិនចូលរួមក្នុងនីតិវិធីសវនាការនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះ ក្រុមលោក និងកូនក្តីគ្មានចេតនាក្នុងការធ្វេសប្រហែស ឬមូលហេតុមិនសមហេតុផលណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះទេ ។

មេធាវីការពារក្តីបានបន្តទៀតថា សវនាការក្នុងថ្ងៃនេះ ដូចលោក លោកស្រីចៅក្រមបានជ្រាបស្រាប់ហើយថា ខៀវ សំផន គ្មានបំណងលះបង់ការចូលរួមសវនាការក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នេះទេ ។ តែបើគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើឲ្យការងារទាំងពីរដើរនៅក្នុងពេលតែមួយបាន លោកសម្រេចជ្រើសរើសយកការងារមួយដែលសំខាន់ជាងដោយទុកការងារមួយទៀតមួយអន្លើសិន ដើម្បីកុំឲ្យវាខូចការងារទាំងពីរនេះ ។ម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងក៏គ្មានបំណងដាក់ឲ្យ ខៀវ សំផន ស្ថិតនៅក្នុងស្ថានភាពជាប់គាំងមិនអាចដកឃ្លារួចដោយសារជាប់រវល់នឹងការរៀបចំសរសេរបណ្តឹងសាទុក្ខផង និងត្រូវចូលរួមសវនាការផងក្នុងពេលតែមួយដើម្បីធ្វើឲ្យលោក ខៀវ សំផន បរាជ័យក្នុងកិច្ចការទាំងពីរនោះឡើយ ។ មេធាវី គង់ សំអុន បានរំពឹងថានេះមិនមែនជាករណីព្រួញមួយបាញ់បានសត្វពីរទេ តែវាជាករណីដែលយើងមិនអាចចាប់ត្រីពីរដោយដៃតែម្ខាងបាន ពីព្រោះវានឹងធ្វើឲ្យត្រីទាំងពីររួចទាំងអស់ ។ខ្ញុំអាចមើលឃើញនូវការលំបាករបស់តុលាការនេះ ក៏ប៉ុន្តែតុលាការត្រូវតែយល់អំពីផលប្រយោជន៍ និងការអនុវត្តច្បាប់ជាពិសេសពាក់ព័ន្ធនឹងការអនុវត្ត សិទ្ធិស្របច្បាប់របស់លោក ខៀវ សំផនផងដែរ ។

ហេតុនេះអង្គជំនុំជម្រះ អាចលើកសវនាការ ឬក៏លោកអាចបន្តសវនាការដោយគ្មានការចូលរួមពីមេធាវីការពាររបស់លោក ខៀវ សំផន ។ បើមិនដូច្នោះទេ មេធាវីការពារក្តីជនជាប់ចោទក៏គ្មានអ្វីនឹងស្នើសុំទាមទារទៀតដែរ ដោយហេតុថាអង្គជំនុំជម្រះបានសម្រេចរួចហើយក្នុងការបដិសេធឲ្យសំណើជាបន្ទាន់របស់ក្រុមមេធាវី ដើម្បីលើកពេលវេលាសវនាការនេះ ។

បន្ទាប់ពីបញ្ចប់ការឆ្លើយតបរបស់ខ្លួន ក្រុមមេធាវីការពារក្តី ខៀវ សំផន និង នួន ជា បានចាកចេញពីបន្ទប់សវនាការដើម្បីធ្វើពហិការ និងដើម្បីធ្វើការលើបណ្តឹងឧទ្ធរណ៍ដែលកូនក្តីរបស់ខ្លួនណែនាំឲ្យធ្វើ ។

ក្រោយពីចាកចេញរបស់ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីរក្រុម អង្គជំនុំជម្រះបានប្រកាសផ្អាកសវនាការដោយសារជនជាប់ចោទពុំមានមេធាវីដើម្បីការពារ ។

សវនាការនេះបានបញ្ចប់នៅម៉ោង ៧:៥៣នាទី នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៤ ។

**លីម ឋ័យឆ័ត្ត, ឌី សុផាតា និង ធួន ឡៃហុល**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្ដី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្ដល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# សំណើសុំធ្វើការផ្លាស់ប្តូរទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**(តចប់)**

អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ពុំមានយន្តការណាមួយនៅក្នុងសំណើសុំធ្វើការកែប្រែលើវិធានផ្ទៃក្នុងបានលើកឡើង ឬដាក់ចេញនូវយុទ្ធសាស្ត្រផ្សះផ្សាជាក់លាក់ណាមួយសម្រាប់ជម្លោះរវាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ការមិនបានចែងអំពីយន្តការ ជាដំណោះស្រាយសម្រាប់ជម្លោះនេះនៅក្នុងសំណើសុំធ្វើការកែប្រែវិធានផ្ទៃក្នុង គឺជាការគេចវេះពីភាពប្រាកដប្រជាមួយដែលជម្លោះនេះ អាចកើតឡើង ។ ជម្លោះនេះអាចកើតឡើងរវាងមេធាវី ជាពិសេស នៅពេលដែល ពួកគេតំណាងឲ្យកូនក្តីជាច្រើន ដែលមានផលប្រយោជន៍ និងគោលបំណងផ្សេងៗគ្នា ។ សំណើសុំធ្វើការកែប្រែ វិធានផ្ទៃក្នុងគ្រាន់តែចែងថាការដោះស្រាយជម្លោះបែបនេះគឺជា «ទំនួលខុសត្រូវរបស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី» ។ នៅពេលដែលសំណើចែងថាសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនឹងដោះស្រាយជម្លោះប្រភេទនេះមិនខុសពីអ្វីឲ្យសត្វចចកគ្រប់គ្រងសម្បុកមាន់នោះទេ ពីព្រោះសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីមួយនៃជម្លោះ ។ សំណើសុំធ្វើការកែប្រែលើវិធានផ្ទៃក្នុងនេះក៏មិនបានផ្តល់អ្វីដែលអាចជំរុញឲ្យសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី គិតពិចារណាពីគំនិតជំទាស់របស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ក្នុងករណីដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំទាស់យ៉ាងខ្លាំងចំពោះសេចក្តីសម្រេចរបស់សហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនោះមានតែជម្រើសពីរប៉ុណ្ណោះ ដែលអាចប្រព្រឹត្តទៅបាន គឺនៅបន្តមុខងារជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ទោះបីខ្លួនមានការជំទាស់ក៏ដោយ ឬលាលែងពីការងារ ។ ដោយសារតែមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានភារកិច្ចតំណាងឲ្យទស្សនៈ ក៏ដូចជាផលប្រយោជន៍របស់កូនក្តីខ្លួននេះនាំឲ្យពួកគេស្ថិតនៅក្នុងស្ថានភាពទាល់ច្រកមួយ ។

ទន្ទឹមនឹងនេះដែរ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ក៏ត្រូវបានកាត់បន្ថយអស់ជាច្រើន ។ ក្នុងអំឡុងពេលនៃដំណើរការសវនាការបឋម ដើមបណ្តឹងរដ្ឋប្បវេណីអាចជ្រើសរើសមេធាវីតំណាងឲ្យខ្លួនដោយសេរី តែនៅពេលដែលសវនាការចាប់ផ្តើមអ្នកទាំងនេះបែរជាបាត់បង់នូវសិទ្ធិអំណាចជ្រើសរើសអ្នកតំណាងឲ្យខ្លួន ។ ក្នុងអំឡុងពេលនៃសវនាការ និងក្រោយមកទៀត ដើមបណ្តឹងរដ្ឋប្បវេណីណាដែលចង់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ត្រូវតែតំណាងដោយសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិក្នុងការជ្រើសរើសនូវអ្នកតំណាងរបស់ខ្លួនក្នុងកិច្ចដំណើរការនីតិវិធីនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីពុំអាចបញ្ឈប់សហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមានការមិនពេញចិត្តចំពោះរបៀបសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋវេណីតំណាងឲ្យផលប្រយោជន៍របស់ខ្លួនក៏ដោយ ។ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បញ្ជាក់យ៉ាងច្បាស់ថា មេធាវីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវតែ «មានជំនាញផ្នែកច្បាប់តាមបទដ្ឋាន និងប្រកបដោយក្រមសីលធម៌» ។ ទោះបីជាការដាក់កម្រិតបែបនេះនៅក្នុងសំណើសុំធ្វើការកែប្រែលើវិធានផ្ទៃក្នុង ហាក់បីដូចជា រំលោភបំពានដល់ច្បាប់ទូន្មានរបស់មេធាវីមួយចំនួនដែលសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់កូនក្តីក្នុងការសម្រេចចិត្តអំពីគោលដៅនៃការតំណាង ក៏ដូចជាការជួល និងការបញ្ឈប់មេធាវីរបស់ពួកគេ ជាឧទាហរណ៍ ក្រឹត្យក្រមនេះរួមមាននៅក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីអន្តរជាតិ គណៈមេធាវីអាមេរិក និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិផងដែរ ។ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា សហមេធាវីនាំមុខតំណាងឲ្យ

ដើមបណ្តឹងរដ្ឋប្បវេណី មិនបានតំណាងឲ្យផលប្រយោជន៍របស់ខ្លួននោះទេ ជម្រើសតែមួយគត់របស់ពួកគេ គឺដកខ្លួនទាំងស្រុងចេញពីដំណើរការនីតិវិធី ។ លទ្ធផលដែលមិនសមស្របនេះត្រូវបានបង្ហាញឡើងច្បាស់ ដោយសារ តែដើមបណ្តឹងភាគច្រើននៅក្នុងសំណុំរឿង ០០២ មានសញ្ជាតិ និងសាសនាខុសប្លែកពីគ្នា ហើយពួកគេត្រូវទទួលរងគ្រោះក្នុងពេលផ្សេងគ្នា ទីកន្លែងខុសគ្នា ដោយជនល្មើសផ្សេងពីគ្នាដែរ ដូច្នេះ ដើមបណ្តឹងទាំងអស់អាចមានគោលដៅនៃការចូលរួមផ្សេងៗពីគ្នា ហើយក៏អាចចង់បានទម្រង់នៃសំណងខុសៗគ្នាដែរ ។

## សិទ្ធិក្នុងការចូលរួម

យោងទៅតាមសេចក្តីព្រាងដំបូងនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី «ជនរងគ្រោះនឹងក្លាយទៅជាភាគីមួយក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ» ។ ជាលទ្ធផល ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិ «ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយគាំទ្រដល់ការកាត់ទោស» ក៏ដូចជាស្នើសុំ «សំណងផ្លូវចិត្ត និងសំណងសមូហភាព» ។ សិទ្ធិក្នុងការចូលរួមពេញលេញនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងនាមជាភាគីនេះភ្ជាប់មកជាមួយនូវសិទ្ធិជាក់លាក់មួយចំនួនមានដូចជា សិទ្ធិក្នុងការកោះហៅពិនិត្យ និងសួរដេញដោលសាក្សី រួមទាំងត្រូវបានសួរចម្លើយក្នុងនាមជាភាគីដែលជាប់ពាក់ព័ន្ធ និងធ្វើការស្នើសុំបំពេញកិច្ចស៊ើបសួរក្នុងចំណោមសិទ្ធិដទៃទៀត ។

ជាមួយនឹងសំណើសុំធ្វើការកែប្រែលើវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាមិនត្រូវបានចាត់ទុកថាជា «ភាគី» នៅក្នុងកិច្ចដំណើរការនីតិវិធីទៀតទេ ។ សេចក្តីព្រាងនៃវិធានផ្ទៃក្នុងនាពេលបច្ចុប្បន្នបានចែងថា ដើមបណ្តឹងរដ្ឋប្បវេណី «ម្នាក់ៗអាចក្លាយជាភាគីនៅក្នុងកិច្ចដំណើរការនៃនីតិវិធីព្រហ្មទណ្ឌនៅក្នុងសវនាការបឋម» ។ ពុំមានមាត្រាណាមួយនៅក្នុងសំណើស្នើសុំធ្វើការកែប្រែលើវិធានផ្ទៃក្នុងបានចែងច្បាស់លាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីនៅនឹងបន្តជា «ភាគី» នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងអំឡុងពេលជំនុំជម្រះ ដែលជាដំណាក់កាលដ៏សំខាន់បំផុតក្នុងកិច្ចដំណើរការនីតិវិធី ។ ដូច្នេះ វាជាការដែលគួរសម្គាល់មួយដែលសេចក្តីព្រាងនៃវិធានផ្ទៃក្នុងចែងថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់សក្ខីកម្ម «ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសាក្សី» នេះជាការផ្លាស់ប្តូរមួយយ៉ាងខ្លាំងពីវិធានផ្ទៃក្នុងមុនៗ ដោយអនុលោមទៅតាមនីតិវិធីនៅក្នុងកម្ពុជាបានចែងថា នៅពេលដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនឹងមិនត្រូវបានចោទសួរដូចសាក្សីធម្មតានោះទេ ។»

លើសពីនេះទៅទៀត ដោយសារតែសិទ្ធិនៃដើមបណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី យោងទៅតាមសេចក្តីព្រាងនៃវិធានផ្ទៃក្នុង សិទ្ធិជាច្រើននឹងត្រូវបានចាត់ថា ជាការបំភាន់ភ្នែកតែប៉ុណ្ណោះ ។ ឧទាហរណ៍ សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសំខាន់ជាចម្បងដែលផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងយុត្តាធិការ ប្រព័ន្ធច្បាប់ស៊ីវិលនៅលើសកលលោក ក៏ដូចជាប្រទេសកម្ពុជាដែរ នោះ គឺជាសិទ្ធិក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ។ ផ្អែកទៅលើសេចក្តីព្រាងវិធានផ្ទៃក្នុង វាពុំមានភាពជាក់លាកថា តើដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែមានសិទ្ធិនេះដែរឬទេ ។ ពីមុន សិទ្ធិនេះត្រូវបានអនុវត្តឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ នាពេលបច្ចុប្បន្ន យើងអាចសន្និតបានថា សិទ្ធិនេះនឹងត្រូវអនុវត្តដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយយោងទៅតាមសំណើស្នើសុំ កែប្រែលើវិធានផ្ទៃក្នុង ។ ប៉ុន្តែ សហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី មានទំនួលខុសត្រូវចំពោះផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលស្ថិតក្នុងក្រុម ។ ដូច្នេះ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី មួយក្រុមចង់ធ្វើសំណើបំពេញកិច្ចស៊ើបសួរ តែសហមេធាវីនាំមុខឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ថា សកម្មភាពនេះអាចប្រឆាំងនឹងយុទ្ធសាស្ត្រទាំងមូល នោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចច្រានចោលនូវសំណើ ដែលសុំឲ្យមានការបំពេញកិច្ចស៊ើបសួរ ទង្វើនេះនឹងបណ្តាលឲ្យសិទ្ធិនេះមានភាពមិនជាក់លាក់ ។ កង្វះខាតនៃយន្តការចំពោះបញ្ហានេះបង្កឲ្យមានភាពស្មុគស្មាញកាន់តែខ្លាំង ។

ដូចដែលចៅក្រម ឡាវែរ៉ញ បានលើកឡើងនៅក្នុងគំនិតជំទាស់របស់គាត់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលស្ថិតនៅក្នុងយុត្តាធិការថ្នាក់ជាតិ «អាចចូលរួមគ្រប់ដំណើរការនីតិវិធីផ្លូវច្បាប់ក្នុងគោលបំណងរួមមួយ ដើម្បីបញ្ជាក់ឲ្យច្បាស់ពីភាពពិតនៃទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដែលអាចជាមូលដ្ឋាននៃទំនួលខុសត្រូវ ផ្នែករដ្ឋប្បវេណីរបស់ជនជាប់ចោទផងដែរ ។ ការយល់ឃើញនេះត្រូវបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនាឆ្នាំ២០០៩ ដែលសម្រេចលុបបំបាត់ចោលទាំងស្រុងនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមនៅក្នុងដំណើរការកាត់ទោស និងធ្វើការកាត់បន្ថយយ៉ាងខ្លាំងទៅលើសិទ្ធិសួរដេញដោលសាក្សីជាក់លាក់ណាមួយ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដាក់ចេញនូវច្បាប់ផ្ទុយពីការអនុវត្តរបស់តុលាការអន្តរជាតិដទៃទៀតដែលអនុញ្ញាតឲ្យជនរងគ្រោះចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ទោះបីមិនមែនក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ជនរងគ្រោះនៅតែទទួលបានសិទ្ធិចូលរួមក្នុងដំណើរការកាត់ទោសផងដែរ ។

ទោះបីជា សំណើសុំការផ្លាស់ប្តូរទាក់ទងនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនអាចទទួលបានការសម្រេចភ្លាមៗក៏ដោយ ជាមួយនឹងការលុបសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងដំណើរការកាត់ទោស ការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ ការសួរដេញដោលសាក្សីជាក់លាក់ និងការផ្តល់សក្ខីកម្មក្នុងនាមជាភាគីមិនមែនជាសាក្សីធម្មតានោះទេបានបង្ហាញថា «ដើមបណ្តឹងរដ្ឋប្បវេណី» នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជា «ភាគី» ក្នុងកិច្ចដំណើរការនីតិវិធីទៀតទេ ។

**សេចក្តីសន្និដ្ឋាន**

ប្រសិនបើសេចក្តីព្រាងនៃវិធានផ្ទៃក្នុងនេះត្រូវបានអនុម័ត តើតួនាទីពេញលេញមួយណាដែលដើមបណ្តឹងរដ្ឋប្បវេណីនៅតែមាននៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប៉ុន្តែ អ្វីដែលជាក់លាក់នោះគឺអ្នកចូលរួមដែលជាអ្នករស់រានមានជីវិតទាំងនេះនឹងមិនមែនជា «ដើមបណ្តឹងរដ្ឋប្បវេណី» ពិតប្រាកដក្នុងន័យច្បាប់ទេ ។ សិទ្ធិជាច្រើនរបស់ពួកគេក្នុងនាមជាភាគីនឹងត្រូវបានដកចេញ ដោយសារតែមូលហេតុការគ្រប់គ្រងនៃតុលាការលើពាក្យបណ្តឹង ។ អង្គជំនុំជម្រះមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការអនុវត្តសកម្មភាពទាំងនេះ ប៉ុន្តែ ប្រសិនបើអង្គជំនុំជម្រះចង់បញ្ចប់នូវការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះគួរតែមានភាពស្មោះត្រង់ចំពោះអ្នករស់រានមានជីវិតអំពីរឿងនេះ ។ ដូចដែលអ្នកអង្កេតការណ៍ពីររូបបានបញ្ជាក់ថា «ប្រសិនបើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជំនួសដោយតំណាងផលប្រយោជន៍របស់ជនរងគ្រោះ តុលាការត្រូវតែបកស្រាយដល់អ្នកដាក់ពាក្យបណ្តឹងថាសិទ្ធិនៃការចូលរួមរបស់គេត្រូវបានលុបបំបាត់ ។

ដូចគ្នានឹងការលើកឡើងរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានថ្លែងថា វាជាការពិតដែលដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនពុំបានយល់ច្បាស់អំពីអត្ថន័យនៃពាក្យថា «ដើមបណ្តឹងរដ្ឋប្បវេណី» និងដែនកំណត់នៃតួនាទីរបស់គេក្នុងដំណើរការនីតិវិធី ។ ទោះបីជាយ៉ាងណាក៏ដោយ វាគឺជារឿងមិនស័ក្តិសមមួយដែលតុលាការធ្វើការលាក់កំបាំងនូវភាពបរាជ័យរបស់កម្មវិធីផ្សព្វផ្សាយ ។ ប្រសិនបើតុលាការចង់កម្រិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការមានកាតព្វកិច្ចក្នុងការបកស្រាយនូវការចូលរួមក្នុងដំណើរការតុលាការដ៏ពេញលេញនេះទាំងស្រុងជូនសាធារណជនទូទៅ និងអ្នកដាក់ពាក្យបណ្តឹងមុនពេលដែនការចុងក្រោយបានត្រូវអនុម័ត ។

ដោយសារអ្នករស់រានមានជីវិតទាំងនេះ បានទទួលរងនូវការឈឺចាប់ដ៏ធ្ងន់ធ្ងរ និងឆ្លងកាត់នូវបទពិសោធដ៏ជូរចត់យ៉ាងហោចណាស់ជាអ្វីអង្គជំនុំជម្រះគួរតែធ្វើ ។ **អេនឡូ អេហ្វ ជាយអាមិន**

**អានទស្សនាវដ្តីតាមគេហទំព័រ**

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ការឆ្លើយតបទៅអត្ថបទរបស់ រ៉េនឌុល ជីហ្វាលក្វ : ការបកស្រាយពាក្យ «អ្នកទទួលខុសត្រូវខ្ពស់បំផុត» នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

(តចប់)

***សេចក្តីសន្និដ្ឋានរបស់ រ៉េនឌុល ដែលយល់ឃើញថា ជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"***

ជាចុងក្រោយ រ៉េនឌុល ពិនិត្យទៅលើការចោទប្រកាន់ប្រឆាំងនឹងបុគ្គលមួយចំនួន ដែលខ្លួនជឿជាក់ថា ជាជនសង្ស័យ ដោយផ្អែកទៅលើឯកសារបែកធ្លាយមួយចំនួនត្រូវបានគេជឿជាក់ថា ជាដីកាបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង០០៣ និងសំណុំរឿង ០០៤ និងការចោទប្រកាន់មួយចំនួនបង្កើតឡើងដោយ ហេដឌ័រ នៅក្នុងសៀវភៅមានចំណងជើងថា "បេក្ខជនទាំងប្រាំពីររូបប្រឈមមុខនឹងការជំនុំជម្រះ" ។ រ៉េនឌ័រ ធ្វើសេចក្តីសន្និដ្ឋានថា ផ្អែកទៅលើការចោទប្រកាន់ទាំងអស់នេះ "ការជំនុំជម្រះនៅក្នុងសំណុំរឿងទាំងពីរ អាចត្រូវបានយកមកធ្វើការការពារក្តីនៅក្នុងដំណាក់កាលនេះ ហើយបច្ច័យណាមួយផ្សេងពីនេះ គួរតែត្រូវបានមើលឃើញថា ជាការវិនិច្ឆ័យដោយមិនមានលក្ខណៈវិជ្ជាជីវៈត្រឹមត្រូវ និងមិនមានសុចរិតភាព" ។ រ៉េនឌុល បានថ្លែងបញ្ជាក់ថា ប្រសិនជាសំណុំរឿងអាចត្រូវបានច្រានចោល "ទង្វើបែបនេះនឹងជួយដល់សុចរិតភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរងការរិះគន់ក្នុងនាមជាស្ថាប័នច្បាប់មួយ" ។ ខុសពីសហចៅក្រមស៊ើបអង្កេត រ៉េនឌុល មិនទទួលបានផលប្រយោជន៍ពីការពិនិត្យលើខ្លឹមសារនៅក្នុងដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ប៉ុន្តែឯកសារទាំងឡាយដែលប្រមូលបានក្នុងការស៊ើបអង្កេតរបស់តុលាការអស់រយៈកាលជាច្រើនឆ្នាំ ។



ម៉ៃឃើល កាណាវ៉ាស (រូបថត អ.វ.ត.ក)

ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបអង្កេតគឺជាការចោទប្រកាន់ដែលធ្វើឡើង បន្ទាប់ពីការស៊ើបអង្កេតបឋមបានបញ្ចប់ ។ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានតម្រូវឲ្យកំណត់នូវជនសង្ស័យ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្រោយពីការបញ្ចប់នៃការស៊ើបអង្កេតបឋមជាមុនសិន មុននឹងអាចបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលបង្ហាញពីអត្តសញ្ញាណរបស់ជនសង្ស័យ ។ សេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានច្រានចោលដោយសហព្រះរាជអាជ្ញាជាតិ រួមទាំងសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និងចៅក្រម ប្លាំង (យ៉ាងហោចណាស់មានការជំទាស់ទាក់ទិននឹងជនសង្ស័យមួយចំនួន) ដោយសារតែការបិទការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ដោយគ្មានការចោទប្រកាន់ណាមួយឡើយ ។ ការស៊ើបអង្កេតរបស់តុលាការគឺធ្វើឡើងដើម្បីកំណត់ថាតើមានភស្តុតាងគ្រប់គ្រាន់ដែលប្តូទេ ដើម្បីគាំទ្រដល់ការចោទប្រកាន់ ធ្វើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ការកំណត់បឋមរបស់សហព្រះរាជអាជ្ញាអន្តរ

ជាតិមិនអាចទទួលយកបានដោយគ្មានការស៊ើបអង្កេតរបស់តុលាការពេញលេញ ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត ខកខានមិនបានធ្វើការស៊ើបអង្កេតឲ្យបានពេញលេញ ហើយធ្វើសេចក្តីសម្រេចដោយខ្លួនឯងផ្ទាល់ថា តើជនសង្ស័យរូបណាមួយអាចត្រូវបានចាត់ទុកជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ទង្វើនេះជាការបោះបង់ចោលមុខតំណែងជា សហចៅក្រមស៊ើបអង្កេតរបស់ខ្លួន ។

ម្យ៉ាងទៀត វ៉េនឌល បានធ្វើការប្រៀបធៀបខុសនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានអំពីជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ។ វ៉េនឌល ប្រៀបធៀបការចោទប្រកាន់នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ទៅនឹងករណី លូគិក មីកូសូវិក និងឌីលិក នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលសំណុំរឿងទាំងអស់នេះមិនត្រូវបានបញ្ជូនទៅកាន់តុលាការថ្នាក់ជាតិ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ពីព្រោះជនសង្ស័យទាំងអស់ត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ។ វ៉េនឌល ក៏ចង្អុលបង្ហាញថា នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ជនសង្ស័យដល់ទៅ១២រូប យោងទៅតាម វ៉េនឌល ទោះបីជាពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខន្តិកៈរបស់តុលាការពិសេសមួយនេះថាមានលក្ខណៈតូចចង្អៀតជាងពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅសាលាក្តីខ្មែរក្រហមក៏ដោយ ។

ដោយសារតែ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោះស្រាយព្រឹត្តិការណ៍ជាអង្គហេតុខុសគ្នា ការប្រៀបធៀបសំណុំរឿងដែលត្រូវបានជំនុំជម្រះនៅក្នុងតុលាការផ្សេងពីគ្នា ហាក់បីដូចជាគ្មានប្រយោជន៍ឡើយ ។ មីលាន លូគិក ប្រហែលជាត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់" ចំពោះឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនដែលបានប្រព្រឹត្តឡើងនៅអតីតប្រទេសយូហ្គោស្លាវី ហើយឧក្រិដ្ឋកម្មទាំងអស់នេះប្រហែលជាមានស្ថានទម្ងន់ស្រាលជាងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាមានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ នេះមិន បានបង្ហាញប្រាប់យើងថាតើជនសង្ស័យ នៅក្នុងសំណុំរឿង០០៣ និង០០៤ គួរតែចាត់ទុកជា "អ្នកទទួលខុស ត្រូវខ្ពស់" ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ។ ប្រហែលជាមានបុគ្គលចំនួន១២រូប ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅប្រទេសសេរ៉ាឡេអូន ។ ប៉ុន្តែ នេះនៅតែមិនបានបង្ហាញឲ្យយើងឃើញថាតើមនុស្សចំនួនប៉ុន្មាននាក់គួរតែចាត់ទុកថា ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។

ការប្រៀបធៀបដែលស័ក្តិសមតែមួយគត់ ដើម្បីកំណត់ថាតើជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតឬមួយយ៉ាងណា គឺប្រៀបធៀបស្ថានទម្ងន់ទោសនៃឧក្រិដ្ឋកម្ម ដែលពួកគេត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ពួកគេ ជាមួយនឹងជនជាប់ចោទត្រូវបានរកឃើញពិរុទ្ធភាពនៅក្នុងសំណុំរឿង០០២ និង០០៣ ។ វ៉េនឌល ខកខានមិនបានធ្វើការប្រៀបធៀបនេះ ។

### ៣) សេចក្តីសន្និដ្ឋាន

និយមន័យច្បាប់នៃពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ងាយនឹងទទួលរងឥទ្ធិពល ។ ឧទាហរណ៍ ករណី លូគិក នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក់ ហាម៉ុន (ធ្លាប់បម្រើការជាមេធាវីជាន់ខ្ពស់) ព្រះរាជអាជ្ញាបានតវ៉ាថាករណីនេះគួរតែផ្ទេរទៅតុលាការជាតិវិញ ថ្វីបើមានស្ថានទម្ងន់នៃឧក្រិដ្ឋកម្មច្បាស់លាស់ក៏ដោយ ។

លូគិក ដែលចង់ឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវីកាត់ទោសខ្លួនជាជាងតុលាការថ្នាក់ជាតិនៅប្រទេសបូស្នៀហឺហ្ស៊េហ្គោវីណា (និងអនុវត្តទោសរបស់ខ្លួនក្នុងពន្ធនាគារនៅប្រទេសបូស្នៀហឺហ្ស៊េហ្គោវីណា) បានអះអាងថា "កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ និងស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់" មិនស័ក្តិសមចំពោះការផ្ទេរសំណុំរឿង ។ នៅក្នុងសវនាការ មុខងាររបស់ភាគីទាំងឡាយច្បាស់ណាស់ត្រូវបានផ្លាស់ប្តូរ ។ ទង្វើនេះ នាំឲ្យមានការពិចារណាសំដីរបស់ចៅក្រមជនជាតិអង់គ្លេស លោក អេតឃីន (Atkin) ដែលត្រូវបានដកស្រង់ដោយចៅក្រម ដេវីត ហាត (David Hunt) នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស យូហ្គោស្លាវីថា ៖

ខ្ញុំយល់ឃើញថាមានអំណាចតែមួយគត់ ដែលអាចផ្តល់ហេតុផលចំពោះការតាក់តែងពាក្យនេះឡើងៈ

“នៅពេលដែលខ្ញុំប្រើពាក្យមួយ” ហាមផី ដាមផី (Humpty Dumpty ជាតួអង្គមួយក្នុងរឿងព្រេង Alice in Wonderland) និយាយបែបចំអក “ពាក្យហ្នឹងមានន័យដូចអ្វីដែលខ្ញុំជ្រើសរើសឲ្យមានន័យអ៊ីចឹងដែរ វាមិនអាចមានន័យច្រើនជាង ឬតិចជាងនោះទេ” ។ អាលីស និយាយថា “សំណួរសួរថាតើអ្នកអាចធ្វើឲ្យពាក្យមួយមានន័យច្រើនដែរឬទេ?” ។ “សំណួរសួរថា” ហាមផី ដាមផី និយាយតបវិញ “នរណាគឺជាចៅហ្វាយនាយ? រឿងហ្នឹងវាតែប៉ុណ្ណឹងទេ ។”

ពីព្រោះពាក្យ “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ងាយទទួលរងឥទ្ធិពល ការពិចារណាលើប្រវត្តិចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងគោលបំណងរបស់អ្នកតាក់តែងឯកសារទាំងឡាយដើម្បីបង្កើតតុលាការមានសារសំខាន់ណាស់ ។ ដូចដែលបានពិភាក្សាខាងលើ អ្នកតាក់តែងពាក្យនេះចង់ឲ្យពាក្យនេះ មានន័យចង្អៀត ។ ជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ នឹងត្រូវចាត់ទុកជាអ្នកទទួលខុសខ្ពស់បំផុត ឬក៏អត់ គឺអាស្រ័យលើការស៊ើបអង្កេតរបស់តុលាការ មិនមែនអាស្រ័យតែលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឬក៏គំនិតយោបល់របស់ រ៉េនឌល នោះទេ ។

ការវិភាគរបស់ រ៉េនឌល ផ្អែកទៅលើការអះអាងថា ជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវតែនាំមកជំនុំជម្រះ ពីព្រោះជនសង្ស័យទាំងអស់នេះត្រូវបានចោទប្រកាន់ថា ជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ។ ក្នុងករណីដែលជនសង្ស័យទាំងនេះមិនត្រូវបានកាត់ក្តីដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ពួកគេនឹងគេចពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងអស់ ។ កំហុសនៅក្នុងការវិភាគរបស់ រ៉េនឌល កើតចេញពីការប្រើប្រាស់វិធីសាស្ត្រដែលមាននិន្នាការទៅរកលទ្ធផល នៅពេល រ៉េនឌល ព្រាងអត្ថបទនេះ ។ រ៉េនឌល ជ្រើសរើសតែឯកសារណាធានាបាននូវលទ្ធផលមួយដែលខ្លួនចង់បាន ។

រ៉េនឌល បានកំណត់ទុកជាមុនរួចហើយថាជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និង០០៤ គឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ចំពោះបទល្មើសដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់សាលាក្តី បន្ទាប់មក ក៏សរសេរអត្ថបទមួយក្នុងគោលបំណងបង្ហាញពីការយល់ឃើញនេះ និងជំរុញឲ្យសហចៅក្រមស៊ើបអង្កេត ចោទប្រកាន់ជនសង្ស័យ ។ រ៉េនឌល ប្រហែលជាជ្រើសរើសយកវិធីសាស្ត្រនេះ ដោយសារតែគាត់ជាទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការមួយបង្កើតឡើងដើម្បីបញ្ជាក់អំពីការសន្និដ្ឋានហើយជាមុន ដែលថា មានការកើតឡើងនូវអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា ។ ដោយសារតែអត្ថបទដែលមានចំណងជើងថា សំណុំរឿង០០៣ និង០០៤ ៈ និយមន័យនៃពាក្យអ្នកទទួលខុសត្រូវខ្ពស់បំផុតផ្អែកលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ សរសេរដោយទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អត្ថបទរបស់ រ៉េនឌល មួយនេះមិនអាចចាត់ទុកបានថា ជាការវិភាគអព្យាក្រឹតទេ ។ អត្ថបទនេះជាការជំទាស់យ៉ាងខ្លាំង និងត្រូវបានសរសេរឡើងក្នុងគោលបំណងជះឥទ្ធិពលទៅលើសហចៅក្រមស៊ើបអង្កេតឲ្យងាកទៅរកលទ្ធផលមួយដែលចង់បាន ។

ដោយពិចារណាទៅលើតួនាទីនិងគោលបំណងរបស់ រ៉េនឌល ការបង្កើតកំហុសដ៏ធ្ងន់ធ្ងរនៅក្នុងការអះអាងរបស់គាត់មិនមែនជារឿងអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ។ កំហុសនៅក្នុងការត្រិះរិះពិចារណារបស់ រ៉េនឌល មិនពិបាកនឹងយល់នោះទេ ពីព្រោះការស៊ើបអង្កេតរបស់តុលាការគឺធ្វើឡើងក្នុងគោលបំណងដើម្បីកំណត់ថា តើមានភ័ស្តុតាងគ្រប់គ្រាន់ដែរឬទេក្នុងការបង្ហាញថា ជនសង្ស័យពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមការចោទប្រកាន់ និងថាតើជនសង្ស័យទាំងនោះស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ។ លុះត្រាតែការស៊ើបអង្កេតនេះបានបញ្ចប់ហើយមានភ័ស្តុតាងសម្រាប់ការវិភាគ ទើបការសម្រេចចិត្តបែបនេះអាចធ្វើបាន ។

ការសន្និដ្ឋានរបស់ រ៉េនឌល ផ្អែកទៅលើការរកហេតុផលទាក់ទងទៅនឹងអារម្មណ៍ដែលបិទបាំងទៅដល់ការវិភាគតាមច្បាប់ដែលសមហេតុផលមួយ ។ ការខកខានមិនបានបកស្រាយច្បាប់ឲ្យបានត្រឹមត្រូវបង្ហាញឲ្យឃើញថា រ៉េនឌល មិនបានឲ្យតម្លៃទាល់តែសោះទៅដល់វិធាននៃច្បាប់ រួមមានដូចជា គោលការណ៍សច្ចាធារណ៍នៃនិរទោស និងប្រព័ន្ធនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ **ម៉ៃឃើល កាណាវ៉ាស**

# ក្លាយជាក្មេងកំព្រាដោយរបបខ្មែរក្រហម

រយៈពេល៣ឆ្នាំ ៨ខែ២០ថ្ងៃគឺជារយៈពេលដែលប្រជាជនកម្ពុជាមិនអាចបំភ្លេចបាន ពីព្រោះប្រជាជនកម្ពុជាទូទាំងប្រទេសត្រូវរស់នៅជាមួយទុក្ខវេទនា ដូចជា ការឃុំឃាំង ការធ្វើទារុណកម្ម ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំង និងសកម្មភាពអមនុស្សធម៌ផ្សេងទៀតដែលពួកខ្មែរក្រហមបានប្រព្រឹត្ត ។ ទោះបីជា របបកម្ពុជាប្រជាធិបតេយ្យ "របបខ្មែរក្រហម" បានបញ្ចប់ទៅជាង៣០ឆ្នាំក៏ដោយ ក៏ប៉ុន្តែ វាហាក់ដូចជាព្រឹត្តិការណ៍មួយដែលនៅថ្មីចំពោះម្តាយរបស់ខ្ញុំដែលធ្លាប់បានរស់នៅដោយភាពភ័យខ្លាចក្នុងរបបមួយនេះ ។



(រូបខាងឆ្វេង) ម្តាយរបស់ខ្ញុំ និងប្អូនប្រុសគាត់

ម្តាយរបស់ខ្ញុំឈ្មោះទី សុខែ ដែលមានស្រុកកំណើតនៅក្នុងស្រុកមេមត់ ខេត្តកំពង់ចាម ។ ដោយសារតែស្ថានភាពគ្រួសារលំបាក ឪពុកម្តាយបង្កើតរបស់គាត់បានយកគាត់ឲ្យទៅរស់នៅជាមួយគ្រួសារមួយដែលមានកម្រិតជីវភាពប្រសើរជាងពួកគាត់ ។ ម្តាយខ្ញុំស្ទើរតែភ្លេចមុខមាត់ឪពុកម្តាយបង្កើតរបស់គាត់ ពីព្រោះនៅពេលដែលគាត់ទៅរស់នៅជាមួយក្រុមគ្រួសារថ្មី គាត់ទើបតែមានអាយុ៨ឆ្នាំ ។ នៅក្នុងក្រុមគ្រួសារថ្មីមានកូនចិញ្ចឹមទាំងអស់ចំនួនបីនាក់ ហើយម្តាយរបស់ខ្ញុំ គឺជាកូនស្រីច្បងទី២នៅក្នុងគ្រួសារ ។ ទោះបីជាក្មេងទាំងបីនាក់នេះមកពីគ្រួសារផ្សេងពីគ្នាក៏ដោយ ក៏ប៉ុន្តែពួកគេស្រលាញ់គ្នាដូចជាបងប្អូនបង្កើតអ៊ីចឹង ។ ការរស់នៅរបស់ម្តាយខ្ញុំ គឺប្រសើរជាងមុនដោយឪពុកម្តាយចិញ្ចឹមរបស់គាត់មានកម្រិតជីវភាពល្អប្រសើរ ។

ប៉ុន្តែអ្វីៗទាំងអស់នេះបានរលាយអស់ទៅវិញនៅពេល ដែលពួកខ្មែរក្រហមឡើងគ្រប់គ្រងអំណាចនៅថ្ងៃទី១៧ មេសា ១៩៧៥ ។ ដូចក្រុមគ្រួសារដទៃទៀតក្នុងប្រទេសកម្ពុជា ក្រុមគ្រួសារម្តាយខ្ញុំត្រូវបានជម្លៀសពីស្រុកកំណើតរបស់គាត់ទៅកាន់ភូមិឡោក្រព័ន្ធ ជាភូមិមួយដែលស្ថិតនៅក្នុងស្រុកមេមត់ដែរ ។ នៅពេលនោះ ប្រជាជនមិនអនុញ្ញាតឲ្យយករបស់របរមានតម្លៃដែលជាកម្មសិទ្ធិទៅជាមួយទេ លើកលែងតែរបស់របរដែលពួកគេប្រើប្រាស់ជារៀងរាល់ថ្ងៃដូចជា សម្លៀកបំពាក់ ម្ហូបអាហារបន្តិចបន្តួចជាដើម ។

នៅតាមដងផ្លូវ ម្តាយខ្ញុំបានឃើញប្រជាជនខ្លះស្រែកយំ

ខណៈពេលដែលពួកគេកំពុងតែស្វែងរកសមាជិកគ្រួសាររបស់ពួកគេដែលបានវង្វេងបាត់ ។ បន្ទាប់ពីមកដល់ភូមិឡោក្រពន្ធ អង្គការបានចាត់ឲ្យម្ដាយខ្ញុំទៅធ្វើការនៅកងចល័តនារី ខណៈពេលដែលបងស្រីរបស់គាត់ អង្គការឲ្យធ្វើនៅកងចល័តនារីផ្សេងទៀតដែលជាកងពិសេស ។ ចំណែកឯ ឪពុកម្ដាយចិញ្ចឹមរបស់គាត់ អង្គការចាត់តាំងឲ្យទៅមើលក្មេង ពីព្រោះពួកគាត់ចាស់ពេក ដែលអង្គការមិនអាចចាត់តាំងពួកគាត់ទៅធ្វើអ្វីផ្សេងក្រៅពីហ្នឹងបាន ហើយប្អូនប្រុសពៅរបស់ម្ដាយខ្ញុំត្រូវបានចាត់តាំងដោយអង្គការទៅនៅកងកុមារ ដើម្បីដើររើសលាមកសត្វ និងធ្វើការងារផ្សេងទៀត ។ ម្ដាយរបស់ខ្ញុំមិនអាចជួបឪពុកម្ដាយ និងបងប្អូនប្រុសស្រីរបស់គាត់ទេ ទោះបីជា ពួកគាត់រស់នៅក្នុងភូមិតែមួយក៏ដោយ ។ នៅពេលនោះ គាត់ពិតជានឹកនឹងចង់ជួបឪពុកម្ដាយ និងបងប្អូនរបស់គាត់ណាស់ ប៉ុន្តែវាមិនអាចទៅរួចទេ ពីព្រោះគាត់ត្រូវតែស្នាក់នៅកងចល័តរបស់គាត់ ។ បន្ទាប់មក អង្គការបានចាត់តាំងឲ្យម្ដាយរបស់ខ្ញុំទៅធ្វើស្រែ ។ បន្ទាប់ពីរស់នៅនិងធ្វើការនៅភូមិនោះបានរយៈពេល២ទៅ៣ខែមក ម្ដាយរបស់ខ្ញុំបានទទួលដំណឹងថា អង្គការបានចាត់តាំងឪពុកម្ដាយ និងបងប្អូនប្រុសស្រីរបស់គាត់ឲ្យទៅរស់នៅភូមិផ្សេងមួយទៀត ។

ពេលនោះគឺជាពេលវេលាដែលម្ដាយរបស់ខ្ញុំមានអារម្មណ៍ឯកោបំផុត ។ វាគឺជាអារម្មណ៍ដែលក្មេងស្រីម្នាក់ដែលមិនបានទទួលនូវភាពកក់ក្ដៅពីឪពុកម្ដាយបង្កើត ហើយថែមទាំងឪពុកម្ដាយថ្មីបានចាកចេញ ដោយមិនដឹងថា ពេលណានឹងជួបជុំគ្នាវិញ ។ ជីវិតម្ដាយខ្ញុំពេលនោះកាន់តែពិបាកទៅៗ ដោយណាមួយ រស់នៅតែម្នាក់ឯង ហើយថែមទាំងត្រូវបានអង្គការបង្ខំឲ្យធ្វើការគ្មានពេលសម្រាកគ្រប់គ្រាន់ ។ បន្ថែមពីលើនេះទៀត មិនមានម្ហូបអាហារគ្រប់គ្រាន់សម្រាប់បរិភោគទេ ដោយអង្គការផ្ដល់ឲ្យតែបបររាវមួយចានសម្រាប់បរិភោគ ។ ទោះបីជារស់នៅជាមួយការបង្ខំឲ្យធ្វើការហួសកម្លាំងនិងការបង្អត់អាហារក៏ដោយ ក៏គ្មាននរណាម្នាក់ហ៊ានតវ៉ា និងរអ៊ូរទាំឡើយ ពីព្រោះតែខ្លាចស្លាប់ ។ នៅថ្ងៃមួយ នៅពេលដែលម្ដាយ ខ្ញុំកំពុងដកស្ទូងនៅក្នុងវាលស្រែ គាត់បានឃើញកងឈ្លបបណ្ដើរបុរសម្នាក់ដែលបានលួចបេះអំពិលយកមកញ៉ាំ ។ បន្ទាប់មក ម្ដាយរបស់ខ្ញុំដឹងថា អង្គការបានសម្លាប់បុរសនោះដោយចោទប្រកាន់ថាគាត់មិនមានភាពស្មោះត្រង់ជាមួយអង្គការ ។ ចាប់តាំងពីបានឃើញនឹងបានដឹងពីហេតុការណ៍មួយនេះមក ម្ដាយរបស់ខ្ញុំកាន់តែភិតភ័យនឹងក្លាយទៅជាស្មៀមស្ងាត់ ។ គាត់គ្រាន់តែធ្វើនូវអ្វីដែលអង្គការបានចាត់តាំងឲ្យគាត់ធ្វើ ។ នៅពេលយប់ គ្មាននរណាម្នាក់ហ៊ាននិយាយអ្វីផ្ដេសផ្ដាសអំពីអង្គការឡើយ ពីព្រោះតែខ្លាចគេលួចស្ដាប់ហើយយកទៅរាយការណ៍ឲ្យអង្គការ ។ ប្រសិនបើអង្គការដឹងថា នរណាម្នាក់និយាយអ្វីអាក្រក់ពីអង្គការ ម្នាក់នោះនឹងត្រូវអង្គការចាប់ខ្លួននឹងសម្លាប់នៅពេលក្រោយ ។ យប់មួយ នៅពេលដែលអ្នកគ្រប់គ្នានៅក្នុងកងចល័តរបស់គាត់កំពុងតែលង់លក់ ម្ដាយរបស់ខ្ញុំបានឃើញដោយផ្ទាល់ភ្នែក កងឈ្លបកំពុងបណ្ដើរមនុស្ស៧ទៅ៨នាក់ដែលត្រូវបានគេចងមុខ យកទៅព្រៃខាងក្រោយភូមិ ។ នៅពេលព្រឹកឡើង ម្ដាយរបស់ខ្ញុំធ្វើហាក់ដូចជាមិនដឹងថា រឿងអីបានកើតឡើង ហើយទៅធ្វើការដូចធម្មតា ប៉ុន្តែព្រលឹងរបស់គាត់មិននៅជាមួយគាត់ទេ ដោយសារតែការភិតភ័យខ្លាំងពេក ។ ចាប់តាំងពីនោះមក ម្ដាយរបស់ខ្ញុំកាន់តែព្រួយបារម្ភខ្លាំងឡើងៗអំពីសុវត្ថិភាពរបស់គាត់ ។

នៅដើមឆ្នាំ១៩៧៦ ពួកខ្មែរក្រហមបានចាប់ផ្ដើមសម្លាប់ប្រជាជនក្នុងភូមិ ខណៈពេលដែលប្រជាជនមួយចំនួនធំត្រូវបានអង្គការបញ្ជូនទៅសមរភូមិដើម្បីវាយជាមួយទាហានវៀតណាម ។ មនុស្សដែលត្រូវបានសម្លាប់ ដោយអង្គការចោទប្រកាន់ថា ជាជនក្បត់ ឬក៏មិនស្មោះត្រង់ចំពោះអង្គការ ។ បន្ថែមពីលើនេះទៀត ម្ដាយរបស់ខ្ញុំក៏ស្ថិតក្នុងមនុស្សដែលអង្គការចង់កម្ទេចដែរ ។ ជារៀងរាល់ថ្ងៃ អង្គការបានចាត់តាំងឲ្យម្ដាយខ្ញុំ និងអ្នកភូមិផ្សេងទៀតទៅអង្គុយជាជួរនៅក្នុងព្រៃ ។ ដំបូង ម្ដាយខ្ញុំពិតជាមិនដឹងថាតើហេតុអ្វីបានជាអង្គការចាក់តាំងឲ្យពួកគាត់ធ្វើអ៊ីចឹង ។ ប៉ុន្តែក្រោយមកទើបគាត់ដឹងថា អង្គការចង់សម្លាប់គាត់ជាមួយអ្នកផ្សេងទៀត ។ បន្ទាប់ពីបានដឹងដំណឹងនេះ ម្ដាយរបស់ខ្ញុំស្ទើរតែមិនអាចកម្រើកបាន ពីព្រោះវាគឺជាអ្វីដែលគាត់តែងតែបារម្ភ ។ ដោយសារតែមានភាពតានតឹងនៅទល់ដែនកម្ពុជា-វៀតណាម រវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម អង្គការក៏បានផ្អាកផែនការសម្លាប់របស់វាទៅលើប្រជាជន ដែលជាហេតុធ្វើម្ដាយរបស់ខ្ញុំបានរួចផុតពីសេចក្ដីស្លាប់នៅពេលនោះ ។

បន្ទាប់មក ខ្មែរក្រហមបានជម្លៀសម្តាយរបស់ខ្ញុំពីភូមិឡោក្រព័ន្ធទៅភូមិស្រែកក់ ។ ខណៈពេលកំពុងធ្វើដំណើរ គាត់នៅតែព្យាយាមស្វែងរកឪពុកម្តាយនឹងបងប្អូនប្រុសស្រីរបស់គាត់ ប៉ុន្តែ គាត់មិនបានឃើញ ។ ដោយនៅតែភ័យខ្លាចការសម្លាប់ពីខ្មែរក្រហម ម្តាយខ្ញុំនៅតែបន្តដំណើរទៅមុខ ដោយទឹកមុខភិតភ័យ ហើយមិននិយាយអ្វីទាំងអស់ ។ នៅពេលទៅដល់ភូមិមួយដែលគាត់មិនបានចាំឈ្មោះ ម្តាយរបស់ខ្ញុំ និងអ្នកផ្សេងទៀតបានស្នាក់នៅក្នុងផ្ទះមួយដែលពុំមានមនុស្ស ។ នៅពេលដែលគាត់កំពុងតែលង់លក់ស្រាប់តែអ្នកគ្រប់គ្នានៅក្នុងផ្ទះប្រញាប់ប្រញាល់ប្រមូលរបស់របរ ហើយចាកចេញពីផ្ទះនោះ ។ ម្តាយរបស់ខ្ញុំឃើញដូច្នេះ គាត់ក៏ចុះចេញពីផ្ទះនោះដែរ ហើយទៅតាមអ្នកផ្សេងទៀត ។ បន្ទាប់មក ទើបគាត់ដឹងថា មានសាកសពដែលទើបកប់ថ្មីៗនៅខាងក្រោយផ្ទះនោះ ។

បន្ទាប់ពីមកដល់ភូមិថ្មី អង្គការបានចាត់តាំងម្តាយខ្ញុំឲ្យទៅធ្វើការនៅកងចល័ត ។ ពីមួយថ្ងៃទៅមួយថ្ងៃ ម្តាយរបស់ខ្ញុំរស់នៅជាមួយភាពភ័យខ្លាច ភាពឯកោ និងការអស់សង្ឃឹម ដោយមិនដឹងថា ថ្ងៃណាគាត់អាចរួចផុតពីគុកគ្មានជញ្ជាំងមួយនេះ ហើយទៅជួបជុំជាមួយក្រុមគ្រួសារ ប៉ុន្តែទាំងអស់គ្រាន់តែអ្វីដែលមិនអាចទៅរួច ។ ថ្ងៃមួយ អង្គការបានហៅនារីនៅក្នុងកងចល័តទាំងអស់មកប្រជុំ ដោយអង្គការបាននិយាយថា សូមសមមិត្តនារីទាំងអស់ឈប់ព្រួយបារម្ភពីសម្លៀកបំពាក់របស់យើងទៀតទៅ ពីព្រោះអង្គការបានរៀបចំសម្លៀកបំពាក់ថ្មីសម្រាប់អ្នកទាំងអស់គ្នា ដោយមិនចាំបាច់ចំណាយពេលវេលាដើម្បីកាត់ទេ ។ បន្ទាប់ពីបានឮដូច្នេះ អ្នកទាំងអស់គ្នានៅក្នុងកន្លែងប្រជុំបានទះដៃ ហើយសប្បាយរីករាយជាមួយសម្លៀកបំពាក់ថ្មីរបស់ពួកគេ លើកលែងតែម្តាយរបស់ខ្ញុំ និងនារីពីរបីនាក់ផ្សេងទៀតដែលមិនបានទទួលសម្លៀកបំពាក់ថ្មីទាំងនោះ ។ ហេតុផលដែលម្តាយរបស់ខ្ញុំមិនទទួលបានសម្លៀកបំពាក់ថ្មីនោះ គឺដោយសារតែគាត់មិនជិតស្និទ្ធជាមួយមេក្រុមរបស់គាត់ដោយម្នាក់ៗចែកឲ្យតែអ្នកដែលស្និទ្ធស្នាលជាមួយពួកគេ ។ ប៉ុន្តែម្តាយខ្ញុំពុំមានអារម្មណ៍ប្រណែននឹងអ្នកទាំងនោះទេ ហើយគាត់នៅតែបន្តធ្វើការដូចធម្មតា ។ បន្ទាប់មកទើបគាត់ដឹងថា សម្លៀកបំពាក់ថ្មីដែលអង្គការចែកឲ្យពួកគេនោះគឺជាសម្លៀកបំពាក់របស់មនុស្សដែលអង្គការបានសម្លាប់កាលពីយប់មិញ ។ បន្ទាប់ពីដឹងរឿងនេះមក កាន់តែព្រួយបារម្ភថែមទៀត ដោយគិតថា គាត់នឹងអាចត្រូវអង្គការសម្លាប់នៅថ្ងៃណាមួយ ។

នៅដើមឆ្នាំ១៩៧៧ អង្គការនៅតែបន្តជម្លៀសម្តាយរបស់ខ្ញុំពីភូមិមួយទៅភូមិមួយ រហូតដល់ភូមិស្នួង ។ នៅពេលនោះគាត់គិតថា វាគឺជាការធ្វើដំណើរដោយមិនមានទិសដៅពិតប្រាកដ ។ នៅពេលដែលកំពុងធ្វើដំណើរ គាត់បានឃើញសាកសពនៅតាមដងផ្លូវ ។ ទោះបីជាបានឃើញទិដ្ឋភាពទាំងអស់នេះ ក៏ដោយ ក៏គាត់នៅតែបន្តដំណើរទៅមុខជានិច្ច ពីព្រោះគាត់ត្រូវតែធ្វើនូវអ្វីដែលអង្គការចាត់តាំងឲ្យគាត់ធ្វើ ។ បន្ទាប់ពីបានមកដល់ភូមិស្នួង អង្គការបានចាត់តាំងឲ្យគាត់ស្នាក់នៅម្តុំវត្តវិហារខ្ពស់ ហើយគាត់នៅតែសាកសួររកព័ត៌មានពីក្រុមគ្រួសាររបស់គាត់ ។ អ្នកភូមិបានប្រាប់ប្រសិនបើក្មួយស្រីចង់រកឪពុកម្តាយ និងបងប្អូន ក្មួយស្រីត្រូវទៅខេត្តព្រៃវែង ពីព្រោះអ្នកដែលមកពីកន្លែងផ្សេង ត្រូវបានអង្គការជម្លៀសទៅព្រៃវែងអស់ហើយ ។ បន្ទាប់ពីឮដូច្នេះ ម្តាយរបស់ខ្ញុំពិតជាចង់ទៅខេត្តព្រៃវែងដើម្បីស្វែងរកឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់គាត់ដែលបានបែកបាក់គ្នាអស់រយៈពេលជាយូរមកហើយ ប៉ុន្តែវាមិនអាចទៅរួចទេ ពីព្រោះអង្គការបានចាត់តាំងឲ្យគាត់ទៅដាំដំឡូងនៅក្បែរចម្ការកៅស៊ូ ។ គាត់មិនហ៊ានលួចរត់ និងប្រកែកនូវអ្វីដែលអង្គការបានចាត់តាំងទេពីព្រោះអង្គការនិងសម្លាប់អ្នកដែលហ៊ានធ្វើអ្វីចឹង ។ ដូច្នេះ ម្តាយរបស់ខ្ញុំត្រូវទៅដាំដំឡូងជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយ បន្ទាប់ពីធ្វើការពេញមួយព្រឹក គាត់នឹងអ្នកឯទៀតបានទៅសម្រាកក្រោមដើមឈើមួយនៅក្បែរចម្ការកៅស៊ូ ហើយពួកគាត់បានឃើញរណ្តៅសាកសពជាច្រើននៅទីនោះ ។ វាគឺជាទិដ្ឋភាពដែលម្តាយរបស់ខ្ញុំបានឃើញច្រើនលើកច្រើនសា ដែលជាហេតុធ្វើឲ្យគាត់គ្មានសង្ឃឹមនឹងបានជួបក្រុមគ្រួសាររបស់គាត់ម្តងទៀត ពីព្រោះមនុស្សកាន់តែច្រើនទៅៗ ត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ។

នៅឆ្នាំ១៩៧៨ ដោយសារតែស្ថានភាពតឹងតែងរវាងកងទ័ពរំដោះ នឹងកងទ័ពខ្មែរក្រហម ម្តាយខ្ញុំក៏សម្រេចចិត្តចាកចេញពីភូមិស្នួង ឆ្ពោះទៅកាន់ខេត្តព្រៃវែងដើម្បីគោលដៅតែមួយនោះ គឺស្វែងរកឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់គាត់ ។ បន្ទាប់ពីធ្វើ

ដំណើរអស់រយៈពេលជាច្រើនថ្ងៃមក គាត់ក៏បានមកដល់ភូមិមួយនៅក្នុងខេត្តព្រៃវែងដែលគាត់មិនបានចាំឈ្មោះភូមិនោះទេ ។ ហើយម្ដាយរបស់ខ្ញុំ ក៏បានសុំអ្នកភូមិនៅទីនោះស្នាក់នៅ ។ អ៊ំស្រីម្នាក់ក៏បានអនុញ្ញាតឲ្យស្នាក់នៅជាមួយគាត់បណ្ដោះអាសន្ន ។ ប៉ុន្តែម្ចាស់ផ្ទះនោះបានប្រាប់ម្ដាយខ្ញុំកុំឲ្យចេញទៅខាងក្រៅផ្ដេសផ្ដាស ពីព្រោះពួកខ្មែរក្រហមតែងតែមកភូមិនេះ ដើម្បីមកប្រមូលយកក្មេងៗទៅសមរភូមិ ។ បន្ទាប់ពីឮដូច្នេះ ម្ដាយរបស់ខ្ញុំមិនបានទៅណាមកណាផ្ដេសផ្ដាសទេ ដោយគ្រាន់តែសម្ងំនៅលើផ្ទះ ។ ប៉ុន្មានថ្ងៃក្រោយមក ដូចអ្វីដែលអ៊ុំស្រីម្ចាស់ផ្ទះនិយាយមែននោះគឺពិតជាមានខ្មែរក្រហមមកភូមិដើម្បីប្រមូលយកក្មេងៗដើម្បីបញ្ជូនទៅសមរភូមិមែន ។

មុនពេលដែលពួកខ្មែរក្រហមមកដល់ អ៊ំស្រីម្ចាស់ផ្ទះក៏បានប្រាប់ម្ដាយខ្ញុំឲ្យទៅពួននៅកន្លែងងងឹតខាងក្រោយផ្ទះ ដើម្បីកុំឲ្យពួកខ្មែរក្រហមឃើញ ។ បន្ទាប់មក គាត់បានបើកទ្វារនិងបង្អួចចំហ ពីព្រោះ ប្រសិនបើមានផ្ទះណាបិទទ្វារ ឬបង្អួច អង្គការនឹងសង្ស័យហើយមកពិនិត្យផ្ទះនោះមិនខាន ។ នៅពេលដែលមកដល់ភូមិ អង្គការបានស្រែកឲ្យអ្នកភូមិចេញមកក្រៅ ដើម្បីឲ្យពួកវាងាយស្រួលពិនិត្យមើល ថាតើមាននៅសល់ក្មេងៗនៅក្នុងភូមិនេះអត់ ។ អង្គការបានស្រែកថា «អង្គការត្រូវការយុវជន និងយុវនារី ដើម្បីបម្រើអង្គការ ដូចជា យុវជនត្រូវទៅសមរភូមិ និងយុវនារីត្រូវទៅធ្វើការជាកងឈ្លប» ។ បន្ទាប់មក អ្នកភូមិក៏ចេញមកក្រៅផ្ទះ ដែលអ្នកភូមិម្នាក់បានឆ្លើយតបវិញថា «តើឲ្យយើងមានក្មេងៗនៅក្នុងភូមិមកពីណាទៀត បើអង្គការបានចាត់តាំងឲ្យកូនចៅរបស់យើងទៅសមរភូមិអស់ហើយ ហើយពួកគេមិនដែលត្រលប់មកវិញទេ ដូច្នេះហើយមិនមានក្មេងនៅក្នុងភូមិនេះទៀតទេ» ។ បន្ទាប់មក អង្គការបានត្រលប់ទៅវិញ ដោយមិនបាននិយាយអ្វីមួយម៉ាត់ ។ ហើយម្ដាយខ្ញុំក៏មានអារម្មណ៍ធូរស្បើយបន្តិច ប៉ុន្តែអ្វីដែលគាត់នឹកស្មានមិនដល់នោះគឺ គាត់បានទទួលដំណឹងថា ឪពុកម្ដាយរបស់គាត់ក៏បានត្រូវជម្លៀសមកដល់ភូមិនេះដែរ ។ គាត់មិនដឹងថានេះគឺជាការពិតរឺក៏យ៉ាងណាទេ? បន្ទាប់មក គាត់ក៏បានសុំលាម្ចាស់ផ្ទះដើម្បីស្វែងរកឪពុកម្ដាយ ។ ជាការពិតអ្វីដែលគាត់បានទន្ទឹងរង់ចាំបានក្លាយជាការពិត ដោយបានជួបជាមួយឪពុកម្ដាយគាត់ដែលកំពុងរស់នៅក្នុងខ្ទមមួយនៅចុងភូមិ ប៉ុន្តែបងប្អូនប្រុសស្រី របស់គាត់មិនបាននៅទីនោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ម្ដាយខ្ញុំនៅតែព្យាយាមស៊ើបសួរដំណឹងពីបងប្អូនទាំង២នាក់នេះ ប៉ុន្តែគាត់មិនបានទទួលដំណឹងអ្វីទាល់តែសោះ ។ បន្ទាប់ពីបានជួបជុំជាមួយឪពុកម្ដាយបានមួយរយៈ ម្ដាយរបស់ខ្ញុំក៏បានសម្រេចចិត្តបន្តស្នាក់នៅក្នុងភូមិនេះតទៅទៀត ពីព្រោះគាត់ខ្លាចអង្គការចាប់គាត់បាន ។ បីទៅបួនថ្ងៃក្រោយមក ក៏មានទាហានខ្មែរក្រហមខ្លះបានតម្រង់ត្រង់មកភូមិដែលម្ដាយខ្ញុំកំពុងតែស្នាក់នៅនោះ ។ បន្ទាប់ពីឃើញដូច្នេះ អ្នកភូមិម្នាក់ក៏បានស្រែកថា «ពួកខ្មែរក្រហម កំពុងតែតម្រង់មកដើម្បីចាប់និងសម្លាប់អ្នកភូមិនេះហើយ! ឆាប់ឡើង ឆាប់រត់ទៅ!» ។ បន្ទាប់ពីឮដូចច្នេះ អ្នកភូមិទាំងអស់បានប្រញាប់ប្រញាល់រត់យកតែរួចខ្លួន ។ ដោយសារតែការច្របូកច្របល់ពេក ម្ដាយរបស់ខ្ញុំក៏បានបែកពីឪពុកម្ដាយម្ដងទៀត ហើយគាត់ចេះតែរត់តាមអ្នកភូមិដែលកំពុងរត់ចូលទៅក្នុងព្រៃ ដែលជាហេតុធ្វើឲ្យគាត់អាចរួចផុតពីកណ្ដាប់ដៃពួកខ្មែរក្រហមនៅពេលនោះ ។ ប៉ុន្តែវាគឺជាពេលវេលាដែលគាត់ត្រូវតែរស់នៅដោយបែកពីឪពុកម្ដាយម្ដងទៀត ។ នៅក្នុងព្រៃគាត់បានស្នាក់នៅជាមួយប្ដីប្រពន្ធមួយគូ ដែលអ្នកទាំងពីរ កំពុងតែមានកូនតូចនៅក្នុងដៃ ។ ពួកគាត់បានឲ្យម្ដាយរបស់ខ្ញុំជួយមើលថែរក្សាកូនអ្នកទាំងពីរ ដោយពួកគេអាណិតស្រលាញ់គាត់ ។ នៅពេលយប់គ្មាននរណាម្នាក់ហ៊ាននិយាយ ឬក៏ដុតភ្លើងអ្វីឡើយ ដោយខ្លាចពួកខ្មែរក្រហមដឹង ។ បើសិនជាពួកខ្មែរក្រហមដឹងថា មានមនុស្សនៅក្នុងព្រៃ នោះវាពិតជាអាសន្នធំហើយ ។

បន្ទាប់មកម្ដាយរបស់ខ្ញុំបានដឹងថា ឪពុកម្ដាយរបស់គាត់ត្រូវបានអង្គការចាប់ខ្លួន ។ គាត់ពិតជាចង់មកភូមិវិញ ប៉ុន្តែអ្នកភូមិដែលនៅក្នុងព្រៃជាមួយគាត់បានហាមមិនឲ្យគាត់ត្រលប់ទៅភូមិវិញទេ ពីព្រោះវាគ្រោះថ្នាក់ណាស់ ។ ប៉ុន្មានថ្ងៃក្រោយមក អង្គការបានបញ្ជូនឪពុកម្ដាយរបស់គាត់ និងអ្នកភូមិផ្សេងទៀតទៅទីកន្លែងមួយដែលពួកគេរៀបចំសម្លាប់អ្នកភូមិទាំងនេះ ។ មុនពេលសម្លាប់ពួកខ្មែរក្រហម បានចាក់ខគ្បាសនស័ព្ទ ដើម្បីកុំឲ្យឮសំឡេងជនរងគ្រោះស្រែកនៅពេលវាយសម្លាប់ ។ ប៉ុន្តែឪពុកម្ដាយរបស់គាត់អាចរស់រានមានជីវិតវិញ នៅពេលដែលទាហានវៀតណាមបានចូលមកទឹកដីកម្ពុជានៅចុងឆ្នាំ១៩៧៨ ។ បន្ទាប់ពីការដួលរលំ

របបខ្មែរក្រហមមក ម្តាយរបស់ខ្ញុំបានជួបជុំជាមួយឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់គាត់វិញ ដោយពុំមាននរណាម្នាក់នៅក្នុងគ្រួសារបានរងគ្រោះឡើយ ។ ហើយគាត់ទាំងអស់គ្នាបានត្រលប់ទៅរស់នៅស្រុកកំណើតវិញ ។ ទោះបីជាម្តាយរបស់ខ្ញុំអាចរស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដោយ ក៏គាត់នៅតែមានអារម្មណ៍ភ័យខ្លាច ដោយគាត់បានឃើញដោយផ្ទាល់ភ្នែកមនុស្សជាច្រើនត្រូវអង្គការសម្លាប់ ។ ហើយទិដ្ឋភាពទាំងនេះនៅតែដក់ជាប់ក្នុងអារម្មណ៍របស់គាត់ ។ ម្តាយរបស់ខ្ញុំសង្ឃឹមថា ប្រជាជនកម្ពុជានឹងទទួលបាននូវយុត្តិធម៌នឹងការផ្សះផ្សា ដោយការយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ បន្ថែមពីលើនេះទៅទៀត ម្តាយរបស់ខ្ញុំពិតជាពេញចិត្តនៅពេលដែលគាត់បានឃើញ ឌុច ដែលជាមេគុកទួលស្លែងត្រូវបានកាត់ទោសអស់មួយជីវិត ស្របពេលដែលសំណុំរឿង០០២ កំពុងតែដំណើរការ ។ នេះមិនត្រឹមតែជាស្លាកស្នាមនៅក្នុងជីវិតរបស់ម្តាយខ្ញុំទេ ប៉ុន្តែវាក៏ជាបទពិសោធដ៏ជូរជត់ ដែលគាត់ចង់ឲ្យក្មេងជំនាន់ក្រោយដឹងនឹងរៀនសូត្រអំពីមេរៀនដែលមិនអាចបំភ្លេចបានទាំងនេះ ដើម្បីកុំឲ្យរបបដ៏ឃោរឃៅមួយនេះកើតឡើងនៅក្នុងប្រទេសកម្ពុជាម្តងទៀត ។

**ស៊ាង ចិន្តា**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ: ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : truthfatily.s@dccam.org គេហទំព័រ : www.ariverchangescourse.com







# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

***រឿងពិតរបស់ ជា សីហា***

***(តពីលេខមុន)***

## ***ជម្លៀសជាលើកទីពីរ***

នៅព្រឹកនាថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៥ ជំងឺរាកមួល របស់ខ្ញុំពុំទាន់បាត់នៅឡើយ ខ្ញុំរត់ទៅ រត់មកដើម្បីបត់ជើង ។ ខ្ញុំកំពុងបត់ជើងនៅក្នុងដុបដោយចុកចាប់ក្នុងពោះដូចជាគេចាប់ មួល ស្រាប់តែកងយោធាខ្មែរក្រហមមួយក្រុមប្រដាប់ដោយ កាំភ្លើងគ្រប់ដៃដើរចូលមកក្នុងភូមិហើយបាញ់រះឡើងលើ ដោយ ស្រែកសម្លុតប្រជាជនថា «ចេញពីផ្ទះឲ្យឆាប់ ព្រោះកងទ័ពសៀម វាយចូលមកហើយ លឿនឡើង១» ។ ខ្ញុំប្រញាប់ប្រញាល់រត់ពី ព្រៃមកផ្ទះ ឃើញទាហានខ្មែរក្រហម៣នាក់ឈរនៅពីមុខផ្ទះខ្ញុំ លើកកាំភ្លើងតម្រង់ទៅរកភរិយាខ្ញុំដោយស្រែក «កុំយកអ្វីចេញពី ផ្ទះ ចុះតែខ្លួនឲ្យលឿនឡើង» ។ ភរិយារបស់ខ្ញុំឈរនៅមាត់ជណ្ដើរ បង្អោនខ្លួនចូលទៅក្នុងផ្ទះដៃលូកយកស្បោងដាក់ថ្នាំ និងសម្ភារពេទ្យ ចេញមកក្រៅ ស្រាប់តែទាហានខ្មែរក្រហមបាញ់បញ្ឆិតក្បាលមួយ គ្រាប់ឬស្សីរដាំង ។ ខ្ញុំស្រែកឲ្យភរិយា ខ្ញុំចុះមកដីឲ្យរហ័សកុំយករបស់ អ្វីទៀត ឯពួកខ្មែរក្រហម ក៏ស្រែកសម្លុតឲ្យភរិយាខ្ញុំបន្ថែមទៀតថា «ចង់ងាប់ហ្អី» ។ ភរិយាខ្ញុំ ក៏ស្ទុះចុះមកដី យកអីវ៉ាន់តាមដែលអាច យកទៅបាន ហើយដឹកដៃកូនចេញដំណើរទៅ ។ ខ្ញុំស្ទុះទៅគ្រាហ៍ ឪពុកខ្ញុំ ដែលមានជំងឺទុរន់ទុរា ហើយរែករបស់ដែលអាចយកបាន ទៅជាមួយ ។ នៅពេលនោះ អ្នកភូមិទាំងអស់ប្រញាប់ប្រញាល់ ចេញចោលភូមិ និងស្រែពស្រោះដែលកំពុងលាស់ខៀវខ្ចី តាមបញ្ជា របស់អង្គការបាត់តាំង ។ ហ៊ា ស្រ៊ុន ជាអ្នកជិតខាងខ្ញុំ និងគ្រួសារ របស់គាត់អង្គុយនៅមាត់ ផ្លូវធ្លារធំចាំសុំរទេះអ្នកភូមិទៅជាមួយ ។ ពីរថ្ងៃមកហើយ ហ៊ាស្រ៊ុន កើតរោគមួលចុះឈាមដុនដាបខ្លាំង ខ្ញុំមានថ្នាំវីតាម៉េទិន០,០៤ មួយប្រអប់មាន៤អំពូល ។ ខ្ញុំចាក់ថ្នាំ នោះឲ្យគាត់អស់ពីរអំពូល រោគរបស់គាត់បានធូរស្រាលបន្តិច បត់ ជើងរង្វើលជាងមុនប៉ុន្តែឈាមនៅតែធ្លាក់ដដែល ។ គាត់បានរទេះ ដឹកគាត់ និងឥវ៉ាន់ខ្លះ ព្រមទាំងកូនតូចៗផង ។ គាត់មានកូនច្រើនដូច ខ្ញុំដែរ ។ បន្ទុករបស់យើងប្រហាក់ប្រហែលគ្នា ។ ខ្ញុំបានសុំផ្ញើឪពុកខ្ញុំ ជាមួយរទេះអ្នកភូមិម្នាក់ទៀត ។ ខ្ញុំរែកអីវ៉ាន់ និងដឹកដៃកូនតូចៗ ។ ភរិយាខ្ញុំបីកូនតូច និងយួរត្រកអីវ៉ាន់មួយ ។ ចេញផុតពីភូមិតាគង់ រួចទំនប់តាបែសំដៅទៅភូមិកូបតូច ។ យើងទាំងអស់គ្នាចាប់ផ្ដើម ឃ្លានបាយ ព្រោះថ្ងៃត្រង់ទៅហើយ ។ យើងពុំហ៊ានឈប់ដាំបាយទេ ព្រោះយើងដើរយឺតជាងគេ ។ ក្រុមអ្នកភូមិយើងគេទៅមុនអស់ ហើយ គេដាក់ឪពុកខ្ញុំចុះពីរទេះឲ្យចាំគ្រួសារខ្ញុំដែលមកតាមក្រោយ ។ ពួកពាក្យខ្សឹបប្រាប់ខ្ញុំថា «កុំដើរយឺតពេក ខ្លាចពួកយោធាសម្លាប់» ។ ខ្ញុំ និងក្រុមគ្រួសារខំប្រឹងបន្ថែមល្បឿន ។ មេឃចាប់ផ្ដើមស្រទុំ ហើយ បង្អុរទឹកភ្លៀងពីតិចទៅខ្លាំង ។ ភ្លៀងដំបូងធ្វើឲ្យយើងបាត់ក្ដៅត្រជាក់ ស្រួល មានកម្លាំងជាងមុន ប៉ុន្តែយូរៗទៅធ្វើឲ្យយើងរងាស្ទើរលើក ជើងលែងរួច ។ ឪពុកខ្ញុំ និងកូនតូចៗមានមុខឡើងស្វាយញ័រថ្គាម ប៉ប៉ប់ និយាយលែងចេញ ។ ខ្ញុំ ត្រូវអៀវឪពុកផង រែកអីវ៉ាន់ផង ។ អៀវឪពុកលើខ្នងទៅដាក់ខាងមុខទើបត្រឡប់មករែកអីវ៉ាន់ ។ ធ្វើ យ៉ាងដូច្នេះជារហូត ។ ថែមទាំងផ្លូវរអិលផង ខ្ញុំមានឪពុកនៅលើខ្នង ផង រអិលធ្លាក់ចូលទៅក្នុងស្រែជាញយដង ។ លំបាកក្រៃលែង ស្ទើរ ស្ទុះដង្ហើម ប៉ុន្តែ ត្រូវតែតស៊ូក្នុងនាមជាកូន ឪពុក ជាប្ដី មិនត្រូវរា ថយឡើយ ។ ឃ្លានេះជាការតាំងចិត្តរបស់ខ្ញុំ ។ ដោយឃើញខ្ញុំនឿយ ហត់លំបាកពេក ឪពុកខ្ញុំលែងឲ្យខ្ញុំអៀវគាត់ទៀត ។ គាត់ប្រាប់ខ្ញុំឲ្យ ទៅចោលគាត់ចុះ ទុកគាត់នៅក្នុងខ្ទមមួយប្របមាត់ផ្លូវ ។ គាត់ថា បើយកគាត់ទៅ ក៏គាត់មុខជាស្លាប់តាមផ្លូវដដែល ដូច្នេះ ទុកឲ្យគាត់ ស្លាប់ម្នាក់ឯងក្នុងខ្ទមនេះប្រសើរជាង ជីវិតចៅតូចៗមានប្រយោជន៍ ជាងជីវិតរបស់គាត់ ។ ខ្ញុំអង្វរគាត់កុំឲ្យគាត់អស់សង្ឃឹម គាត់នៅតែ ប្រកាន់ចិត្តថា ឈប់ទៅមុខទៀតហើយ ។ យោធាខ្មែរក្រហមបង្ខំខ្ញុំ ឲ្យទៅមុខកុំអែអង់ ។ ខ្ញុំអង្វរយោធានោះ ឲ្យទុកពេលឲ្យខ្ញុំបន្តិចទៀត ដើម្បីនិយាយលួងលោមឪពុកខ្ញុំឲ្យគាត់ព្រមបន្តដំណើរទៅមុខ ។

ឪពុកខ្ញុំ គាត់ស្ដីបន្ទោសខ្ញុំដោយពោលតិចៗថា មិនស្ដាប់តាមគាត់ ព្រោះកាលពីបីបួនថ្ងៃមុន គាត់បានប្រាប់ខ្ញុំឲ្យប្រញាប់នាំគាត់ និងប្រពន្ធកូនទៅស្រុកសៀម ។ ដោយគាត់ដើរឆ្ងាយពុំរួច គាត់ឲ្យយោបល់ថា ឲ្យខ្ញុំទៅចាប់ក្របីអ្នកភូមិមួយមក ហើយចងគាត់ជាប់ពីលើខ្នងក្របីនោះ ធ្វើដូចនេះ ខ្ញុំអាចនាំគាត់ទៅស្រុកសៀមជាមួយប្រពន្ធកូនខ្ញុំបានជាក់ជាពុំខាន ។ គាត់ប្រាប់ខ្ញុំទៀតថា បើល្អិកណាត្រូវខ្មែរក្រហមដេញតាម ឲ្យខ្ញុំលែងក្របីដែលមានគាត់នៅពីលើខ្នងនោះចោលចុះ ហើយប្រឹងរត់ទៅមុខកុំបែរក្រោយឲ្យសោះ ។ បើខ្ញុំព្រមស្ដាប់គាត់នៅពេលនោះ ម៉្លេះប្រហែលជាបានទៅដល់ស្រុកសៀមបាត់ទៅហើយ ម៉្លេះមិនបានត្រូវខ្មែរក្រហមជម្លៀសទៀតដូចពេលនេះទេ ។ គាត់បន្ទោសខ្ញុំទៀតថា ខ្ញុំមានចិត្តមិនដាច់ តើធ្វើស្ដេចម្ដេចបាន ។ នៅពេលគាត់មានប្រសាសន៍ចប់ ខ្ញុំតឿនគាត់ឲ្យគាត់ឱបក និងទ្រាបលើខ្នងខ្ញុំ ដើម្បីបន្តដំណើរទៅមុខទៀត ។ យោធាខ្មែរក្រហមនៅអង្គុយឃ្លាំមើលយើងព្រោះយើងនៅដាច់ឆ្ងាយពីហ្វូងប្រជាជនជម្លៀស ។ ខ្ញុំអង្វរតឿនគាត់ជាច្រើនដង គាត់នៅតែប្រកែកដដែល ។ ចុងក្រោយបំផុត ខ្ញុំសម្រេចចិត្តថា នៅជាមួយគាត់ មិនអាចទៅចោលគាត់បានឡើយ ទោះបីជា ត្រូវខ្មែរក្រហមសម្លាប់ក៏ដោយ ។ ខ្ញុំនិយាយជម្រាបគាត់ថា «យើងនឹងស្លាប់ជាមួយគ្នានៅទីនេះ ព្រោះកូនអ្នកមានពូជគេមិនដែលបោះបង់ឪពុកចោលកណ្ដាលផ្លូវដូចនេះទេ» ។ គ្រាន់តែខ្ញុំនិយាយចប់ភ្លាម ឪពុកខ្ញុំយល់ព្រមឲ្យខ្ញុំអៀវគាត់បន្តដំណើរទៅមុខទៀត ។ ភ្លៀងរលឹមឥតដាច់សោះ ធាតុអាកាសត្រជាក់ខ្លាំងឡើង យើងម្នាក់ៗរណ្ដំក្ដាម ។ ខ្លួនឪពុកខ្ញុំឡើងរឹងនៅពីលើខ្នងខ្ញុំ កូនតូចឱបជាប់ដើមទ្រូងម្ដាយវាមានក្រមាគ្របពីលើបបូរមាត់មានពណ៌ស្វាយក្រមៅ ។ យើងមានសង្ឃឹមតិចណាស់ថា អាចទ្រាំទ្រស្ថានភាពបែបនេះ បានយូរទៅទៀត ពីព្រោះមេឃនៅតែបង្អុរទឹកភ្លៀងឥតឈប់ ។ សាច់ដុំរបស់យើងឡើងរឹងស្ទើរលើកជើងដើរពុំរួច ពោះស្រេកឃ្លានព្រោះមិនទាន់បានបរិភោគអ្វីសោះតាំងពីម្សិលមិញមកម៉្លេះ អស់កម្លាំងហេវហត់ស្ទើរដាច់ខ្យល់ ។ ពេលល្ងាចណាស់ទៅហើយ ផ្ទៃមេឃងងឹតស្លុប ជើងប្រឹងបោះទៅមុខ វិញ្ញាណគ្មាននៅជាប់នឹងខ្លួនសោះ លែងគិតឃើញអ្វីទៀតហើយ ។ មួយសន្ទុះក្រោយមកយើងបានទៅដល់វត្តកូបតូច ។ យើងហាក់បីដូចជាមានកម្លាំងបន្តិចឡើងវិញ ។ នៅពេលឮសំឡេងភរិយាខ្ញុំសួរខ្ញុំរកក្រឡអំបិលនៅក្នុងគ្រាកអីវ៉ាន់ទើបខ្ញុំភ្ញាក់ស្មារតីនឹកឃើញថា ខ្ញុំបានបោះអីវ៉ាន់ចោលនៅតាមផ្លូវមិនដឹងជាអ្វីខ្លះទេ ព្រោះធ្ងន់ពេកហើយ ។ ខ្ញុំ និងឪពុក ដួលធ្លាក់ពីលើភ្លឺស្រែដែលមានទឹកពេញ ជាច្រើនដង ។ ភរិយារបស់ខ្ញុំខ្សឹបប្រាប់ខ្ញុំថា គាត់បានយកមាសពេជ្រទាំងអស់ដាក់ពីក្រោមអំបិលនៅបាតក្រឡនោះ ដូច្នេះ មាសពេជ្ររបស់យើងអស់ត្រឹមនេះតែម្ដង ។ ភរិយាខ្ញុំ យំសោកស្ដាយរបស់មានតម្លៃទាំងអស់នោះ ដែលជាញើសឈាមរបស់យើងតាំងពីដើមមក ។ មនុស្សម្នានៅកកកុញប្រជ្រៀតគ្នាពេញធ្លាក្នុងវត្ត ។ ដីបែកភក់ម៉ដ្ឋដូចម្សៅផ្អៀបស្អិតជាប់ជើង ។ យើងដើររកទីទួលរាងស្ងួតបន្តិចដើម្បីសម្រាក ។ ភ្លៀងចាប់ផ្ដើមរាំងហើយ នៅសល់តែដំណក់ទឹកស្ទារៗធ្លាក់មកលើជនានុជនដែលបានដល់ទីសម្រាក ។ គ្មានទីទួលណាមួយទំនេរសោះ ។ សុទ្ធតែមានមនុស្សណែនណាន់តាន់តាប់ ។ ភរិយាខ្ញុំចង់បានបង្អែកទប់ខ្លួនឲ្យកូនបៅ ។ ចំណែកខ្ញុំ ខ្ញុំចង់បានទីទួលគ្មានភក់ ដើម្បីដាក់ផ្ដេកឪពុកខ្ញុំដែលនៅជាប់ពីលើខ្នងរបស់ខ្ញុំនៅឡើយ ។ ដើរទៅមុខបន្តិចឃើញមានផ្ទះតូចមួយបិទបាំង ដោយស្លឹកកណ្ដុបខ្ពស់ពីដី ។ យើងដើរសំដៅទៅផ្ទះតូចនោះ ។ មនុស្សម្នាកកកុញជិតជុំផ្ទះនោះ ព្រោះ ជាទីបង្អែកដ៏ស្ដុកស្ដម្ភរបស់មនុស្ស ហេវហត់និងគ្មានទីពឹង ។ ខ្ញុំ និងភរិយាលែងទ្រាំទ្របានតទៅទៀតហើយ ។ ខ្ញុំដាក់ គូទអង្គុយ ដាក់ឪពុកខ្ញុំឲ្យអង្គុយលើភក់ ។ ភរិយាខ្ញុំផ្អែកទៅនឹងសសរផ្ទះទប់ជំហរសើយដោះឲ្យកូនបៅ ។ ខ្ញុំដាច់ចិត្តទៅទាញកន្ទ្រាក់ស្លឹកកណ្ដុបបាំងជញ្ជាំងបានបីកណ្ដុបមកក្រាលលើភក់ឲ្យឪពុកខ្ញុំសម្រាន្ត ។ យើងទាំងអស់គ្នា ហេវហត់ខ្លាំងមែនទែនហើយ ព្រោះយើងឥតទាន់បានបរិភោគអ្វីសោះតាំងពីម្សិលមិញមកម៉្លេះ ។ ឥឡូវយប់ណាស់ទៅហើយ ទៅរកអ្វីមកបរិភោគបាន? ខ្ញុំហៅកូនៗមកប្រាប់ឲ្យដើររកសុំបាយគេបរិភោគខ្លួនឯងចុះ ប៉ុន្តែ កុំឲ្យវង្វេង ត្រូវចំណាំផ្លូវមកជួបជុំគ្នាវិញនៅកន្លែងនេះ ។ កូនៗចេញដំណើរទៅស្វែងរកបាយបរិភោគ ។ ភ្នែកខ្ញុំជិតដាមដោយទឹកភ្នែក ពេលសម្លឹងមើលកូនៗពីក្រោយ នៅពេលកូនៗចាកចេញទៅ និងដោយឡែកទៀត ឃើញឪពុកខ្ញុំសម្រាន្តលើស្លឹកកណ្ដុបក្រាលលើភក់ ។ ខ្ញុំលែងអត់ធ្មត់បានទៀតហើយ ព្រោះទ្រូងខ្ញុំសែនតឹងស្ទើរស្ទុះដង្ហើម ។ ដើម្បីបន្ធូរដើមទ្រូង ខ្ញុំស្រែកសួរទេព្ដាដែលគ្មានរូបថា «ឱ! លោកទេព្ដា លោកមានព្រះនេត្រឬទេ? លោកឃើញខ្ញុំលំបាកយ៉ាងនេះ

ម្តេចលោកមិនជួយខ្ញុំផង!» ។ ស្រែកបានតែប៉ុណ្ណោះ ស្រាប់តែឮសំឡេងនិយាយគ្នានៅក្នុងផ្ទះតូចនោះថា «សំឡេងនរណា? ដូចសំឡេងគ្រូពេទ្យ ។ ឮដូច្នេះ ខ្ញុំឆ្លើយទៅវិញភ្លាម ដោយកំប៉ុតកំប៉ុយថា «គ្រូពេទ្យថាមិនគ្រូពេទ្យ» ។ ស្រាប់តែទ្វារផ្ទះបើកឡើង ខ្ញុំឃើញបុរសម្នាក់មានអាយុស្របាលនឹងខ្ញុំ បង្ហាញខ្លួនពីមុខខ្ញុំ ហើយត្រឡប់ចូលទៅក្នុងផ្ទះវិញ ដោយនិយាយបន្ទឺថា «ម៉ែវា គ្រូពេទ្យមែន» ។ មួយរំពេចនោះ បុរសដដែលបានកាន់ថ្ដិលដែលមានបាយដំណើបពេញហុចមកឲ្យខ្ញុំហើយនិយាយតិចៗប្រាប់ខ្ញុំថា «លោកគ្រូ! ខ្ញុំបើកទ្វារឲ្យអង្គការ អង្គការឲ្យខ្ញុំស្នាក់នៅទីនេះមួយរយៈពេលមកហើយ ។ ខ្ញុំសល់បាយដំណើបមួយកូនថ្ដិលនេះតែប៉ុណ្ណោះ ។ ខ្ញុំជូនលោកគ្រូគ្រាន់សម្រន់ពោះ ។ ខ្ញុំថ្លែងអំណរគុណដោយរំភើបបំផុតចំពោះអ្នកម្ចាស់ទាន ។ ខ្ញុំបេះបាយដំណើបមួយដុំជូនទៅឪពុកខ្ញុំ គាត់លូកដៃទទួលដុំបាយពីខ្ញុំដោយញញើញញ័រ ព្រោះរងាផង និងគ្រេកអរផង ។ កូនរបស់ខ្ញុំបានវិលមកវិញ ដោយដៃទទេ ហើយនិយាយថា «ប៉ា ខ្ញុំសុំបាយគេអត់បានទេ!» ។ ខ្ញុំបេះបាយជាដុំទំហំប៉ុនៗគ្នាចែកឲ្យកូន ភរិយា និងខ្លួនខ្ញុំម្នាក់មួយដុំ ។ រំពេចនោះ ខ្ញុំគិតថា ទាកាប៉ាដំទង់ៗរបស់ខ្ញុំទាំង៥ ដែលខ្ញុំរែកតាំងពីផ្ទះនៅឯអូរវែងមកគួរតែប្រគល់ឲ្យបុរសនោះចុះពីព្រោះខ្ញុំពុំអាចរែកវាតទៅមុខទៀតរួចទេ ។ ខ្ញុំក៏យកគំនិតនេះ ទៅពិគ្រោះនឹងភរិយាខ្ញុំ ។ ភរិយាខ្ញុំប្រគល់ឲ្យខ្ញុំជាអ្នកសម្រេច ។ ខ្ញុំក៏លើកទាទាំងប្រាំនោះជូនទៅបុរសនោះ ដោយប្រាប់គាត់ថា ខ្ញុំជូនទាទាំងនេះទៅគាត់ ព្រោះខ្ញុំពុំអាចរែកវាតទៅមុខបានទៀតទេ ដោយខ្ញុំមានបន្ទុកច្រើនពេក បន្ទុកជាឪពុកចាស់ជរា ជាអីវ៉ាន់ ជាកូនតូចៗទៀតផង ។ បុរសនោះ ទទួលទាពីដៃខ្ញុំយកចូលទៅក្នុងផ្ទះគាត់ បាត់ទៅដោយឥតពោលពាក្យអ្វីមួយម៉ាត់សោះ ។ ប្រមាណដល់ពេលអធ្រាត្រ បុរសនោះលើកបបរមួយឆ្នាំងធំមកឲ្យខ្ញុំដោយប្រាប់ថា ចែកគ្នាពិសាចុះ ហើយទៅយកសាច់ទាប្រឡាក់ឲ្យខ្ញុំមួយឆ្នាំងទៀត និងខោជើងវែងមួយដោយ ពោលពាក្យគួរសមជាមួយខ្ញុំដោយខ្សឹបៗថា «លោកគ្រូ ខ្ញុំគ្មានអ្វីជូនលោកគ្រូទេ ក្រៅពីធ្វើទាជូនលោកគ្រូពិសា និងប្រឡាក់សាច់ទានេះជូនលោកគ្រូទៅតាមផ្លូវ» ។ គាត់វិលចូលលំនៅរបស់គាត់វិញ ដោយស្ងៀមស្ងាត់បំផុត ។ ខ្ញុំនឹកឃើញឥតភ្លេចនូវកាយវិការប្រកបដោយចិត្តបុណ្យរបស់បុរសនោះ ។ ខ្ញុំដួសបបរជូនឪពុកខ្ញុំមួយចានឲ្យទៅ ហ៊ាស្រ៊ុន មួយចានស្មើគ្នា ។ ខ្ញុំនិងគ្រួសាររបស់ខ្ញុំ ព្រមទាំងគ្រួសាររបស់ ហ៊ាស្រ៊ុន និងចាស់ៗម្នាក់ពីរទៀតចែកបបរគ្នាបរិភោគរហូតដល់អស់ពីឆ្នាំង ។ អាហារប្រៀបបាននឹងអាហារទិព្វ ដែលបានជួយជីវិតយើងតទៅទៀត ជាពិសេសចំពោះ អ្នកជំងឺទាំងពីរនាក់ គឺឪពុកខ្ញុំ និងហ៊ាស្រ៊ុន ព្រមទាំងក្មេងៗទាំងពីរគ្រួសារ ។ គួរឲ្យសោកស្ដាយ ដោយខ្ញុំពុំអាចស្គាល់អត្តសញ្ញាណរបស់អ្នកម្ចាស់ទាននោះ ពីព្រោះសម័យបដិវត្តន៍ យើងម្នាក់ៗពុំមានសេរីភាពធ្វើទំនាក់ទំនងគ្នាបានទេ គឺអង្គការកាត់ខ្សែរយៈ គឺមិនឲ្យចងក្រងគ្នាជាខ្សែបាន ។ ការផ្ដល់អាហារឲ្យយើងរបស់អ្នកមានចិត្តធម៌ធ្វើឡើងដោយលួចលាក់ និងប្រថុយប្រថាន ។

ប្រមាណជាម៉ោង៧រំលងអាធ្រាត្រ គេស្រែកប្រកាសតាមខគ្យោសនស័ព្ទឲ្យប្រជាជនក្រោកឡើងធ្វើដំណើរទៅកាន់ផ្លូវរថភ្លើង ដើម្បីបន្តដំណើរទៅមុខទៀត ។ នៅលើផ្លូវរថភ្លើង ទូររថភ្លើងបើកចំហឲ្យប្រជាជនឡើង ។ មួយសន្ទុះក្រោយមក សំឡេងកញ្ចែរថភ្លើងលាន់ឮជ្រែកវេហា រថភ្លើងចេញដំណើរទាំងពពើមទៅមុខ ។ ប្រមាណពីម៉ោងក្រោយមករថភ្លើងបានឈប់ស្ងៀម ។ គេស្រែកឲ្យប្រជាជនចុះពីលើរថភ្លើង ។ យើងនាំគ្នាប្រវេប្រវាចុះពីលើរថភ្លើង ហើយសម្រូតខ្លួនចុះឲ្យផុតពីផ្លូវរថភ្លើងទាំងងងឹតចាក់ភ្នែកមិនធុះ ប៉ុន្តែចេះតែនាំគ្នាដើរចុះទាំងពពាក់ពពើមដួលតិតដួលតួងទៅដល់ខាងក្រោមថ្នល់ ។ មិនយូរប៉ុន្មានក្រោយមកទៀត ក្លិនអសោចនៃលាមកមនុស្ស ឆ្អួលដល់ក្បាល ។ យើងទ្រាំនៅទីនោះរង់ចាំថ្ងៃរះ ។ ឪពុកខ្ញុំសម្រាន្តផ្អែកលើការុងសម្លៀកបំពាក់ និងអីវ៉ាន់របស់យើង ។ កូនៗដេកប្រជ្រៀតគ្នាលើគំនរអីវ៉ាន់យ៉ាងស្ងៀមស្ងាត់ ។ ពន្លឺព្រាងៗលេចឡើងឯកើត ខ្ញុំដាស់ភរិយា និងកូនៗរបស់ខ្ញុំឲ្យក្រោកឡើង ឪពុកខ្ញុំក៏ក្រហែម យើងបន្តដំណើរតាមហ្វូងមនុស្សនៅពីមុខយើង ។ ខ្ញុំគ្រាហ៍ឪពុក និងរែកអីវ៉ាន់ ជួនកាលត្រូវអៀវគាត់ពីលើខ្នងតាមការចាំបាច់ ។ ភរិយាខ្ញុំឱបកូនតូច និង ទូលបង្វេចខោអាវ កូនៗយួរធុងយួរឆ្នាំងចាន ។ ដោយខ្លាចជាន់លើលាមកមនុស្ស យើងឡើងមកដើរលើថ្នល់ដែក ។ ទោះបីមកលើថ្នល់ដែកទៅហើយ ក៏នៅតែមានលាមកមនុស្សពាសពេញ ។ ប្រមាណ២០០ម៉ែត្រពីទីសំចតដំបូង យើងចុះពីផ្លូវរថភ្លើងសំដៅទៅផ្លូវជាតិលេខ៥ ។ នៅទីនោះមានរថយន្ត មានរ៉ឺម៉កសណ្ដោងត្រាក់ទ័រច្រើនគ្រឿងរង់ចាំដឹកជញ្ជូន

ប្រជាជនទៅកាន់ទីដៅកំណត់ដោយអង្គការ ។ ក្រុមគ្រួសារខ្ញុំសំចត នៅពីមុខអតីតមន្ទីរកសិកម្មជ្រោយស្ដៅ ព្រោះឪពុកខ្ញុំហេវហត់ពេក ពុំអាចបន្តដំណើរបាន ។ មានយោធាមកតឿនយើងឲ្យចាកចេញទៅ ប៉ុន្តែ ដោយឃើញស្ថានភាពរបស់ឪពុកខ្ញុំ យ៉ាប់យ៉ឺនពេក ពួកនោះក៏លែងមកតឿនទៀត ។ មនុស្សម្នាចាកចេញជាបន្តបន្ទាប់អស់ពីកន្លែងនោះ ឬថាខ្លះទៅភូមិនិគម ខ្លះទៅភូមិគោកឃ្មុំ ខ្លះទៀតទៅកៀនកែស ។ នៅសល់តែមួយគ្រួសារខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំរង់ចាំឲ្យឪពុកខ្ញុំមានកម្លាំងខ្លះឡើងវិញ ដើម្បីបន្តដំណើរទៅជាមួយប្រជាជនឯទៀត ។ ខ្ញុំឥតស្គាល់ភូមិសាស្ត្រតំបន់នោះទេ ។ ខ្ញុំដណ្ដឹងសួរខ្លួនឯងថា ទោះបី ឪពុកខ្ញុំមានកម្លាំងឡើងវិញ តើយើងត្រូវទៅទីណា មានយានជំនិះមកពីណា បើគេចាកចោលអស់ស្ងាត់ជ្រៀបទៅហើយ ។ យើងចាត់ចែងរកទឹកដាំបាយបរិភោគសិនចាំមើលតទៅទៀត ។ ភរិយាខ្ញុំ និងកូន បានដាំបាយឆ្អិនហើយ ។ សាច់ទាប្រឡាក់មួយដុំក៏ដល់ពេលឆ្អិនដែរ ។ យើងដួសបាយមួយចាន និងសាច់ទាបន្តិចជូនឪពុកខ្ញុំ ។ ខ្ញុំ ភរិយា និងកូនៗដួសបាយដាក់មួយចានធំបរិភោគរួមគ្នាជាមួយសាច់ទាអាំង ។ យើងបរិភោគដោយឆ្ងាញ់ពិសា ព្រោះឃ្លាន ។ ថ្ងៃបាក់រសៀលទៅហើយ ឪពុកខ្ញុំហាក់ដូចជាមានកម្លាំងបន្តិចវិញ តើយើងត្រូវទៅទីណាទៀត ឬក៏ដេកនៅទីនេះមួយយប់ទៀត ។ ខ្ញុំកំពុងទញ់គំនិត ស្រាប់តែឃើញមិត្តខ្ញុំម្នាក់ឈ្មោះ ឃី ដើរសំដៅមករកខ្ញុំ ។ គាត់ជាមិត្តរាប់អានគ្នា កាលយើងនៅកំលុងជាមួយគ្នានៅផ្សារនិមិត្ត ។ គាត់ប្រាប់ខ្ញុំថា គាត់សុំ ប្រធានភូមិទួលគ ឲ្យខ្ញុំនៅទីនោះជាមួយប្អូនជីទូតមួយរបស់ខ្ញុំមួយគ្រួសារទៀត ។ យើងរូតរះចេញដំណើរដោយថ្មើរជើងទៅកាន់ភូមិទួលគ ។ ភូមិទួលគ ស្ថិតនៅពុំឆ្ងាយប៉ុន្មានពីភូមិជ្រោយស្ដៅទេ ។ យើងធ្វើដំណើរដោយយឺតៗតាមកម្លាំងរបស់ឪពុកខ្ញុំ ។ ខ្ញុំគ្រាហ៍គាត់ផង វែកអីវ៉ាន់ផង ។ យើងម្នាក់ៗមានភារៈដូចកាល យើងចេញដំណើរមក ។ យើងដើរតាមមាត់ប្រឡាយប៉ាតង់ របស់អតីតមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជាមេច្បារ ប្រមាណមួយគីឡូម៉ែត្រហើយបត់តាមផ្លូវលំខាងស្ដាំដៃ ប្រមាណមួយគីឡូម៉ែត្រទៀតទើបដល់ភូមិទួលគ ។ ទីភូមិស្ថិតនៅលើដីទួលតូចមួយប្រមាណ៣០ម៉ែត្របួនជ្រុង មានប្រឡាយមួយកាត់ទទឹងផ្លូវ ។ នៅលើទួល នោះមានប្រជាជនប្រមាណ១០គ្រួសារដែលជាប្រជាជនជម្លៀសមកពីភូមិជ្រោយស្ដៅតាំងទីលំនៅ ។ លំនៅស្ថានទាំងនោះ តម្រៀបគ្នាជាជួរតាមជាយទួល ។ នៅចំកណ្ដាលមានរោងដោលមួយសម្រាប់ធ្វើជារោងគោផង ជារោងបាយផង ឬក៏ជារោងប្រជុំផង ។ ខណៈដែលគ្រួសាររបស់ខ្ញុំទៅដល់ប្រធានភូមិឲ្យពួកយើងឈប់សម្រាកនៅក្នុងរោងនោះ ។ រំពេចនោះមាននារីក្រមុំៗបួនប្រាំនាក់ស្ទុះមកឆែកឆេរអីវ៉ាន់របស់យើង ។ យើងមិនដឹងថា នារីទាំងនោះមកឆែកឆេររកអ្វីនោះទេ ។ មាននារីម្នាក់នោះលើកធុងអង្ករបស់យើង បម្រុងនឹងចាក់យក ប៉ុន្តែ ប្រធានភូមិស្រែកទុកឲ្យគាត់ទៅ គាត់កូនច្រើនណាស់ ។ ខណៈនោះ ខ្ញុំឃើញឪពុកខ្ញុំធ្វើសញ្ញាប្រាប់ខ្ញុំដោយលើកម្រាមដៃចង្អុលទៅខ្លួនគាត់ ។ ខ្ញុំមិនយល់ពីសញ្ញារបស់ឪពុកខ្ញុំនោះទេ ។ ប៉ុន្តែ ក្រោយមកទើបខ្ញុំដឹងថា ឪពុកខ្ញុំលាក់ក្រដាសប្រាក់យ៉ាងច្រើនក្រោមអង្ករក្នុងធុងនោះ ។ អង្ករមានតែបន្តិចពីលើប៉ុណ្ណោះ ខាងក្រោមសុទ្ធតែក្រដាសប្រាក់៥០០រៀលទាំងអស់ ។ គាត់ធ្វើសញ្ញាចង់ឲ្យខ្ញុំដឹងថា បើគេចាក់អង្ករនោះទៅ ឃើញក្រដាសប្រាក់នៅខាងក្រោម ឲ្យខ្ញុំឆ្លើយថា គាត់ជាអ្នកធ្វើ ប៉ុន្តែ ជាសំណាងល្អ ពួកស្រីក្រមុំទាំងនោះមិនចាក់អង្ករចេញពីធុងនោះទេ ។ គេគ្រាន់តែលូកដៃរាវក្នុងបង្វេចខោអាវ ក្រែងយើងលាក់របស់មានតម្លៃមិនប្រគល់ឲ្យអង្គការ ។ បើសិនគេឆែករកឃើញរបស់ទាំងនោះ គេនឹងរឹបអូសយកទៅឲ្យអង្គការ ហើយអ្នកមានកំហុសអាចនឹងមានទោសស្រាល ឬធ្ងន់រហូតដល់ទោសប្រហារជីវិតផង ក៏សឹងមាន គឺសម្រេចលើកម្មាភិបាលរបស់ពួកគេ ។ ការត្រួតពិនិត្យដោយកញ្ជក់កណ្ដៀតនេះពុំបានឃើញអ្វីខុសច្បាប់អង្គការរបស់គេទេ ។ ខ្ញុំឆ្ងល់ថា ពួកអ្នកទាំងអស់នេះជាអ្នករងគ្រោះដូចពួកយើងដែរ គឺសុទ្ធតែពួក ១៧មេសា ដូចគ្នាម្ដេចក៏ពួកនេះបញ្ចេញចរិតប្រឡោងខាមដាក់មកលើពួកយើងហាក់ដូចជា ពួកយើងជាសត្រូវរបស់គេ ឬជាឈ្លើយសឹករបស់ពួកគេពីអង្កាល់មក ។ ទើបតែបានបីខែសោះ មនោគមន៍វិជ្ជាខ្មែរក្រហមមនោគមន៍វិជ្ជាស្រែកឈាម បានជ្រាបចូលដល់សរសៃឈាមនៃសរព៌ាង្គកាយទាំងមូលរបស់គេទៅហើយ ។ ខ្ញុំតក់ស្លុតនូវភាពសាហាវយង់ឃ្នងរបស់យុវជន យុវតីទាំងនោះ ។ នៅចំពោះមុខរបស់ពួកគេ ខ្ញុំមិនដែលហ៊ានសម្លឹងមើលមុខពួកគេឲ្យចំម្ដងណាឡើយ ព្រោះខ្លាចអំណាចខ្មៅរបស់ពួកគេ ។ ពួកអង្គការខ្មែរក្រហមប្រៀបបាននឹងបិសាចដែលកើតមកជាកូនខ្មែរ ដើម្បីជញ្ជក់ឈាម

ខ្មែរឲ្យសោះសូន្យ ។ ពួកនេះ ជ្រើសរើសយកតែកុមារ និងយុវជនល្ងង់ខ្លៅធ្វើជាពេជ្ឈឃាដបម្រើផែនការដ៏ខ្មៅងងឹតរបស់ពួកវាលើជនជាតិរបស់ឯង ដែលមានជីវភាព ឬឋានៈក្នុងសង្គមពីអតីតកាលខ្ពស់ជាងពួកវា ។ វាចាត់ពួកនោះជាខ្មាំងរបស់បដិវត្តន៍ ។ ផែនការកម្ទេចខ្មាំងបដិវត្តន៍ធ្វើមិនរើសមុខ ទោះបីជនរងគ្រោះនោះជាឪពុកម្តាយ ឬញាតិសាច់សាលោហិតរបស់ពួកវាក៏ដោយ ។ សង្គមបដិវត្តន៍របស់ពួកវា មានតែកម្មករ និងកសិករតែប៉ុណ្ណោះ ។ អំពើនិងគំនិតរបស់អង្គការ គឺជារោគសញ្ញានៃជំងឺឆ្កួតដ៏មានគ្រោះថ្នាក់បំផុត ពីព្រោះ មនុស្សជាឬមនុស្សធម្មតា ពុំអាចប្រព្រឹត្តអំពើដ៏លាមកបែបនោះបានឡើយ ។ ពួកវាសម្លាប់គេ ព្រោះខ្លាចគេសម្លាប់ពួកវា ។ សម្លាប់គេយូរៗទៅនៅតែមិនស្កប់ចិត្ត ក៏ចាប់ផ្តើមសម្លាប់គ្នាវាទៀត ។ តើអំពើទាំងនេះ ពុំមែនជាអំពើរបស់មនុស្សឆ្កួតទេឬ? ។ មានពាក្យជំណាលតៗមកថា អ្នកសម្លាប់គេ កាលបើមានឈាមខ្ទាតចូលភ្នែកអ្នកនោះឃើញអ្នកដទៃ សុទ្ធតែជាមនុស្សសមនឹងត្រូវវាសម្លាប់ ។ ពាក្យជំណាលនេះ បានសេចក្តីថា មនុស្សឯណាដែលធ្លាប់បានសម្លាប់គេ ហើយរមែងចង់សម្លាប់គេទៀត ព្រោះជក់ចិត្តនឹងសម្លាប់មនុស្ស ។

**គំនិតថ្មី សង្គមថ្មី**

យើងរស់នៅបណ្តោះអាសន្នក្រោមដំបូលរោងនោះ បានពីរថ្ងៃ យើងរើរីវ៉ាន់មកនៅក្នុងខ្ទមផ្ទាល់ ខ្លួនរបស់យើងដែលស្ថិតនៅវាលស្រែខាងត្បូងទួលនោះ ។ ខ្ទមនេះ ខ្ញុំជាមួយកូនទៅរកឈើឯភរិយាខ្ញុំទៅ រកស្បូវ យើងសង់ដោយខ្លួនឯងទៅតាមសម្ភារ ដែលយើងរកបានល្មមតែការពារកម្តៅថ្ងៃ ភ្លៀងខ្យល់តែប៉ុណ្ណោះ ។ យើងប្រឹងប្រែងសម្របខ្លួនឲ្យដូចពួកគេជាកម្មករ ជាកសិករ ។ ពួកទាំងនោះ ភាគច្រើនមិនរាក់ទាក់រកពួកយើងទេ ។ គេមើលមកយើងដោយទឹកមុខមិនអើពើ ព្រោះយើងជាអ្នកក្រុង ដែលអង្គការស្អប់ខ្ពើម ។ យើងទំប្រឹងធ្វើការងារដោយឥតហ៊ានធ្វេស ។ យើងរៀនធ្វើស្រែ លើកទំនប់ ជីកប្រឡាយ លីបាវស្រូវអង្ករ កាប់ដីធ្វើស្រែចម្ការដោយឥតហ៊ានត្អូញត្អែរ ។ ភរិយាខ្ញុំទៅកិនស្រូវ រែងអង្ករដកស្ទូងដូចអ្នកដទៃ ។ ការងារថ្មីទាំងនេះ ដែលយើងមិនធ្លាប់ធ្វើពីមុនមកធ្វើឲ្យយើងហត់នឿយលំបាកស្ទើរទ្រាំពុំបាន ។ ក្រោមកម្តៅថ្ងៃ ត្រាំទឹកត្រាំភក់ធ្វើការធ្ងន់ បរិភោគតិចតួចធ្វើឲ្យយើងអស់កម្លាំងស្ទើរដើរពុំរួច ។ បាតដៃ បាតជើង ពោរពងឈឺចាប់ពន់ពេក ។ ក្រោយមក ប្រធានភូមិអនុញ្ញាតឲ្យខ្ញុំធ្វើការនៅរោងបាយ ។ ខ្ញុំក្រោកទៅធ្វើការចាប់ពីម៉ោង៣រំលងអធ្រាត្រ ។ ខ្ញុំបង្កាត់ភ្លើងដាំបបរពរៗដោយដាក់អង្ករ៥កំប៉ុងក្នុងទឹកមួយខ្ទះធ្លោត ។ ម៉ោង៥:០០ អ្នកចេញទៅធ្វើការហូបបបរពរម្តងដល់ពេលល្ងាចហូបម្តងទៀត ។ នៅពេលនោះ វិន័យអង្គការនៅធូរ យើងអាចឆ្លៀតរកអាហារផ្សេងៗទៀតមកបំពេញក្រពះបាន ។ ក្រៅអំពីដាំបបរ ខ្ញុំពុះអុស រែកទឹក បោសសម្អាតរោងបាយ ។ ប្រជាជនអ្នកភូមិត្រូវទៅបរិភោគនៅរោងរួមទាំងអស់គ្នា ។ យើងលែងមានអ្វីជាឯកជនទៀតហើយ លើកលែងតែសម្លៀកបំពាក់ចាស់ៗ ចាន និងស្លាបព្រាតែប៉ុណ្ណោះ ។ យើងយកសម្លៀកបំពាក់ថ្មីទៅជាន់ក្នុងភក់ ដើម្បីឲ្យមានពណ៌ស្រអាប់ ចៀសវាងភាពឆើតឆាយ ។ របស់មានតម្លៃដូចជាគ្រឿងអលង្ការជាដើម យើងលាក់ទុកមិនឲ្យអង្គការឃើញឡើយ ។ បើឲ្យអង្គការឃើញ គេអាចរឹបអូសយក ឬកសាង យើងតាមចិត្តរបស់គេ ។ គេអាចចោទយើងថា ជាអ្នកប្រឆាំងបដិវត្តន៍ មិនលះបង់គំនិតស្វ័យជាអ្នកមានវណ្ណៈអនុធនប្រតិកិរិយា ។ យើងត្រូវតែដាក់ខ្លួនរៀនសូត្រតាមប្រជាជនក្រីក្រ ។ ជីវិតរបស់យើងប្រព្រឹត្តទៅបែបនេះ សម្រាប់អនាគតមួយមិនប្រាកដប្រជា ។ ឪពុករបស់ខ្ញុំមានសុខភាពគ្រាន់បើជាងពេលមុន ។ គាត់ស្វែងរកការងារស្រាលៗធ្វើនៅក្នុងភូមិ ។ កូនធំទាំងពីរនាក់ របស់ខ្ញុំចូលក្នុងកងកុមារ ។ កូនស្រីទី៣ មើលថែប្អូននៅក្នុងរោងរួម ។

ថ្នាំអំពូលដែលខ្ញុំទុកសម្រាប់តែព្យាបាលជូនឪពុកខ្ញុំ នៅសល់កាន់តែតិចទៅ ។ កាលពីពេលមុន ខ្ញុំចាក់ថ្នាំជូនគាត់២ថ្ងៃម្តង បន្ទាប់មក ៣ថ្ងៃម្តង ហើយ៥ថ្ងៃម្តង ។ មកដល់ចុងខែសីហានេះ ថ្នាំអំពូល ទុកសម្រាប់ចាក់ជូនគាត់បានអស់ហើយ ។ ខ្ញុំជម្រាបជូនគាត់ពីដំណឹងអភ័ព្វនេះ ។ គាត់អស់សង្ឃឹមក្នុងការរក្សាជីវិតរបស់គាត់ ។ រាល់ពេលដែលខ្ញុំវិលមកពីធ្វើការវិញ គាត់តែងតែពិភាក្សាជាមួយខ្ញុំ គាត់ដាស់តឿនខ្ញុំកុំឲ្យភ្លេចខ្លួន ធ្វើខ្លួនឲ្យពេញលក្ខណៈជាបុរសក្លាហានម្នាក់ ហើយបើមានឱកាសត្រូវគៀសខ្លួនចេញពីរបបនេះ ។ គាត់បានផ្តាំផ្ញើឲ្យរៀបចំទុកដាក់សពរបស់គាត់ក្រោយពេលមរណភាពរបស់គាត់ថា បើមានឱសគ្រប់គ្រាន់ ត្រូវដុតគាត់ឲ្យឆេះកុំឲ្យសេសសល់ ព្រោះពួកកុម្មុយនីស្តមិនគោរពជូនតាទេ ។

បើគ្មានឱស ត្រូវកប់សពគាត់ឲ្យជ្រៅប្រមាណ១ម៉ែត្រកន្លះ ទៅ២ម៉ែត្រ បង្ការក្រែងគេកាប់គាស់ទៅដល់ ។ ចាប់ពីពេលនោះមក ខ្ញុំសង្កេតឃើញឪពុកខ្ញុំស្រកសាច់ចុះស្គម ជើងរបស់គាត់ហើមកាន់តែធំ ខ្ញុំពុំមានសមត្ថភាពជួយឪពុកក្នុងកាលៈទេសៈបែបនេះទេ ។ ពីរបីថ្ងៃក្រោយមក គាត់ដើរលែងរួច គាត់សម្រាន្តជាប់នឹងកន្ទេល ។ ពេលយប់ ខ្ញុំទទួលទានដំណេកជាមួយគាត់ នាំគាត់សូត្រធម៌ដោយស្ងាត់ៗ ។ ខ្ញុំនិទានអំពីពុទ្ធប្បវត្តិ កាលណាខ្ញុំនិយាយខុស គាត់កែតម្រូវពាក្យសម្ដី ឬសាច់រឿងឲ្យខ្ញុំ ។ ពេលថ្ងៃ ខ្ញុំឆ្លៀតឱកាសទំនេររត់មកមើលថែទាំគាត់ ។ នៅពេលយប់ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៥ ស្រាប់តែជើងម្ខាងរបស់គាត់រលួយហូរទឹកចេញរហូតដល់ស៊ិតនៅសល់តែស្បែកខ្មោចខ្មៅគ្របលើឆ្អឹងស្ងួន ។ យប់ស្អែកឡើង អាការដដែលនេះ បានយកសាច់ពីជើងម្ខាងរបស់គាត់ថែមទៀត ។

នៅម៉ោង៤ទៀបភ្លឺថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៧៥ ឪពុកខ្ញុំបានលាចាកលោកនេះទៅចោលកូនចៅជារៀងរហូត ។ ពេលនោះស្ថិតនៅក្នុងរដូវវស្សាទឹកធំ ទឹកភ្លៀងជោរជន់បែកវាល ។ ទឹកលិចវាលស្រែល្ហល្ហាចរកមើលភ្លឺមិនចង់ឃើញ ។ បន្ទាប់ពីពិគ្រោះជាមួយមិត្តជិតខាង ខ្ញុំសម្រេចយកសពឪពុកខ្ញុំ ទៅធ្វើឈាបនកិច្ចនៅទីទួលឯណាមួយ ។ បងស្អួស អ្នកជិតខាងបានផ្ដល់ឱសសម្រាប់បូជា ។ មិត្តជិត ខាងជួយធ្វើមឈូស និងរៀបចំសព ។ នៅពេលព្រឹកប្រមាណជាម៉ោង៨ យើងសែងមឈូសដើរកាត់ទឹកស្វែងរកទីទួល ។ គ្មានទីទួលណាមួយគេចផុតពីទឹកជំនន់នេះបានឡើយ ។ យើងសែងសពប្ដូរវេនគ្នារហូតដល់ហេវហត់រៀងខ្លួន ។ ចុងក្រោយ បងស្អួស សម្រេចយកចំណុចខ្ទែងនៃភ្លឺស្រែធំៗពីរសម្រាប់ធ្វើឈាបនកិច្ច ទោះបីជាទីនោះ នៅពៀបនឹងទឹកក្ដី ។ យើងកាយភក់ទប់ជុំវិញ ហើយលើកដីឲ្យខ្ពស់ ហើយពង្រាបឲ្យស្មើសម្រាប់ដាក់តម្កល់មឈូស ។ យើងគរឱសជុំវិញមឈូសហើយបញ្ឆេះភ្លើង ។ ភ្លើងឆេះមឈូស ឆេះសាកសពរហូតដល់ក្លាយទៅជាធ្យូង និងផេះ ។ ភ្លើងឆេះមឈូស ឆេះសាកសពរហូតដល់ក្លាយទៅជាធ្យូង និងផេះ ។ ខ្ញុំមិនអស់ចិត្តនឹងបណ្ដាំឪពុកដែលថា បូជាឲ្យអស់កុំទុកឲ្យសល់នៅ ។ ខ្ញុំពុំដាច់ចិត្តធ្វើតាមបណ្ដាំរបស់គាត់ទាំងស្រុងបានទេ ។ ខ្ញុំរើសអដ្ឋិធាតុរបស់ឪពុកបានពីរបីដុំទុកជាទីសក្ការៈទៅថ្ងៃក្រោយ ។ នៅពេលមួយក្រោយមក ខ្ញុំពឹងភរិយារបស់ខ្ញុំឲ្យយកក្រណាត់ក្រាស់ខ្ចប់អដ្ឋិធាតុនោះជាបីចំណែក ។ មួយចំណែក សម្រាប់ខ្លួនខ្ញុំ និងពីរ ចំណែកទៀត ទុកឲ្យកូនប្រុសច្បងទាំងពីររបស់ខ្ញុំ ។ ចុងបញ្ចប់ អដ្ឋិធាតុដែលនៅជាប់នឹងខ្លួនខ្ញុំនៅគង់វង្ស ឯពីរកញ្ចប់ទៀត ដែលជាចំណែករបស់កូនបានបាត់បង់នៅពេលសៀមជម្លៀសពួកគេឲ្យចុះតាមភ្នំព្រះវិហារ ។

## ជីវិតក្នុងសហករណ៍

អំឡុងដើមខែវិច្ឆិកា អង្គការបានប្រមូលប្រជាជនពីភូមិតូចៗ បានប្រមាណ១០០គ្រួសារឲ្យទៅនៅផ្តុំគ្នាធ្វើជាសហករណ៍ហៅថា សហករណ៍ស្នួលកោង ស្ថិតនៅពីខាងក្រោយអតីតមេច្បារកម្ពុជា-ជប៉ុន ប្រមាណ២គីឡូម៉ែត្រ ។ សហករណ៍ស្នួលកោងមានបួនភូមិគឺ ភូមិទួលគ ភូមិស្នួលកោង ភូមិអូរ ប្រគាប និងភូមិគោកប្រដាក ។ ទាំងបួនភូមិមានរោងបាយរួមចំនួនបី ។ រោងបាយគេហៅថា ការដ្ឋាន ។ គណៈគ្រប់គ្រងសហករណ៍មានប្រធានឈ្មោះមិត្ត ឌុំ អនុប្រធានឈ្មោះ ចាន់ គេមិនហៅគាត់ថា មិត្ត ទេ ព្រោះគាត់មានអាយុច្រើន គេអាចហៅគាត់ថា ពុក (ឬតា) និង សមាជិកឈ្មោះ ឆឹយ ។ គណៈគ្រប់គ្រងមានកម្មាភិបាល ទាំងប្ដីប្រពន្ធបួនគូជាជំនួយការ ។ ក្នុងសហករណ៍មានឈ្លបឈ្មោះ យៃ មានឈ្លបជាច្រើននាក់នៅក្រោមបង្គាប់ ។ ពួកកម្មាភិបាលទាំងអស់សុទ្ធតែមានអតីតភាពជាអ្នកតស៊ូ ។ គេបែកមុខព្រួញដាច់ដោយឡែកពីគ្នា ។ ក្នុងមុខព្រួញនីមួយៗមានកម្មាភិបាលជាអ្នកគ្រប់គ្រងផ្ទាល់ ។ កម្មាភិបាលនោះអាចស្នើតែងតាំងប្រជាជនថ្មីឲ្យធ្វើ ជាមេកង មេក្រុមតទៅទៀត ។ កម្មាភិបាលនៅស្នួលកោង ភាគច្រើនមានដើមកំណើតជាជនជាតិភាគតិចសៀម ឬលាវ មកពីភូមិក្តុលតាហែន ។ ក្រោយមក ក្នុងពាក់កណ្ដាលឆ្នាំ១៩៧៨ ពួកនេះ ត្រូវបានខ្មែរក្រហមមកពីភូមិភាគនិរតី (តាម៉ុក) យកទៅរៀនសូត្រទាំងអស់ ។

មកនៅក្នុងសហករណ៍ស្នួលកោង គ្រួសារខ្ញុំមានភារកិច្ចរៀងខ្លួន ។ ខ្លួនខ្ញុំធ្វើការនៅមន្ទីរសង្គមកិច្ច (មន្ទីរពេទ្យ)ផង និងធ្វើចម្ការផង ភរិយាខ្ញុំធ្វើអង្ករ កូនប្រុសធំពីរនាក់ និងកូនស្រីបន្ទាប់ធ្វើកងចល័តកុមារ កូនទី៤ និងទី៥ ជាកងកុមារតូច កូនទី៦ និងកូនទី៧ជាកុមារក្មេងខ្ចី និងទារកនៅឡើយ ។ ទាំងពីរនាក់ចុងក្រោយនេះពេលថ្ងៃនៅរោងបាយក្រោមការថែទាំពីយាយៗ ដល់ពេលល្ងាចទើបភរិយាខ្ញុំទៅយកមកផ្ទះ ។

នៅពេលនោះ រឿងដែលនាំឲ្យខ្ញុំចុកចាប់បំផុតជារៀងរាល់ថ្ងៃ គឺឃើញកូនៗ ធ្វើពលកម្ម លើកទំនប់ ជីកប្រឡាយ ។ ជាពិសេសចំពោះ កូនស្រីទីបីដែលគេប្រើឲ្យលើកទំនប់ដ៏ធំមួយនៅជិតសហករណ៍ ។ ក្នុងអាយុ៧ឆ្នាំ គេប្រើឲ្យទូលបង្គីដាក់ដីពេញ ដើរឡើងទៅចាក់លើខ្នងទំនប់ដែលមានកម្ពស់ប្រមាណបីម៉ែត្រ ។ មានតែកូនស្រីខ្ញុំតែម្នាក់ដែលស្លៀកខោពណ៌ក្រហម ព្រោះគ្មានខោខ្មៅស្លៀកដូចកូនគេ ។ នៅពេលកូនទូលបង្គីដើរឡើងទៅលើខ្នងទំនប់ ខ្ញុំមើលពីចម្ងាយឃើញខោពណ៌ក្រហមច្បាស់ ធ្វើឲ្យបេះដូងខ្ញុំចុកចាប់ ទឹកភ្នែក ខ្ញុំហូរ ព្រោះតែវាសនាអភ័ព្វរបស់កូន ។

អង្គការបដិវត្តន៍បង្កើតពាក្យថ្មីជាច្រើនសម្រាប់សម្គាល់ សម្រាប់ប្រើប្រាស់ដើម្បីទាក់ទងគ្នា សម្រាប់ទទួលបញ្ជា សម្រាប់សុំអភ័យទោស សម្រាប់ចោទប្រកាន់ ។ ហាក់បីដូចជា ពាក្យបច្ចេកទេសក្នុងបដិវត្តន៍ ។ ទាំងបុរស ទាំងស្ត្រី យើងមានអង្គភាពដោយឡែកពីគ្នា ។ មួយអង្គភាពមានគ្នាបីនាក់ គឺប្រធានអនុប្រធាន និងសមាជិក ។ ច្រើនអង្គភាពបានជាក្រុមមួយ ។ ក្រុមមិនកំណត់ចំនួនមនុស្សទេ ជួនតិច ជួនច្រើន ។ បើក្នុងការងារពលកម្មគេរាប់ជាកង ។ ឧទាហរណ៍ កងភ្ជួរ កងស្ទូង កងច្រូត កងដក កងរកជី កងលើកប្រឡាយ កងចល័តជាដើម ។ ពួកគ្រូធ្វើថ្នាំព្យាបាលរោគ ហៅថា គ្រូសង្គមកិច្ច ។ ពួកនេសាទហៅថា ពួកអាជីវកម្ម ។ ក្រុមនីមួយៗមានស្វ័យភាពក្នុងការងាររបស់គេរៀងៗខ្លួនហៅថា "ម្ចាស់ការលើទិសដែលអង្គការចាត់តាំងដាក់ឲ្យ" ។ ពាក្យថា "ទទួលខុសត្រូវលើខ្លួនឯង" មានន័យថា បើមានកំហុសត្រូវទទួលទោស គឺអាចមានទោសដល់ស្លាប់ ព្រោះខ្មែរក្រហមគ្មានគុក ឬមន្ទីរឃុំឃាំងដាច់ដោយឡែកតាមភូមិឃុំទេ ។ ប្រជាជនពុំអាចដឹងបានអំពីវត្តមាននៃមន្ទីរឃុំឃាំង ឬគុកនៅទីណាឡើយ ។ បើកម្មាភិបាល ឬកងឈ្លបចាប់អ្នកទោសណាម្នាក់ដែលត្រូវចោទថា ធ្វើខុសនឹងអង្គការចាត់តាំង ឬអង្គការវិន័យ កម្ររួចខ្លួនមកវិញណាស់ គឺគេយកមនុស្សនោះទៅបាត់ជារៀងរហូត ។ គ្រួសាររបស់មនុស្សដែលគេចោទថា មានទោសនោះពុំអាចតវ៉ាសួររកខុសត្រូវបានឡើយ ។ ពាក្យ "ខ្មាំង" គឺចាប់ហើយ ។ អ្នកមានទំនាក់ទំនងជាមួយខ្មាំងក៏ត្រូវមានទោសធ្ងន់ដែរ គឺស្លាប់ដូចគ្នា ។ ដូច្នេះ ក្នុងគ្រួសារណាមួយ បើមានសមាជិកណាម្នាក់ត្រូវគេចាប់យកទៅ អ្នកឯទៀតត្រូវតែភ័យរន្ធត់ ព្រោះខ្លាចពាក់ព័ន្ធដល់ខ្លួន ។ ប្រជាជនម្នាក់ៗតែងប្រុងប្រយ័ត្នអំពីទំនាក់ទំនងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ទោះមនុស្សនោះជាគ្នាឯងក៏ដោយ ។ ដោយមូលហេតុនេះហើយបានជាមនុស្សម្នាក់ៗ និយាយស្តិតិចបំផុត ។ ពេលដែលប្រជាជនម្នាក់ៗត្រូវនិយាយដោយខានពុំបាន គឺនៅពេលប្រជុំ ។

ប្រជុំជីវភាពត្រូវធ្វើជារៀងរាល់ល្ងាច បន្ទាប់ពីបរិភោគអាហាររួចទៅតាមអង្គភាពដែលមានមនុស្សបីនាក់ ។ ប្រជុំក្រុម ឬប្រជុំកងស្រេចតែមេក្រុម ឬមេកងជាអ្នកសម្រេចឲ្យធ្វើ ។ ការប្រជុំទាំងនេះ គេនាំគ្នាធ្វើច្រើនតែនៅទីវាលស្ងាត់ ។ គេនិយាយសារភាពពីកំហុសរបស់ខ្លួនម្នាក់ៗដែលបណ្តាលមកពីជំហរផ្ទាល់ខ្លួនក្នុងបដិវត្តន៍នៅខ្សោយ ព្រោះការខ្ជិលច្រអូស ការធ្វេសប្រហែស ការពុំយកតម្រាប់តាមវីរយុទ្ធមិត្ត ដែលវាយឈ្នះចក្រពត្តិអាមេរិក ។ នៅចុងបញ្ចប់ គេសូមឲ្យមិត្តនៅក្នុងអង្គភាពជួយកសាងដាស់តឿនដល់រូបគេ ដើម្បីបានកែខ្លួនឲ្យបានល្អសមជាអ្នកបដិវត្តន៍ ដោយពោលពាក្យចុង ក្រោយថា "ដូចភក់ប្រឡាក់ខ្នង មើលខ្លួនឯងមិនឃើញ បើមិត្តមើលឃើញកំហុស សូមជួយកែលម្អខ្ញុំផង" ។ សមាជិកនៃអង្គប្រជុំឡើង និយាយម្នាក់ម្តងៗដល់អស់គ្នាទើបបិទអង្គប្រជុំ ហើយវិលទៅលំនៅរៀងៗខ្លួន ។ នៅពេលយប់ ប្រជាជនម្នាក់ៗតែងបារម្ភអំពីអាយុជីវិតរបស់ខ្លួន ព្រោះបើមានឈ្លបមកហៅ នៅពេលយប់ច្រើនតែឥតបានវិលមកវិញទេ ។ កងឈ្លបមានប្រធានដែលជាកម្មាភិបាលជាអ្នកទទួលខុសត្រូវ ។ នៅពេលយប់ឡើង យុវជន ឈ្លបទាំងនោះ ដើរចេញមកប្រសាចតាមទិសដៅរបស់គេ ទៅយកការណ៍ពីប្រជាជននៅតាមផ្ទះក្រែង ប្រជាជនទាំងនោះប្រព្រឹត្តអ្វីខុសនឹងវិន័យ តាមកាយ ឬតាមវាចាដូចជា លួចបរិភោគជាឯកជន ឬត្អូញត្អែរពីការលំបាកក្នុងជីវភាព ឬក្នុងពលកម្ម ឬនិយាយប្រឆាំងនឹងអង្គការជាដើម ។ ពួកឈ្លបទាំងនោះមិនរួញរានឹងដេកស្តាប់អំពីសកម្មភាពរបស់ប្រជាជនទោះនៅពីក្រោមផ្ទះ ឬកៀនជញ្ជាំងក៏ដោយ ។ នៅមានប្រជុំធំមួយទៀត គឺប្រជុំនៅក្នុងសហករណ៍ ។

ប្រជុំនេះ មិនប្រកាន់ពេលវេលាសម្រេចលើអង្គការចាត់តាំង ។ កម្មាភិបាលថ្នាក់សហករណ៍ ឬថ្នាក់ឃុំ ឬថ្នាក់ស្រុកមកជាអធិបតី ។ កម្មវត្ថុនៃអង្គប្រជុំនេះច្រើនជាការរៀនសូត្រ ដែលកម្មា

ភិបាលលើកមកខ្ទេសនាម ជួនកាលជាបញ្ហាថ្មីពីអង្គការលើ ឬជាការបំផ្លើសនៃព្រឹត្តិការណ៍របស់ជាតិ ឬអន្តរជាតិ។ ជួនកាលមិនត្រឹមតែនិយាយបំផ្លើស គឺនិយាយកុហកទាំងស្រុង ដោយអត់អៀនខ្មាស ឬមួយក៏កម្មាភិបាលអ្នកខ្ទេសនាមនោះជឿថា រឿងនោះពិតដូច្នោះមែន? ពីព្រោះ មនុស្សទាំងនោះច្រើន តែអនក្ខរជន ។ មានពេលមួយនោះ ប្រធានសហករណ៍លើកមកនិយាយ ហើយបន្ទាប់មកកម្មាភិបាលឯទៀត និងមេកង មេក្រុមបន្តតាមថា ៖ ចក្រពត្តិអាមេរិក កំពុងភ័យស្ទន់ស្ទោ ព្រោះ ឥតមានអង្ករហូប ។ អង្គការយើងឥតព្រមលក់អង្ករឲ្យវា ។ វាមុខជានឹងដាច់ពោះស្លាប់មិនខាន ព្រោះវាអត់ចេះធ្វើស្រែ ។ វាចេះតែធ្វើយន្តហោះ រថក្រោះ កាំភ្លើង រថយន្តតែប៉ុណ្ណោះ ។ ឥឡូវនេះ អង្គការលក់កាត់ថ្លៃក្នុងស្រូវមួយបាវដូរយកត្រាក់ទ័រមួយគ្រឿង ។ ទៅថ្ងៃមុខ យើងឥតខ្វះត្រាក់ទ័រប្រើទេ ។ យើងឈប់ឲ្យគោទាញនង្គ័លទៀតហើយ ។ យើងនាំគ្នាត្រេកអរទុកឲ្យហើយទៅ យើងនឹងបានស្រណុកហើយ ព្រោះអង្គការលើទើបនឹងប្រាប់ដំណឹងល្អនេះ នៅពេលយើងទៅរៀនសូត្រ ។ អង្គប្រជុំទាំងមូលទះដៃត្រេកអរចំពោះដំណឹងល្អនេះ ។ វាគ្មិនខ្លះឡើង ចាប់អារម្មណ៍ប្រកបដោយមោទកភាពថា «សមមុខហើយចក្រពត្តិអាមេរិកប្បាំងចាញ់អង្គការយើង ហើយអត់អង្ករហូបទៀត» ។ មានរឿងច្រើនណាស់ ដែលគួរឲ្យអស់សំណើច ។ មានម្តងនោះ ក្នុងអង្គប្រជុំធំ ប្រធានសហករណ៍លើកយកប្រធានបទសន្សំសំចៃមកធ្វើខ្ទេសនាមថា «ដើម្បីសន្សំសំចៃ មានថ្ងៃមួយអង្គការយើងដិះឡានទៅលើថ្នល់ជាតិ ហើយប្រទះឃើញដែកគោលមួយដើមនៅលើថ្នល់ អង្គការយើងឲ្យបញ្ឈប់ឡាន ហើយចុះទៅរើសយកដែកគោលនោះ ទោះបី អង្គការយើងមានបេសកកម្មដ៏មមាញឹកក្តី» ។ បន្ទាប់មក ប្រធានសហករណ៍សុំឲ្យប្រជាជនយកតម្រាប់តាមអង្គការរបស់យើង ក្នុងការសន្សំសំចៃនេះ ។

ការលើករឿងមិនសមហេតុ មិនសមផល មកនិយាយ ធ្វើឲ្យអ្នកស្តាប់ដឹងពីកម្រិតចំណេះដឹងរបស់អង្គការយើងទាំងនោះហើយ ។ តើបដិវត្តន៍នឹងបានជោគជ័យឬទេ? បើគំនិត និងប្រាជ្ញារបស់ ថ្នាក់ដឹកនាំឪនថយយ៉ាងនេះ ។

អង្គប្រជុំធំប្រៀបបាននឹងមហាសន្និបាតវិសាមញ្ញរបស់សមាគម ឬស្ថាប័នក្នុងពេលបច្ចុប្បន្ននេះ ។ អង្គប្រជុំធំ ក្រៅអំពីរៀនសូត្រអាចផ្សព្វផ្សាយអំពីការដាក់ទិសរបស់អង្គការចាត់តាំង ឬវិធានការនានា ឬកាត់ទោសអ្នកមានកំហុសធ្ងន់ដូចជា ខុសសីលធម៌ក្បត់សមូហភាព ធ្វើឲ្យខូចឧបករណ៍ប្រើប្រាស់ដោយចេតនា ឬអចេតនា ឬធ្វើឲ្យសត្វពាហនៈស្លាប់ ឬមានរបួស ។ អង្គប្រជុំធំសម្រាប់រៀបការយុវជនយុវតីទៀតផង ។

**ឌា សីហា**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រងែ ស្រុកត្រាំកក់ ខេត្តតាកែវ បាត់ខ្លួននៅឆ្នាំ១៩៧៩ ពេលវៀតណាមចូល ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣១៧៨៩៦៧ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨
DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 181, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.